សាកលវិទ្យាល័យជាតិគ្រប់គ្រង
National University of Management



# រូបិយវត្ថុ ធនាគារ និង ទីផ្សារហិរញ្ញវត្ថុ



បណ្ឌិត **លី សុខហេង**

# រូបិយវត្ថុ ធនាគារ និង
# ទីផ្សារហិរញ្ញវត្ថុ


**បណ្ឌិត លី  សុខហេង**

**សាកលវិទ្យាល័យជាតិគ្រប់គ្រង**



**ព.ស. ២៥៦៥ - គ.ស. ២០២១**

*បោះពុម្ពលើកទី១*

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឬសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាព និងស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ ៥៣%នៅឆ្នាំ២០០៤ មកនៅទាបជាង១០%នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក និងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាព និងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថល ដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ី កំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាង ហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូង និងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះ

ក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុង

សង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទា ក្នុងបុព្វហេតុនៃមនុស្សជាតិ និងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ជាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំគឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទី ដែលប្រកបដោយការឆ្លើយតបចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិនៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍ ដែលជំរុញនិងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះ កើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាព

នៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅតាមគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំមានសៀវភៅជាង២,២លានចំណងជើងត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើន ជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍ អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗ ដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ដែមនៃការអប់រំ ជាពិសេសការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក និងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណានតាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្ស

ជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្ត និងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យត្រូវរៀបចំដំណើរការរៀន បង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យ ដែលតម្រូវឱ្យនិស្សិតត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើត បណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថល ជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សា អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណាន កាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សា ត្រូវខិតខំនិងចំណាយពេលអាន និងចាត់ទុកវប្បធម៌ និងអាកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញ និងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.ន.គ" និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្មនិងសាកលភាវូបនីយកម្ម។ មូលនិធិ ស.ន.គ បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្មទី៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្ម ទៅលើទិសដៅនៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការ**រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសាជូនដល់និស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិត នៅកម្រិតឧត្តមសិក្សា
២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀន និងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់
៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈ និងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ក្នុងការរៀបចំរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណលើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់ នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀត ដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិដើម្បី រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូច និងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះ ជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថា ជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# អារម្ភកថា

មុខវិជ្ជា រូបិយវត្ថុ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ គឺជាមូលដ្ឋានគ្រឹះដែលអ្នកសិក្សាផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធុរកិច្ច ត្រូវស្វែងយល់។ មុខវិជ្ជានេះ មានសារៈសំខាន់សម្រាប់គ្រប់ប្រភេទនៃអង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ ព្រមទាំងរួមចំណែកក្នុងការលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃរបស់បុគ្គល និងគ្រួសារ ឱ្យកាន់តែប្រសើរឡើងផងដែរ។ នៅតាមគ្រឹះស្ថានសិក្សាឯកទេស និងឧត្តមសិក្សា ផ្នែកសេដ្ឋកិច្ច និងធុរកិច្ច គេតែងបញ្ចូលមុខវិជ្ជានេះ ទៅក្នុងកម្មវិធីសិក្សា។ ម្យ៉ាងទៀត យើងបានប្រើប្រាស់ក្រដាសប្រាក់ក្នុងការចាយវាយ ទូទាត់ជារៀងរាល់ថ្ងៃ ប៉ុន្តែ យើងមិនបានដឹងច្បាស់ថា វាជាអ្វី? បានកើតឡើងយ៉ាងដូចម្តេច? ហើយហេតុអ្វីបានជាសង្គមទទួលស្គាល់ក្រដាសប្រាក់ទាំងនេះក្នុងការទូទាត់?

ធនាគារ និងទីផ្សារហិរញ្ញវត្ថុ បានបំពេញតួនាទីយ៉ាងសំខាន់ ដោយបានរួមចំណែកក្នុងការផ្តល់មូលធនវិនិយោគ និងអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានការរីកចម្រើន។ នៅពេលដែលគេនិយាយពីកំណែទម្រង់សេដ្ឋកិច្ច គេមិនអាចបំភ្លេចបានទេ ពីកំណែទម្រង់ហិរញ្ញវត្ថុ និងធនាគារ ពីព្រោះ ហិរញ្ញវត្ថុ និងធនាគារ ជាសសៃឈាមនៅក្នុងចរន្តសេដ្ឋកិច្ច។ ហេតុនេះ ការសរសេរសៀវភៅ រូបិយវត្ថុ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ នឹងជួយជាគំនិត ជាពុទ្ធិ សម្រាប់ប្រិយមិត្តអ្នកអាន សិស្ស និស្សិត និងអ្នកស្រាវជ្រាវ អាចសិក្សាស្វែងយល់ បង្កើនចំណេះបន្ថែម ជាភាសាជាតិ។

ការរៀបចំចងក្រងសៀវភៅនេះ គឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវក្នុងរយៈពេលវែង ដោយប្រើឯកសារយោងផ្សេងៗជាច្រើន ទាំងភាសាជាតិ និងភាសាបរទេស ដោយផ្សារភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានកើតឡើងជាក់ស្តែង ពាក់ព័ន្ធនឹងដំណើរវិវត្តន៍ រីកចម្រើន ទាំងក្នុងក្របខ័ណ្ឌសកល ក្នុងតំបន់ និងនៅកម្ពុជាផងដែរ។ ម្យ៉ាងទៀត ការសរសេរសៀវភៅនេះ ក៏ជាការចែករំលែកបទពិសោធន៍ តាមរយៈការបង្រៀនដល់និស្សិតគ្រប់កម្រិត នៅគ្រឹះស្ថានឧត្តមសិក្សា ជាពិសេស នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង តាំងពីឆ្នាំ១៩៩០មក។

ការចងក្រងសៀវភៅនេះ ត្រូវបានបែងចែកជា៥ជំពូក ដោយមាន១០មេរៀនសំខាន់ៗ។ ជំពូក១ សញ្ញាណទូទៅនៃរូបិយវត្ថុ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ រួមមាន

២មេរៀន។ មេរៀនទី១ រូបិយវត្ថុ និងអតិផរណា និង មេរៀនទី២ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ។ ជំពូក២ អត្រាការប្រាក់ និងការគណនា រួមមាន ២មេរៀនដែរ គឺ មេរៀនទី៣ ទ្រឹស្តីនៃអត្រាការប្រាក់ និងមេរៀនទី៤ ការគណនាអត្រាការប្រាក់ និងតម្លៃទ្រព្យហិរញ្ញវត្ថុ។ ចំណែកជំពូក៣ នឹងអត្ថាធិបាយអំពីការគ្រប់គ្រងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលមាន២មេរៀន គឺ មេរៀនទី៥ ការគ្រប់គ្រងធនាគារពាណិជ្ជ និងសេវាកម្ម និងមេរៀនទី៦ គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងតួនាទី។ នៅក្នុងជំពូក៤ នឹងលើកឡើងពីរបាយការណ៍ហិរញ្ញវត្ថុ ការវិភាគ និងវាយតម្លៃ ដែលមាន ២មេរៀន គឺ មេរៀនទី៧ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និង មេរៀនទី៨ ការវាស់វែង និងវាយតម្លៃប្រតិបត្តិការរបស់ធនាគារ។ ជំពូក៥ នឹងបង្ហាញពីធនាគារកណ្តាល និងគោលនយោបាយរូបិយវត្ថុ ដែលមាន ២មេរៀន គឺ មេរៀនទី៩ ធនាគារកណ្តាល និងតួនាទី និងមេរៀនទី១០ ឧបករណ៍គោលនយោបាយរូបិយវត្ថុ។

អ្នកសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងសង្ឃឹមថា សៀវភៅនេះ នឹងក្លាយជាឯកសារយោងជាភាសាខ្មែរ ដែលជាពន្លឺ ជាគតិ និងជាជំនួយស្មារតី ដែលមានសារៈសំខាន់សម្រាប់ប្រិយមិត្តអ្នកអាន សិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវ ក្នុងវិស័យសេដ្ឋកិច្ចរូបិយវត្ថុ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ ដោយទទួលបាននូវចំណេះដឹងបន្ថែមជាមិនខាន។

អ្នករៀបចំចងក្រង សូមប្រិយមិត្តអ្នកអាន មេត្តាខន្តី អភ័យទោសទុកជាមុនចំពោះកំហុសឆ្គង និងកង្វះខាត ដោយប្រការណាមួយ។

ថ្ងៃព្រហស្បតិ៍ ០៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
*រាជធានីភ្នំពេញ* ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១

**បណ្ឌិត លី សុខហេង**

**(LY SOK HENG, Ph.D.)**

# អំពីអ្នកនិពន្ធ



កុមារ **លី សុខហេង** មានឈ្មោះដើម លី សុខម៉េង មានស្រុកកំណើត នៅភូមិថ្លុកជ្រៅ ឃុំខ្ចៅ ស្រុកកងមាស ខេត្តកំពង់ចាម។ កុមាររូបនេះ បានកើត និងដឹងក្តី នៅក្នុងសម័យសង្គ្រាម ក្នុងរវាងទសវត្សរ៍ឆ្នាំ១៩៦០ និងឆ្នាំ១៩៧០ ដែលត្រូវរៀនសូត្រផង និងរត់គៀសខ្លួនដោយសារគ្រាប់បែក បេ-៥២ (B-52) របស់អាមេរិក និងគ្រាប់ផ្លោងដ៏ច្រើនសន្ធឹកសន្ធាប់ផង។ ជាពិសេស ទុក្ខវេទនាដ៏សែនខ្លោចផ្សារជាទីបំផុត ដែលមិនអាចបំភ្លេចបាន ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ និងធ្វើឱ្យបាត់បង់ពេលវេលារៀនសូត្រថែមទៀត។ ជាភព្វសំណាងល្អ កុមារ លី សុខម៉េង មានឱកាសបានចូលរៀនវិញ នៅសាលាកម្រិតសិក្សាទី១ ថ្លុកជ្រៅ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩។ នៅឆ្នាំ១៩៨០ ដោយបានប្រឡងផ្លោះថ្នាក់ផង កុមារ លី សុខហេង បានទៅស្នាក់នៅក្រុងកំពង់ចាម ដើម្បីបន្តការសិក្សានៅសាលាកម្រិតសិក្សាទី២ កំពង់ចាមក្រុង រយៈពេល១ឆ្នាំ។ បន្ទាប់មក បានផ្លាស់មករស់នៅឯភ្នំពេញ ដើម្បីបន្តការរៀនសូត្រនៅសាលាកម្រិតសិក្សាទី២ ទួលគោក។ ខ្ញុំបាទបានប្រឡងជាប់សញ្ញាបត្រកម្រិតសិក្សាទី២ (មធ្យមសិក្សាបឋមភូមិ) នៅឆ្នាំ១៩៨២។ ចាប់ពីឆ្នាំ១៩៨២មក ខ្ញុំបាទបានផ្លាស់ទៅរៀននៅសាលាកម្រិតសិក្សាទី៣ ភ្នំដូនពេញ (បច្ចុប្បន្ន វិទ្យាល័យព្រះស៊ីសុវត្ថិ) ហើយបានប្រឡងជាប់សញ្ញាបត្រកម្រិតសិក្សាទី៣ (មធ្យមសិក្សាទុតិយភូមិ) នៅឆ្នាំ១៩៨៥។

នៅឆ្នាំ១៩៨៥ ខ្ញុំបាទបានប្រឡងជាប់អាហារូបករណ៍ និងបានចូលរៀននៅវិទ្យាស្ថានសេដ្ឋកិច្ច (បច្ចុប្បន្ន សាកលវិទ្យាល័យជាតិគ្រប់គ្រង) រហូតដល់ឆ្នាំ១៩៩០។ ក្រោយពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ ខ្ញុំបាទត្រូវបានចាត់តាំងឱ្យបម្រើការងារ នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងតួនាទីជាគ្រូបង្រៀនកម្រិតឧត្តម រហូតដល់ឆ្នាំ១៩៩៤។ ដោយបានប្រឡងជាប់អាហារូបករណ៍ MOMBUSHO របស់ជប៉ុន ខ្ញុំបាទបានទៅស្នាក់នៅទីក្រុងអូសាកា ដើម្បីរៀនភាសាជប៉ុន នៅសាកលវិទ្យាល័យអូសាកា (Osaka Univerty)។ បន្ទាប់មក ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ខ្ញុំបាទត្រូវសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញសេដ្ឋកិច្ច

នៅសាកលវិទ្យាល័យស៊ីហ្កា (Shiga University)។ ខ្ញុំបាទបានបន្តការសិក្សា ថ្នាក់បណ្ឌិតសេដ្ឋកិច្ច នៅសាកលវិទ្យាល័យកូឃឹហ្កាឃឹអ៊ិន (Kokugakuin University), ក្រុងតូក្យូ នៅឆ្នាំ១៩៩៧ និងបានបញ្ចប់ការសិក្សាដោយជោគជ័យ នៅឆ្នាំ២០០០។

ចាប់ពីឆ្នាំ២០០០មក ខ្ញុំបាទបានត្រឡប់មកបម្រើការងារនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងវិញ ដោយមានតួនាទីជាប្រធានអាសនៈហិរញ្ញវត្ថុ ជានាយករងសាលាក្រោយឧត្តម ទទួលបន្ទុកកិច្ចការស្រាវជ្រាវ និងបន្ទាប់មក ជាសាកលវិទ្យាធិការរងទទួលបន្ទុកហិរញ្ញវត្ថុ និងកិច្ចការស្រាវជ្រាវ រហូតមកដល់បច្ចុប្បន្ន។ ខ្ញុំបាទក៏បានបម្រើការងារ ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅក្នុង "ក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន" ហៅកាត់ថា "កសវព" (Information Research and Analysis Group - IRAG) នៃខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផងដែរ។

*សូមអរគុណ!*

# លិខិតថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះប្រមុខដឹកនាំរាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព វិបុលភាព មានចក្ខុវិស័យវែងឆ្ងាយ និងយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យអប់រំ បង្កឱកាសឱ្យកុលបុត្រ កុលធីតាខ្មែរគ្រប់ៗរូប បានសិក្សារៀនសូត្រ នៅគ្រប់កម្រិតសិក្សា ទាំងនៅទីក្រុង និងជនបទ។

ខ្ញុំបាទ សូមគោរពថ្លែងអំណរយ៉ាងជ្រាលជ្រៅ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានដឹកនាំ និងធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ ធ្វើឱ្យមានសន្ទុះរីកចម្រើន បង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋយ៉ាងខ្លាំងក្លា។ ទន្ទឹមនឹងនោះ ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** ដែលបានដឹកនាំ សម្របសម្រួល និងគាំទ្រផ្នែកហិរញ្ញវត្ថុលើគម្រោងសរសេរសៀវភៅនេះ ឱ្យទទួលលទ្ធផលល្អ និងប្រកបដោយផ្លែផ្កា។

សូមគោរពថ្លែងអំណរគុណ ឯកឧត្តមបណ្ឌិត **ហោ ប៉េង** សាកលវិទ្យាធិការ ដែលបានដឹកនាំសាកលវិទ្យាល័យជាតិគ្រប់គ្រង ឱ្យមានការរីកចម្រើនឥតឈប់ឈរ ហើយតែងតែជំរុញ និងលើកទឹកចិត្តចំពោះសាស្ត្រាចារ្យទាំងអស់ ឱ្យចូលរួមក្នុងសកម្មភាពស្រាវជ្រាវជាបន្តបន្ទាប់។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណ ចំពោះគណៈកម្មការត្រួតពិនិត្យ និងអ្នកស្រី ប៉ុក ភារុន ដែលបានសម្របសម្រួលគម្រោងសរសេរសៀវភៅនេះ ឱ្យប្រព្រឹត្តទៅបានរលូន និងទទួលជោគជ័យ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា និងមូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលមានគំនិតផ្តួចផ្តើម ជំរុញ និងលើកទឹកចិត្ត ដោយផ្តល់មូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនលោកអ្នកមានគុណ គឺលោកឪពុក លី ចេងហ៊ុយ (ដែលបានអនិច្ចកម្មហើយ) និងអ្នកម្តាយ

ចេង ឡេងីម ព្រមទាំងឪពុកក្មេក ហោ ហួត និងម្ដាយក្មេក លី ឆៃឡេក ដែលហត់នឿយណាស់ក្នុងការចិញ្ចឹម បីបាច់ថែរក្សា អប់រំ ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាង ដើម្បីឱ្យកូនៗបានរៀនសូត្រជ្រៅជ្រះ ទោះបីជាអ្នកមានគុណ ត្រូវតស៊ូចិញ្ចឹមកូនៗនៅក្នុងបន្ទុកយ៉ាងច្រើនក៏ដោយ។ ជាពិសេស សូមថ្លែងអំណរគុណចំពោះឧត្តមភរិយា ហោ ណារ៉េត និងកូនស្រីច្បង លី សុគន្ធី កូនប្រុស លី សុខសេដ្ឋា កូនប្រសារ សេង រដ្ឋា និងចៅសំណព្វ សេង សុន្ទរាយុត្ត ដែលតែងតែគាំទ្រ ជំរុញលើកទឹកចិត្ត និងបង្កឱកាសគ្រប់បែបយ៉ាង ដែលជាកម្លាំងចិត្តមិនអាចខ្វះបាន ដើម្បីឱ្យការសិក្សាស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅនេះ សម្រេចបានជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ០៨រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥<br>*រាជធានីភ្នំពេញ* ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១

**បណ្ឌិត លី សុខហេង**

# មាតិកា


ទំព័រ

បុព្វកថា ………………………………………………………………… i

សេចក្ដីបញ្ជាក់នៃមូលនិធិការស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ …… viii

អារម្ភកថា ………………………………………………………………… ix

អំពីអ្នកនិពន្ធ ……………………………………………………………… xi

លិខិតថ្លែងអំណរគុណ ……………………………………………………… xiii

មាតិកា ………………………………………………………………… xv

រូបភាព តារាង និងក្រាហ្វិក ……………………………………………… xxiv

ជំពូក១: សញ្ញាណទូទៅនៃរូបិយវត្ថុ ធនាគារ និងទីផ្សារហិរញ្ញវត្ថុ ……… ១

មេរៀនទី១: រូបិយវត្ថុ និងអតិផរណា ………………………………… ២

១. ប្រវត្តិកកើតរបស់រូបិយវត្ថុ ……………………………………… ២

១.១. ទំនិញដូរទំនិញ …………………………………………… ៤

ក. ការដោះដូរដោយផ្ទាល់ ………………………………… ៤

ខ. ការដោះដូរដោយប្រយោល ……………………………… ៥

១.២. រូបិយវត្ថុទំនិញ ……………………………………………… ៦

ក. ភាពឋិតថេរ ……………………………………………… ៩

ខ. អាចកាត់ច្រៀកបាន ……………………………………… ៩

គ. ងាយស្រួលក្នុងការប្រើប្រាស់ ……………………………… ១០

ឃ. សុគតភាព ………………………………………………… ១០

ង. អាចលក់ដូរបានងាយ ……………………………………… ១០

១.៣. បទដ្ឋានមាស ………………………………………………… ១២

១.៤. ក្រដាសប្រាក់ ………………………………………………… ១៣

១.៥. ប្រាក់អេឡិចត្រូនិក …………………………………………… ១៥

២. ប្រវត្តិរូបិយវត្ថុនៅកម្ពុជា ………………………………………… ១៥

២.១. កាសដែលធ្វើចរាចរណ៍នៅសម័យហ្វូណន ……………………… ១៨

២.២. ប្រាក់ស្លឹង ……………………………………………………… ១៩

២.៣. ប្រាក់ប្រាសាទ ........................................................ ២០
២.៤. ក្រដាសប្រាក់ ........................................................ ២១
៣. ការវាស់វែងរូបិយវត្ថុ ........................................................ ២៥
៤. មុខងាររូបិយវត្ថុ ........................................................ ២៧
៤.១. មុខងារទូទាត់ ........................................................ ២៨
៤.២. មុខងារវាស់តម្លៃ ........................................................ ២៨
៤.៣. មុខងារសមាច្ឆ័យ ឬ មុខងាររក្សាទុក ........................................................ ២៨
៥. តួនាទីរបស់រូបិយវត្ថុ ........................................................ ៣០
៦. អតិផរណា ........................................................ ៣១
៦.១. សញ្ញាណ និងនិយមន័យនៃអតិផរណា ........................................................ ៣១
៦.២. ការសំដែងឡើងរបស់អតិផរណា ........................................................ ៣៣
៦.៣. ប្រភេទអតិផរណា ........................................................ ៣៥
៦.៤. ការជះឥទ្ធិពលរបស់អតិផរណា ........................................................ ៣៦
ក. ផលវិបាកចំពោះសេដ្ឋកិច្ច ........................................................ ៣៦
ខ. ផលវិបាកចំពោះសង្គម ........................................................ ៣៦
មេរៀនទី២: ធនាគារ និងទីផ្សារហិរញ្ញវត្ថុ ........................................................ ៣៧
១. ប្រវត្តិកកើតរបស់ធនាគារ ........................................................ ៣៧
២. ប្រព័ន្ធហិរញ្ញវត្ថុ ........................................................ ៣៨
៣. មុខងាររបស់ប្រព័ន្ធហិរញ្ញវត្ថុ និងទីផ្សារហិរញ្ញវត្ថុ ........................................................ ៣៩
២.១. មុខងារសន្សំ ........................................................ ៤០
២.២. មុខងារទ្រព្យសម្បត្តិ ........................................................ ៤០
២.៣. មុខងារសន្ទនីយភាព ........................................................ ៤០
២.៤. មុខងារឥណទាន ........................................................ ៤១
២.៥. មុខងារទូទាត់ ........................................................ ៤១
២.៦. មុខងារការពារហានិភ័យ ........................................................ ៤១
២.៧. មុខងារគោលនយោបាយ ........................................................ ៤២
ក. ការកំណត់តម្លៃ ........................................................ ៤២
ខ. គៀរគរមូលធន ........................................................ ៤៣

គ. សន្ទនីយភាព ……………………………………………… ៤៣
ឃ. ការរំលែកហានិភ័យ ……………………………………… ៤៤
ង. ងាយស្រួលក្នុងការស្វែងរក ………………………………. ៤៤
ច. កាត់បន្ថយថ្លៃសេវា និងការផ្តល់ព័ត៌មាន …………………… ៤៥
ឆ. ប្រមូលផ្តុំមូលធន ………………………………………….. ៤៥
៤. រចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ……………………………………. ៤៥
៤.១. អ្នកឱ្យខ្ចី ឬអ្នកសន្សំ …………………………………………. ៤៧
៤.២. អ្នកខ្ចី ឬអ្នកចំណាយ ………………………………………….. ៤៧
៤.៣. ស្ថាប័នហិរញ្ញវត្ថុអន្តរការី …………………………………….. ៤៧
៤.៤. ទីផ្សារហិរញ្ញវត្ថុ ………………………………………………… ៤៧
៥. ប្រភេទស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ ……………………………… ៤៩
៥.១. គ្រឹះស្ថានទទួលប្រាក់បញ្ញើ …………………………………… ៤៩
៥.២. គ្រឹះស្ថានចុះកិច្ចសន្យាសន្សំ …………………………………. ៤៩
ក. ក្រុមហ៊ុនធានារ៉ាប់រងជីវិត ………………………………… ៥០
ខ. ក្រុមហ៊ុមធានារ៉ាប់រងលើអគ្គីភ័យ និងឧបទ្ទវហេតុផ្សេងៗ ….. ៥០
គ. មូលនិធិសោធន ……………………………………………. ៥១
៥.៣. អន្តរការីកម្មវិនិយោគ ……………………………………… ៥១
ក. ក្រុមហ៊ុនហិរញ្ញវត្ថុ ………………………………………… ៥១
ខ. ធនាគារវិនិយោគ …………………………………………. ៥១
គ. ក្រុមហ៊ុនមូលប័ត្រ ………………………………………… ៥២
៦. ឧបករណ៍ហិរញ្ញវត្ថុ ឬមូលប័ត្រ …………………………………… ៥៣
៦.១. ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងទីផ្សាររូបិយវត្ថុ …………………… ៥៣
ក. មូលប័ត្ររតនាគារ ………………………………………… ៥៥
ខ. ផលប័ត្រពាណិជ្ជកម្ម ……………………………………… ៥៥
គ. វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចរចាបាន ………………… ៥៥
ឃ. កិច្ចសន្យាទិញយកវិញ …………………………………… ៥៦
៦.២. ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងទីផ្សារមូលធន …………………… ៥៦
ក. សញ្ញាប័ណ្ណ ……………………………………………… ៥៦

ខ. ប័ណ្ណភាគហ៊ុន ........................................................ ៥៩
ជំពូក២: អត្រាការប្រាក់ និងការគណនា........................................ ៦២
មេរៀនទី៣: ទ្រឹស្តីអត្រាការប្រាក់ ............................................ ៦៣
១. សញ្ញាណទូទៅ ........................................................ ៦៣
២. ទ្រឹស្តីមូលធនដែលអាចផ្តល់ឱ្យខ្ចីបាន ........................................ ៦៤
២.១. តម្រូវការឥណទានរបស់គ្រួសារ ........................................ ៦៤
២.២. តម្រូវការឥណទានរបស់អង្គភាពអាជីវកម្ម ................................ ៦៥
២.៣. តម្រូវការឥណទានរបស់រដ្ឋាភិបាល ...................................... ៦៧
២.៤. តម្រូវការឥណទានពីបរទេស ............................................ ៦៨
២.៥. តម្រូវការឥណទានសរុប ................................................ ៦៨
២.៦. ការផ្គត់ផ្គង់ឥណទាន .................................................. ៦៩
២.៧. ការផ្គត់ផ្គង់សរុបនៃមូលធន ............................................ ៧០
២.៨. តម្លៃសមាតាអត្រាការប្រាក់ ............................................ ៧១
៣. មុខងារ និងតួនាទីនៃអត្រាការប្រាក់ ........................................ ៧២
មេរៀនទី៤: ការគណនាអត្រាការប្រាក់ និងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ ..... ៧៥
១. សញ្ញាណទូទៅ ........................................................ ៧៥
២. វិធីសាស្ត្រនៃការគណនាអត្រាការប្រាក់ ...................................... ៧៦
២.១. អត្រាការប្រាក់ ...................................................... ៧៦
ក. ការប្រាក់ធម្មតា .................................................... ៧៦
ខ. ការប្រាក់ផ្តួប ឬការប្រាក់សមាច្ច័យ ...................................... ៧៧
២.២. ការគណនាតម្លៃសន្លឹកហ៊ុន ............................................ ៧៧
២.៣. ការគណនាតម្លៃសញ្ញាប័ណ្ណ ............................................ ៧៨
២.៤. ការគណនាតម្លៃបង់រំលស់អចលនទ្រព្យ .................................. ៨០
ជំពូក៣: ការគ្រប់គ្រងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ............ ៨១
មេរៀនទី៥: ការគ្រប់គ្រងធនាគារពាណិជ្ជ និង សេវាកម្ម .......................... ៨២
១. សញ្ញាណទូទៅ ........................................................ ៨២
២. មុខងារ និងតួនាទីរបស់ធនាគារពាណិជ្ជ ...................................... ៨២
២.១. មុខងារអន្តរការីយកម្ម .............................................. ៨២

២.២. មុខងារទូទាត់ ........................................................ ៨៣
២.៣. មុខងារជាអ្នកជានា ........................................................ ៨៣
២.៤. មុខងារគ្រប់គ្រងហានិភ័យ ........................................................ ៨៥
២.៥. មុខងារជាអ្នកពិគ្រោះយោបល់ហិរញ្ញវត្ថុ ........................................................ ៨៥
២.៦. មុខងាររក្សាសុវត្ថិភាពទ្រព្យសម្បត្តិមានតម្លៃ ........................................................ ៨៦
២.៧. មុខងារជាភ្នាក់ងារ ........................................................ ៨៦
២.៨. មុខងារគោលនយោបាយ ........................................................ ៨៦
៣. សេវាកម្មធនាគារពាណិជ្ជ ........................................................ ៨៧
៣.១. សេវាកម្មជាប្រពៃណីយ៍ ........................................................ ៨៧
ក. ការប្តូរប្រាក់ ........................................................ ៨៧
ខ. ផលប័ត្រពាណិជ្ជកម្ម ........................................................ ៨៨
គ. សេវាប្រាក់បញ្ញើសន្សំ និងគណនីចរន្ត ........................................................ ៨៨
ឃ. រក្សាសុវត្ថិភាពទ្រព្យសម្បត្តិមានតម្លៃ ........................................................ ៨៨
ង. គាំទ្រសកម្មភាពរដ្ឋាភិបាលដោយផ្តល់ឥណទាន ........................................................ ៨៩
៣.២. សេវាកម្មបច្ចុប្បន្ន ........................................................ ៨៩
ក. ឥណទានសម្រាប់ប្រើប្រាស់ ........................................................ ៨៩
ខ. ពិគ្រោះយោបល់ហិរញ្ញវត្ថុ ........................................................ ៨៩
គ. ការគ្រប់គ្រងសាច់ប្រាក់ ........................................................ ៩០
ឃ. ជួលឧបករណ៍សម្ភារៈ ........................................................ ៩០
ង. ឥណទានមូលធនចាប់ផ្តើម ........................................................ ៩១
ច. លក់ផលិតផលធានារ៉ាប់រង ........................................................ ៩១
ឆ. ការធានាទិញមូលប័ត្រ និងដើងសារជំនួញ ........................................................ ៩១
ជ. មូលនិធិទៅវិញទៅមក និងអនុសំវច្ឆរត្ន ........................................................ ៩២
ឈ. សេវាធនាគារជំនួញ ........................................................ ៩២
៤. និន្នាការប្រែប្រួលរបស់ធនាគារ ........................................................ ៩៣
៤.១. ការរីកសាយនៃសេវា ........................................................ ៩៣
៤.២. ការប្រកួតប្រជែង ........................................................ ៩៣
៤.៣. ការសម្រាលបន្ទុកបទប្បញ្ញត្តិ ........................................................ ៩៣

៤.៤. ការកើនឡើងនៃថ្លៃមូលធន ……………………………………… ៩៤
៤.៥. ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់ ……………………….. ៩៤
៤.៦. បច្ចេកវិទ្យា ……………………………………………………………. ៩៥
៤.៧. ការពង្រឹង និងពង្រីកទៅតាមទីតាំងភូមិសាស្ត្រ ……………….. ៩៥
៤.៨. ការកើនឡើងនូវហានិភ័យក្ស័យធន ……………………………. ៩៥
មេរៀនទី៦: គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និង តួនាទី …………………….. ៩៦
១. សញ្ញាណទូទៅ ………………………………………………………………. ៩៦
២. ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ………………….. ៩៦
២.១. តួនាទី និងរចនាសម្ព័ន្ធរបស់ធនាគារពិភពលោក …………….. ៩៧
២.២. តួនាទី និងរចនាសម្ព័ន្ធរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ……… ៩៩
ក. តាមដានសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក ………………… ១០០
ខ. ផ្តល់ឱ្យខ្ចីដល់ប្រទេសជាសមាជិក ……………………………….. ១០០
គ. ជួយប្រទេសជាសមាជិកធ្វើទំនើបកម្មសេដ្ឋកិច្ច ……………… ១០១
៣. ធនាគារអភិវឌ្ឍន៍អាស៊ី ………………………………………………… ១០១
៤. ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងធនាគារអភិវឌ្ឍន៍ថ្មី … ១០៤
៤.១. សាវតា ……………………………………………………………… ១០៤
៤.២. តួនាទីរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និង ធនាគារអភិវឌ្ឍន៍ថ្មី ……………………………………………… ១០៦
ជំពូក៤: របាយការណ៍ហិរញ្ញវត្ថុ ការវិភាគ និងវាយតម្លៃ ………………….. ១១១
មេរៀនទី៧: របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ……………………… ១១២
១. សញ្ញាណទូទៅ …………………………………………………………… ១១២
២. តារាងតុល្យការ ………………………………………………………… ១១២
២.១. ទ្រព្យសកម្ម ……………………………………………………….. ១១៣
ក. ទ្រព្យជាសាច់ប្រាក់ ……………………………………………… ១១៣
ខ. វិនិយោគមូលប័ត្រ ………………………………………………. ១១៤
គ. ឥណទាន …………………………………………………………. ១១៤
ឃ. ទ្រព្យផ្សេងទៀត ……………………………………………….. ១១៤
២.២. បំណុល ……………………………………………………………. ១១៤

២.៣. មូលធនផ្ទាល់ ........................................................ ១១៥
ក. ទ្រព្យសកម្ម ........................................................ ១១៦
ខ. បំណុល ........................................................ ១១៩
គ. មូលធនផ្ទាល់ ........................................................ ១២០
៣. របាយការណ៍ចំណេញ-ខាត ........................................ ១២០
៣.១. ចំណូលការប្រាក់ ........................................................ ១២១
៣.២. ចំណាយការប្រាក់ ........................................................ ១២១
៣.៣. ចំណូលការប្រាក់សុទ្ធ ........................................ ១២២
៣.៤. ចំណាយលើបំណុលខាត ........................................ ១២២
៣.៥. ចំណូលមិនមែនការប្រាក់ ........................................ ១២២
៣.៦. ចំណាយមិនមែនការប្រាក់ ........................................ ១២២
៣.៧. ចំណូលប្រតិបត្តិការសុទ្ធ និងចំណូលសុទ្ធ ........................ ១២៣
៤. របាយការណ៍លំហូរសាច់ប្រាក់ ........................................ ១២៣
មេរៀនទី៨: ការវាស់វែង និងវាយតម្លៃប្រតិបត្តិការរបស់ធនាគារ ............ ១២៦
១. សញ្ញាណទូទៅ ........................................................ ១២៦
២. វិភាគតាមខ្សែឈរ និងខ្សែដេក ........................................ ១២៦
២.១. វិភាគតាមខ្សែឈរ ........................................................ ១២៦
២.២. វិភាគតាមខ្សែដេក ........................................................ ១២៨
៣. វិភាគអនុបាតហិរញ្ញវត្ថុ ........................................................ ១២៩
៣.១. អនុបាតចំណេញ ........................................................ ១២៩
ជំពូក៥: ធនាគារកណ្ដាល និងគោលនយោបាយរូបិយវត្ថុ ........................ ១៣៣
មេរៀនទី៩: ធនាគារកណ្ដាល និងតួនាទី ........................................ ១៣៤
១. សញ្ញាណទូទៅ ........................................................ ១៣៤
២. តួនាទីរបស់ធនាគារកណ្ដាល ........................................ ១៣៥
២.១. គ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ ........................................ ១៣៥
២.២. ធ្វើឱ្យមានស្ថិរភាពទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន ............ ១៣៦
២.៣. អ្នកផ្ដល់ឱ្យខ្ចីចុងក្រោយ ........................................ ១៣៧
២.៤. អ្នកត្រួតពិនិត្យប្រព័ន្ធធនាគារ ........................................ ១៣៨

២.៥. ថែទាំ និងធ្វើឱ្យប្រសើរឡើងនូវយន្តការទូទាត់ ………………… ១៣៨
៣. គោលដៅរបស់ធនាគារកណ្តាល ……………………………………… ១៣៩
៣.១. ប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព ……………………………….. ១៣៩
ក. ធនធានមនុស្ស ………………………………………………. ១៣៩
ខ. ធនធានហិរញ្ញវត្ថុ ……………………………………………. ១៤០
គ. ធនធានផ្សេងទៀត …………………………………………… ១៤០
៣.២. រក្សាស្ថិរភាពថ្លៃទីផ្សារ ……………………………………… ១៤០
៣.៣. កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព ………………………… ១៤១
៣.៤. ធ្វើឱ្យមានតុល្យភាពជញ្ជីងពាណិជ្ជកម្មអន្តរជាតិ ……………… ១៤១
៤. រចនាសម្ព័ន្ធធនាគារកណ្តាលរបស់ប្រទេសមួយចំនួន ……………… ១៤៣
៤.១. ប្រព័ន្ធធនបម្រុងសហព័ន្ធ ……………………………………. ១៤៤
ក. ធនាគារធនបម្រុងសហព័ន្ធ …………………………………. ១៤៤
ខ. ធនាគារជាសមាជិក …………………………………………. ១៤៨
គ. ក្រុមប្រឹក្សាអភិបាលកិច្ចនៃប្រព័ន្ធធនបម្រុងសហព័ន្ធ ………… ១៤៩
ឃ. គណៈកម្មាធិការទីផ្សារបើកចំហសហព័ន្ធ ……………………. ១៥១
៤.២. ធនគារកណ្តាលសហភាពអឺរ៉ុប ………………………………… ១៥២
ក. ការប្រៀបធៀបរវាងប្រព័ន្ធធនាគារកណ្តាលអឺរ៉ុប និង
ប្រព័ន្ធធនបម្រុងសហព័ន្ធ ……………………………………… ១៥៣
ខ. ក្រុមប្រឹក្សាភិបាល ……………………………………………. ១៥៤
៤.៣. ធនគារកណ្តាលរបស់ប្រទេសផ្សេងៗ ………………………… ១៥៤
ក. ធនាគារកាណាដា …………………………………………… ១៥៥
ខ. ធនាគារអង់គ្លេស …………………………………………… ១៥៦
គ. ធនាគារជប៉ុន ………………………………………………. ១៥៧
៥. ប្រវត្តិ និងការរីកចម្រើនប្រព័ន្ធធនាគារនៅកម្ពុជា …………………. ១៥៨
៥.១. ឯករាជ្យភាព និងការបង្កើតឡើងវិញ (១៩៥៤-១៩៦៤) …… ១៥៨
៥.២. របបខ្មែរក្រហម (១៩៧៥-១៩៧៩) ………………………. ១៥៩
៥.៣. កសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)… ១៥៩
៥.៤. ទំនើបភាវូបនីយកម្មប្រព័ន្ធធនាគារ (១៩៩៣-បច្ចុប្បន្ន) …… ១៦០

៦. របនាសម្ព័ន្ធធនាគារជាតិនៃកម្ពុជា …………………………………….. ១៦៥
មេរៀនទី១០: ឧបករណ៍គោលនយោបាយរូបិយវត្ថុ ……………………….. ១៦៧
១. សញ្ញាណទូទៅ …………………………………………………………. ១៦៧
២. ឧបករណ៍គោលនយោបាយរូបិយវត្ថុ ……………………………….. ១៦៨
២.១. ទុនបម្រុងកាតព្វកិច្ច ……………………………………………. ១៦៨
២.២. អត្រាអប្បហារ ………………………………………………… ១៧០
ក. ឥណទានដំបូង ………………………………………………. ១៧០
ខ. ឥណទានបន្ទាប់ ………………………………………………. ១៧០
គ. ឥណទានតាមរដូវកាល ………………………………………. ១៧១
២.៣. ប្រតិបត្តិការទីផ្សារបើកចំហ …………………………………….. ១៧២
ក. ប្រតិបត្តិការត្រង់នៅក្នុងទីផ្សារបើកចំហ …………………….. ១៧៣
ខ. ប្រតិបត្តិការដោយទិញយកវិញ នៅក្នុងទីផ្សារបើកចំហ …….. ១៧៤
គ. ប្រតិបត្តិការទូទាត់ផុតថ្ងៃកំណត់សង ……………………….. ១៧៥
ឃ. គោលដៅនៃការប្រើទីផ្សារបើកចំហ ……………………….. ១៧៦
ង. គោលដៅអត្រាការប្រាក់ ……………………………………….. ១៧៦
ឯកសារយោង ………………………………………………………………. ១៧៨

# រូបភាព តារាង និងក្រាហ្វិក ទំព័រ


រូបភាពទី១.១: ទំនិញផ្សេងៗត្រូវបានប្រើសម្រាប់ដោះដូរ ………………… ៥
រូបភាពទី១.២: រូបិយវត្ថុទំនិញ ……………………………………………… ៨
រូបភាពទី១.៣: កាសមាសក្រេស៊ុស …………………………………………. ១៦
រូបភាពទី១.៤: កាសត្រាច្នរបស់ក្រុងអាថែន ……………………………….. ១៧
រូបភាពទី១.៥: រូបិយវត្ថុនៅសម័យរាជាណាចក្រហ្វូណន ………………… ១៩
រូបភាពទី១.៦: រូបិយវត្ថុ ប្រាក់ស្លឹង ………………………………………….. ២០
រូបភាពទី១.៧: រូបិយវត្ថុ ប្រាក់ប្រាសាទ …………………………………….. ២១
រូបភាពទី១.៨: រូបិយវត្ថុកម្ពុជា ……………………………………………….. ២៣
តារាងទី១.១: សមាសជាតុនៃរូបិយវត្ថុ M1 និង M2 ……………………….. ២៦
គំនូសបំព្រួញទី២.១: មុខងារទីផ្សារហិរញ្ញវត្ថុ …………………………….. ៤៣
គំនូសបំព្រួញទី២.២: លំហូរមូលធនតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ …………. ៤៨
គំនូសបំព្រួញទី២.៣: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សារ រូបិយវត្ថុ ……………………………………………… ៥៤
គំនូសបំព្រួញទី២.៤: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សារ សញ្ញាប័ណ្ណ ……………………………………………… ៥៧
គំនូសបំព្រួញទី២.៥: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សារហ៊ុន… ៦០
ក្រាហ្វិក៣.១: ទំនាក់ទំនងរវាងអត្រាការប្រាក់ និងតម្រូវការឥណទាន របស់គ្រួសារ ……………………………………………… ៦៥
ក្រាហ្វិក៣.២: ទំនាក់ទំនងរវាងអត្រាការប្រាក់ និងតម្រូវការឥណទាន របស់អង្គភាពអាជីវកម្ម ……………………………… ៦៦
ក្រាហ្វិក៣.៣: ឥទ្ធិពលនៃការកើនឡើងឱនភាពថវិកាទៅលើតម្រូវការ ឥណទាន ……………………………………………………… ៦៧
ក្រាហ្វិក៣.៤: ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់នៅបរទេសទៅលើ តម្រូវការឥណទានពីស.រ.អា. …………………………………… ៦៨
ក្រាហ្វិក៣.៥: ខ្សែកោងផ្គត់ផ្គង់សរុបនៃមូលធនដែលអាចផ្តល់ឥណទាន.. ៧០
ក្រាហ្វិក៣.៦: តម្លៃសមាតាអត្រាការប្រាក់ …………………………… ៧២

គំនូសបំព្រួញ៥.១: ដំណើរការលិខិតឥណទាន ………………………… ៨៤
តារាង៧.១: គំរូ តារាងតុល្យការ …………………………………………… ១១៥
តារាង៧.២: គំរូ របាយការណ៍ចំណេញ-ខាត ………………………… ១២១
តារាង៧.៣: លំហូរសាច់ប្រាក់សង្ខេប …………………………………… ១២៤
តារាង៨.១: របាយការន៍ចំណេញ-ខាត និងការវិភាគតាមខ្សែឈរ ……… ១២៧
តារាង៨.២: របាយការន៍ចំណេញ-ខាត និងការវិភាគតាមខ្សែដេក ……… ១២៨
គំនូសបំព្រួញ៩.១: បណ្ដាញដែលធនាគារកណ្ដាលដំណើរការ ………… ១៤៣
ផែនទី៩.១: ផែនទីបង្ហាញទីតាំងធនាគារធនបម្រុងសហព័ន្ធនៅក្នុងតំបន់
និងសាខានៅក្នុងទីក្រុងផ្សេងៗ ………………………………… ១៤៤
គំនូសបំព្រួញ៩.២: រចនាសម្ព័ន្ធ និងការទទួលខុសត្រូវលើឧបករណ៍
គោលនយោបាយនៅក្នុងប្រព័ន្ធធនបម្រុងសហព័ន្ធ ….. ១៤៧
គំនូសបំព្រួញ៩.៣: រចនាសម្ព័ន្ធធនាគារជាតិនៃកម្ពុជា …………………… ១៦៦
គំនូសបំព្រួញ១០.១: ប្រតិបត្តិការត្រង់ …………………………………… ១៧៤
គំនូសបំព្រួញ១០.២: ប្រតិបត្តិការដោយទិញយកវិញ …………………….. ១៧៤
គំនូសបំព្រួញ១០.៣: ប្រតិបត្តិការទូទាត់ផុតថ្ងៃកំណត់សង ……………… ១៧៥
ក្រាហ្វិក១០.១: គោលដៅអត្រាការប្រាក់ …………………………………… ១៧៧

# ជំពូក១

# សញ្ញាណទូទៅនៃ
# រូបិយវត្ថុ ធនាគារ និង
# ទីផ្សារហិរញ្ញវត្ថុ

# មេរៀនទី១

## រូបិយវត្ថុ និងអតិផរណា

## ( Money and Inflation )

### ១. ប្រវត្តិកកើតរបស់រូបិយវត្ថុ

**រូបិយវត្ថុ** គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ច-សង្គម ដោយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងបម្រើផលប្រយោជន៍នៅក្នុងសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការ វិនិយោគ។ ប៉ុន្តែ មានប្រជាពលរដ្ឋតិចណាស់ដែលបានគិតពិចារណាថា វាជាអ្វី។ ចំពោះប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រើប្រាស់ក្រដាសប្រាក់ មូលប្បទានប័ត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដូចជា ប័ណ្ណភាគហ៊ុនសញ្ញាប័ណ្ណ និងមូលប័ត្រផ្សេងទៀត ដែលប្រជាពលរដ្ឋទូទៅរឹតតែពិបាកយល់ទៀតថា វាជាអ្វី? បានកើតឡើងយ៉ាងដូចម្តេច? និងបានកើតពីពេលណាមក?

តាមការស្រាវជ្រាវរបស់ប្រវត្តិវិទូ និងសេដ្ឋវិទូជាច្រើន បានបង្ហាញឱ្យឃើញថា រូបិយវត្ថុបានវិវត្ត ដោយឆ្លងកាត់ដំណាក់កាលជាច្រើន អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ។ រូបិយវត្ថុ ជាផ្នែកមួយនៃសេដ្ឋកិច្ច ដែលបានកើតឡើងរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ្យ ស្របជាមួយនឹងកម្មសិទ្ធិឯកជន និងការបែងចែកកម្លាំងពលកម្ម នៅក្នុងសង្គម ដោយមានការបែងចែកជំនាញ/ឯកទេស ការងារ និងមុខរបរ[1]។ តើការបែងចែកកម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ច-សង្គម បានកើតឡើងយ៉ាងដូចម្តេច? តើការបែងចែកកម្លាំងពលកម្មពាក់ព័ន្ធយ៉ាងណាជាមួយនឹងការវិវត្តិរបស់រូបិយវត្ថុ?

នៅក្នុងសម័យបុព្វកាលដ៏យូរលង់មកហើយ (Pre-history) ប្រជាពលរដ្ឋរស់នៅដោយគ្មានកម្មសិទ្ធិឯកជន។ ប្រជាពលរដ្ឋបានធ្វើការងារប្រចាំថ្ងៃ ដើម្បីបំពេញតម្រូវការចាំបាច់សម្រាប់ជីវិតរស់នៅ។ មានន័យថា បើគេត្រូវការត្រី គេទៅនេសាទ បើគេត្រូវការផ្លែឈើ ឬសាច់សត្វ គេទៅបេះផ្លែឈើ ឬទៅបបាញ់សត្វ ដើម្បីបំពេញតម្រូវការរៀងៗខ្លួន។ នៅក្នុងដំណាក់កាលនេះ មិនទាន់មានកម្មសិទ្ធិឯកជន និងមិន

---

[1] James R., *The History of Money: From Its Origins to Our Time*, November 2007.
http://www.jamesrobertson.com/book/historyofmoney.pdf

ទាន់មានការដោះដូរទេ ឬហៅថា **ខ្លួនឧបត្ថម្ភខ្លួន**។ ប៉ុន្តែ ដោយសារបញ្ញាញាណរបស់មនុស្សកាន់តែរីកចម្រើន តម្រូវការសង្គមកាន់តែសម្បូរបែប ធ្វើឱ្យមនុស្សម្នាក់ៗមិនអាចធ្វើការងារគ្រប់បែបយ៉ាងក្នុងមួយថ្ងៃៗ ដើម្បីបំពេញតម្រូវការនៅក្នុងជីវភាពរស់នៅបានទេ។ ហេតុនេះ គេសង្កេតឃើញថា មានមនុស្សមួយក្រុមបានផលិតនូវផលិតផលមួយចំនួនលើសពីតម្រូវការ ប៉ុន្តែ ពួកគេបែរជាខ្វះផលិតផលផ្សេងទៀតដែលគេមិនបានផលិតទៅវិញ។ ដើម្បីបំពេញតម្រូវការទាំងនេះ ធ្វើឱ្យមានការដោះដូររវាងទំនិញ និងទំនិញ ឬសេវាកម្មផ្សេងទៀត ស្របជាមួយនឹងការបែងចែកកម្លាំងពលកម្មនៅក្នុងសង្គមទៅតាមជំនាញ ឬឯកទេស ដូចជា អ្នកនេសាទ អ្នកបេះផ្លែឈើ ការងារកសិកម្ម អ្នកបបាញ់សត្វ ឬកែច្នៃឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត។ ការបែងចែកកម្លាំងពលកម្មតាមផ្នែកបែបនេះ ធ្វើឱ្យកើតឡើងនូវភាពប៉ិនប្រសប់ ឬជំនាញ ដែលគេហៅថា **ឯកទេសនីយកម្ម** (Specialization) ប៉ុន្តែ នៅមានកម្រិតទាបនៅឡើយ។

ដំណាក់កាលនៃឯកទេសនីយកម្ម បានរីកចម្រើនយ៉ាងឆាប់រហ័ស និងបានបង្កើនប្រសិទ្ធភាពនៃការផលិតកាន់តែខ្ពស់ ការកែច្នៃឧបករណ៍ប្រើប្រាស់នៅក្នុងសង្គមកាន់តែរីកចម្រើន ធ្វើឱ្យលេចឡើងនូវតួនាទីថ្មីមួយទៀត គឺការសម្របសម្រួល និងភាពជាអ្នកដឹកនាំនៅក្នុងសង្គម ជាហេតុធ្វើឱ្យមានការបែងចែករវាងអ្នកដឹកនាំគេ និងអ្នកដែលនៅក្រោមការដឹកនាំ ឬរវាងរដ្ឋ និងឯកជន។ ចំណែក ការដោះដូរទ្រព្យសម្ភារៈ និងសេវាកម្មផ្សេងៗវិញ ត្រូវបានអភិវឌ្ឍយ៉ាងទូលំទូលាយ និងឆាប់រហ័ស ធ្វើឱ្យជួបការលំបាក និងស្មុគស្មាញកាន់តែខ្លាំង ដោយសារមុខទំនិញដែលត្រូវដោះដូរ នៅក្នុងសេដ្ឋកិច្ច-សង្គម កាន់តែសម្បូរបែប។ ហេតុនេះ មធ្យោបាយដោះដូរទូទៅ ទំនិញដូរយកទំនិញបែបនេះ មិនអាចបំពេញមុខងារដោះដូរបានទៀតទេ ពោលគឺត្រូវជំនួសដោយទំនិញពិសេស ដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងសេដ្ឋកិច្ច-សង្គម ដែលគេហៅថា **មធ្យោបាយកណ្ដាលសម្រាប់ដោះដូរ**។ ទំនិញពិសេស ដែល ត្រូវបានប្រើធ្វើជាមធ្យោបាយកណ្ដាលសម្រាប់ដោះដូរ ត្រូវបានអ្នកសិក្សាស្រាវជ្រាវទទួលស្គាល់ថា ជារូបិយវត្ថុដំបូងគេនៅក្នុងប្រវត្តិសាស្ត្រ ដែលគេឱ្យឈ្មោះថា **រូបិយវត្ថុទំនិញ** (Commodity money)។ នេះជាដំណាក់កាលដំបូង នៃការកកើតរូបិយវត្ថុ។ តើ

ទំនិញដូរយកទំនិញកើតឡើងយ៉ាងដូចម្តេច? ហើយអ្វីទៅជា **ទំនិញពិសេសដែលត្រូវបានទទួលស្គាល់ជាទូទៅ** (General acceptability) នៅក្នុងសេដ្ឋកិច្ច-សង្គមនោះ?

### ១.១. ទំនិញដូរទំនិញ (Barter)

ទំនិញដូរទំនិញ គឺជាការដោះដូរទំនិញ ឬសេវាកម្មដំបូងគេ នៅក្នុងដំណាក់កាលមិនទាន់កើតមានរូបិយវត្ថុនៅឡើយ។ ការដោះដូរនេះ មិនត្រូវបានយកចិត្តទុកដាក់ ទៅលើបរិមាណ ឬតម្លៃនៃការដោះដូរទេ។ គោលបំណងសំខាន់នៃការដោះដូរនេះ គឺដើម្បីបំពេញតម្រូវការទៅវិញទៅមក នៅក្នុងជីវភាពរស់នៅ។ ឧទាហរណ៍ៈ សកម្មភាពដោះដូរបានកើតឡើង ដោយសារ មានបុគ្គលដែលនេសាទត្រីបានច្រើនលើសពីតម្រូវការ ហើយក្នុងពេលទន្ទឹមគ្នា មានបុគ្គលម្នាក់ទៀត ដាំដុះពោតបានច្រើនលើសពីតម្រូវការដែរ ជាហេតុធ្វើឱ្យបុគ្គលទាំងពីរត្រូវការដោះដូរ ដើម្បីបំពេញតម្រូវការទៅវិញទៅមកនូវផលិតផលដែលខ្លួនមិនបានផលិត ដោយមិនយកចិត្តទុកដាក់ទៅលើបរិមាណទំនិញ ឬសេវាកម្ម ដែលត្រូវដោះដូរនោះឡើយ។ ការដោះដូរបែបនេះ ត្រូវបានបែងចែកជាពីរដំណាក់កាល គឺ ការដោះដូរដោយផ្ទាល់ និងការដោះដូរដោយប្រយោល។

#### ក. ការដោះដូរដោយផ្ទាល់ (Direct exchange)

ការដោះដូរដោយផ្ទាល់ គឺជាការដោះដូរទៅវិញទៅមក រវាងទំនិញ និងទំនិញ ឬសេវាកម្ម ដោយសារ ប្រជាពលរដ្ឋមានតម្រូវការប្រភេទទំនិញ ឬសេវាកម្មផ្សេងទៀត ដែលខ្លួនមិនបានផលិត។ ឧទាហរណ៍ៈ បុគ្គលម្នាក់នេសាទបានត្រី ហើយត្រូវការសាច់សត្វ ដូច្នេះ គាត់អាចយកត្រីទៅដូរយកសាច់សត្វដោយផ្ទាល់តែម្តង ឬ យកត្រីដូរយកពោត យកគោដូរយកអំបិល ជាដើម។ ដើម្បីអាចដោះដូរបាន អ្នកមានត្រី ឬគោ ត្រូវស្វែងរកអ្នកមានសាច់សត្វ ពោត ឬ អំបិល ហើយត្រូវការត្រី ឬ គោ ផងដែរ នោះទើបធ្វើឱ្យការដោះដូរអាចប្រព្រឹត្តទៅបាន។ ការដោះដូរបែបនេះ បានជួបការលំបាកជាខ្លាំង នៅពេលផលិតផលសង្គមកាន់តែរីកចម្រើន និងសម្បូរបែប ពីព្រោះនៅពេលដោះដូរម្តងៗ យើងត្រូវស្វែងរកបុគ្គលដែលមានទំនិញដូចយើងត្រូវការ ហើយគេក៏ត្រូវការទំនិញរបស់យើងដែរ នោះទើបធ្វើឱ្យការដោះដូរអាចកើតឡើងបាន។

ហេតុនេះ ការដោះដូរដោយផ្ទាល់មិនអាចបន្តមុខងាររបស់ខ្លួនបានទៀតទេ ធ្វើឱ្យមុខងារថ្មីបានកើតឡើង គឺ ការដោះដូរដោយប្រយោល។

ខ. **ការដោះដូរដោយប្រយោល** (Indirect exchange)

ការដោះដូរដោយប្រយោល គឺជាការដោះដូរដោយឆ្លងកាត់ដំណាក់កាលពីរ ឬច្រើន ដោយសារបុគ្គលដែលមានទំនិញត្រូវដោះដូរ មិនត្រូវការទំនិញរបស់ភាគីមួយទៀត។ ឧទាហរណ៍: អ្នកមានត្រីចង់ដូរយកសាច់សត្វ តែអ្នកមានសាច់សត្វមិនត្រូវការត្រីទេ ប៉ុន្តែ គេត្រូវការផ្លែឈើទៅវិញ។ ពេលនោះ អ្នកមានត្រីត្រូវស្វែងរក ដូរយកផ្លែឈើជាមុនសិន។ បន្ទាប់មក ទើបយកផ្លែឈើនោះ ទៅដូរយកសាច់សត្វវិញបាន។ ការដោះដូរបែបនេះ ហៅថា **ការដោះដូរដោយប្រយោល**។ គួរកត់សម្គាល់ថា នៅក្នុងដំណាក់កាលនៃការដោះដូរដោយផ្ទាល់ និងដោះដូរដោយប្រយោល រូបិយវត្ថុមិនទាន់កើតឡើងនៅឡើយទេ។ ពោលគឺ គ្រាន់តែជាការដោះដូរធម្មតារវាងទំនិញ និងទំនិញ ឬ សេវាកម្មផ្សេងទៀត ដើម្បីបំពេញតម្រូវការនៅក្នុងជីវភាពរស់នៅតែប៉ុណ្ណោះ។

**រូបភាពទី១.១: ទំនិញផ្សេងៗត្រូវបានប្រើសម្រាប់ដោះដូរ**



ប្រភព: How money is created ?

https://shankarmuthu.com/2015/09/19/how-money-is-created/

## ១.២. រូបិយវត្ថុទំនិញ (Commodity money)

ការដោះដូរដោយប្រយោល បានជួបការលំបាកកាន់តែខ្លាំង នៅពេលដែលផលិតផលសង្គម និងសេវាកម្មកាន់តែសម្បូរបែប ហើយចំនួនមុខទំនិញដែលត្រូវដោះដូរ ក៏បានកើនឡើងកាន់តែច្រើន។ ម្យ៉ាងទៀត នៅពេលដែលចំនួនមុខទំនិញដែលត្រូវដោះដូរកាន់តែច្រើន ធ្វើឱ្យតម្លៃដែលត្រូវផ្ទៀងផ្ទាត់ ក៏បានកើនឡើងកាន់តែច្រើនដែរ។ ឧទាហរណ៍ៈ បើយើងមានទំនិញ ៣ ប្រភេទសម្រាប់ដោះដូរ នោះយើងមានតម្លៃដែលត្រូវផ្ទៀងផ្ទាត់ចំនួន ៣ ដែរ។ បើទំនិញកើនដល់ ៤ ប្រភេទ នោះតម្លៃដែលត្រូវផ្ទៀងផ្ទាត់នឹងកើនដល់ ៦។ បើទំនិញកើនដល់ ៥ ប្រភេទ តម្លៃដែលត្រូវផ្ទៀងផ្ទាត់កើនដល់ ១០។ បើទំនិញកើនដល់ ៦ ប្រភេទ តម្លៃដែលត្រូវផ្ទៀងផ្ទាត់កើនដល់ ១៥ ហើយបើទំនិញកើនដល់ ១០ ប្រភេទ តម្លៃដែលត្រូវផ្ទៀងផ្ទាត់កើនដល់ ៤៥។ល។ ប៉ុន្តែបើទំនិញកើនឡើងដល់ ១០០ ប្រភេទវិញ នោះតម្លៃដែលត្រូវផ្ទៀងផ្ទាត់ នឹងកើនឡើងដល់ ៤.៩៥០ ធ្វើឱ្យការដោះដូរកាន់តែលំបាក និងស្មុគស្មាញ។ លទ្ធផលខាងលើត្រូវបានគណនាដោយអនុវត្តតាមរូបមន្តដូចខាងក្រោម៖[2]

$$C^n_r = n! / [r!(n-r)!]$$

ឬ $C(n, 2) = n! / [2!(n-2)!]$

$C^n_r$ : តម្លៃដែលត្រូវផ្ទៀងផ្ទាត់

$n$ : ចំនួនប្រភេទទំនិញដែលត្រូវដោះដូរ

$r$ : ដៃគូដោះដូរ (ទ្វេភាគី ឬ ស្មើ២)

ឧទាហរណ៍ទី១: បើយើងមានទំនិញ៥ប្រភេទខុសៗគ្នាដែលត្រូវដោះដូរ នោះយើងនឹងមានតម្លៃដែលត្រូវផ្ទៀងផ្ទាត់ ចំនួន ១០ ត្រូវបានគណនាដូចខាងក្រោម៖

$$C^n_r = n! / [r!(n-r)!]$$

---

[2] Glyn D., *A History of Money: From Ancient Times to the Present Day*, 2002, Pp. 15-16.

$= 5! / [2! \times (5-2)!]$

$= (5 \times 4 \times 3 \times 2 \times 1) / [(2 \times 1)(3 \times 2 \times 1)]$

$= 120 / 12 = 10$ តម្លៃដែលត្រូវផ្គូរផ្គង

ឧទាហរណ៍ទី២: បើយើងមានទំនិញ ១០ ប្រភេទខុសគ្នាដែលត្រូវដោះដូរ នោះយើងនឹងមានតម្លៃ ដែលត្រូវផ្គូរផ្គងចំនួន ៤៥ ត្រូវបានគណនាដោយម៉ាស៊ីនគិតលេខដែលមានហ្វាក់តូរៀល (Factorielle-x!) ជាជំនួយ៖

$C^n_r = n! / [r! (n-r)!]$

$= 10! / [2! \times (10-2)!]$

$= 3.628.800 / 2 \times 40.320$

$= 3.628.800 / 80.640 = 45$ តម្លៃដែលត្រូវផ្គូរផ្គង

នេះជាឧបសគ្គធំជាងគេ ដែលធ្វើឱ្យការដោះដូរដោយប្រើទំនិញទូទៅ មិនអាចបន្តអនុវត្តនៅក្នុងសេដ្ឋកិច្ច-សង្គម បានទៀតទេ។ ហេតុនេះ ទំនិញពិសេសដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងសង្គម ត្រូវបានប្រើប្រាស់ធ្វើជាមធ្យោបាយកណ្តាលសម្រាប់ដោះដូរ។ សកម្មភាពដោះដូរបែបនេះ គឺ មានប្រភេទទំនិញណាមួយដែលជាតម្រូវការចាំបាច់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ត្រូវបានគេទទួលស្គាល់ជាទូទៅ ធ្វើជាវត្ថុកណ្តាលសម្រាប់ដោះដូរ។ ឧទាហរណ៍: នៅតាមតំបន់ ឬប្រទេសផ្សេងគ្នា បានទទួលយកប្រភេទទំនិញផ្សេងៗគ្នា ដូចជា គោ ក្របី ចៀម គ្រាប់ធញ្ញជាតិ ឬរបស់ប្រើប្រាស់ផ្សេងទៀត ធ្វើជាវត្ថុកណ្តាលសម្រាប់ដោះដូរ។ មានន័យថា អ្នកផលិតបានផលិតផលអ្វីក៏ដោយ ត្រូវដូរយកវត្ថុ កណ្តាលនេះសិន ទើបយកវត្ថុកណ្តាលនោះ ទៅដូរយកផលិតផលផ្សេងទៀត ដែលខ្លួនត្រូវការ ហើយគ្មានអ្នកណាម្នាក់បដិសេធ មិនទទួលស្គាល់វត្ថុកណ្តាលនេះទេ។ **វត្ថុកណ្តាលសម្រាប់ដោះដូរនេះហើយ ត្រូវបានគេទទួលស្គាល់ថា ជាការកកើតរូបិយវត្ថុដំបូងគេ** នៅក្នុងប្រវត្តិសាស្ត្ររូបិយវត្ថុ ដែលគេឱ្យឈ្មោះថា **រូបិយវត្ថុទំនិញ** (Commodity money)។

ទោះបីជារូបិយវត្ថុទំនិញ បានកើតឡើងជាយូរយាណាស់មកហើយ ពោលគឺបានកើតឡើងតាំងពីរាប់ពាន់ឆ្នាំមុនគ្រឹះសករាជ្យ ក្នុងប្រវត្តិសាស្ត្ររូបិយវត្ថុ។ ប៉ុន្តែសម្រាប់កម្ពុជា ជាករណីពិសេស ដែលបានកើតឡើងប្រមាណជាងបួនទសវត្សរ៍

កន្លងទៅ ពោលគឺ ក្រោយការដួលរលំនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅឆ្នាំ ១៩៧៩។ របបខ្មែរក្រហម បានលុបបំបាត់ចោលទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដល់កម្រិតសូន្យ ជាពិសេស គឺ លុបបំបាត់មិនឱ្យមានការចាយវាយក្រដាសប្រាក់ និងបំផ្លាញចោលប្រព័ន្ធធនាគារទាំងមូល។ ហេតុនេះ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រជាពលរដ្ឋកម្ពុជាដែលបានងើបពីភាពអត់ឃ្លាន ក្នុងសម័យប៉ុលពត បានទទួលយកស្រូវ ឬអង្ករ ជាទំនិញដែលត្រូវបានទទួលស្គាល់ជាទូទៅ ធ្វើជាមធ្យោបាយកណ្ដាលសម្រាប់ដោះដូរ។ មានន័យថា ប្រជាពលរដ្ឋផលិតបានផលិតផលអ្វីក៏ដោយ ត្រូវដូរយកស្រូវ ឬអង្ករជាមុនសិន ទើបយកស្រូវ ឬអង្ករនោះ ទៅដូរយកទំនិញផ្សេងទៀត ដែលពួកគេត្រូវការ។ ដូច្នេះ ស្រូវ ឬអង្ករ បានក្លាយជាវត្ថុកណ្ដាលសម្រាប់ដោះដូរ។ ចំណែក លោហធាតុ "**មាស**" ជាប្រភេទទំនិញពិសេស ត្រូវបានទទួលស្គាល់ជាមធ្យោបាយកណ្ដាល សម្រាប់ទូទាត់ទំនិញ ដែលមានតម្លៃខ្ពស់ ដូចជា ទិញគោ រទេះគោ ដីធ្លី កង់ ឬ ទ្រព្យសម្បត្តិមានតម្លៃផ្សេងទៀត ជាពិសេស មាសត្រូវបានប្រើសម្រាប់នាំទំនិញចូលពីប្រទេសវៀតណាម។

រូបភាពទី១.២: រូបិយវត្ថុទំនិញ (Commodity money)




ប្រភព: Commodity Money Definition / 9 Examples / 4 Characteristics

https://boycewire.com/commodity-money-definition/

ដោយឡែក នៅក្នុងប្រទេស ឬ តំបន់ផ្សេងៗ ស្ថិតក្នុងសម័យកាលខុសៗគ្នា មានប្រភេទទំនិញកណ្ដាលផ្សេងៗ ត្រូវបានទទួលស្គាល់ជាទូទៅ ជាមធ្យោបាយកណ្ដាលសម្រាប់ដោះដូរ។ ឧទាហរណ៍: គោ ក្របី សំបកខ្យងសមុទ្រ គ្រាប់ធញ្ញជាតិ

តែ គ្រាប់កាការ ថ្នាំជក់ ពូថៅ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត ត្រូវបានប្រើធ្វើជាមធ្យោបាយកណ្តាលសម្រាប់ដោះដូរ។

នៅពេលដែលសេដ្ឋកិច្ច-សង្គមកាន់តែរីកចម្រើន ផលិតផល/ទំនិញកាន់តែសម្បូរបែប នោះក្របខ័ណ្ឌនៃដោះដូរកាន់តែទូលំទូលាយ និងរីកសាយពីតំបន់មួយទៅតំបន់មួយទៀត ធ្វើឱ្យការប្រើរូបិយវត្ថុទំនិញសម្រាប់ដោះដូរ បានជួបការលំបាកកាន់តែខ្លាំង ដោយសារ ទំនិញមួយចំនួនត្រូវបានគេទទួល ស្គាល់នៅក្នុងតំបន់មួយ ប៉ុន្តែ មិនត្រូវបានទទួលស្គាល់នៅក្នុងតំបន់ផ្សេងទៀតទេ។ ហេតុនេះ រូបិយវត្ថុទំនិញ មិនអាចបន្តបំពេញមុខងារជារូបិយវត្ថុបានទៀតទេ និងដោយសារ ការលំបាកផ្សេងៗទៀតជាច្រើន ដូចជា ទំនិញធម្មតាមានតម្លៃថោក និងគ្មានស្ថិរភាព ត្រូវការបរិមាណច្រើននៅពេលដោះដូរម្តងៗ ទំនិញធម្មតាឆាប់ខូច មិនអាចរក្សាទុកបានយូរ ជាដើម។ ដូច្នេះ ដើម្បីអាចបំពេញមុខងារជារូបិយវត្ថុបាន វត្ថុឬទំនិញទាំងនោះ ត្រូវមានលក្ខណៈពិសេស៥យ៉ាង ដូចខាងក្រោម៖

**ក. ភាពឋិតថេរ** (Durability)

ជាវត្ថុដែលអាចរក្សាទុកបានយូរ មិនខូច ទោះបីស្ថិតនៅក្នុងស្ថានភាពបែបណាក៏ដោយ និងមិនបាត់បង់តម្លៃរបស់វា។ ហេតុនេះ ធ្វើឱ្យរូបិយវត្ថុអាចបំពេញមុខងាររក្សាទុក ឬហៅថា មុខងារសមាច្ច័យ។ ឧទាហរណ៍: សាច់សត្វ ផ្លែឈើ មិនអាចរក្សាទុកបានយូរ ឆាប់ខូច។ ក៏ដូចគ្នាដែរ លោហធាតុ ដូចជា ដែក ងាយនឹងច្រេះស៊ី ឆាប់ខូច ឬបាត់បង់តម្លៃរបស់វា។ បើរូបិយវត្ថុទំនិញមិនអាចរក្សាតម្លៃបានយូរបែបនេះ ធ្វើឱ្យបាត់ជំនឿទុកចិត្តពីអ្នកប្រើប្រាស់ ឬសាធារណជន។

**ខ. អាចកាត់ច្រៀកបាន** (Divisibility)

ជាវត្ថុដែលអាចកាត់ជ្រៀកជាបំណែកតូចៗ ឬហូតជាខ្សែ ចាក់ពុម្ពជារូបរាងផ្សេងៗ ដើម្បីទូទាត់ទំនិញគ្រប់ប្រភេទ ទោះជាមានតម្លៃទាប ឬខ្ពស់ក៏ដោយ នៅតែអាចទូទាត់បាន។ រូបិយវត្ថុ ត្រូវតែជាប្រភេទទំនិញដែលអាចរក្សាតម្លៃពិតរបស់វា ទោះបីជាមានការប្រែប្រួលទ្រង់ទ្រាយយ៉ាងណាក៏ដោយ។ ឧទាហរណ៍: បើយើងប្រើសម្លៀកបំពាក់ធ្វើជាមធ្យោបាយដោះដូរ វាមានការលំបាកជាងការប្រើប្រាស់គ្រឿងឧបភោគបរិភោគ ដោយសារ សម្លៀកបំពាក់មិនអាចកាត់ច្រៀក ដើម្បីដោះដូរបាន

ឡើយ ពីព្រោះ វានឹងប្រើលែងកើត ឬធ្វើឱ្យបាត់បង់តម្លៃរបស់វា។ សត្វពាហនៈជាករណីពិសេស ទោះបីជា គោមិនអាចកាត់ច្រៀកបាន ប៉ុន្តែ គេអាចប្រើ គោ ក្របី ធ្វើជាមធ្យោបាយដោះដូរ នៅក្នុងសេដ្ឋកិច្ច-សង្គមទូទៅ ឬនៅក្នុងវិស័យកសិកម្ម ពីព្រោះគេអាចទទួលផលប្រយោជន៍បានច្រើន ដូចជា យកទឹកដោះ បន្តពូជ ឬ ជាមធ្យោបាយដឹកជញ្ជូន ហើយនៅតែរក្សា គោ ក្របី ដដែល។ ម៉្យាងទៀត គេអាចប្រើ គោ ក្របី ដើម្បីទិញ ឬដោះដូរ របស់ដែលមានតម្លៃខ្ពស់បាន ដូចជា ដីធ្លី ផ្ទះសម្បែង ជាដើម។ លក្ខណៈពិសេសមួយទៀត គឺ គោ ក្របី យើងមិនចាំបាច់ដឹកជញ្ជូនទេ ពីព្រោះ វាអាចធ្វើដំណើរដោយខ្លួនវា ហើយអាចដឹកម្ចាស់វាបានថែមទៀតផង។

**គ. ងាយស្រួលក្នុងការប្រើប្រាស់** (Processability)

ជាវត្ថុងាយស្រួលក្នុងវាស់វែង និងមានតម្លៃខ្ពស់ បរិមាណតិចអាចដោះដូរទំនិញផ្សេងទៀតបានច្រើន ងាយស្រួលយកតាមខ្លួន ឬងាយស្រួលក្នុងការដឹកជញ្ជូន នៅពេលមានតម្រូវការទូទាត់ ឬដោះដូរម្តងៗ។ ប៉ុន្តែ នៅពេលទូទាត់ម្តងៗ ត្រូវថ្លឹងទម្ងន់ ឬវាស់វែងបរិមាណ ធ្វើឱ្យមានភាពស្មុគស្មាញដែរ។ ហេតុនេះ ប្រើលោហធាតុជាមធ្យោបាយដោះដូរ មានលក្ខណៈងាយស្រួលជាង ជាពិសេស លោហធាតុមានតម្លៃ ពីព្រោះ គេអាចចាក់ពុម្ពជាទម្រង់ផ្សេងៗ និងដាក់សញ្ញាជាទម្ងន់ (ជី តម្លឹង ឬផោន) នៅលើលោហធាតុនោះ ធ្វើឱ្យមានភាពងាយស្រួល នៅពេលដោះដូរ ឬទូទាត់ម្តងៗ។

**ឃ. សុគតតាព** (Homogeneity)

ជាវត្ថុកម្រដែលអាចរក្សាបាននូវស្ថិរភាពតម្លៃរបស់វា ចៀសផុតពីការខាតបង់ក្នុងការរក្សាទុក។ ទោះបីជាត្រូវកែច្នៃ ឬប្តូររូបភាពទៅជាទម្រង់ផ្សេងៗក៏ដោយ ក៏នៅតែរក្សាសារជាតិដើម និងតម្លៃរបស់វានៅដដែល។ ម៉្យាងទៀត នៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើនឡើង គេអាចពង្រីកការផ្គត់ផ្គង់ទំនិញពិសេសនេះ ស្របនឹងទំហំ ឬសកម្មភាពសេដ្ឋកិច្ច។

**ង. អាចលក់ដូរបានងាយ** (Marketability)

ទំនិញដែលអាចប្រើជារូបិយវត្ថុបាន ត្រូវមានភាពងាយស្រួលក្នុងការទិញ-លក់ ឬដោះដូរ ដែលត្រូវបានទទួលស្គាល់ដោយតួអង្គសេដ្ឋកិច្ចទាំងអស់។ កត្តាសំខាន់

បំផុត ទំនិញដែលប្រើជារូបិយវត្ថុ ត្រូវមានតម្លៃទីផ្សារជាក់លាក់ដោយខ្លួនវា ជាមធ្យោបាយដោះដូរ ហើយក៏អាចប្រើជាទំនិញធម្មតាផងដែរ ដោយសារ វាអាចប្រើប្រាស់បាននៅក្នុងតម្រូវការសេដ្ឋកិច្ច-សង្គម[3]។

តាមការសង្កេតនៅក្នុងប្រវត្តិនៃការរីកចម្រើនរបស់រូបិយវត្ថុ មានតែលោហធាតុមាសនិងប្រាក់ទេ ដែលមានលក្ខណៈពិសេសទាំង៥យ៉ាង ដូចបានរៀបរាប់ខាងលើ។ ហេតុនេះ លោហធាតុមាស និងប្រាក់ ត្រូវបានគេទទួលស្គាល់ជាទូទៅជារូបិយវត្ថុ ដោយប្រើប្រាស់សម្រាប់ទូទាត់ក្នុងពេលដំណាលគ្នា និងមានតម្លៃស្មើគ្នា។ មានន័យថា គេអាចប្រើមាស ដើម្បីទូទាត់ក៏បាន ឬ ប្រើប្រាក់ ដើម្បីទូទាត់ក៏បាន ក្នុងទម្ងន់ ឬបរិមាណស្មើគ្នា មានតម្លៃស្មើគ្នា។ លោហធាតុមាស ឬប្រាក់ ត្រូវបានប្រើក្នុងទម្រង់ផ្សេងគ្នា ដូចជា មាស ឬប្រាក់ ត្រូវបានកាត់ ច្រៀក ជាដុំតូចៗ ឬហូតជាខ្សែ ផែជាបន្ទះ ឬសន្លឹក ឬចាក់ពុម្ពជាកាក់មូល ឬរាងពងក្រពើ និងទម្រង់ផ្សេងទៀត ហើយគេដាក់តម្លៃនៅលើលោហធាតុនោះ ដើម្បីងាយស្រួលក្នុងការទូទាត់។ ទោះជាយ៉ាងនេះក្តី តម្លៃលោហធាតុមាស និងប្រាក់ បានប្រែប្រួលមិនទៀងទាត់ ម្តងលោហធាតុប្រាក់ចុះថោក និងម្តងលោហធាតុមាសចុះថោកវិញ។ មកដល់ដំណាក់កាលចុងក្រោយ ដោយសារ ការរកឃើញលោហធាតុប្រាក់ច្រើនសន្ធឹកសន្ធាប់ ធ្វើឱ្យតម្លៃលោហធាតុប្រាក់បានធ្លាក់ចុះជាបន្តបន្ទាប់ ធ្វើឱ្យអ្នករក្សាទុកលោហធាតុប្រាក់ទទួលរងការខាតបង់។ ជាបណ្តើរៗ លោហធាតុប្រាក់បានឃ្លាតឆ្ងាយពីតួនាទីជារូបិយវត្ថុ ដោយបន្សល់ទុកលោហធាតុមាសតែមួយគត់ បំពេញតួនាទីជារូបិយវត្ថុ រហូតមកដល់បច្ចុប្បន្ននេះ។

សរុបសេចក្តីមក លោហធាតុមាសបំពេញតួនាទីពីរសំខាន់ នៅក្នុងសេដ្ឋកិច្ច-សង្គម នាពេលបច្ចុប្បន្ន គឺជា"**ទំនិញធម្មតា**" និងជា"**ទំនិញពិសេស**"។ "**មាស**"ជាទំនិញធម្មតានៅពេលដែលគេប្រើវា ដោយកែច្នៃជាគ្រឿងអលង្ការ ឬរបស់ប្រើប្រាស់ដើម្បីបំពេញតម្រូវការផ្សេងទៀត។ ប៉ុន្តែ "**មាស**" នឹងក្លាយជាទំនិញពិសេស នៅពេលគេផែជាសន្លឹក ចាក់ពុម្ពជាបន្ទះ ឬកាសមូល ឬជាទម្រង់ផ្សេងទៀត សម្រាប់ប្រើប្រាស់ជាមធ្យោបាយទូទាត់ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។ ជាពិសេស មាសត្រូវបានប្រើជាធនបម្រុងរបស់ប្រទេសនីមួយៗ

---

[3] Hakan Ş., *An Essay on the Nature and Types of Money*, Medipol University, 2017.

នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិនានា ដូចជា ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ជាដើម។ ប្រទេសនីមួយៗអាចមានជម្រើស ដោយប្រើរូបិយវត្ថុអន្តរជាតិណាមួយ ដូចជា ប្រាក់ដុល្លារអាមេរិក ឬប្រាក់ផោនស៍របស់អង់គ្លេស ឬ អាចប្រើមាសក៏បាន ក្នុងការដំកល់ជាធនបម្រុងអន្តរជាតិ ដើម្បីក្លាយជាសមាជិកនៃស្ថាប័នហិរញ្ញវត្ថុអន្តរជាតិណាមួយនោះ។

ម្យ៉ាងទៀត មាសត្រូវបានប្រើធ្វើជាវត្ថុធានាក្នុងការបោះផ្សាយក្រដាសប្រាក់នៅក្នុងប្រទេសនីមួយៗ នៅក្នុងដំណាក់កាលដំបូងនៃការប្រើប្រាស់ក្រដាសប្រាក់ទន្ទឹមនឹងការប្រើលោហធាតុមាស ឬ ហៅថា **បទដ្ឋានមាស**។

### ១.៣. បទដ្ឋានមាស (Gold standard)

ទម្រង់ដំបូងគេរបស់រូបិយវត្ថុទំនិញ ដែលមានតម្លៃពិតប្រាកដរបស់វា ដូចជា ទំនិញធម្មតា និងលោហធាតុមាស ឬប្រាក់ ជាដើម។ តម្លៃដែលត្រូវដោះដូរ គឺអាស្រ័យលើតម្លៃរូបិយវត្ថុទំនិញផ្ទាល់ ឬ កម្លាំងទិញរបស់វា។ ដំណាក់កាលក្រោយមក មាសត្រូវបានគេទទួលស្គាល់ជារូបិយវត្ថុអន្តរជាតិ នៅក្នុងសតវត្សរ៍ទី១៧ ហើយចក្រភពអង់គ្លេសជាប្រទេសដំបូងគេ ដែលបានអនុវត្តបទដ្ឋានមាស នៅដើមទសវត្សរ៍ឆ្នាំ១៧០០ ហើយត្រូវបានប្រើប្រាស់ទូលំទូលាយ នៅក្នុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ ទី២០។ មានន័យថា ប្រព័ន្ធនេះត្រូវបានគេទទួលស្គាល់រហូតដល់អំឡុងសង្គ្រាមលោកលើកទី១ ដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩១៤។ បន្ទាប់មក ប្រព័ន្ធនេះ បានជួបការលំបាកខ្លាំង ធ្វើឱ្យគេលែងអនុវត្តតាមបទដ្ឋានមាសនេះតទៅទៀតនៅក្នុងសតវត្សរ៍ទី២០កន្លងទៅ[4]។ តម្លៃក្រដាសប្រាក់ តែងតែធ្លាក់ចុះ ធៀបនឹងតម្លៃមាស ដោយសារការបោះផ្សាយក្រដាសប្រាក់កាន់តែច្រើនឡើង ដើម្បីបំពេញតម្រូវការ ប៉ុន្តែ បរិមាណមាសដែលដាក់ដំកល់នៅដដែល ដែលគេហៅថា គោលនយោបាយបញ្ចុះបទដ្ឋានមាស។

បទដ្ឋានមាស គឺជាការសន្យារបស់ប្រទេសដែលចូលរួមក្នុងប្រព័ន្ធនេះ កំណត់តម្លៃរូបិយវត្ថុក្នុងស្រុករបស់ខ្លួនធៀបនឹងបរិមាណមាស។ មានន័យថា រូបិយវត្ថុជាតិ និងទម្រង់ផ្សេងទៀតនៃរូបិយវត្ថុ ដូចជា ប្រាក់បញ្ញើធនាគារ និងកំណត់ត្រាធនាគារ

[4] Muhammad Rizwan, *Introductionand Evolution of Money. Why is it needed ?* 2014.

(bank notes) ជាដើម អាចប្តូរយកមាសបានដោយសេរី តាមអត្រាតម្លៃដែលបានកំណត់។ សហរដ្ឋអាមេរិកបានអនុវត្តបទដ្ឋានមាស នៅឆ្នាំ១៨៣៤ ដោយកំណត់តម្លៃ២០,៦៧ដុល្លារក្នុង១អោនស៍ ហើយបានរក្សាអត្រាតម្លៃនេះរហូតដល់ឆ្នាំ១៩៣៣។ ចំណែក ប្រទេសមួយចំនួនផ្សេងទៀត បានចូលរួមក្នុងប្រព័ន្ធបទដ្ឋានមាសនេះ ក្នុងរវាងទសវត្សរ៍ឆ្នាំ១៨៧០[5]។

ហេតុនេះ បទដ្ឋានមាស គឺជាប្រព័ន្ធរូបិយវត្ថុដែលក្រដាសប្រាក់អាចមានតម្លៃដោយសារការផ្សារភ្ជាប់ទៅនឹងតម្លៃមាស។ ក្នុងបរិបទនេះ ប្រទេសផ្សេងៗជាច្រើនបានឯកភាពគ្នា ដោយអនុញ្ញាតឱ្យប្តូរបានដោយសេរី ពីក្រដាសប្រាក់ទៅមាស ឬ ពីមាសទៅក្រដាសប្រាក់វិញ ក្នុងអត្រាតម្លៃដែលបានកំណត់។ តម្លៃមាសត្រូវបានកំណត់ក្នុងការទិញ-លក់នៅក្នុងទីផ្សារ ហើយគេយកតម្លៃមាសនោះ ដើម្បីកំណត់តម្លៃក្រដាសប្រាក់ ដែលត្រូវបោះពុម្ពផ្សាយ។ មកដល់ឆ្នាំ១៩៤៤ កិច្ចព្រមព្រៀង Bretton Woods បានកំណត់អត្រាប្តូរប្រាក់របស់ប្រទេសផ្សេងៗ ធៀបនឹងប្រាក់ដុល្លារអាមេរិក ហើយធនាគារកណ្តាលអាមេរិក អាចប្តូរប្រាក់ដុល្លារជាមួយមាស ក្នុងតម្លៃ៣៥ដុល្លារ ក្នុង១អោនស៍ ហើយបន្ទាប់មក ក្នុងតម្លៃ៣៨ដុល្លារក្នុង១អោនស៍។ តម្លៃក្រដាសប្រាក់ដុល្លារអាមេរិកបានធ្លាក់ចុះជាបន្តបន្ទាប់ ពីគ្រាមួយទៅគ្រាមួយ។ ជាក់ស្តែង នៅឆ្នាំ១៩៧៣ តម្លៃមាសបានកើនឡើងដល់៤២,២២ដុល្លារក្នុង១អោនស៍ ធ្វើឱ្យអាមេរិកសម្រេចចិត្តបោះបង់ចោលបទដ្ឋានមាសនេះជាផ្លូវការ នៅឆ្នាំ១៩៧៦ ដោយមិនអនុញ្ញាតឱ្យប្តូរប្រាក់ដុល្លារអាមេរិកជាមួយមាសបានទៀតទេ[6]។

### ១.៤. ក្រដាសប្រាក់ (Paper money)

មកដល់សតវត្សរ៍ទី១៦ ស្របជាមួយនឹងការរីកចម្រើនខាងវិស័យពាណិជ្ជកម្ម តម្រូវការនៃការប្រាស្រ័យទាក់ទងពីតំបន់មួយទៅតំបន់មួយ ការដោះដូរកាន់តែមានភាពសកម្ម និងមមាញឹក ជាមួយនឹងបរិមាណនៃការដោះដូរកាន់តែច្រើន។ ក្នុងដំណាក់កាលនេះ ការដោះដូរ និងការទូទាត់ដោយប្រើមាស ឬ ប្រាក់ បានជួបនូវ

---

[5] Michael D. Bordo, *Gold Standard*, https://www.econlib.org/library/Enc/GoldStandard.html

[6] Wikipedia, *Gold Standard*, https://en.wikipedia.org/wiki/Gold_standard.

ឧបសគ្គជាច្រើន ដូចជា ការដឹកជញ្ជូន ការរក្សាសុវត្ថិភាព និងការរក្សាទុក ជាដើម។ ហេតុនេះ ក្រដាសប្រាក់បានកើតឡើងជំនួសលោហធាតុមាស ឬប្រើប្រាស់ក្នុងពេលទន្ទឹមគ្នាជាមួយរូបិយវត្ថុមាស។ ហេតុអ្វីបានជាក្រដាសប្រាក់កើតឡើងជំនួសមាស?

ដោយមានការព្រួយបារម្ភពីសុវត្ថិភាព នៅពេលដឹកជញ្ជូនដើម្បីទូទាត់ និងសុវត្ថិភាពក្នុងការរក្សាទុក ពាណិជ្ជករធំៗ បានយកលោហធាតុមាសទៅរក្សាទុក នៅទីកន្លែងដែលមានសុវត្ថិភាព ហើយប្តូរមកវិញនូវវិក្កយបត្រទទួលមាសដោយបញ្ជាក់ពីបរិមាណមាសច្បាស់លាស់។ ជាបណ្តើរៗ វិក្កយបត្រនោះ ត្រូវបានទទួលស្គាល់ និងប្រើប្រាស់ក្នុងការទូទាត់ ដោយផ្អែកលើតម្លៃដែលបានសរសេរនៅលើវិក្កយបត្រនោះ ពីព្រោះពួកគេជឿជាក់ថា គេអាចយកវិក្កយបត្រនោះ ទៅបើកយកមាសវិញ នៅពេលណាក៏បាន។ ជាបន្តបន្ទាប់ វិក្កយបត្រទាំងនោះ បានធ្វើចរាចរណ៍ពីបុគ្គលម្នាក់ទៅម្នាក់ទៀត ដោយមិនបានវិលត្រឡប់មកកន្លែងរក្សាទុក ដើម្បីដកយកមាសទៅវិញទេ។ វិក្កយបត្រសំគាល់បរិមាណមាសទាំងនោះហើយ ត្រូវបានគេទទួលស្គាល់ថា ជាការកកើតដំបូងរបស់ក្រដាសប្រាក់ ឬ មូលប្បទានបត្រ ដែលកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន។ ស្ថាប័នដែលទទួលរក្សាទុកមាសនោះ ត្រូវបានគេទទួលស្គាល់ថា ជាធនាគារ ពីព្រោះវាបានបំពេញមុខងារបីយ៉ាង គឺ ទទួលប្រាក់បញ្ញើ ផ្តល់ឥណទាន និងបម្រើសេវា ទូទាត់ ដូចមានក្នុងខ្លឹមសារខាងក្រោម៖

- ***ទទួលប្រាក់បញ្ញើ:*** ទទួលរក្សាទុកមាស ហើយចេញវិក្កយបត្រសម្គាល់បរិមាណមាស ដែលបានដាក់ផ្ញើ ឬរក្សាទុកនោះ។
- ***ផ្តល់ឥណទាន:*** នៅពេលទទួលរក្សាទុកមាស អ្នកផ្ញើកម្រមកដកយកមាសទៅប្រើដើម្បីទូទាត់ណាស់ ធ្វើឱ្យគេនៅសល់មាសច្រើនដែលបានរក្សាទុក។ ហេតុនេះ គេអាចយកមាសទាំងនោះសម្រាប់ផ្តល់ឱ្យខ្ចី។
- ***សេវាទូទាត់:*** គេអាចយកវិក្កយបត្ររក្សាទុកមាស ទៅបើកយកមាសវិញបាន នៅពេលគេត្រូវការមាស ពោលគឺមានលក្ខណៈដូចមូលប្បទានប័ត្រ ដែលយើងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

ក្នុងដំណាក់កាលនោះ មានវិក្កយបត្រទទួលរក្សាទុកមាសជាច្រើន ត្រូវបានបោះពុម្ពផ្សាយ ជាពិសេស វិក្កយបត្របោះពុម្ពផ្សាយដោយសិប្បកររចាក់ពុម្ពមាស។ បន្ទាប់មក សិប្បកររចាក់ពុម្ពមាស បានប្រែក្លាយទៅអាជីវកររជួញដូរលោហធាតុមាន

តម្លៃ ហើយបានបំពេញមុខងារទាំងបីខាងលើ។ ម៉្យាងទៀត នៅទីអារាមនៃសាសនាក៏ជាកន្លែងមានសុវត្ថិភាព ដែលទទួលបានការជឿទុកចិត្តពីពាណិជ្ជករ ក្នុងការរក្សាទុកមាសផងដែរ។ វិក្កយបត្រដែលបោះផ្សាយទាំងនោះ មួយចំនួនត្រូវបានទទួលស្គាល់ទូលំទូលាយ ប៉ុន្តែ មួយចំនួនទៀតមិនសូវមានជំនឿទុកចិត្តពីអ្នកប្រើប្រាស់ ឬពាណិជ្ជករឡើយ ធ្វើឱ្យក្របខ័ណ្ឌក្នុងការទទួលស្គាល់វិក្កយបត្រនោះក្នុងការទូទាត់នៅមានកម្រិតនៅឡើយ។ ហេតុនេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗ បានទាញយកតួនាទីនៃការបោះពុម្ពផ្សាយក្រដាសប្រាក់ មកធ្វើជាតួនាទីផ្ដាច់មុខរបស់ធនាគារកណ្ដាល (Central bank) ក្នុងរវាងសតវត្សរ៍ទី១៩។ បច្ចុប្បន្ននេះ ការបោះពុម្ពផ្សាយក្រដាសប្រាក់ ត្រូវបានកំណត់ដោយច្បាប់នៅក្នុងប្រទេសនីមួយៗ ហើយបង្ខំឱ្យប្រជាពលរដ្ឋគ្រប់ៗរូប ត្រូវតែទទួលស្គាល់ក្រដាសប្រាក់ក្នុងការទូទាត់។

### ១.៥. ប្រាក់អេឡិចត្រូនិក (Electronic money)

ទន្ទឹមនឹងការរីកចម្រើននៃបច្ចេកវិទ្យា ជាពិសេសផ្នែកព័ត៌មានវិទ្យា ធ្វើឱ្យរូបិយវត្ថុក៏បានវិវត្តយ៉ាងឆាប់រហ័សផងដែរ។ ក្រៅពីមូលប្បទានបត្រ និងប័ណ្ណឥណទាន ដែលអាចប្រើប្រាស់ក្នុងការទូទាត់បានទូលំទូលាយ គេក៏អាចប្រើការទូទាត់ដោយផ្ទេរខ្ទង់ពីគណនីមួយទៅគណនីមួយទៀត តាមប្រព័ន្ធធនាគារ ទាំងក្នុងនិងក្រៅប្រទេស ឬ ប្រើអេប (App) ដែលធ្វើឱ្យគេអាចផ្ទេរប្រាក់ ដោយប្រើទូរស័ព្ទស្មាតហ្វូន (Smart phone) ដើម្បីទិញទំនិញ ឬសេវាកម្មផ្សេងៗ បានយ៉ាងងាយស្រួល ឆាប់រហ័ស សុវត្ថិភាព និងចំណាយអស់តិចបំផុត។

**ជារួម** ក្នុងសម័យទំនើបនាពេលបច្ចុប្បន្ន យើងមានមធ្យោបាយទូទាត់សម្បូរបែប ហើយអាចប្រើប្រាស់បានទូលំទូលាយ ដូចជា ក្រដាសប្រាក់កាស មូលប្បទានបត្រ ប័ណ្ណឥណទាន រូបិយវត្ថុចំណារ ការបញ្ជូន-ផ្ទេរ ដើម្បីទូទាត់ដោយប្រើបច្ចេកវិទ្យា ឬប្រព័ន្ធអេឡិចត្រូនិក និងមធ្យោបាយទូទាត់ផ្សេងៗទៀត។

## ២. ប្រវត្តិរូបិយវត្ថុនៅកម្ពុជា

រូបិយវត្ថុដំបូងកើតឡើងក្រោមរូបភាពពីរ គឺការដោះដូរទំនិញនិងទំនិញ និងត្រូវបានប្រើធ្វើជាតង្វាយ ឬជំនូន សម្រាប់អ្នកមានសក្ដិយស។ រូបិយវត្ថុមានតួនាទីក្នុងការសម្របសម្រួលកិច្ចការជំនួញ និងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច ផ្សេងទៀត។

នៅពេលដែលសេដ្ឋកិច្ច-សង្គម កាន់តែមានការរីកចម្រើន ធ្វើឱ្យមានការបែងចែកកម្លាំងពលកម្ម និងមធ្យោបាយផលិតកម្ម ទៅតាមប្រភេទនៃការងារ ឬ ឯកទេសនីយកម្មកម្រិតទាប។ មនុស្សម្នាក់ៗ ឬ មួយក្រុម ផលិតបាននូវផលិតផលផ្សេងៗ ឬសេវាកម្មទៅតាមការច្នៃប្រឌិត និងភាពប៉ិនប្រសប់រៀងៗខ្លួន។ ប៉ុន្តែ ពួកគេមិនអាចផលិតវត្ថុគ្រប់យ៉ាង ដើម្បីបំពេញតម្រូវការខ្លួនឯងបានគ្រប់គ្រាន់ទេ។ ហេតុនេះ ទើបធ្វើឱ្យមានការដោះដូររវាងទំនិញ និងទំនិញបានកើតឡើង។ នៅក្នុងប្រទេសនីមួយៗ រូបិយវត្ថុមិនបានលេចចេញភ្លាមៗ ប្រកបដោយប្រសិទ្ធភាពនោះទេ ពោលគឺ បានជួបនឹងឧបសគ្គ និងឆ្លងកាត់ការវិវត្តិជាច្រើនដំណាក់កាល។

ការប្រើលោហធាតុមាស និងប្រាក់ជារូបិយវត្ថុ បានកើតឡើងតាំងពីសតវត្សរ៍ទី៧ ឬ ទី៨ មុនគ្រិស្តសករាជ នៅអាស៊ីមីន័រ (Asia Minor)[7]។ រីឯ នៅប្រទេសក្រិចបុរាណ គេឃើញមានកាស សម្រាប់ប្រើប្រាស់ក្នុងការចាយវាយ តាំងពីពេលដែលក្រិចមានទីក្រុងនៅលីឌី (Lydia) មកម្ល៉េះ។ ប៉ុន្តែ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា ស្តេចក្រេស៊ុស (Croesus) ជាអ្នកបង្កើតឡើងក្នុងរវាង ១ ឬ២ សតវត្សរ៍ក្រោយមកទៀតវិញ។ កាសនេះ ត្រូវបានគេឆ្លាក់ជាត្រារូបតោ ប្រើជារូបិយវត្ថុក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសក្រិចបុរាណ។

**រូបភាពទី១.៣: កាសមាសក្រេស៊ុស** (Croesus coin)



Source: *Croeseid*, https://en.wikipedia.org/wiki/Croeseid

ដំណើរការបោះផ្សាយកាសបានវិវត្តិជាបន្តបន្ទាប់ ដែលទទួលឥទ្ធិពលនៃអារ្យធម៌ក្រិច ចាប់តាំងពីសតវត្សរ៍ទី៥មកម្ល៉េះ ហើយគេច្រើនតែបោះផ្សាយកាសមាស ឬ

[7] អាស៊ីមីន័រ ឬហៅថា អាណាតូលី (Anatolia) គឺជាឧបទ្វីបផ្នែកអាស៊ីនៃទឹកដីតួកគី

ប្រាក់សុទ្ធ ដោយសារ ការរីកចម្រើននៃការផលិតលោហធាតុមាស និងប្រាក់ ហើយកាន់តែសម្បូរបែប។ ប្រទេសផ្សេងៗទៀត ក៏បានបោះផ្សាយកាសក្នុងរូបភាពផ្សេងៗគ្នា ទៅតាមជំនឿ សាសនា ឬប្រពៃណី រៀងៗខ្លួន។ ប្រទេសខ្លះយករូបសត្វ ប្រទេសខ្លះយករូបអាទិទេព ប្រទេសខ្លះយករូបស្ដេច ដែលគេគោរព ជារូបសំណាក។ ប៉ុន្តែ កាសដែលល្បីសុសសាយជាងគេ គឺ **កាសត្រាច្ម** (drachme) របស់ទីក្រុងអាថែន ជាពិសេស គឺ កាសប្រាក់ដែលមានតម្លៃ៤ត្រាច្ម។ កាសនេះសុទ្ធល្អ ហើយមានទម្ងន់ត្រឹមត្រូវ និងទៀងទាត់ណាស់។ គេបានទទួលស្គាល់កាសនេះ ជារូបិយវត្ថុអន្តរជាតិគោល នៅសម័យកាលនោះ។

នៅក្នុងសករាជនៃពិភពក្រិច បានរីករាលដាលជាបន្តបន្ទាប់ ទៅពាសពេញតំបន់មហាសមុទ្រមេឌីទែរ៉ាណេ និងបានរីកសាយមកដល់បណ្ដាប្រទេសនៅអាស៊ីដូចជា ប្រទេសឥណ្ឌា និងប្រទេសចិន ជាដើម។

**រូបភាពទី១.៨: កាសត្រាច្មរបស់ក្រុងអាថែន** (Drachme athénienne)



Source: *Monnaie athénienne*,
https://fr.wikipedia.org/wiki/Monnaie_ath%C3%A9nienne

**រូបិយវត្ថុសាប៉ែក (Sapecs)** របស់ចិនធ្វើពីទង់ដែង ឬ ស្ពាន់ ក៏ដូចជា ដែក ឬ សំណ បានឈានដល់កម្រិតកំពូល នៅក្នុងសម័យរាជវង្ស តាំង និងសុង (Tang and Song Dynasty) ហើយបានរីកសាយរហូតមកដល់អាស៊ី-អាគ្នេយ៍យើងនេះ។ ប្រជាជនខ្មែរ នៅសម័យហ្វូណន ធ្លាប់បានស្គាល់ប្រភេទរូបិយវត្ថុនេះផងដែរ ដោយពួកអ្នកជំនួញមកពីឆ្ងាយៗ បានចូលមកសំចតតាមកំពង់ផែនៃទន្លេមេគង្គភាគខាងក្រោម។ ប៉ុន្តែ អ្នកស្រុកហ្វូណនមិនសូវប្រើប្រាស់រូបិយវត្ថុរបស់អ្នកជំនួញទាំងនោះ

ញឹកញាប់ប៉ុន្មានទេ។ ទាល់តែ ប្រហែលជា២០សតវត្សរ៍ក្រោយមក ទើបកម្ពុជាអាចរៀបចំបោះពុម្ពផ្សាយរូបិយវត្ថុខ្លួនឯង។ ការបោះផ្សាយរូបិយវត្ថុខ្មែរដំបូងគេ កើតមាននៅក្នុងរាជ្យព្រះបាទ**ស្រីជេដ្ឋា** ក្នុងចន្លោះពីចុងសតវត្សរ៍ទី១៥ និងដើមសតវត្សរ៍ទី១៦។ នៅគ្រានោះ គេសង្កេតឃើញមានរូបិយវត្ថុជាច្រើនប្រភេទ រួមទាំងប្រភេទរូបិយវត្ថុសាមញ្ញដំបូងៗ ត្រូវបានគេប្រើប្រាស់នៅកម្ពុជារហូតដល់ចុងសតវត្សរ៍ទី១៩។

នៅក្នុងសម័យកាលនោះ មានព្រះរាជាកែទម្រង់មួយចំនួនតូច ដែលបានយល់ពីសារៈសំខាន់របស់រូបិយវត្ថុ។ ព្រះរាជាទាំងនោះមានព្រះទ័យចង់ឱ្យខ្មែរមានអំណាចដូចពីមុនឡើងវិញ ហើយបានបោះពុម្ពរូបិយវត្ថុឡើង ដោយចាប់ផ្ដើមចេញពីរូបិយប័ណ្ណបរទេស ដូចជា ប្រាក់បាតរបស់សៀម ប្រាក់ពីយ៉ាស់ (Piastre) របស់ម៉ិចស៊ិក និងប្រាក់ហ្វ្រង់របស់បារាំង ជាដើម។ តាមឯកសារប្រវត្តិសាស្ត្រខ្មែរបង្ហាញថា ការបោះពុម្ពរូបិយវត្ថុ សម្រាប់ការដោះដូរក្នុងពាណិជ្ជកម្ម នៅក្រោមរជ្ជកាលរបស់ព្រះបាទបរមរាជាទី៧ ក្នុងចន្លោះពីឆ្នាំ១៦០២ ដល់ឆ្នាំ១៦១៩ ក្រោមគំនិតផ្ដួចផ្ដើម និងការគ្រប់គ្រងរបស់ ព្រះបុត្រាច្បងរបស់ព្រះរាជា គឺ ព្រះបាទជ័យជេដ្ឋា ដែលឡើងស្នងរាជ្យបន្តពីព្រះបិតា។

ព្រះបាទជ័យជេដ្ឋា បានរៀបចំសណ្ដាប់ធ្នាប់ក្នុងប្រទេស និងពង្រឹងស្ថាប័នរដ្ឋបន្តពីព្រះបិតា ហើយទ្រង់បានចាប់ផ្ដើមសើរើ ពិនិត្យមើលឡើងវិញ និងចងក្រងច្បាប់ទំលាប់ ដែលកំពុងមានជាធរមាន នៅក្នុងអំឡុងពេលដែលព្រះអង្គគ្រងរាជសម្បត្តិ ពីឆ្នាំ១៦១៩ ដល់ឆ្នាំ១៦២៧។ កាលទ្រង់នៅជារជ្ជទាយាទនៅឡើយ ទ្រង់បានចាប់ផ្ដើមបោះពុម្ពរូបិយវត្ថុ ដោយប្រើរូបិយវត្ថុចាស់ មានឈ្មោះថា ទួន គឺជាកាសមានរាងជុំមូល មានប្រភពចេញពីស្រុកសៀម។ ក្រោយមក ទ្រង់បានកែប្រែរូបិយវត្ថុដែលមានស្រាប់ ឬ ដែលយកមកពីស្រុកសៀម ឱ្យទៅជាប្រាក់ស្លឹងទាំងអស់[8]។

## ២.១. កាសដែលធ្វើចរាចរណ៍នៅសម័យហ្វូណន

នៅក្នុងសម័យកាលរាជាណាចក្រហ្វូណន ដែលមានអារ្យធម៌រុងរឿង ទទួលឥទ្ធិពលពីអារ្យធម៌ឥណ្ឌា និងមានឥទ្ធិពលខ្លាំងក្លានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងសម័យកាលនោះ គេសង្កេតឃើញមានរូបិយវត្ថុធ្វើពីប្រាក់ ត្រូវបានធ្វើចរាចរណ៍

[8] ហ្សង់ ម៉ីយែរ *រូបិយវត្ថុ និងអធិបតេយ្យភាព* ភាគ១ ឆ្នាំ២០០៩

ក្នុងរវាងសតវត្សរ៍ទី៤ ដល់សតវត្សរ៍ទី៦ នៃគ្រិស្តសករាជ។ ប្រភេទរូបិយវត្ថុនេះ ទំនងជាមិនមែនបោះពុម្ពផ្សាយដោយរាជាណាចក្រហ្វូណនទេ ប៉ុន្តែ ប្រហែលជាត្រូវបានបោះពុម្ពផ្សាយដោយឧត្តរាធិការី (អ្នកស្នងរាជ្យ) គឺជា រាជាណាចក្រទ្វារវត្តី (Kingdom of Dvaravati)។ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនយល់ឃើញថា រាជាណាចក្រទ្វារវត្តី គឺជារាជាណាចក្រសៀមដំបូង[9]។

**រូបភាពទី១.៥: រូបិយវត្ថុនៅសម័យរាជាណាចក្រហ្វូណន**



រូបិយវត្ថុនេះត្រូវបានបោះពុម្ពផ្សាយ ក្នុងរវាងឆ្នាំ២០០ ទៅ ៥០០ នៃគ្រិស្តសករាជ

Source: *Funan Kingdom*, https://www.cointalk.com/threads/funan-kingdom.240800/

## ២.២. ប្រាក់ស្លឹង

ប្រាក់ស្លឹង គឺជារូបិយវត្ថុកម្ពុជាដំបូងគេ ត្រូវបានបោះពុម្ព និងដាក់ឲ្យធ្វើចរាចរណ៍ នៅក្នុងរាជ្យព្រះស្រីជេដ្ឋាធិរាជរាមាធិបតី (ហៅស្ដេចកន) នៅក្នុងសតវត្សរ៍ទី១៦។ ព្រះអង្គបានដណ្ដើមរាជសម្បត្តិ និងឡើងសោយរាជ្យពីឆ្នាំ១៥១២ រហូតដល់ឆ្នាំ១៥២៦។ ប្រាក់ស្លឹងនេះ ជាប្រភេទកាសមូលស្តើងមានទម្ងន់ក្រោម២ភាគ៣នៃជី ដែល១ជីស្មើនឹង២,៥ក្រាម។ ប្រាក់ស្លឹងត្រូវបានបោះពុម្ពពីមាស ប្រាក់ ឬស្ពាន់ ដែលមានត្រារូបនាគនៅពីមុខជាសញ្ញាសម្គាល់។

ព្រះអង្គបានបង្កើតប្រាក់នេះឡើង ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មជាមួយបរទេស ព្រោះកាលពីមុនរជ្ជកាលរបស់ព្រះអង្គ ការដោះដូរធ្វើ

---

[9] *Funan Kingdom*, https://www.cointalk.com/threads/funan-kingdom.240800/

ឡើងដោយការប្តូរទំនិញគ្នា ឬ យកមាសមកប្តូរយកទំនិញតែម្តង ដែលគេពិបាកក្នុងការកំណត់តម្លៃរបស់វា។ តាមឯកសារប្រវត្តិសាស្ត្របង្ហាញថា ព្រះស្រីជេដ្ឋា បានចរចាសន្តិភាពជាមួយប្រទេសជិតខាង ហើយមានទំនាក់ទំនងពាណិជ្ជកម្មជាច្រើនជាមួយបរទេស។

រូបភាពទី១.៦: រូបិយវត្ថុ ប្រាក់ស្លឹង




ប្រភព: *សម្តេចតេជោ ហ៊ុន សែន ផ្តល់ «ប្រាក់ស្លឹង» ជារង្វាន់លើកទឹកចិត្តដល់សិស្សនិទ្ទេស A នៅឆ្នាំនេះ*២០១៨, https://www.interconrooster.com/archives/2018/11/08/25213

## ២.៣. ប្រាក់ប្រាសាទ

ប្រាក់ប្រាសាទត្រូវបានបោះពុម្ព និងដាក់ឱ្យប្រើប្រាស់នៅក្នុងចរាចរណ៍ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ក្នុងរវាងពីឆ្នាំ១៨៥០ ដល់ឆ្នាំ១៩៥៩។ នៅឆ្នាំ១៨៧៦ ព្រះបាទអង្គឌួង បានឱ្យបោះពុម្ពប្រាក់បីប្រភេទ គឺ ប្រាក់ស្លឹង (ទម្ងន់ប្រាក់១ជី) ប្រាក់ហ្លួង (ទម្ងន់ប្រាក់៥ហ៊ុន) ប្រាក់ប្រាសាទ (ទម្ងន់ប្រាក់៤ជី) ដែលនៅផ្ទៃកណ្តាលមានរូបសត្វហង្ស តំណាងឱ្យឈ្មោះ លោក សំអាង ហង្ស ដែលព្រះបាទអង្គឌួងបានបញ្ជូនឱ្យទៅរៀនពីវិជ្ជាបោះពុម្ពប្រាក់ នៅប្រទេសសៀម។ ចំណែក នៅម្ខាងទៀតមានរូបប្រាសាទកំពូលបីនិងត្រីសូល៍ និងមានចារឹកអក្សរថា ក្រុងកម្ពុជា (កម្ពុជា)។

រូបភាពទី១.៧: រូបិយវត្ថុ ប្រាក់ប្រាសាទ



ប្រភព: *ប្រាក់ប្រាសាទរបស់ព្រះបាទអង្គដួង* បោះពុម្ពផ្សាយនៅឆ្នាំ១៨៤៧

https://spktliv.com/archives/3470

## ២.៤. ក្រដាសប្រាក់

បារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជានៅឆ្នាំ១៨៦៣។ មកដល់ឆ្នាំ១៨៧៥ បារាំងបានផ្តល់សិទ្ធិពិសេសទៅឱ្យធនាគារឥណ្ឌូចិន ដែលជាធនាគារពាណិជ្ជមួយរបស់បារាំង ដើម្បីបោះពុម្ពផ្សាយក្រដាសប្រាក់ សម្រាប់ប្រទេសនៅក្នុងតំបន់ឥណ្ឌូចិនទាំងមូលប្រើប្រាស់រួមគ្នា។ ការចាប់ផ្តើមបោះពុម្ពលើកដំបូង គឺជាកាស (កាក់ដែលមានប្រហោងបួនជ្រុងនៅចំកណ្តាល) ដែលមានឈ្មោះថា ពីយ៉ាស់។ បន្ទាប់មក នៅឆ្នាំ១៨៩១ ធនាគារឥណ្ឌូចិនបានបោះផ្សាយជាក្រដាសប្រាក់ដោយដាក់ឱ្យប្រើប្រាស់រូបិយវត្ថុរួមគ្នា សម្រាប់បីប្រទេស គឺ កម្ពុជា វៀតណាម និងឡាវ ដែលស្ថិតនៅក្រោមអាណានិគមបារាំងដូចគ្នា។ នៅពេលនោះ ឈ្មោះក្រដាសប្រាក់ដែលប្រើរួមគ្នានោះ គឺ ពីយ៉ាស់ ប៉ុន្តែ ក៏មានឯកតាផ្សេងៗគ្នាទៅតាមប្រទេសនីមួយៗផងដែរ ដូចជា រៀលសម្រាប់កម្ពុជា ដុងសម្រាប់វៀតណាម និង គីបសម្រាប់ឡាវ។ ហេតុនេះ ឈ្មោះប្រាក់រៀលនេះ គឺចាប់ផ្តើមមានមុនការបង្កើតធនាគារជាតិនៃកម្ពុជាទៅទៀត។ មកដល់ឆ្នាំ១៩៤៨ បារាំងបានដកសិទ្ធិពីធនាគារឥណ្ឌូចិន ឈប់ឱ្យបោះពុម្ពក្រដាសប្រាក់ទៀត។ បន្ទាប់មក នៅឆ្នាំ១៩៥២ បារាំងបានបង្កើតវិទ្យាស្ថានបោះពុម្ពផ្សាយនៃរដ្ឋ កម្ពុជា វៀតណាម ឡាវ ដែលមានស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ (ជិតស្ពាននាគក្បែររមណីយដ្ឋានវត្តភ្នំ) ដើម្បីបោះពុម្ពផ្សាយរូបិយវត្ថុសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសទាំងបី។

ក្រោយពីអតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ ព្រះបាទ នរោត្តម សីហនុ បានចាប់ផ្តើមទាមទារឯករាជ្យ កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ រួចមក ទើបប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញពីអាណានិគមនិយមបារាំង នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៥៤ ហើយបានចាប់ផ្តើមបង្កើតធនាគារកណ្តាលរបស់ខ្លួន ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ និងបានបោះពុម្ពផ្សាយក្រដាសប្រាក់រៀល ដោយចាប់ផ្តើមដាក់ឱ្យធ្វើចរាចរណ៍ នៅខែកញ្ញា ឆ្នាំ១៩៥៥។ ចាប់ពីពេលនោះមក កម្ពុជាអាចកំណត់ដោយខ្លួនឯងនូវតម្លៃរូបិយវត្ថុជាតិ និងបរិមាណរូបិយវត្ថុ ដែលត្រូវបោះផ្សាយ។

ក្រោយមក ការធ្វើចរាចរណ៍ក្រដាសប្រាក់ត្រូវបានអាក់ខានក្នុងការប្រើប្រាស់ នៅពេលដែលប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៥។ របប ប៉ុល ពត បានកំទេចចោលទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចដល់កម្រិតសូន្យ ជាពិសេស លុបបំបាត់ចោលប្រព័ន្ធធនាគារ និងលែងឱ្យមានការចាយវាយក្រដាសប្រាក់តទៅទៀត។ ជាក់ស្តែង ក្នុងសម័យប៉ុលពតក៏មានបោះពុម្ពក្រដាសប្រាក់ដែរ ប៉ុន្តែ ដោយមានការពិភាក្សា និងបានឯកភាពគ្នាដោយមានទស្សនៈថា "លុយគឺជាប្រភពនៃការកេងប្រវ័ញ្ច និងជិះជាន់" ទើបនៅក្នុងសម័យប៉ុលពតក្រដាសប្រាក់នោះមិនត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងការចាយវាយទេ។

ក្រោយពីរបប ប៉ុល ពត ត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៩ ក្រដាសប្រាក់រៀលត្រូវបានបោះផ្សាយ និងដាក់ឱ្យធ្វើចរាចរណ៍ឡើងវិញ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ រហូតមកដល់ពេលបច្ចុប្បន្ន ហើយត្រូវបានធ្វើឱ្យកាន់តែល្អប្រសើរឡើងជាលំដាប់។ ក្រដាសប្រាក់រៀលត្រូវបានបោះពុម្ពផ្សាយ ដោយមានរូបភាពផ្សេងៗគ្នា ដូចជា វីរបុរសខ្មែរ សម្បត្តិវប្បធម៌ ប្រជាជន និងសកម្មភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីជំរុញសាមគ្គីភាពជាតិ ជាដើម[10]។

[10] *តើប្រាក់រៀលខ្មែរចាប់ផ្តើមចរាចរលើទីផ្សារតាំងពីពេលណាមក?* March 20, 2018, http://www.lareine.com.kh/news/eco-bussiness/20526/

រូបភាពទី១.៨: រូបិយវត្ថុកម្ពុជា




ប្រភព: *រូបិយវត្ថុស្ថិតក្នុងចរាចរណ៍*, https://www.nbc.org.kh/about_the_bank/banknotes_in_circulation.php

## ដំណើរវិវត្តិសង្ខេបរបស់រូបិយវត្ថុ ពីជំណាក់កាលទំនិញដូរទំនិញមកដល់ក្រដាសប្រាក់

-***ឆ្នាំ៩០០០-៦០០០មុនគ.ស.*** *គោ ក្របី ចៀម អូដ និងបសុសត្វផ្សេងទៀត ត្រូវបានប្រើមុនគេ ជារូបិយវត្ថុ។ បន្ទាប់មកនៅពេលកសិកម្មបានរីកចម្រើនឡើង បន្លែ ផ្លែឈើ ក៏ត្រូវបានប្រើជារូបិយវត្ថុដែរ។*

-***ឆ្នាំ១២០០មុនគ.ស.*** *សំបកខ្យងសមុទ្រត្រូវបានប្រើជារូបិយវត្ថុ ហើយត្រូវបានទទួលស្គាល់ និងប្រើប្រាស់ទូលំទូលាយ និងរយៈពេលយូរនៅក្នុងប្រវត្តិសាស្ត្ររូបិយវត្ថុ។*

-***ឆ្នាំ១០០០មុនគ.ស.*** *សង្កសី និងទង់ដែង ត្រូវបានចាក់ពុម្ពជាទម្រង់ផ្សេងៗ ដូចជា កាំបិត ប៉ែល ចបជីក ឬកាក់មូល ដែលផលិតដោយប្រទេសចិន។*

-***ឆ្នាំ៥០០មុនគ.ស.*** *កាក់ទំនើប លោហធាតុប្រាក់ត្រូវបានចាក់ពុម្ពជាកាក់មូលដូចទម្រង់កាក់ដែលប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ដោយមានឆ្លាក់ជារូបព្រះ ឬ ព្រះមហាក្សត្រ។ កាក់ប្រភេទនេះ គេឃើញមាននៅ លីឌៀ (Lydia) បច្ចុប្បន្នជាផ្នែកនៃប្រទេសតួកគី បន្ទាប់មក គេឃើញមានផលិតនៅប្រទេសក្រិច ពើស៊ាន (Persian) ជាឈ្មោះជនជាតិនៅអ៊ីរ៉ង់បច្ចុប្បន្ន ម៉ាសេដូនី និង រ៉ូម៉ាំង ជាដើម។*

-***ឆ្នាំ១១៨មុនគ.ស.*** *រូបិយវត្ថុស្បែកត្រូវបានប្រើនៅប្រទេសចិន។*

-***ឆ្នាំ៨០៦គ.ស.*** *ក្រដាសប្រាក់ ត្រូវបានរកឃើញដំបូងគេនៅប្រទេសចិន ក្នុងចន្លោះពីសតវត្សទី៩ ដល់សតវត្សទី១៥។ មកដល់ឆ្នាំ១៤៥៥ ក្រដាស់ប្រាក់មិនឃើញមានប្រើប្រាស់នៅប្រទេសចិនទៀតទេ ក្នុងរយៈពេលរាប់រយឆ្នាំ។ បន្ទាប់មកទើបឃើញមានក្រដាសប្រាក់បានកើតឡើងវិញនៅតំបន់អឺរ៉ុប។*

Source: *The History of Money*,

https://www.pbs.org/wgbh/nova/article/history-money/

## ៣. ការវាស់វែងរូបិយវត្ថុ (Measuring Money)

រូបិយវត្ថុ គឺជាអ្វីដែលត្រូវបានទទួលស្គាល់ជាទូទៅក្នុងការទូទាត់ទំនិញ ឬសេវាកម្ម។ គេទទួលយករូបិយវត្ថុក្នុងការទូទាត់ ពីព្រោះគេជឿជាក់ថា អ្នកដទៃទៀតក៏នឹងទទួលយកការទូទាត់ដែរ មានន័យថា រូបិយវត្ថុជាអ្វីដែលត្រូវបានសង្គមទទួលស្គាល់។ ដូចបានលើកឡើងខាងលើ ទ្រព្យ សម្ភារៈ ជាច្រើន បានបំពេញតួនាទីជារូបិយវត្ថុ នៅក្នុងប្រទេសនីមួយៗ រាប់ចាប់ពី ទំនិញ មាស ក្រដាសប្រាក់ រហូតដល់គណនីចរន្ត។ ក្នុងន័យនេះ និយមន័យរូបិយវត្ថុមិនបានកំណត់ច្បាស់ថា ប្រភេទសម្ភារៈណា នៅក្នុងសេដ្ឋកិច្ច ដែលចាត់ទុកជារូបិយវត្ថុនោះទេ។ ហេតុនេះ យើងត្រូវកំណត់ឱ្យបានច្បាស់ថា ទ្រព្យអ្វីខ្លះ ដែលត្រូវបានរាប់បញ្ចូលនៅក្នុងប្រភេទរូបិយវត្ថុ។ ធនាគារកណ្តាលនៃប្រទេសនីមួយៗ មានតួនាទីក្នុងការបោះផ្សាយ ផ្គត់ផ្គង់ និងគ្រប់គ្រងបរិមាណប្រាក់នៅក្នុងចរាចរណ៍។ បរិមាណរូបិយវត្ថុនៅក្នុងចរាចរណ៍ ត្រូវបានបែងចែកជា ប្រភេទ រូបិយវត្ថុ M1 រូបិយវត្ថុ M2 និងរូបិយវត្ថុ M3។

***រូបិយវត្ថុ M1*** ជាប្រភេទទ្រព្យ(assets) ដែលមានកម្រិតសន្ទនីយភាពខ្ពស់ជាងគេ អាចបំឡែងទៅជាសាច់ប្រាក់បានទាន់ពេលវេលា និងមិនទទួលរងការខាតបង់ ដើម្បីបំពេញតម្រូវការសាច់ប្រាក់បានភ្លាមៗ។ រូបិយវត្ថុ M1 រួមមានៈ ក្រដាសប្រាក់ដែលមាននៅក្នុងចរាចរណ៍ ធនបម្រុង និងសមមូលរូបិយវត្ថុផ្សេងទៀត ដែលអាចបំឡែងទៅជាសាច់ប្រាក់បានដោយងាយ ដូចជាៈ គណនីចរន្ត ដែលប្រើសម្រាប់បញ្ជូន-ផ្ទេរ ឬទូទាត់ក្នុងកិច្ចការជំនួញ និងមូលប្បទានប័ត្រ ជាដើម។

***រូបិយវត្ថុ M2*** រួមមានៈ រូបិយវត្ថុ M1 បូកបន្ថែមប្រាក់បញ្ញើសន្សំ ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លី និងមូលនិធិទីផ្សាររូបិយវត្ថុ (money market funds) ដូចជាៈ ហ៊ុននៅក្នុងមូលនិធិទៅវិញទៅមករបស់ទីផ្សាររូបិយវត្ថុ (money market mutual funds shares) ដែលមិនមានសន្ទនីយភាពខ្ពស់ ដូចរូបិយវត្ថុ M1 ទេ មានន័យថា អាចមានការលំបាកជាងក្នុងការបំឡែងទៅជាសាច់ប្រាក់ ឬអាចទទួលរងការខាតបង់បន្តិចបន្តួច[11]។

---

[11] Frederic S., *The economics of money, banking, and financial markets*, 2013, Pp. 58-61.

***រូបិយវត្ថុ M3*** គឺជាការបូកសរុបការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ទាំងអស់រួមមាន: រូបិយវត្ថុ M2 (ដែលមាន M1 នៅក្នុងនោះ) បូកបន្ថែមប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង និងមូលនិធិទីផ្សាររូបិយវត្ថុរបស់ស្ថាប័ន (institutional money market funds) កិច្ចសន្យាទិញយកវិញរយៈពេលខ្លី (short-term repurchase agreements) និងទ្រព្យដែលមានសន្ទនីយភាព និងមានទំហំធំ (larger liquid assets)។ ទោះជាយ៉ាងនេះក្តី ធនាគារធនបម្រុងសហព័ន្ធ ដែលជាធនាគារកណ្តាលរបស់សហរដ្ឋអាមេរិក មិនបានដាក់បញ្ចូលរូបិយវត្ថុ M3 នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ តាំងពីឆ្នាំ២០០៦ មក[12]។ ក៏ដូចគ្នាដែរ ធនាគារជាតិនៃកម្ពុជាក៏មិនបានបង្ហាញពីបរិមាណរូបិយវត្ថុ M3 នៅក្នុងរបាយការណ៍ប្រចាំឆ្នាំដែរ។

**តារាងទី១.១: សមាសធាតុនៃរូបិយវត្ថុ M1 និង M2**

| ស្ថានភាពរូបិយវត្ថុក្នុងចរាចរណ៍នៅសហរដ្ឋអាមេរិក | បរិមាណរូបិយវត្ថុ (ប៊ីលានដុល្លារ) គិតត្រឹមថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១ |
|---|---|
| M1 = រូបិយវត្ថុ (ក្រដាសប្រាក់) | ៩៥៨,៨ |
| + មូលប្បទានបត្រទេសចរណ៍ | ៤,៦ |
| + គណនីចរន្ត | ៥៧៣,១ |
| + គណនីចរន្តផ្សេងទៀត | ៣៩៩.០ |
| **សរុប រូបិយវត្ថុ M1** | **១.៩៣៥,៥** |
| M2 = M1 | |
| + គណនីមានកាលកំណត់ខ្នាតតូច | ៨៤៨,៣ |
| + ប្រាក់បញ្ញើសន្សំ | ៥.៥៣០,៤ |
| + ហ៊ុននៅក្នុងមូលនិធិទៅវិញទៅមកនៅក្នុងទីផ្សាររូបិយវត្ថុ | ៦៨៨,៤ |
| **សរុប រូបិយវត្ថុ M1** | **៩.០០២,៦** |

Source: Frederic S., *The economics of money, banking, and financial markets*, 2013, P. 59.

[12] James Chen, *What Is M3?* https://www.investopedia.com.

ចំពោះកម្ពុជាវិញ រូបិយវត្ថុ M1 ត្រូវបានកំណត់ដោយបរិមាណរូបិយវត្ថុនៅក្នុងចរាចរណ៍ និងប្រាក់បញ្ញើចរន្តជាប្រាក់រៀល។ ចំណែក រូបិយវត្ថុទូទៅ M2 រួមមាន រូបិយវត្ថុ M1 និងរូបិយវត្ថុផ្សេងទៀត ដូចជា ទ្រព្យដែលអាចបំប្លែងទៅជាសាច់ប្រាក់បាន (Quasi money) ដែលមានប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំជាប្រាក់រៀល និងប្រាក់បញ្ញើជារូបិយប័ណ្ណគ្រប់ប្រភេទរបស់និវាសជន ដែលជាអាចបំប្លែងទៅជាសាច់ប្រាក់ ឃើតជាងរូបិយវត្ថុ M1 ដើម្បីបំពេញតម្រូវការទូទាត់។ ជាក់ស្តែង នៅឆ្នាំ២០២០ រូបិយវត្ថុទូទៅ M2 បានកើនឡើង១៤,៧% ទាបជាងកំណើននៅឆ្នាំ២០១៩ ដែលមាន១៨,២% និងកំណើនមធ្យមរយៈពេល៥ឆ្នាំចុងក្រោយ គឺ ២១%។ កំណើនទាបនៃរូបិយវត្ថុនៅក្នុងចរាចរណ៍ បណ្តាលមកពីការផ្អាកធ្វើអន្តរាគមន៍ទិញប្រាក់ដុល្លារអាមេរិក ចាប់ពីខែឧសភា ឆ្នាំ២០២០មក គួបផ្សំនឹងការឆ្លើយតបទៅនឹងតម្រូវការខ្ពស់លើប្រាក់រៀល ក្នុងឆ្នាំ២០១៩ ទោះបីជាប្រតិបត្តិការផ្តល់សន្ទនីយភាព ដោយមានការធានា (LPOC[13]) បានកើនឡើង ២៤,៥% ក៏ដោយ[14]។

## ៤. មុខងាររូបិយវត្ថុ (Functions of Money)

ជាទូទៅ គេអាចប្រើពាក្យរូបិយវត្ថុក្នុងន័យពីរផ្សេងគ្នា។ ទី១ សម្រាប់វាស់វែងកម្រិតចំណូល ឬ ទ្រព្យរបស់បុគ្គល ឬគ្រួសារនីមួយៗ ដើម្បីអាចបែងចែកបានថា ជាអ្នកមាន ឬ ជាអ្នកក្រ។ ម្យ៉ាងទៀត យើងក៏អាចប្រើពាក្យរូបិយវត្ថុក្នុងន័យផ្សេងទៀត គឺ សំដៅទៅលើអ្វីដែលអាចទូទាត់ទំនិញ ឬសេវាកម្មបាននៅក្នុងសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្នុងន័យនេះ យើងអាចឱ្យនិយមន័យរូបិយវត្ថុបានយ៉ាងទូលំទូលាយថា **ជាអ្វីមួយដែលគេអាចប្រើបានក្នុងការទូទាត់ទំនិញ សេវាកម្ម ឬសងបំណុល**។

ផ្អែកលើនិយមន័យនេះ យើងអាចយល់បានថា រូបិយវត្ថុបំពេញមុខងារសំខាន់ៗបីយ៉ាង គឺជា មធ្យោបាយទូទាត់ មុខងារវាស់តម្លៃ និងមុខងារសមាច្ច័យ ឬមុខងាររក្សាទុក។

---

[13] LPCO: Liquidity-Providing Collateralised Operation គឺជាឧបករណ៍ហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជា ផ្តល់ទុនឱ្យខ្ចីចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ ជារូបិយវត្ថុជាតិ ដែលជាវិធានការជំរុញសន្ទនីយភាព ដើម្បីជួយដល់អង្គភាពអាជីវកម្ម

[14] ធនាគារជាតិនៃកម្ពុជា *របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១*, P. 14.

### ៤.១. មុខងារទូទាត់ ( Means of Payment )

មុខងារទូទាត់ ឬមធ្យោបាយដោះដូរ គឺជាមុខងារដើម និងមានសារៈសំខាន់របស់រូបិយវត្ថុ។ នៅក្នុងសម័យកាល "ទំនិញដូរទំនិញ" ទំនិញ ឬសេវាកម្ម ត្រូវបានដោះដូរដោយផ្ទាល់ ឬដោយប្រយោលជាមួយទំនិញ ឬសេវាកម្មផ្សេងទៀត។ នៅពេលដោះដូរម្តងៗ គេតែងគិតពីបរិមាណទំនិញដែលត្រូវដោះដូរ ដើម្បីឱ្យសមាមាត្រទៅនឹងតម្លៃទំនិញដែលត្រូវដោះដូរ។ ក្នុងសម័យបច្ចុប្បន្ន គេទិញ-លក់ទំនិញ ឬសេវាកម្ម ឬឧបករណ៍ហិរញ្ញវត្ថុ ដោយទទួលយកក្រដាសប្រាក់ ជាមធ្យោបាយទូទាត់។ មធ្យោបាយដោះដូរ បានវិវត្តិដោយឆ្លងកាត់ដំណាក់កាលជាច្រើន ដូចជា ការដោះដូរដោយផ្ទាល់ ការដោះដូរដោយប្រយោល ដោយប្រើទំនិញធម្មតា ការដោះដូរដោយប្រើមាស និងប្រាក់ និងប្រើប្រាស់ក្រដាសប្រាក់ ឬកាស ធ្វើពីលោហធាតុ និងរូបិយវត្ថុទំនើបក្នុងសម័យបច្ចុប្បន្ន។ ក្រដាសប្រាក់ត្រូវបានប្រើសម្រាប់បូកសរុប និងប្រើក្នុងការទូទាត់ នៅទីបំផុត។

### ៤.២. មុខងារវាស់តម្លៃ ( Unit of Account )

យើងអាចវាស់វែងប្រវែងដោយប្រើម៉ែត្រ ឬគីឡូម៉ែត្រ ប៉ុន្តែ យើងវាស់វែងតម្លៃដោយប្រើឯកតារូបិយវត្ថុ (រៀល ឬដុល្លារ)។ ហេតុនេះ រូបិយវត្ថុបំពេញមុខងារវាស់តម្លៃ ពោលគឺវាអាចវាស់វែងថ្លៃទំនិញផ្សេងៗបាន ហើយអាចប្រៀបធៀបគ្នាថា ទំនិញមួយថ្លៃជាង ឬថោកជាងទំនិញមួយទៀតបាន។ ម៉្យាងទៀត គេអាចប្រើរូបិយវត្ថុ ដើម្បីវាស់បរិមាណបំណុលដែលជំពាក់ ឬ ទិញទំនិញជឿ (ជំពាក់) ក៏គេនៅតែកត់ត្រាបំណុលជាឯកតារូបិយវត្ថុដដែល។

### ៤.៣. មុខងារសមាច្ច័យ ឬ មុខងាររក្សាទុក ( Store of Value )

យើងបានប្រើរូបិយវត្ថុជាមធ្យោបាយទូទាត់ ហេតុនេះ រូបិយវត្ថុក៏ត្រូវបំពេញមុខងាររក្សាទុកផងដែរ។ មានន័យថា នៅពេលយើងប្រើក្រដាសប្រាក់ដើម្បីទូទាត់ទំនិញ ឬសេវាកម្ម ក្រដាសប្រាក់នោះ ត្រូវរក្សាស្ថិរភាពតម្លៃរបស់វា។ អ្នកលក់មិនចង់ទទួលយកអ្វីដែលមិនស្ថិតស្ថេរ ឬ ឆាប់ខូចនោះទេ។ ពោលគឺ គេមានបំណងទទួលយកអ្វីដែលមានអាយុកាលវែង ប្រើប្រាស់បានយូរ និងអាចរក្សាបាននូវកម្លាំងទិញ ( purchasing power ) របស់វា ពីគ្រាមួយទៅគ្រាមួយទៀត។

បំពេញមុខងាររក្សាទុក មិនមែនមានតែរូបិយវត្ថុមួយប្រភេទប៉ុណ្ណោះទេ ពោល គឺ គេអាចរក្សាទុកជាទំនិញវិញ ប្រសិនបើរូបិយវត្ថុមិនអាចរក្សាស្ថិរភាពតម្លៃរបស់វាបាន ពីព្រោះ វានឹងធ្វើឱ្យអ្នករក្សាទុកទទួលរងការខាតបង់។ ការរក្សាទុកទំនិញមិនធ្វើឱ្យទទួលរងការខាតបង់ទេ ប៉ុន្តែ គេត្រូវចំណាយក្នុងការរក្សាទុក និងពិបាកក្នុងការបំប្លែងទៅជាសាច់ប្រាក់ នៅពេលគេត្រូវការសាច់ប្រាក់ដើម្បីទូទាត់។ ម្យ៉ាងទៀត ការរក្សាទុកទំនិញមិនធ្វើឱ្យកើនចំណូលបន្ថែមនាពេលអនាគតទេ។ ហេតុនេះ គេអាចប្តូរមករក្សាទុកជាឧបករណ៍ហិរញ្ញវត្ថុវិញ ដូចជា ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ ប័ណ្ណរតនាគារជាដើម ពីព្រោះ ឧបករណ៍ហិរញ្ញវត្ថុ មិនត្រឹមតែបំពេញមុខងាររក្សាទុកប៉ុណ្ណោះទេ ប៉ុន្តែ វាអាចបង្កើតចំណូលនាពេលអនាគតថែមទៀត។ មិនតែប៉ុណ្ណោះ ឧបករណ៍ហិរញ្ញវត្ថុក៏អាចងាយស្រួលក្នុងការបំប្លែងទៅជាសាច់ប្រាក់បានផងដែរ ដោយលក់វានៅក្នុងទីផ្សារបន្ទាប់[15]។

ជារួម យើងអាចធ្វើការសន្និដ្ឋានបានថា ការបំពេញមុខងាររក្សាទុក ក្នុងជម្រើសទាំងបី ដែលបានរៀបរាប់ខាងលើ មានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ **ការរក្សាទុកជាសាច់ប្រាក់** ងាយស្រួលក្នុងការចាយវាយ ប៉ុន្តែ ការរក្សាទុកសាច់ប្រាក់ឬសន្ទនីយភាព បង្កើតចំណូលបានតិចតួច ឬមិនបង្កើតចំណូលនាពេលអនាគតសោះតែម្តង។ មិនតែប៉ុណាញណោះ គេអាចទទួលរងការខាតបង់ ប្រសិនបើក្រដាសប្រាក់បាត់តម្លៃ។ **ការរក្សាទុកជាទំនិញ** មិនទទួលរងការខាតបង់ទេ ប៉ុន្តែពិបាកក្នុងការរក្សាទុក និងត្រូវចំណាយក្នុងការរក្សាទុក។ ផលវិបាកម្យ៉ាងទៀត គឺ គេមានលំបាកក្នុងបំប្លែងទៅជាសាច់ប្រាក់ ឬត្រូវទទួលរងការខាតបង់ច្រើន នៅពេលគេលក់វា ដើម្បីបំពេញតម្រូវការសាច់ប្រាក់បន្ទាន់។ ចំណែក **ការរក្សាទុកជាឧបករណ៍ហិរញ្ញវត្ថុ**វិញ មានលក្ខណៈល្អប្រសើរជាងគេ ពីព្រោះ វាមិនត្រឹមតែបំពេញមុខងាររក្សាទុកប៉ុណ្ណោះទេ ថែមទាំងបង្កើតបានចំណូលនាពេលអនាគតទៀតផង និងមានភាពងាយស្រួលក្នុងការបំប្លែងទៅជាសាច់ប្រាក់។

---

[15] Stephen G. and Kermit L., *Money, Banking, and Financial Markets*, 2015.

## ៥. តួនាទីរបស់រូបិយវត្ថុ (Roles of money)

ទោះបីជាស្ថិតក្នុងវិស័យសេដ្ឋកិច្ចទំនិញក៏ដោយ ក៏ចាំបាច់ត្រូវមានរូបិយវត្ថុប្រើប្រាស់ក្នុងការទូទាត់ដែរ។ ប្រវត្តិកកើត និងមុខងាររូបិយវត្ថុ បានបង្ហាញយ៉ាងច្បាស់ពីតួនាទីរបស់រូបិយវត្ថុ នៅក្នុងសេដ្ឋកិច្ច។ នៅពេលដែលផលិតកម្មទំនិញ ឬសេវាកម្មកាន់តែរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ នោះតួនាទីសម្របសម្រួលរបស់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច ពាណិជ្ជកម្ម កាន់តែមានសារៈសំខាន់ខ្លាំងឡើង។

រូបិយវត្ថុ គឺជាឧបករណ៍មានថាមភាពខ្លាំងក្លា និងមានប្រយោជន៍បំផុតនៅក្នុងកណ្ដាប់ដៃនៃអ្នកសម្រេចចិត្ត ឬអ្នកដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។ ប៉ុន្តែ រូបិយវត្ថុមានឥទ្ធិពលដោយប្រយោលនៅក្នុងសេដ្ឋកិច្ច គឺ មិនមែនមានឥទ្ធិពលដោយផ្ទាល់ទេ។ នៅពេលដែលបរិមាណក្រដាសប្រាក់ នៅក្នុងចរាចរណ៍កើនឡើងច្រើនពេក នោះវានឹងធ្វើឱ្យតម្លៃក្រដាសប្រាក់ធ្លាក់ចុះ បណ្ដាលឱ្យខាតបង់ដល់អ្នកប្រើប្រាស់។

ការប្រែប្រួលបរិមាណប្រាក់ផ្គត់ផ្គង់នៅក្នុងចរាចរណ៍ នឹងនាំដល់ការប្រែប្រួលនៃអត្រាការប្រាក់លក្ខខណ្ឌឥណទាន និងការវិនិយោគ។ ហេតុនេះ វានឹងធ្វើឱ្យប្រែប្រួលដល់សមាសភាពចំណាយ។ ម្យ៉ាងទៀត រូបិយវត្ថុមានតួនាទីនាំមុខការចំណាយ ការវិនិយោគ និងសន្សំ ដែលជាធាតុផ្សំមានសារៈសំខាន់បំផុតនៅក្នុងសេដ្ឋកិច្ច ទោះបីជាក្នុងបរិបទរូបិយវត្ថុ ជាក្រដាសប្រាក់ក្ដី ជាឧបករណ៍ ឬ ជាមធ្យោបាយផ្សេងទៀតក្ដី។

ទ្រឹស្ដីរូបិយវត្ថុនិយម (Monetarism) បានអធិប្បាយពន្យល់នូវរាល់លក្ខខណ្ឌចាំបាច់ និងដំណាក់កាលសត្យានុម័តដែលរូបិយវត្ថុធ្វើចរាចរណ៍នៅក្នុងវិស័យសេដ្ឋកិច្ច។ គោលដៅនៃទ្រឹស្ដីនេះ គឺធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ច។ តាម Milton Friedman (១៩១២-២០០៦) បានពន្យល់ថា ដើម្បីធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ច ចំណុចគន្លឹះ គឺ ត្រូវជំរុញសេដ្ឋកិច្ចទីផ្សារសេរី តាមរយៈគោលនយោបាយរូបិយវត្ថុ ដូចជា អត្រាសាច់ប្រាក់បម្រុង ច្បាប់កំណត់អត្រាសន្ទនីយភាព ការផ្គត់ផ្គង់ប្រាក់ក្នុងចរាចរណ៍ អត្រាប្ដូរប្រាក់ ឬជាមុខងាររបស់ធនាគារកណ្ដាល។ ប៉ុន្តែ Join Maynard Keynes (១៨៨៣-១៩៤៦) បានពន្យល់ថា ដើម្បីធ្វើឱ្យមានស្ថិរភាពសេដ្ឋកិច្ច គឺ ត្រូវជំរុញ

ការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាល តាមរយៈគោលនយោបាយសារពើពន្ធ ដូចជា ពន្ធ គោលនយោបាយរដ្ឋាភិបាល ឬថវិកា ដែលជាមុខងាររបស់ក្រសួងហិរញ្ញវត្ថុទៅវិញ។ ផ្អែកតាមទ្រឹស្តីរូបិយវត្ថុនិយម បរិមាណប្រាក់ចាំបាច់សម្រាប់ចរាចរណ៍ ត្រូវបាន គណនាតាមរូបមន្តខាងក្រោម៖

$$M = \frac{\sum_{i=1}^{n} Pi \times Qi}{V}$$

M : បរិមាណប្រាក់ចាំបាច់សម្រាប់ចរាចរណ៍

$P_i$ : ថ្លៃទំនិញមធ្យម

$Q_i$ : បរិមាណទំនិញ

V : ល្បឿនបង្វិលមធ្យមរបស់រូបិយវត្ថុ

*ល្បឿនបង្វិលមធ្យមរបស់រូបិយវត្ថុ* គឺជាចំនួនដងនៃការប្រើប្រាស់មួយឯកតារូបិយវត្ថុ ដើម្បីទូទាត់ក្នុងគ្រាមួយឆ្នាំ មានន័យថា មួយឯកតារូបិយវត្ថុ (ក្រដាសប្រាក់ដដែល) តើយើងអាចប្រើប្រាស់ក្នុងការទូទាត់បានប៉ុន្មានដង ក្នុងរយៈពេលមួយឆ្នាំ? ហេតុនេះ បរិមាណប្រាក់នៅក្នុងចរាចរណ៍ ត្រូវបានកំណត់អាស្រ័យលើកត្តាបីយ៉ាង គឺ បរិមាណទំនិញនៅក្នុងសេដ្ឋកិច្ច-សង្គម (Qi) ឬការរីកចម្រើននៃសេដ្ឋកិច្ច ការប្រែប្រួលថ្លៃទំនិញនៅក្នុងទីផ្សារ (Pi) និងល្បឿនបង្វិលរូបិយវត្ថុ (V)។ មានន័យថា បើល្បឿនបង្វិលរូបិយវត្ថុកាន់តែញឹកញាប់ ឬបង្វិលបានកាន់តែលឿន (ប្រើបានច្រើនដង) នោះតម្រូវការសាច់ប្រាក់ពិត(ជាក់ស្តែង)នៅក្នុងចរាចរណ៍កាន់តែតិច។

## ៦. អតិផរណា (Inflation)

### ៦.១. សញ្ញាណ និងនិយមន័យនៃអតិផរណា

អតិផរណា គឺជាបញ្ហារ៉ាំរ៉ៃ ដែលតែងតែកើតមាននៅក្នុងសេដ្ឋកិច្ច ស្ទើរគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។ តម្លៃរបស់ក្រដាសប្រាក់តែងតែប្រែប្រួលមិនទៀងទាត់ដោយសារកត្តាផ្សេងៗ ដូចជា ការផ្គត់ផ្គង់សាច់ប្រាក់ច្រើនពេក វិបត្តិសេដ្ឋកិច្ច សង្គម និងនយោបាយ ជាដើម។ ម៉្យាងទៀត ការបាត់តម្លៃរបស់ក្រដាសប្រាក់ បង្កផលវិបាកជាច្រើនដល់សេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឬ បើ

កាន់តែធ្ងន់ធ្ងរអាចជះឥទ្ធិពលដល់នយោបាយថែមទៀត។ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនបញ្ចេញទស្សនៈ ដោយយល់ឃើញខុសៗគ្នាពាក់ព័ន្ធនឹងអតិផរណានេះ។

តាមទស្សនៈរូបិយវត្ថុនិយម បានឱ្យនិយមន័យអតិផរណាថា ជាការបាត់តម្លៃរបស់ក្រដាសប្រាក់ ដោយសារការផ្គត់ផ្គង់ក្រដាសប្រាក់នៅក្នុងចរាចរណ៍ច្រើនលើសលុប ហើយការកើនឡើងនៃថ្លៃទំនិញនៅក្នុងទីផ្សារ មិនមែនជាអតិផរណាទេ ប៉ុន្តែ គឺជាផលវិបាកនៃអតិផរណា។ ហេតុនេះ ដើម្បីទប់ស្កាត់អតិផរណា គឺជាការងាយស្រួលពោលគឺ គ្រាន់តែទប់ស្កាត់ការផ្គត់ផ្គង់ក្រដាសប្រាក់នៅក្នុងចរាចរណ៍ ឬ បញ្ឈប់ម៉ាស៊ីនលែងឱ្យបោះផ្សាយក្រដាសប្រាក់បន្ថែមទៀត គឺជាការស្រេច។ ប៉ុន្តែ តាមទស្សនៈនៃអ្នកសេដ្ឋកិច្ចទំនើបវិញ បានឱ្យនិយមន័យអតិផរណាថា **គឺជាការឡើងនៃថ្លៃទំនិញជាទូទៅ ឬ ជាការឡើងនៃថ្លៃទំនិញមធ្យម**។ មានន័យថា បើថ្លៃទំនិញ ឬសេវាកម្មនៅក្នុងទីផ្សារកើនឡើងស្ទើរគ្រប់ប្រភេទ នោះនឹងធ្វើឱ្យថ្លៃទំនិញជាមធ្យម នៅក្នុងទីផ្សារកើនឡើងដែរ។ ឧទាហរណ៍ៈ បើគេនិយាយថា នៅឆ្នាំ២០១៩អតិផរណាកើនឡើង២% មានន័យថា ថ្លៃទំនិញកើនឡើងជាមធ្យម ២% ធៀបនឹងឆ្នាំ២០១៨ កន្លងទៅ។ ក្នុងរយៈកាលនៃអតិផរណា គេសង្កេតឃើញថា ថ្លៃទំនិញសព្វសារពើសុទ្ធតែកើនឡើងដូចជា ថ្លៃអង្ករ បន្លែ ផ្លែឈើ ត្រីសាច់ ប្រេងឥន្ធនៈ ជាដើម សុទ្ធតែកើនឡើងខ្ពស់។ នេះជាសញ្ញាសំគាល់ ដែលគេអាចសង្កេតឃើញយ៉ាងច្បាស់លាស់ពីអតិផរណា។ គួរកត់សំគាល់ថា នៅក្នុងរយៈកាលនៃអតិផរណា មិនមែនទំនិញទាំងអស់សុទ្ធតែកើនឡើងសមាមាត្រទៅនឹងអត្រាអតិផរណាទេ គឺវាអាស្រ័យទៅលើកម្រិតនៃការផ្គត់ផ្គង់ និងតម្រូវការរបស់ប្រភេទទំនិញនីមួយៗ ផងដែរ។ ដើម្បីគណនាអត្រាអតិផរណា យើងអាចប្រើរូបមន្តដូចការគណនាកំណើនសេដ្ឋកិច្ចដែរ។

គណនាតាមរូបមន្តខាងក្រោមៈ[16]

$$\text{អត្រាកំណើន } X = \frac{X_t - X_{t-1}}{X_{t-1}}$$

[16] Frederic S., *The economics of money, banking, and financial markets*, 2013, P. 24.

$X_t$ : ទិន្នន័យបច្ចុប្បន្ន (ថ្លៃទំនិញ)

$X_{t-1}$ : ទិន្នន័យឆ្នាំមុនមួយឆ្នាំ

X : អត្រាកំណើនប្រចាំឆ្នាំ (អត្រាអតិផរណា)

ឧទាហរណ៍ៈ ឧបមាថា GDP នៅឆ្នាំ២០១៨ មាន២៥ប៊ីលានដុល្លារ ហើយកើនឡើងដល់ ២៨ប៊ីលានដុល្លារ នៅឆ្នាំ២០១៩ នោះយើងបានកំណើន GDP នៅឆ្នាំ២០១៩ ដូចខាងក្រោមៈ

$$\text{អត្រាកំណើន GDP} = \frac{\text{២៨ប៊ីលានដុល្លារ} - \text{២៥ប៊ីលានដុល្លារ}}{\text{២៥ប៊ីលានដុល្លារ}}$$

$$= \text{០,០៧៧ ឬ ៧,៧\%}$$

ចំពោះអត្រាអតិផរណា ត្រូវបានគណនាដូចកំណើន GDP ដែរ ប៉ុន្តែ ត្រូវបានវាស់វែងដោយ សន្ទស្សន៍ថ្លៃទំនិញសរុបនៅក្នុងទីផ្សារទៅវិញ។ ឧទាហរណ៍ៈ បើថ្លៃទំនិញនៅឆ្នាំគោល (ឆ្នាំ២១៧) មាន ១១២ ហើយបានកើនឡើងដល់១១៥ នៅឆ្នាំ២០១៨ នោះអត្រាអតិផរណានៅឆ្នាំ២០១៨ ត្រូវបានគណនាដូចខាងក្រោមៈ

$$\text{អត្រាអតិផរណា} = \frac{\text{១១៥} - \text{១១២}}{\text{១១២}} = \text{០,០២៦៨ ឬ ២,៦៨\%}$$

អត្រាអតិផរណា ២,៦៨% នេះ មានន័យថា ថ្លៃទំនិញជាមធ្យមនៅលើទីផ្សារក្នុងឆ្នាំ២០១៨ បានកើនឡើងក្នុងអត្រា ២,៦៨% ធៀបនឹងឆ្នាំ២០១៧។

### ៦.២. ការស្តែងឡើងរបស់អតិផរណា

នៅក្នុងរយៈកាលនៃអតិផរណា ថ្លៃទំនិញនៅក្នុងទីផ្សារកើនឡើងជាបន្តបន្ទាប់ នាំដល់ការថយចុះតម្លៃរូបិយវត្ថុ ហើយក៏ធ្វើឱ្យកម្លាំងទិញ ឬលទ្ធភាពទិញរបស់រូបិយវត្ថុធ្លាក់ចុះផងដែរ។ នៅពេលដែលថវិកាត្រូវបានចំណាយច្រើនលើសលុប (ការបញ្ចេញសាច់ប្រាក់ទៅក្នុងទីផ្សារកើនឡើង) ធ្វើឱ្យកើតឡើងនូវទំនាស់រវាងផលិតកម្មនិងទីផ្សារ និងធ្វើឱ្យបាត់ស្ថិរភាពសេដ្ឋកិច្ច។ នៅក្នុងស្ថានភាពបែបនេះ យើងត្រូវយកចិត្តទុកដាក់ទៅលើកត្តាសំខាន់ពីរ គឺ ការតាមដាន និងវាយតម្លៃអំពីស្ថានភាពអតិផរណា ដើម្បីរកមធ្យោបាយដោះស្រាយ។

តាមទស្សនៈរបស់អ្នកសេដ្ឋកិច្ចទីផ្សារ បានលើកឡើងថា អតិផរណា គឺជាបាតុភាពពិបាកនឹងជៀសផុតនៅក្នុងវិស័យសេដ្ឋកិច្ច ពោលគឺ វាកើតមានឡើងតាំងពីគេចាប់ផ្តើមប្រើប្រាស់ក្រដាសប្រាក់នៅក្នុងចរាចរណ៍មកម្លេះ។ បច្ចុប្បន្ន ស្ទើរតែគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក សុទ្ធតែប្រឈមនឹងអតិផរណា ប៉ុន្តែ កម្រិតនិងមូលហេតុ ដែលនាំឱ្យមានអតិផរណានៅក្នុងប្រទេសនីមួយៗ មិនដូចគ្នាទេ។ ទោះជាយ៉ាងនេះក្តី គេក៏អាចបូកសរុបបាននូវមូលហេតុរួមមួយចំនួន ដែលតែងតែកើតមាននៅក្នុងសេដ្ឋកិច្ចនៃប្រទេសនីមួយៗ។

## ៦.៣. ប្រភេទអតិផរណា

**អត្រាអតិផរណាកម្រិតទាប និងមធ្យម:** ក្នុងរយៈកាលនៃអតិផរណាកម្រិតមធ្យម ថ្លៃទំនិញកើនឡើងយឺតៗ អត្រាអតិផរណាមិនលើសពី១០% ឡើយ។ ក្នុងស្ថានភាពអតិផរណាកម្រិតមធ្យម ការប្រែប្រួលថ្លៃទំនិញនៅក្នុងទីផ្សារ មិនខុសពីអតិផរណាកម្រិតទាបប៉ុន្មានទេ។ ចំណែក អតិផរណាកម្រិតទាបវិញ ជាទូទៅមានអត្រាមិនលើសពី ៥% ទេ។

**អត្រាអតិផរណាកម្រិតខ្ពស់:** ក្នុងស្ថានភាពអតិផរណាកម្រិតខ្ពស់នេះ គេសង្កេតឃើញថា អត្រាអតិផរណាកើនឡើងជាបន្តបន្ទាប់ អាចលើសពី១០% ទៅ ២០% ឬអាចកើនដល់១០០% ទៅ ២០០% ក្នុងមួយឆ្នាំ ឬអាចលើសពីនេះក៏មាន។ ក្នុងរយៈពេលកន្លងទៅ មានប្រទេសជាច្រើននៅលើពិភពលោក ដែលបានប្រឈមនឹងបញ្ហាសេដ្ឋកិច្ច នយោបាយ ឬ មានសង្គ្រាម ធ្វើឱ្យប្រទេសទាំងនោះ តែងតែជួបប្រទះនឹងវិបត្តិអតិផរណាកម្រិតខ្ពស់ ដែលធ្វើឱ្យមានការលំបាកក្នុងការដោះស្រាយនិងទប់ទល់ណាស់។ ឈានដល់ដំណាក់កាលអតិផរណាកម្រិតខ្ពស់នេះ ដំណោះស្រាយចុងក្រោយបំផុត គឺ ត្រូវប្តូរក្រដាសប្រាក់ចាស់ចេញ ដោយបោះផ្សាយក្រដាសប្រាក់ថ្មីមកជំនួសវិញ។ ប៉ុន្តែ បើសេដ្ឋកិច្ចមិនទាន់ត្រូវបានស្តារឡើងវិញឱ្យបានរឹងមាំទេ ទោះបីជាប្តូរក្រដាសប្រាក់ថ្មីក៏ដោយ ក៏នៅតែប្រឈមនឹងការបាត់តម្លៃរបស់ក្រដាសប្រាក់ថ្មីនោះដដែល។

ក្នុងដំណាក់កាលអតិផរណាកម្រិតខ្ពស់ ធ្វើឱ្យមានការប្រែប្រួលយ៉ាងខ្លាំងនៅក្នុងស្ថានភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ដូចខាងក្រោម៖

- ❖ កិច្ចសន្យាពាណិជ្ជកម្ម អាចប្រែប្រួលតាមសន្ទស្សន៍ថ្លៃទំនិញនៅលើទីផ្សារ ឬប្រើប្រាស់រូបិយប័ណ្ណបរទេសដែលមានស្ថិរភាព ដូចជា ប្រាក់ដុល្លារ អាមេរិក ធ្វើជាមូលដ្ឋានក្នុងការចុះកិច្ចសន្យាពាណិជ្ជកម្ម
- ❖ ក្រដាសប្រាក់បាត់តម្លៃយ៉ាងឆាប់រហ័ស
- ❖ អត្រាការប្រាក់ពិត (Real interest rate) ធ្លាក់ចុះ
- ❖ ប្រជាពលរដ្ឋមិនចង់រក្សាទុកប្រាក់ច្រើនទេ ពោលគឺ គេរក្សាទុកប្រាក់តិចបំផុត ដើម្បីបំពេញតម្រូវការចាយវាយប្រចាំថ្ងៃប៉ុណ្ណោះ
- ❖ តម្លៃឧបករណ៍ហិរញ្ញវត្ថុនៅក្នុងទីផ្សារហិរញ្ញវត្ថុធ្លាក់ចុះ
- ❖ ក្តីប៉ងប្រាថ្នាក្នុងការរក្សាទុកទំនិញ ទិញអចលនទ្រព្យកើនឡើង
- ❖ គ្មានអ្នកណាឱ្យខ្ចីក្នុងអត្រាការប្រាក់ទាបបានទេ។

ក្នុងស្ថានភាពអតិផរណាកម្រិតខ្ពស់បំផុតនោះ វាអាចសម្លាប់សេដ្ឋកិច្ចរបស់ប្រទេសមួយបាន ពីព្រោះថ្លៃទំនិញបានកើនឡើងក្នុងកម្រិតខ្ពស់បំផុត។ ឧទាហរណ៍ៈ ប្រទេសអាល្លឺម៉ង់បានបោះផ្សាយក្រដាសប្រាក់ច្រើនលើសលប់ ក្នុងរវាងឆ្នាំ១៩២០-១៩២៣ (ក្នុងអំឡុងវិបត្តិ ក្រោយសង្គ្រាមលោកលើកទី១)។ ពេលនោះ ថ្លៃទំនិញបានកើនឡើងខ្ពស់ សន្ទស្សន៍ថ្លៃទំនិញបានកើនឡើងពី១ ដល់ ១០លានដង ក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ នៅឆ្នាំ២០០៨ ប្រទេសហ្ស៊ីមបាបវ៉េ បានប្រឈមនឹងអតិផរណាកម្រិតខ្ពស់បំផុត គឺអត្រា៩៨%ក្នុងមួយថ្ងៃ ដោយសារភាពចលាចលខាងនយោបាយ និងសេដ្ឋកិច្ច។ ក្នុងស្ថានភាពបែបនេះ ការបោះផ្សាយក្រដាសប្រាក់ថ្មីគឺជារឿងដែលមិនអាចជៀសផុត។ ប៉ុន្តែ ទោះបីជាក្រដាសប្រាក់ថ្មីត្រូវបានបោះផ្សាយក៏ដោយ ក្រដាសប្រាក់មិនអាចរក្សាស្ថិរភាពតម្លៃបានទេ នៅពេលដែលសេដ្ឋកិច្ចនយោបាយ ស្ថិតនៅក្នុងភាពវឹកវរនៅឡើយ។

ទោះបីជា អតិផរណាកម្រិតខ្ពស់បំផុត អាចសម្លាប់សេដ្ឋកិច្ចប្រទេសមួយ ឬអាចសម្លាប់មនុស្សបានក៏ដោយ ប៉ុន្តែ អតិផរណាកម្រិតខ្ពស់បំផុត ក៏មានផលប្រយោជន៍ខ្លះដែរ ដូចជា បង្កលក្ខណៈងាយស្រួលសម្រាប់អ្នកសិក្សាស្រាវជ្រាវ តាមដាន និងពិនិត្យមើលពីដំណើរវិវត្តិ និងការជះឥទ្ធិពលរបស់វាបានកាន់តែច្បាស់លាស់ទៅលើសេដ្ឋកិច្ច នយោបាយ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

## ៦.៤. ការជះឥទ្ធិពលរបស់អតិផរណា

### ក. ផលវិបាកចំពោះសេដ្ឋកិច្ច

អតិផរណាកើនឡើងកាន់តែខ្ពស់ ធ្វើមានឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកាន់តែខ្លាំង ធ្វើឱ្យការគិតគូរខាងសេដ្ឋកិច្ច ឬរៀបចំផែនការកាន់តែលំបាក លំអៀងនៃការព្យាករណ៍កាន់តែខ្ពស់ សមត្ថភាពនៃការប្រកួតប្រជែងធ្លាក់ចុះ ទាំងសេដ្ឋកិច្ចក្នុងស្រុក និងនៅលើទីផ្សារអន្តរជាតិ អត្រានិកម្មជនកើនឡើងកាន់តែខ្ពស់ ហើយកំណើនសេដ្ឋកិច្ចធ្លាក់ចុះខ្លាំង។

### ខ. ផលវិបាកចំពោះសង្គម

អតិផរណាកម្រិតខ្ពស់ ធ្វើឱ្យអន្តរាយដល់គ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែលំបាក ដោយសារកម្លាំងទិញរបស់រូបិយវត្ថុធ្លាក់ចុះ ហើយងាយនឹងកើតឡើងនូវទំនាស់ផ្សេងៗនៅក្នុងសង្គម។ ម៉្យាងទៀត អត្រាអតិផរណាកម្រិតខ្ពស់ក៏បានជំរុញ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ចាយវាយលើការប្រើប្រាស់កាន់តែខ្លាំងឡើង និងបង្កើនការរក្សាទុកជាទ្រព្យ សម្ភារៈ និងទំនិញផ្សេងៗទៀត កាន់តែច្រើនឡើង ដោយសារ ព្រួយបារម្ភពីការបាត់តម្លៃរបស់ក្រដាសប្រាក់ ធ្វើឱ្យថ្លៃទំនិញ និងសេវាកម្ម នៅក្នុងទីផ្សារកើនឡើងជាបន្តបន្ទាប់៕

# មេរៀនទី២

# ធនាគារ និងទីផ្សារហិរញ្ញវត្ថុ
## ( Banking and Financial Markets )

## ១. ប្រវត្តិកកើតរបស់ធនាគារ

ការកកើត និងការរីកចម្រើនរបស់ធនាគារ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការរីកចម្រើននៃកម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្ម។ ប្រវត្តិរបស់ធនាគារក៏ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងប្រវត្តិកកើតរបស់រូបិយវត្ថុ និងចរាចរណ៍រូបិយវត្ថុស្របជាមួយនឹងមធ្យោបាយទូទាត់ បែបបទនៃការទូទាត់ និងការផ្តល់ឥណទានផងដែរ។ ជាពិសេស នៅក្នុងដំណាក់កាលនៃការប្រើលោហធាតុមាស និងប្រាក់ ដែលបំពេញតួនាទីជារូបិយវត្ថុ។ ក្នុងដំណាក់កាលនោះ ការទូទាត់ម្តងៗបានជួបការលំបាកដោយត្រូវកាត់ ជ្រៀក ឬ ថ្លឹង ដើម្បីវាស់វែងបរិមាណមាស ឬប្រាក់ ដែលត្រូវទូទាត់នៅពេលទិញទំនិញ ឬ មានការដោះដូរកើតឡើង។ ម៉្យាងទៀត ការប្រើមាស ឬប្រាក់ក្នុងការទូទាត់ ក៏ជួបការលំបាកក្នុងការដឹកជញ្ជូន និងហេតុផលសុវត្ថិភាពផងដែរ។ ហេតុនេះ ទើបមានពាណិជ្ជករមួយចំនួនបានផ្តាច់ខ្លួនពីការធ្វើជំនួញ ឬអាជីវកម្មផ្សេងទៀត មកប្រកបរបរចាក់ពុម្ពលោហធាតុជាទម្រង់ផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងការទូទាត់ និងបានពង្រីកតួនាទីរហូតដល់ធ្វើអាជីវកម្មរូបិយវត្ថុ ដោយទទួលទិញលក់ ឬ ដាក់បញ្ចាំ ដែលមានន័យដូចទៅនឹង ការទទួលប្រាក់បញ្ញើ ហើយបានចេញវិក្កយបត្រសំគាល់បរិមាណមាស ឬប្រាក់ ដែលបានដាក់ដំកល់នោះ។ ជាបណ្តើរៗវិក្កយបត្របញ្ចាំមាស ឬប្រាក់ទាំងនោះ ត្រូវបានប្រើប្រាស់ក្នុងការទូទាត់ពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតនៅក្នុងសេដ្ឋកិច្ច-សង្គម ឬពាណិជ្ជកម្ម ដោយមិនបានវិលត្រឡប់មកប្តូរយកមាស ឬប្រាក់វិញទេ។ ក្នុងករណីមានបុគ្គលណាម្នាក់ត្រូវការមាស ឬប្រាក់ គេអាចយកវិក្កយបត្រទាំងនោះ មកបើកយកមាស ឬប្រាក់វិញបាន។ វិក្កយបត្រទាំងនោះ ប្រៀបបានទៅនឹងក្រដាសប្រាក់ ឬមូលប្បទានបត្រ ដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។ ដោយសារ អ្នកជំនួញមិនបានយកវិក្កយបត្រមកប្តូរយកមាស ឬប្រាក់ទៅវិញទេ ធ្វើឱ្យអាជីវកររូបិយវត្ថុ មានមាស ឬប្រាក់ច្រើននៅសល់ទំនេរ។ អាជីវកររូបិយវត្ថុបានយកមាស ឬប្រាក់ដែលនៅសល់ទាំងនោះ ដើម្បីផ្តល់ឱ្យខ្ចីចំពោះ

ពាណិជ្ជករ ដោយចេញវិក្កយបត្រដែលមិនមានមាស ឬប្រាក់ ដាក់តម្កល់ឡើយ។ ហេតុនេះ អាជីវកររូបិយវត្ថុ បានបំពេញតួនាទីក្នុងការផ្តល់ឱ្យខ្ចី ដើម្បីទទួលបានកម្រៃ ដែលហៅថា "ការប្រាក់"។ ក្រុមអាជីវកររូបិយវត្ថុទាំងនោះហើយ គឺជាសញ្ញាណនៃ ការកកើតដំបូងរបស់ធនាគារ ពីព្រោះ ពួកគេបានបំពេញមុខងារពាយ៉ាង គឺ ទទួល ប្រាក់បញ្ញើ (ទទួលមាស ឬប្រាក់) ផ្តល់ឥណទាន (ផ្តល់ឱ្យខ្ចីជាមាសឬប្រាក់ ឬ ផ្តល់ ឱ្យខ្ចីដោយចេញវិក្កយបត្រដោយមិនមានមាស ឬប្រាក់តម្កល់) និងបម្រើសេវាទូទាត់ ដោយបើកមាស ឬប្រាក់ឱ្យអតិថិជនវិញ នៅពេលទទួលបានវិក្កយបត្រ។ មុខងារ សំខាន់បីនេះហើយ គឺជានិយមន័យរបស់ធនាគារពាណិជ្ជ ដូចមានចែងនៅក្នុងទ្រឹស្តី និងនៅក្នុងច្បាប់របស់ធនាគារពាណិជ្ជផងដែរ។

## ២. ប្រព័ន្ធហិរញ្ញវត្ថុ (Financial system)

ប្រព័ន្ធហិរញ្ញវត្ថុ គឺជាប្រព័ន្ធអន្តរទំនាក់ទំនងនៃអន្តរការីកម្មហិរញ្ញវត្ថុ ឬជាអ្នក សម្របសម្រួល នៅក្នុងទីផ្សារ ដែលបម្រើគោលដៅបីយ៉ាងសំខាន់ៗគឺ បំណែងចែក មូលធន ចែករំលែកឬផ្ទេរហានិភ័យ និងសម្របសម្រួលពាណិជ្ជកម្ម ឬ ជាការបញ្ជូន ផ្ទេរមូលធន រវាងអ្នកចូលរួមនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដូចជា អ្នកផ្តល់ឱ្យខ្ចី វិនិយោគិន និងអ្នកខ្ចី ដែលធ្វើប្រតិបត្តិការក្នុងកម្រិតជាតិ និងសកលលោក[17]។

ប្រព័ន្ធហិរញ្ញវត្ថុប្រមូលផ្តុំដោយធាតុផ្សំ៦យ៉ាងសំខាន់ៗ ដែលបំពេញតួនាទី ជាមូលដ្ឋាននៅក្នុងសេដ្ឋកិច្ច។ ធាតុផ្សំទាំងនោះ រួមមានៈ រូបិយវត្ថុ ឧបករណ៍ហិរញ្ញវត្ថុ ទីផ្សារហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុ ភ្នាក់ងាររដ្ឋាភិបាល និងធនាគារកណ្តាល។ **រូបិយវត្ថុ** ត្រូវបានប្រើធ្វើជាមធ្យោបាយទូទាត់ វាស់វែងថ្លៃទំនិញនៅលើទីផ្សារ និងមុខងាររក្សា ទុក ដែលតំណាងឱ្យទ្រព្យសម្បត្តិរបស់បុគ្គល អង្គភាពអាជីវកម្ម ឬរដ្ឋាភិបាល។ ចំណែក **ឧបករណ៍ហិរញ្ញវត្ថុ** គឺជាមធ្យោបាយនៃការបញ្ជូនផ្ទេរទុនពីអ្នកសន្សំ (អ្នក មានទុនទំនេរ) ទៅអ្នកដែលត្រូវការទុនវិនិយោគ ប៉ុន្តែ មិនមានទុនគ្រប់គ្រាន់ ដើម្បី បំពេញតម្រូវការ ហើយក៏ជាការផ្ទេរហានិភ័យពីភាគីមួយទៅភាគីមួយទៀត ដែលមាន ការការពារបានល្អជាង ឬប្រឈមនឹងហានិ-ភ័យទាប ដោយសារជាស្ថាប័នជំនាញ។ ឧទាហរណ៍: ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ បំណុលនិក្ខេប និងគោលនយោបាយធានា

[17] Robert E. et al, *Money and Banking*, Flat World Knowledge, Inc., 2009, P. 12.

វ៉ាប់រង ជាដើម។ រីឯ **ទីផ្សារហិរញ្ញវត្ថុ**វិញ គឺជាយន្តការនៃការជួញដូរ ដោយមានការគ្រប់គ្រងច្បាស់លាស់ ដែលអនុញ្ញាតឱ្យវិនិយោគិន អាចទិញឬលក់ឧបករណ៍ហិរញ្ញវត្ថុបានងាយស្រួល និងឆាប់រហ័ស តាមតម្រូវការ។ ឧទាហរណ៍ៈ ទីផ្សារហ៊ុនតូក្យូ (Tokyo Stock Exchange) ទីផ្សារហ៊ុនហុងកុង (Hong Kong Stock Exchange) និងទីផ្សារហ៊ុនញូយ៉ក (New York Stock Exchange)។ល។ ចំណែក **គ្រឹះស្ថានហិរញ្ញវត្ថុ** បម្រើសេវាកម្មផ្សេងៗជាច្រើន ដូចជាភ្ជាប់ទំនាក់ទំនងនៅក្នុងទីផ្សារហិរញ្ញវត្ថុ ប្រមូលផ្តុំ និងផ្តល់ព័ត៌មានអំពីអតិថិជន ឬអ្នកខ្ចី ដែលគួរឱ្យជឿទុកចិត្តបាន។ ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលប័ត្រ ជាឧទាហរណ៍នៃគ្រឹះស្ថានហិរញ្ញវត្ថុ។ ចំពោះ **ភ្នាក់ងាររបស់រដ្ឋាភិបាល**វិញ ជាអ្នកទទួលខុសត្រូវលើដំណើរការនៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីឱ្យប្រាកដថា កត្តាសំខាន់ៗ ដូចជា ឧបករណ៍ហិរញ្ញវត្ថុ ទីផ្សារហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវបានដំណើរការប្រកបដោយសុវត្ថិភាព និងគួរឱ្យជឿទុកចិត្តបាន ដោយដាក់ចេញនូវច្បាប់ បទប្បញ្ញត្តិផ្សេងៗ។ កត្តាគួបផ្សំសំខាន់ចុងក្រោយ គឺ **ធនាគារកណ្តាល** ដែលមានតួនាទីក្នុងការតាមដានត្រួតពិនិត្យ និងធ្វើឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច[18]។ ប្រទេសនីមួយៗ មានធនាគារកណ្តាលតែមួយគត់ ដែលមានឈ្មោះផ្សេងៗគ្នាទៅតាមប្រទេសនីមួយៗ។ ឧទាហរណ៍ៈ នៅកម្ពុជាមាន ធនាគារជាតិនៃកម្ពុជា (Natioanl Bank of Cambodia) នៅជប៉ុន មាន ធនាគារជប៉ុន (Bank of Japan) នៅបារាំង មានធនាគារបារាំង (Banque de France)។ល។

## ៣. មុខងាររបស់ប្រព័ន្ធហិរញ្ញវត្ថុ និងទីផ្សារហិរញ្ញវត្ថុ

ផ្អែកតាម Peter S. Rose នៅក្នុងសៀវភៅ ទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន (Money and Capital Markets) ទីផ្សារហិរញ្ញវត្ថុ មានមុខងារសំខាន់ៗ ដូចខាងក្រោមៈ

[18] Stephen G. and Kermit L., *Money, Banking, and Financial Markets*, 2015.

### ២.១. មុខងារសន្សំ (Savings function)

ទីផ្សារហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត បានផ្តល់ជាមធ្យោបាយ ឬឱកាសយ៉ាងធំធេងដល់សាធារណជនក្នុងការសន្សំ ដោយផ្ញើប្រាក់នៅក្នុងធនាគារ ឬវិនិយោគ ដោយទិញមូលប័ត្រនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដែលជាកត្តាជំរុញ និងលើកទឹកចិត្តសំខាន់ណាស់ ដល់ការសន្សំរបស់ប្រជាពលរដ្ឋ។ ការសន្សំនេះ ជាប្រភពទុនសំខាន់បំផុត ដែលគាំទ្រដល់ការវិនិយោគ និងអភិវឌ្ឍសេដ្ឋកិច្ច។

### ២.២. មុខងារទ្រព្យសម្បត្តិ (Wealth function)

ឧបករណ៍ហិរញ្ញវត្ថុ ដូចជា ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ និងមូលប័ត្រផ្សេងទៀត ត្រូវបានជួញដូរនៅក្នុងទីផ្សាររូបិយវត្ថុ (Money markets) និងទីផ្សារមូលធន (Capital markets) ដែលជាមធ្យោបាយប្រសើរជាងគេ ក្នុងការរក្សាទុកទ្រព្យសកម្ម (Assets) បើប្រៀបធៀបនឹងការរក្សាទុកសាច់ប្រាក់ និងទំនិញផ្សេងទៀត។ ការសន្សំរបស់បុគ្គល ឬគ្រួសារ ត្រូវបានជំរុញ និងលើកទឹកចិត្តដោយទីផ្សារហិរញ្ញវត្ថុ ពីព្រោះវាបង្កើតឱ្យបាននូវអត្រាចំណូល ហើយការសន្សំជាកត្តាកំណត់ និងបង្កើតបាននូវទ្រព្យសម្បត្តិ។ ហេតុនេះ ការរក្សាទុកទ្រព្យ ជាឧបករណ៍ហិរញ្ញវត្ថុ មិនត្រឹមតែជាមធ្យោបាយរក្សាទុកប៉ុណ្ណោះទេ ថែមទាំងបង្កើតឱ្យបាននូវអត្រាចំណូលនាពេលអនាគត ថែមទៀតផង។

### ២.៣. មុខងារសន្ទនីយភាព (Liquidity function)

ទីផ្សារហិរញ្ញវត្ថុ ជាពិសេសទីផ្សាររូបិយវត្ថុ បានផ្តល់នូវសន្ទនីយភាព (ភាពអាចបំប្លែងជាសាច់ប្រាក់បានដោយងាយ) សម្រាប់អ្នកសន្សំប្រាក់ ដោយអាចប្រើប្រាស់ប្រាក់សន្សំទាំងនោះ ដើម្បីផ្ញើនៅធនាគារ ឬវិនិយោគដោយទិញឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី (មិនលើសពី១ឆ្នាំ) ដែលអាចទទួលបានអត្រាចំណូលផង និងអាចបំពេញតម្រូវការសាច់ប្រាក់បានភ្លាមៗផង។ ឧទាហរណ៍ៈ បើយើងផ្ញើប្រាក់នៅក្នុងគណនីសន្សំ ឬ គណនីមានកាលកំណត់រយៈពេលខ្លី យើងនឹងទទួលទទួលបានការប្រាក់ផង និងអាចដកប្រាក់ ដើម្បីបំពេញតម្រូវការផង។ ក៏ដូចគ្នាដែរ បើយើងទិញឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី យើងនឹងទទួលបានការប្រាក់ ហើយ

ប្រសិនយើងត្រូវការសាច់ប្រាក់បន្ទាន់ យើងអាចលក់ឧបករណ៍ហិរញ្ញវត្ថុទាំងនោះ នៅក្នុងទីផ្សារបន្ទាប់ ដើម្បីទទួលបានសាច់ប្រាក់ទាន់ពេលវេលា។

**២.៤. មុខងារឥណទាន** ( Credit function )

ប្រព័ន្ធហិរញ្ញវត្ថុ ដែលមានធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត បំពេញតួនាទីយ៉ាងសំខាន់ ក្នុងការគៀរគរមូលធនទំនេរពីសាធារណជន ដោយទទួលប្រាក់បញ្ញើ និងប្រើប្រាស់ប្រភពទុនទាំងនោះប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឥណទាន សម្រាប់បំពេញតម្រូវការចំណាយលើការប្រើប្រាស់របស់បុគ្គល និងការវិនិយោគរបស់អង្គភាពអាជីវកម្ម។ ឥណទានជាតួនាទីសំខាន់របស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយបានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រដល់ការវិនិយោគ និងជំរុញសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនខ្លាំងក្លាឡើង។

**២.៥. មុខងារទូទាត់** ( Payments function )

ប្រព័ន្ធហិរញ្ញវត្ថុ បំពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការទូទាត់ បញ្ជូនផ្ទេរមូលធនពីតំបន់មួយទៅតំបន់មួយ ឬពីប្រទេសមួយទៅប្រទេសមួយទៀត។ មុខងារនេះ មានសារៈសំខាន់សម្រាប់បំពេញតម្រូវការ ក្នុងទំនាក់ទំនងពាណិជ្ជកម្ម និងការវិនិយោគ ដោយបង្កើតបានជាយន្តការបញ្ជូនផ្ទេរ ឬទូទាត់ ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ដើម្បីជំរុញឱ្យពាណិជ្ជកម្ម និងការវិនិយោគ មានការរីកចម្រើន និងប្រព្រឹត្តិទៅបានរលូន និងទាន់ពេលវេលា។

**២.៦. មុខងារការពារហានិភ័យ** ( Risk protection function )

ប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេសផ្សេងៗ ផ្តល់ការការពារចំពោះអង្គភាពអាជីវកម្ម អ្នកប្រើប្រាស់ និងរដ្ឋាភិបាល ទប់ទល់នឹងគ្រោះថ្នាក់ផ្សេងៗ ដូចជា អាយុជីវិត សុខភាព ទ្រព្យសម្បត្តិ និងហានិភ័យផ្សេងៗទៀត ដោយសារ សេវាធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងគ្រប់ប្រភេទ ដូចជា ធានារ៉ាប់រងអាយុជីវិត ធានារ៉ាប់រងសុខភាព ធានារ៉ាប់រងទ្រព្យសម្បត្តិ។ល។ ក្រុមហ៊ុនធានារ៉ាប់រង រួមចំណែកក្នុងការកាត់បន្ថយហានិភ័យផង ដោយកម្មវត្ថុដែលបានត្រូវធានា ត្រូវតែអនុវត្តតាមវិធានកំណត់ដោយក្រុមហ៊ុនធានារ៉ាប់រង និងម្យ៉ាងទៀត ធានារ៉ាប់រងរួមចំណែកកាត់បន្ថយការលំបាក ក្រោយហេតុការណ៍គ្រោះថ្នាក់កើតឡើង ឬធ្វើឱ្យអង្គភាពអាជីវកម្មអាចវិលទៅរកស្ថានភាព

ដើមវិញបានឆាប់រហ័ស។ ទិញសេវាធានារ៉ាប់រង មានន័យថា ផ្ទេរឬចែករំលែកហានិភ័យជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយក្រុមហ៊ុនធានារ៉ាប់រង ធានាចេញសងការខូចខាតដូចមានចែងនៅក្នុងគោលនយោបាយធានារ៉ាប់រង។

### ២.៧. មុខងារគោលនយោបាយ (Policy function)

ប្រព័ន្ធហិរញ្ញវត្ថុ ដែលមានធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុ បំពេញតួនាទីយ៉ាងសំខាន់ គឺជាភ្នាក់ងាររដ្ឋាភិបាល ដែលជាអ្នកទទួលយកទៅអនុវត្តនូវគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិនានាដែលដាក់ចេញដោយធនាគារកណ្តាលនៃប្រទេសនីមួយៗ ដើម្បីធានាភាពរឹងមាំ និងជំនឿទុកចិត្តពីសាធារណជនទៅលើប្រព័ន្ធធនាគារ និងសម្រេចបាននូវគោលដៅរបស់រដ្ឋាភិបាល គឺ រក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច មានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព កាត់បន្ថយអត្រានិកម្មជន និងបញ្ចៀសបាននូវអតិផរណាកម្រិតខ្ពស់នៅក្នុងទីផ្សារបន្ទាប់[19]។

ប៉ុន្តែ បើផ្អែកតាម Madhuri Thankur នៅក្នុង WallstreetMojo បង្ហាញថា ទីផ្សារហិរញ្ញវត្ថុមានមុខងារផ្សេងទៀត ដែលខុសពីមុខងារទីផ្សារហិរញ្ញវត្ថុ ដែលបានលើកឡើងនៅក្នុងសៀវភៅ Money and Capital Markets របស់ Peter S. Rose។ Madhuri បានលើកឡើងពីមុខងារទីផ្សារហិរញ្ញវត្ថុ ដែលមានខ្លឹមសារ ដូចតទៅ៖

#### ក. ការកំណត់តម្លៃ (Price determination)

ទីផ្សារហិរញ្ញវត្ថុ បំពេញមុខងារជាអ្នកកំណត់ថ្លៃឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានជួញដូររវាងអ្នកលក់ និងអ្នកទិញ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ តម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយកត្តាពីរ គឺ តម្រូវការ និងការផ្គត់ផ្គង់ នៅក្នុងទីផ្សារ។ ហេតុនេះ ទីផ្សារហិរញ្ញវត្ថុផ្តល់ជាមធ្យោបាយក្នុងការកំណត់ថ្លៃឧបករណ៍ហិរញ្ញវត្ថុ ទាំងឧបករណ៍ហិរញ្ញវត្ថុថ្មី ដែលទើបនឹងបោះផ្សាយ ហើយដាក់លក់នៅក្នុងទីផ្សារ និងឧបករណ៍ហិរញ្ញវត្ថុដែលមានស្រាប់ កំពុងធ្វើចរាចរណ៍នៅក្នុងទីផ្សារហិរញ្ញវត្ថុ។

---

[19] Peter S., *Money and Capital Markets*, 2005.

គំនូសបំព្រួញទី២.១: មុខងារទីផ្សារហិរញ្ញវត្ថុ




Souce: Madhuri Thakur, *Functions of Financial Markets*, https://www.wallstreetmojo.com/functions-of-financial-markets/

**ខ. គៀរគរមូលធន** ( Funds Mobilization )

ស្របជាមួយនឹងការកំណត់តម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានជួញដូរ កម្រិតចំណូលពីការវិនិយោគ ក៏ត្រូវបានកំណត់ដោយវិនិយោគិន នៅក្នុងទីផ្សារហិរញ្ញវត្ថុផងដែរ។ កត្តាជំរុញ និងលើកទឹកចិត្តបុគ្គលក្នុងការស្វែងរកទុនវិនិយោគ គឺផ្អែកលើកម្រិតចំណូល ដែលជាក្តីប្រាថ្នារបស់វិនិយោគិន។ ដោយសារមុខងាររបស់ទីផ្សារហិរញ្ញវត្ថុ បានបង្ហាញពីលំហូរមូលធនពីអ្នកមានទុនទំនេរ ឬអ្នកសន្សំ ទៅអ្នកដែលត្រូវការទុនវិនិយោគ ឬអ្នកខ្ចី ដោយបោះផ្សាយ និងលក់មូលប័ត្រ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ហេតុនេះ ទីផ្សារហិរញ្ញវត្ថុ រួមចំណែកយ៉ាងសំខាន់ ក្នុងការគៀគរមូលធនពីអ្នកមានទុនទំនេរ ទៅអ្នកត្រូវការទុនវិនិយោគ។

**គ. សន្ទនីយភាព** ( Liquidity )

សន្ទនីយភាព គឺជាទ្រព្យរយៈពេលខ្លី ដែលអាចបំប្លែងទៅជាសាច់ប្រាក់បានភ្លាមៗ ដោយមិនមានការខាតបង់ ឬខាតបង់តិចតួច។ ចំណែក មុខងារសន្ទនីយភាពរបស់ទីផ្សារហិរញ្ញវត្ថុវិញ គឺជាផ្តល់ឱកាសសម្រាប់វិនិយោគិន អាចលក់ឧបករណ៍ហិរញ្ញវត្ថុ ជាមួយនឹងតម្លៃសមរម្យគ្រប់ពេលវេលា នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ប្រសិនបើ

មិនមានមុខងារសន្ទនីយភាពរបស់ទីផ្សារហិរញ្ញវត្ថុទេ នោះវិនិយោគិនត្រូវបង្ខំចិត្តរក្សាទុកមូលប័ត្ររហូតដល់ផុតកាលកំណត់ ដោយមិនអាចលក់មូលប័ត្រទាំងនោះបានទេ មានន័យថា បើជាប័ណ្ណបំណុល គេត្រូវរង់ចាំរហូតដល់ថ្ងៃផុតកំណត់សង ឬ បើជាប័ណ្ណភាគហ៊ុនវិញ គេត្រូវរង់ចាំរហូតដល់ក្រុមហ៊ុនធ្វើការជម្រះបញ្ជី (ក្ស័យធន) ដោយស្ម័គ្រចិត្ត ឬដោយមិនស្ម័គ្រចិត្ត។ ហេតុនេះ នៅក្នុងទីផ្សារហិរញ្ញវត្ថុ វិនិយោគិនអាចលក់ឧបករណ៍ហិរញ្ញវត្ថុ បានគ្រប់ពេលវេលា ដោយបំប្លែងទៅជាសាច់ប្រាក់ដើម្បីបំពេញតម្រូវការបានទាន់ពេលវេលា។ ក្នុងលក្ខខណ្ឌអាចបំប្លែងទៅជាសាច់ប្រាក់បានបែបនេះ គេអាចនិយាយបានថា គេទទួលបានសន្ទនីយភាព។

**ឃ. ការរំលែកហានិភ័យ** (Risk sharing)

ទីផ្សារហិរញ្ញវត្ថុបំពេញមុខងារចែករំលែកហានិភ័យ ដោយសារបុគ្គលម្នាក់ត្រូវបានទទួលខុសត្រូវក្នុងការវិនិយោគ ដោយបុគ្គលម្នាក់ទៀត ដែលនឹងវិនិយោគទុនរបស់ខ្លួន ក្នុងគម្រោងផ្សេងៗ ដើម្បីទទួលបានចំណូល។ ជាមួយនឹងជំនួយការពីទីផ្សារហិរញ្ញវត្ថុ ហានិភ័យត្រូវបានផ្ទេរ ឬចែករំលែកពីបុគ្គលដែលមានទុនវិនិយោគ (អត់មានជំនាញ) ទៅឱ្យបុគ្គលម្នាក់ទៀត ដែលទទួលខុសត្រូវជំនួសក្នុងការវិនិយោគទៅឱ្យបុគ្គលម្នាក់ទៀត (ដែលមានជំនាញសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ) ដែលអាចកាត់បន្ថយបាននូវការប្រឈមហានិភ័យ។

**ង. ងាយស្រួលក្នុងការស្វែងរក** (Easy Access)

អង្គភាពឧស្សាហកម្មត្រូវការវិនិយោគិន ដើម្បីបង្កើនទុនវិនិយោគ ចំណែកវិនិយោគិនត្រូវការអង្គភាពឧស្សាហកម្ម ដើម្បីវិនិយោគទុនរបស់ខ្លួន និងទទួលបានចំណូលពីការវិនិយោគទាំងនោះ។ ហេតុនេះ វេទិកាទីផ្សារហិរញ្ញវត្ថុផ្តល់ឱ្យអ្នកទិញ និងអ្នកលក់ឧបករណ៍ហរិញ្ញវត្ថុ ដែលមានសក្តានុពលអាចជួបគ្នាបានយ៉ាងងាយ និងអាចជួយឱ្យពួកគេ ចំណេញពេលវេលា និងថវិកា ក្នុងការស្វែងរកគ្នាទៅវិញទៅមក។ តាមរយៈទីផ្សារហិរញ្ញវត្ថុ អ្នកលក់ឧបករណ៍ហិរញ្ញវត្ថុអាចប្រមូលទុនវិនិយោគបានឆាប់រហ័ស ហើយអ្នកទិញឧបករណ៍ហិរញ្ញវត្ថុ មានភាពងាយស្រួល និងមានជម្រើសច្រើន ក្នុងការសម្រេចចិត្តប្រើប្រាស់ទុនក្នុងការវិនិយោគ។

**ច. កាត់បន្ថយថ្លៃសេវា និងការផ្ដល់ព័ត៌មាន** (Reduction in Transaction Costs and Provision of the Information)

ពាណិជ្ជករត្រូវការព័ត៌មានជាច្រើន នៅពេលកំពុងដំណើរការទិញ ឬលក់ឧបករណ៍ហិរញ្ញវត្ថុ។ ទីផ្សារហិរញ្ញវត្ថុអាចបំពេញមុខងារនេះបាន ដោយផ្ដល់ព័ត៌មានគ្រប់បែបយ៉ាងសម្រាប់ពាណិជ្ជករ និងវិនិយោគិន ដោយមិនត្រូវការចំណាយអ្វីទាំងអស់ ដោយសារទីផ្សារហិរញ្ញវត្ថុ ឬធនាគារ មានឧត្តមភាពព័ត៌មាន[20] (Informational advantage)។ តាមមធ្យោបាយនេះ ទីផ្សារហិរញ្ញវត្ថុអាចកាត់បន្ថយបាននូវការចំណាយក្នុងការស្វែងរកព័ត៌មាន និងចំណេញពេលវេលា។

**ឆ. ប្រមូលផ្ដុំមូលធន** (capital formation)

ទីផ្សារហិរញ្ញវត្ថុ ជាយន្តការ ឬជាមធ្យោបាយ សម្រាប់គៀរគរមូលធន តាមរយៈការប្រមូលប្រាក់សន្សំរបស់បុគ្គល ឬគ្រួសារ អង្គភាពអាជីវកម្ម រដ្ឋាភិបាល និងជនបរទេស ហើយប្រមូលផ្ដុំទៅជាប្រភពទុនយ៉ាងសម្បើម និងប្រើប្រាស់ទុនទាំងនោះក្នុងការផ្ដល់ឱ្យខ្ចី ចំពោះអង្គភាពអាជីវកម្ម រដ្ឋាភិបាល និងវិនិយោគិន ផ្សេងទៀត[21]។

## ៤. រចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ

ទីផ្សារហិរញ្ញវត្ថុ គឺជាយន្តការនៃការបែងចែក ឬបញ្ជូនផ្ទេរមូលធន ពីបុគ្គលដែលទទួលបានអតិរេក ដោយការចំណាយតិចជាងចំណូល ឬ ហៅថា "**អ្នកសន្សំ**" ទៅឱ្យបុគ្គលដែលត្រូវការទុន ឬ ហៅថា "**អ្នកខ្ចី**" ដោយសារមិនមានទុនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការចំណាយ ឬវិនិយោគ។ អ្នកសន្សំសំខាន់ជាងគេអាចជាបុគ្គល ឬគ្រួសារ ប៉ុន្តែ អង្គភាពអាជីវកម្ម រដ្ឋាភិបាល និងជនបរទេស ម្ដងម្កាល ក៏មានសល់ទុនទំនេរ ហេតុនេះ ពួកគេក៏អាចផ្ដល់ទុនឱ្យខ្ចីបាន។ ចំណែក អ្នកខ្ចីចម្បងវិញ គឺ

---

[20] ឧត្តមភាពព័ត៌មាន មានន័យថា ធនាគារពាណិជ្ជ តែងមានព័ត៌មានទាំងនេះ ដោយសារ អង្គភាពអាជីវកម្ម ឬវិនិយោគិន ដែលមានបំណងខ្ចីប្រាក់ពីធនាគារ ត្រូវផ្ដល់គម្រោងអាជីវកម្ម ឬរបាយការណ៍ហិរញ្ញវត្ថុ ទៅធនាគារ ដើម្បីសិក្សា និងវាយតម្លៃ សម្រេចថា ផ្ដល់ឥណទាន ឬត្រូវបដិសេធ។ ហេតុនេះ ធនាគារប្រើព័ត៌មានទាំងនេះ ក្នុងគោលដៅផ្សេងៗទៀត។

[21] Madhuri Thakur, *Functions of Financial Markets*, https://www.wallstreetmojo.com/functions-of-financial-markets/

អង្គភាពអាជីវកម្ម និងរដ្ឋាភិបាល ប៉ុន្តែ បុគ្គល ឬគ្រួសារ និងជនបរទេស ក៏ត្រូវការខ្ចីប្រាក់ ដើម្បីទិញ រថយន្ត គ្រឿងសង្ហារឹម ឬផ្ទះសម្បែង ផងដែរ។ ការបែងចែកមូលធនវិនិយោគពីអ្នកសន្សំ ឬអ្នកឱ្យខ្ចី ទៅអ្នកខ្ចី ឬអ្នកចំណាយ អាចប្រព្រឹត្តទៅតាមមធ្យោបាយពីរយ៉ាង គឺ ផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ និងផ្តល់ហិរញ្ញប្បទានដោយប្រយោល។

ដូចបង្ហាញក្នុងរូបភាព២.២ លំហូរមូលធនតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ កើតឡើងក្នុងទម្រង់ពីរយ៉ាង៖ ហិរញ្ញប្បទានដោយផ្ទាល់ គឺ អ្នកខ្ចីឬអ្នកចំណាយ បានខ្ចីប្រាក់ដោយផ្ទាល់ពីអ្នកឱ្យខ្ចីឬអ្នកសន្សំ នៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយលក់មូលប័ត្រឬឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវផ្តល់ផលប្រយោជន៍ទៅឱ្យ "អ្នកឱ្យខ្ចី" នាពេលអនាគត។ មូលប័ត្រ គឺជាទ្រព្យរបស់បុគ្គលដែលជាអ្នកទិញ ឬអ្នកសន្សំ ប៉ុន្តែ ជាបំណុលរបស់បុគ្គល ឬអង្គភាពអាជីវកម្ម ដែលជាអ្នកបោះផ្សាយមូលប័ត្រទាំងនោះ។ ឧទាហរណ៍៖ នៅពេលដែលអ្នកសន្សំផ្តល់ទុនទៅឱ្យក្រុមហ៊ុនណាមួយ តាមរយៈការទិញសញ្ញាប័ណ្ណសាជីវកម្ម ដែលបានបោះផ្សាយ នោះមានន័យថា គេបានផ្តល់ប្រាក់ឱ្យក្រុមហ៊ុននោះខ្ចីដោយផ្ទាល់។ ពោលគឺ គេបានផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ទៅឱ្យក្រុមហ៊ុនដែលកំពុងត្រូវការទុនវិនិយោគ។

ម៉្យាងទៀត ការផ្តល់ទុនវិនិយោគសម្រាប់ក្រុមហ៊ុន មិនមែនសុទ្ធតែកើតឡើងដោយផ្ទាល់នោះទេ។ ឧទាហរណ៍៖ ក្នុងករណី "អ្នកសន្សំ" មិនបានទិញសញ្ញាប័ណ្ណរបស់ក្រុមហ៊ុនដោយផ្ទាល់ទេ ប៉ុន្តែ គេបែរជាយកប្រាក់ទាំងនោះ ទៅផ្ញើនៅធនាគាររយៈពេលវែងទៅវិញ ហើយធនាគារអាចប្រើប្រាស់ប្រភពហិរញ្ញវត្ថុទាំងនោះ ជាមួយនឹងប្រាក់បញ្ញើរបស់អ្នកសន្សំផ្សេងទៀត ដើម្បីទិញសញ្ញាប័ណ្ណរបស់ក្រុមហ៊ុនសាជីវកម្ម ឬផ្តល់ឱ្យខ្ចីចំពោះវិនិយោគិនផ្សេងទៀតវិញ។ ក្នុងករណីនេះ គេអាចនិយាយបានថា អ្នកសន្សំ បានផ្តល់ហិរញ្ញប្បទានដោយប្រយោល ចំពោះវិនិយោគិន ឬវិនិយោគដោយប្រយោល។ ចំណែកធនាគារវិញ បានបំពេញតួនាទីជា **អន្តរការីកម្មហិរញ្ញវត្ថុ** រវាងអ្នកសន្សំ និងអ្នកខ្ចី[22]។ ភាគីពាក់ព័ន្ធនៅក្នុងរចនាសម្ព័ន្ធហិរញ្ញវត្ថុ មានដូចតទៅ៖

[22] Frederic S. (2013), *The Economics of Money, Banking, and Financial Markets*, Pp. 25-26.

### ៤.១. អ្នកឱ្យខ្ចី ឬអ្នកសន្សំ

អ្នកសន្សំ គឺជាបុគ្គលដែលសល់ទុនទំនេរលើសពីតម្រូវការ ហើយត្រូវការប្រើប្រាស់ទុនទាំងនោះក្នុងការវិនិយោគ។ ចំណែក អ្នកឱ្យខ្ចីឬអ្នកសន្សំដែលមានសមាមាត្រធំជាងគេ គឺ គ្រួសារ ឬបុគ្គល ប៉ុន្តែ អង្គភាពអាជីវកម្ម រដ្ឋាភិបាល និងជនបរទេស ក៏ជាអ្នកឱ្យខ្ចី ឬអ្នកសន្សំ ផងដែរ។

### ៤.២. អ្នកខ្ចី ឬអ្នកចំណាយ

អ្នកខ្ចីសំខាន់ជាងគេ គឺ អង្គភាពអាជីវកម្មដែលតែងតែមានតម្រូវការទុនច្រើនដើម្បីពង្រីកការអាជីវកម្ម ឬបង្កើនការវិនិយោគ។ ប៉ុន្តែ រដ្ឋាភិបាល គ្រួសារ ឬបុគ្គល និងជនបរទេស ក៏ជាអ្នកខ្ចី ដើម្បីបំពេញតម្រូវការផ្សេងៗ ក្នុងលំដាប់លំដោយ ជាបន្តបន្ទាប់ផងដែរ។

### ៤.៣. ស្ថាប័នហិរញ្ញវត្ថុអន្តរការី

ស្ថាប័នហិរញ្ញវត្ថុអន្តរការី គឺជាស្ថាប័នដែលស្ថិតនៅកណ្តាល ដោយបំពេញតួនាទីជាអ្នកបញ្ជូនទុន ពីអ្នកមានទុនទំនេរ ទៅឱ្យអ្នកដែលត្រូវការទុន ប៉ុន្តែ មិនមានទុនគ្រប់គ្រាន់ដោយខ្លួនឯង។ ស្ថាប័នហិរញ្ញវត្ថុអន្តរការីនៅកម្ពុជា រួមមាន៖ ធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនមូលប័ត្រ ជាដើម។

### ៤.៤. ទីផ្សារហិរញ្ញវត្ថុ

ទីផ្សារហិរញ្ញវត្ថុ គឺជាអ្នកសម្របសម្រួលយ៉ាងទូលំទូលាយ ពាក់ព័ន្ធនឹងការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុ ឬមូលប័ត្រ ដែលមានផលប្រយោជន៍ដល់ភាគីទាំងពីរ គឺអ្នកខ្ចីនិងអ្នកឱ្យខ្ចី។ ទីផ្សារហិរញ្ញវត្ថុត្រូវបានបែកចែកជាពីរ គឺទីផ្សារដំបូង និងទីផ្សារបន្ទាប់។ **ទីផ្សារដំបូង** (primary markets) គឺជាការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុថ្មីដែលទើបនឹងបោះផ្សាយ ហើយដាក់លក់គ្រាដំបូងនៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ចំណែក **ទីផ្សារបន្ទាប់** (secondary markets) គឺជាការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុ ដែលបានទិញ-លក់នៅគ្រាដំបូង ទៅឱ្យបុគ្គល ឬ អ្នកវិនិយោគផ្សេងទៀត ជាបន្តបន្ទាប់។

ម្យ៉ាងទៀត គេអាចបែងចែកទីផ្សារហិរញ្ញវត្ថុជាពីរផ្សេងទៀត ដោយផ្អែកលើរយៈពេលខ្លី ឬវែងនៃឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានជួញដូរ។ **ទីផ្សាររូបិយវត្ថុ** (Money markets) គឺជាការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី (តិចជាង១ឆ្នាំ) ដូចជា: ប័ណ្ណរតនាគារ (Treasury bills) មូលប័ត្រពាណិជ្ជកម្ម (Commercial papers) វិញ្ញាបនប័ត្រប្រាក់បញ្ញើ (Certificates of deposit) ជាដើម។ **ទីផ្សារមូលធន** (Capital markets) គឺជាការទិញ-លក់ឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែង (ពី១ឆ្នាំឡើងទៅ) ដូចជា ប័ណ្ណភាគហ៊ុន (Stocks) សញ្ញាប័ណ្ណសាជីវកម្ម (Coporate bonds) ឬ សញ្ញាប័ណ្ណ រដ្ឋាភិបាល (Government bonds) ជាដើម[23]។

គំនូសបំព្រួញទី២.២: លំហូរមូលធនតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ




Souce: Frederic S. (2013), *The Economics of Money, Banking, and Financial Markets*, p. 26.

---

[23] Robert E. et al, *Money and Banking*, Flat World Knowledge, Inc., 2009, P. 15.

## ៥. ប្រភេទស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ

ស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ មានសារៈសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច-សង្គម។ ហេតុនេះ យើងត្រូវពិនិត្យមើលខ្លឹមសារជាមូលដ្ឋាន នៃស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ ហើយបានបំពេញតួនាទីយ៉ាងដូចម្ដេច? គេអាចចែកស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុជាបីផ្នែក គឺ គ្រឹះស្ថានទទួលប្រាក់បញ្ញើ គ្រឹះស្ថានចុះកិច្ចសន្យាសន្សំ (ក្រុមហ៊ុនធានារ៉ាប់រង) និងក្រុមហ៊ុនហិរញ្ញវត្ថុ។

### ៥.១. គ្រឹះស្ថានទទួលប្រាក់បញ្ញើ (Depository institutions)

គ្រឹះស្ថានសន្សំ គឺជាស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ ដែលទទួលប្រាក់បញ្ញើពីសាធារណជន (បុគ្គល ឬគ្រួសារ) និងអង្គភាពអាជីវកម្មផ្សេងៗ ហើយផ្ដល់ទុនទាំងនោះឱ្យវិនិយោគិនខ្ចី។ ហេតុនេះ ការសិក្សាពីរូបិយវត្ថុ និងធនាគារ គេតែងផ្ដោតជាពិសេសលើគ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ ពីព្រោះវាទាក់ទងនឹងការបង្កើតសេវាទទួលប្រាក់បញ្ញើ ដែលមានសមាមាត្រធំជាងគេក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុ។ គ្រឹះស្ថានហិរញ្ញវត្ថុទាំងនេះ រួមមាន ធនាគារពាណិជ្ជ និងស្ថាប័នសន្សំផ្សេងៗទៀត។

### ៥.២. គ្រឹះស្ថានចុះកិច្ចសន្យាសន្សំ (Contractual savings institutions)

គ្រឹះស្ថានចុះកិច្ចសន្យាសន្សំ សំដៅលើក្រុមហ៊ុនធានារ៉ាប់រង ដែលមានតួនាទីចុះកិច្ចសន្យាធានារ៉ាប់រងលើគ្រោះថ្នាក់ផ្សេងៗ ហើយកម្រៃសេវាធានារ៉ាប់រង ដែលអតិថិជនបានបង់ ជាកម្មវត្ថុត្រូវសន្សំ ឬប្រមូលផ្ដុំ និងប្រើប្រាស់មូលធនទាំងនោះក្នុងការវិនិយោគ។ គ្រឹះស្ថានទាំងនោះ រួមមាន ក្រុមហ៊ុនធានារ៉ាប់រង មូលនិធិសោធននិវត្តន៍ ដែលជាស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ ទទួលបានទុនតាមកាលកំណត់ ដូចមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង ឬ គោលនយោបាយធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ។ ដោយសារគេអាចព្យាករណ៍បាន ដោយមានភាពជឿជាក់នូវបរិមាណប្រាក់ ដែលត្រូវចំណាយសង ចំពោះអតិថិជនដែលទិញធានារ៉ាប់រង ធ្វើឱ្យគេមិនសូវព្រួយបារម្ភដូចស្ថាប័នសន្សំ ឬទទួលប្រាក់បញ្ញើផ្សេងទៀត ដែលអាចខាតបង់ ឬថយចុះនូវប្រភពទុនភ្លាមៗនោះទេ។ ជាលទ្ធផល ការរក្សាទុកសន្ទនីយភាព (ទុកបម្រុងជាសាច់ប្រាក់) មិនសូវមានសារៈសំខាន់ ដូចស្ថាប័នសន្សំទេ។ ហេតុនេះ គ្រឹះស្ថានចុះកិច្ចសន្យាសន្សំ អាចវិនិយោគទុនទាំងនោះទៅលើមូលប័ត្ររយៈពេលវែង ដូចជា

សញ្ញាប័ណ្ណសាជីវកម្ម សញ្ញាប័ណ្ណរដ្ឋាភិបាល ប័ណ្ណភាគហ៊ុន និងឥណទាននិក្ខេប[24] (mortgage) បាន។ ស្ថាប័នចុះកិច្ចសន្យាសន្សំទាំងនោះ មានដូចខាងក្រោម៖

**ក. ក្រុមហ៊ុនធានារ៉ាប់រងជីវិត** (Life Insurance Company)

ក្រុមហ៊ុនធានារ៉ាប់រងជីវិត គឺជាក្រុមហ៊ុនបម្រើសេវាធានារ៉ាប់រងចំពោះអតិថិជន ទប់ទល់នឹងគ្រោះអាសន្នហិរញ្ញវត្ថុ ក្រោយពីបុគ្គលដែលត្រូវបានធានា ឬទិញសេវាធានារ៉ាប់រងទទួលមរណភាព និងលក់ធនលាភ (Annuities) ដោយតម្រូវឱ្យអតិថិជនត្រូវបង់ថ្លៃសេវាធានារ៉ាប់រងតាមកាលកំណត់ និងត្រូវបើកផ្តល់ជូនអតិថិជនវិញ នៅពេលដល់អាយុចូលនិវត្តន៍។ ក្រុមហ៊ុនធានារ៉ាប់រង ទទួលបានប្រភពទុនពីការលក់សេវាធានារ៉ាប់រង ដែលមួយផ្នែកត្រូវប្រើប្រាស់ ដើម្បីអនុវត្តតាមគោលនយោបាយធានារ៉ាប់រង ដោយផ្តល់សំណងចំពោះអតិថិជននៅពេលទទួលរងគ្រោះថ្នាក់ ឬបើកផ្តល់ដល់អតិថិជននៅពេលដល់អាយុចូលនិវត្តន៍ និងមួយផ្នែកទៀត ត្រូវប្រើសម្រាប់វិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដូចជា ទិញមូលប័ត្រ និងឥណទាននិក្ខេប ជាដើម។ ក្រុមហ៊ុនធានារ៉ាប់រងជីវិត ក៏អាចវិនិយោគ ដោយទិញប័ណ្ណភាគហ៊ុនក្នុងកម្រិតណាមួយផងដែរ។

**ខ. ក្រុមហ៊ុមធានារ៉ាប់រងលើអគ្គីភ័យ និងឧបទ្ទវហេតុផ្សេងៗ**

ក្រុមហ៊ុនធានារ៉ាប់រងលើអគ្គីភ័យ និងឧបទ្ទវហេតុផ្សេងៗ គឺជាការធានាចំពោះអតិថិជន ទប់ទល់នឹងចោរកម្ម អគ្គីភ័យ និងគ្រោះថ្នាក់ផ្សេងៗទៀត។ ក្រុមហ៊ុនធានារ៉ាប់រងនេះ មានលក្ខណៈដូចគ្នាច្រើន ធៀបនឹងក្រុមហ៊ុនធានារ៉ាប់រងជីវិតដែរ ដោយទទួលកម្រៃសេវាធានារ៉ាប់រងពីអតិថិជន ប៉ុន្តែ អាចទទួលរងការខាតបង់ច្រើនជាងប្រសិនបើគ្រោះមហន្តរាយកើតឡើង។ ដោយយោងលើហេតុផលនេះ ក្រុមហ៊ុនធានារ៉ាប់រងអាចវិនិយោគ ដោយទិញឧបករណ៍ហិរញ្ញវត្ថុណា ដែលមានសន្ទនីយភាពខ្ពស់

---

[24] ជាទូទៅ និក្ខេបមានទម្រង់បីយ៉ាង៖ ទី១ ទ្រព្យសម្បត្តិត្រូវគេដាក់ទៅក្នុងអាណាត្តិព្យាបាលភាពជាមួយមនុស្សឯករាជ្យ រហូតទាល់តែបំណុលត្រូវបានសងរួចរាល់ ទី២ កម្មសិទ្ធិលើទ្រព្យសម្បត្តិដែលផ្ទេរដាក់ស្តែងទាំងមូល ឬមួយភាគទៅឱ្យអ្នកជំពាក់ប្រាក់ និងទី៣ កម្មសិទ្ធិមិនបានផ្លាស់ប្តូរទេ ហើយនិក្ខេបមានផលដូចគ្នានឹងសិទ្ធិឃាត់ទុកដែរ។
(See: Wikipedia, https://km.wikipedia.org/wiki/និក្ខេប)

ជាង បើធៀបនឹងការវិនិយោគរបស់ក្រុមហ៊ុនធានារ៉ាប់រងជីវិត។ ជាទូទៅ ក្រុមហ៊ុនធានារ៉ាប់រងប្រភេទនេះ វិនិយោគដោយទិញសញ្ញាប័ណ្ណក្រុងភាគច្រើន (Municipal bond) ប៉ុន្តែ គេក៏អាចទិញសញ្ញាប័ណ្ណសាជីវកម្ម ប័ណ្ណភាគហ៊ុន និងសញ្ញាប័ណ្ណរដ្ឋាភិបាល ផងដែរ។

**គ. មូលនិធិសោធន**

មូលនិធិសោធនឯកជន និងរដ្ឋ ផ្តល់ប្រាក់ចូលនិវត្តន៍ជារៀងរាល់ខែដល់បុគ្គលិក ដែលត្រូវបានធានាដោយផែនការសោធន។ មូលនិធិនេះ មួយផ្នែកទទួលបានពីការរួមចំណែករបស់និយោជក និងមួយចំណែកទៀត ចូលរួមដោយនិយោជិតផ្ទាល់។ មូលនិធិសោធន ត្រូវបានប្រើប្រាស់ ដោយវិនិយោគលើសញ្ញាប័ណ្ណសាជីវកម្ម និងប័ណ្ណភាគហ៊ុន។

**៥.៣. អន្តរការីកម្មវិនិយោគ** (Investment intermediaries)

ប្រភេទអន្តរការីកម្មវិនិយោគ រួមមាន ក្រុមហ៊ុនហិរញ្ញវត្ថុ និងធនាគារវិនិយោគ ដែលផ្តល់ទុនឱ្យខ្ចីរយៈពេលវែង និងបរិមាណទុនច្រើន និងធ្វើសកម្មភាពនៅក្នុងទីផ្សារមូលប័ត្រ។ អន្តរការីកម្មវិនិយោគទាំងនោះ រួមមានៈ

**ក. ក្រុមហ៊ុនហិរញ្ញវត្ថុ**

បង្កើនទុនដោយលក់មូលប័ត្រពាណិជ្ជកម្ម ដែលជាប័ណ្ណបំណុលរយៈពេលខ្លី និងដោយបោះផ្សាយប័ណ្ណភាគហ៊ុន និងសញ្ញាប័ណ្ណ។ បន្ទាប់មក ក្រុមហ៊ុនអាចប្រើប្រាស់ទុនទាំងនោះ ក្នុងការផ្តល់ឱ្យខ្ចីចំពោះអ្នកប្រើប្រាស់ ដើម្បីទិញគ្រឿងសង្ហារឹម រថយន្ត កែលំអផ្ទះសម្បែង និងបង្កើតអាជីវកម្មធុនតូច។ ក្រុមហ៊ុនហិរញ្ញវត្ថុខ្លះ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនសាជីវកម្មមេ ដើម្បីលក់ផលិតផលរបស់គេ។ ឧទាហរណ៍ៈ ក្រុមហ៊ុនឥណទានរថយន្តហ្វត (Ford Motor Credit Company) ត្រូវបានបង្កើតឡើង សម្រាប់ផ្តល់ឥណទានចំពោះអតិថិជនដែលទិញរថយន្តហ្វត។

**ខ. ធនាគារវិនិយោគ**

ធនាគារវិនិយោគមិនដូចធនាគារ ឬក្រុមហ៊ុនហិរញ្ញវត្ថុទូទៅទេ គឺវាមិនទទួលប្រាក់បញ្ញើ និងមិនផ្តល់ទុនឱ្យខ្ចីទេ។ ប៉ុន្តែ ធនាគារវិនិយោគ គឺជាស្ថាប័នអន្តរការីកម្ម

ហិរញ្ញវត្ថុ ដែលជួយក្រុមហ៊ុនសាជីវកម្ម ក្នុងការបោះផ្សាយមូលប័ត្រ។ ជាដំបូង ធនាគារវិនិយោគផ្តល់យោបល់ចំពោះសាជីវកម្ម ថាតើប្រភេទមូលប័ត្រណា ដែលត្រូវបោះផ្សាយ ដូចជា ប័ណ្ណភាគហ៊ុន ឬ សញ្ញាប័ណ្ណ។ បន្ទាប់មក ជួយលក់មូលប័ត្រ ដោយធានាទិញ (underwrite) ពីសាជីវកម្ម ក្នុងតម្លៃដែលបានកំណត់ និងលក់បន្តទៅឱ្យវិនិយោគិន នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ធនាគារវិនិយោគ ក៏ធ្វើសកម្មភាពជាអ្នកដោះស្រាយបញ្ហា ហើយទទួលបានកម្រៃយ៉ាងច្រើន ដោយជួយសាជីវកម្មឱ្យទទួលយកក្រុមហ៊ុនមួយទៀត តាមរយៈការចងសម្ព័ន្ធគ្នា ឬទិញយកក្រុមហ៊ុននោះតែម្តង[25]។

គ. ក្រុមហ៊ុនមូលប័ត្រ

ក្រុមហ៊ុនមូលប័ត្រ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មា-ធិការមូលប័ត្រកម្ពុជា។ សម្រាប់កម្ពុជា ក្រុមហ៊ុនមូលប័ត្រ ត្រូវបានបែងចែកជាបីប្រភេទ គឺ ក្រុមហ៊ុនធានាទិញមូលប័ត្រ ក្រុមហ៊ុនជួញដូរមូលប័ត្រ និងក្រុមហ៊ុនជើងសារមូលប័ត្រ។

- **ក្រុមហ៊ុនធានាទិញមូលប័ត្រៈ** គឺជាក្រុមហ៊ុនមូលប័ត្រដែលមានទំហំដើមទុនធំជាងគេ និងមានតួនាទីក្នុងការជួយរៀបចំ ដើម្បីឱ្យអង្គភាពអាជីវកម្មដែលមានបំណងចូលក្នុងទីផ្សារមូលប័ត្រ ដោយបោះផ្សាយប័ណ្ណភាគហ៊ុនជាសាធារណៈ លើកដំបូង (Initial Public Offering-IPO) និងធានាទិញមូលប័ត្រ ដើម្បីចែកចាយ ឬលក់បន្តទៅវិនិយោគិន។ ម៉្យាងទៀត ក្រុមហ៊ុនធានាទិញមូលប័ត្រ ក៏បំពេញតួនាទី ជាអ្នកជួញដូរមូលប័ត្រ និងជើងសារជំនួញ ផងដែរ។
- **ក្រុមហ៊ុនជួញដូរមូលប័ត្រៈ** មានតួនាទីជាអ្នកជួញដូរមូលប័ត្រ និងជើងសារជំនួញ ប៉ុន្តែ មិនអាចបំពេញតួនាទីជាអ្នកធានាទិញមូលប័ត្របានទេ។ ការជួញដូរមូលប័ត្រ គឺជាការទិញ ឬលក់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីទទួលបានផលចំណេញ ដែលជាលំអៀងរវាងថ្លៃលក់ និងថ្លៃទិញ។
- **ក្រុមហ៊ុនជើងសារមូលប័ត្រៈ** មានតួនាទីត្រឹមតែជាអន្តរការីកម្ម រវាងអ្នកលក់ និងអ្នកទិញ មានន័យថា បំពេញតួនាទីជាអ្នកសម្របសម្រួល ដោយ

[25] Robert E. et al, *Money and Banking*, Flat World Knowledge, Inc., 2009, Pp. 41-45.

នាំអ្នកលក់ និងទិញឱ្យបានជួបគ្នានៅក្នុងទីផ្សារមូលប័ត្រ ដើម្បីលក់ ឬទិញមូលប័ត្រ និងទទួលបានកម្រៃជើងសារ។

## ៦. ឧបករណ៍ហិរញ្ញវត្ថុ ឬមូលប័ត្រ

ដើម្បីយល់ឱ្យបានពេញលេញអំពីដំណើរការទីផ្សារហិរញ្ញវត្ថុ ដែលបំពេញតួនាទីយ៉ាងសំខាន់ ដោយបញ្ជូនទុនពីអ្នកសន្សំ ទៅអ្នកដែលត្រូវការទុន យើងត្រូវពិនិត្យមើលឧបករណ៍ហិរញ្ញវត្ថុ ឬមូលប័ត្រ ដែលត្រូវបានជួញដូរ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ជាដំបូង យើងត្រូវពិនិត្យមើលឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានជួញដូរ នៅក្នុងទីផ្សាររូបិយវត្ថុជាមុនសិន បន្ទាប់មកយើងនឹងពិនិត្យមើលឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានជួញដូរ នៅក្នុងទីផ្សារមូលធន។

### ៦.១. ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងទីផ្សាររូបិយវត្ថុ

មូលប័ត្រទីផ្សាររូបិយវត្ថុ គឺជាមូលប័ត្របំណុលដែលមានរយៈមិនលើសពី១ឆ្នាំ។ មូលប័ត្រនេះ ត្រូវបានបោះផ្សាយដោយធនាគារ សាជីវកម្ម និងស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុផ្សេងទៀត ដែលមានបំណងបង្កើនទុនរយៈពេលខ្លី។ រតនាគារសហរដ្ឋអាមេរិកបោះផ្សាយមូលប័ត្រទីផ្សាររូបិយវត្ថុ ដូចជាផលប័ត្ររតនាគារ ហើយប្រើប្រាស់ទុនទាំងនោះ ដើម្បីផ្តល់ហិរញ្ញប្បទានទៅលើឱនភាពថវិកា។ ចំណែកសាជីវកម្មវិញ បោះផ្សាយមូលប័ត្រទីផ្សាររូបិយវត្ថុ ហើយប្រើប្រាស់ទុនទាំងនោះ ដើម្បីគាំទ្រអាជីវកម្មកំពុងដំណើរការ ឬពង្រីកប្រតិបត្តិការបន្ថែម។ រីឯ ស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុវិញ បោះផ្សាយមូលប័ត្រទីផ្សាររូបិយវត្ថុ និងប្រមូលផ្តុំប្រភពទុនទាំងនោះ ដើម្បីផ្តល់ឱ្យខ្ចីចំពោះគ្រួសារ ឬសាជីវកម្ម។ ហេតុនេះ ស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ ជាអ្នកគៀគរមូលធន ដើម្បីគាំទ្រការទិញរបស់គ្រួសារ ដូចជា រថយន្ត ផ្ទះ និងគាំទ្រការវិនិយោគរបស់សាជីវកម្ម ទៅលើអាគារ បំពាក់ឧបករណ៍សម្ភារៈ គ្រឿងម៉ាស៊ីន ជាដើម។ ជាទូទៅ រតនាគារ ឬសាជីវកម្មទូទាត់បំណុលទាំងនោះ នៅពេលមូលប័ត្រទីផ្សាររូបិយវត្ថុដល់ថ្ងៃកំណត់សង ដោយដំណើរការបោះផ្សាយមូលប័ត្រទីផ្សាររូបិយវត្ថុថ្មី។ ដោយប្រើមធ្យោបាយបែបនេះ គេអាចផ្តល់ហិរញ្ញប្បទានលើការចំណាយរយៈពេលវែងបាន ទោះបីជាមូលប័ត្រទីផ្សាររូបិយវត្ថុ មានរយៈពេលខ្លី ក៏ដោយ។

តំនួសបំព្រួញទី២.៣: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សាររូបិយវត្ថុ




Source: Jeff Madura, *Financial Markets and Institutions*, 2015, P.136.

មូលប័ត្រទីផ្សាររូបិយវត្ថុ ជាទូទៅត្រូវបានទិញដោយគ្រួសារ សាជីវកម្ម ស្ថាប័នអន្តរការីកម្មហិរញ្ញវត្ថុ និងភ្នាក់ងាររដ្ឋាភិបាល ដែលមានទុនទំនេររយៈពេលខ្លី។ ម៉្យាងទៀត មូលប័ត្រទីផ្សាររូបិយវត្ថុមានរយៈពេលខ្លី និងអាចលក់បាននៅក្នុងទីផ្សារបន្ទាប់ (secondary market) ធ្វើឱ្យមូលប័ត្រទីផ្សាររូបិយវត្ថុផ្តល់នូវសន្ទនីយភាពសម្រាប់វិនិយោគិន។ អង្គភាពអាជីវកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ រក្សាទុកមូលប័ត្រទីផ្សាររូបិយវត្ថុដោយសារហេតុផលទាំងនេះ។ មូលប័ត្រទីផ្សាររូបិយវត្ថុ ដូចជា មូលប័ត្ររតនាគារ (treasury bills) ផលប័ត្រពាណិជ្ជកម្ម (commercial paper) វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចរចាបាន (negotiable certificates of deposit) កិច្ចសន្យាទិញយកវិញ (repurchase agreements) ជាដើម។

**ក. មូលប័ត្ររតនាគារ** (Treasury bills or T-bills)

នៅពេលដែលរដ្ឋាភិបាលត្រូវការខ្ចីប្រាក់ នោះរតនាគារតែងតែបោះផ្សាយមូលប័ត្ររយៈពេលខ្លី ដែលគេហៅថា មូលប័ត្ររតនាគារ។ រតនាគារសហរដ្ឋអាមេរិកបោះផ្សាយមូលប័ត្ររតនាគារ ជារៀងរាល់សប្តាហ៍ ដែលមានរយៈពេលកំណត់សង៤សប្តាហ៍ ១៣សប្តាហ៍ និង២១សប្តាហ៍។ មូលប័ត្ររតនាគារអាចត្រូវបានបោះផ្សាយជាទៀងទាត់ ក្នុងរយៈពេលតិច៤សប្តាហ៍ ដែលគេហៅថា មូលប័ត្រគ្រប់គ្រងសាច់ប្រាក់ (cash management bills) ហើយក៏មានបោះផ្សាយមូលប័ត្ររតនាគារ ដែលមានរយៈពេល១ឆ្នាំ ជារៀងរាល់ខែផងដែរ។ កាលពីអតីតកាល មូលប័ត្ររតនាគារត្រូវបានបោះផ្សាយជា ប័ណ្ណ ប៉ុន្តែ បច្ចុប្បន្ន គេរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក។

**ខ. ផលប័ត្រពាណិជ្ជកម្ម** (Commercial paper)

ផលប័ត្រពាណិជ្ជកម្ម គឺជាឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី ត្រូវបានបោះផ្សាយដោយក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះ មានប្រវត្តិឥណទានល្អ។ ផលប័ត្រពាណិជ្ជកម្មត្រូវបានបោះផ្សាយ ដើម្បីផ្តល់សន្ទនីយភាព ឬផ្តល់ហិរញ្ញប្បទានសម្រាប់ការវិនិយោគទៅលើសន្និធិ និងគណនីត្រូវទាររបស់ក្រុមហ៊ុន។ ការបោះផ្សាយផលប័ត្រពាណិជ្ជកម្មគឺជាវិធីបង្កើនទុនរយៈពេលខ្លី ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ។ ក្រុមហ៊ុនធំៗ និយមបោះផ្សាយផលប័ត្រពាណិជ្ជកម្មនេះ ដោយសារត្រូវចំណាយការប្រាក់ទាបជាងធនាគារ។ ជាទូទៅ ធនាគារ និងក្រុមហ៊ុនហិរញ្ញវត្ថុជាអ្នកបោះផ្សាយផលប័ត្រពាណិជ្ជកម្មសំខាន់ជាងគេ។

**គ. វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចរចាច្បាន** (Negotiable certificates of deposit-NCDs)

វិញ្ញាបនប័ត្រប្រាក់បញ្ញើដែលអាចរចាបាន (NCDs) គឺជាវិញ្ញាបនប័ត្រ ដែលបោះផ្សាយដោយធនាគារធំៗ និងស្ថាប័នទទួលប្រាក់បញ្ញើផ្សេងទៀត ដែលជាប្រភពទុនរយៈពេលខ្លីយ៉ាងសំខាន់។ នៅសហរដ្ឋអាមេរិក តម្លៃអប្បបរិមានៃ NCDs ដែលត្រូវបោះផ្សាយគឺ១០ម៉ឺនដុល្លារ។ ប៉ុន្តែ ជាទូទៅគេបោះផ្សាយ NCDs ក្នុងតម្លៃ១លានដុល្លារ។ រយៈពេលកំណត់សងរបស់ NCDs នៅក្នុងចន្លោះពី ២សប្តាហ៍ ទៅ១ឆ្នាំ។

NCDs អាចត្រូវបានជួញដូរ (ទិញ-លក់) នៅក្នុងទីផ្សារបន្ទាប់ ហេតុនេះ NCDs អាច ផ្តល់នូវសន្ទនីយភាពសម្រាប់វិនិយោគិន។

**ឃ. កិច្ចសន្យាទិញយកវិញ** (Repurchase agreements-Repos)

កិច្ចសន្យាទិញយកវិញ (Repos) គឺជាការលក់មូលប័ត្រដោយភាគីមួយ ជាមួយនឹងកិច្ចសន្យាថា នឹងទិញយកវិញក្នុងតម្លៃណាមួយ និងពេលវេលាជាក់លាក់។ មានន័យថា Repos គឺជាការខ្ចីប្រាក់ ហើយត្រូវដាក់ធានាដោយមូលប័ត្រ។ ប្រសិនបើអ្នកខ្ចីប្រាក់មិនសងបំណុលតាមការកំណត់ អ្នកឱ្យខ្ចីនឹងយកមូលប័ត្រនោះ ដើម្បីសងបំណុល។ ជាទូទៅ គេប្រើប្រាស់មូលប័ត្ររដ្ឋាភិបាលក្នុង Repos នេះ ប៉ុន្តែ គេក៏ឃើញមានប្រើមូលប័ត្រដទៃទៀត ដូចជា ផលប័ត្រពាណិជ្ជកម្ម ឬ NCDs ផងដែរ[26]។

## ៦.២. ឧបករណ៍ហិរញ្ញវត្ថុនៅក្នុងទីផ្សារមូលធន

ទីផ្សារមូលធន គឺជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុដែលការសន្សំនិងការវិនិយោគត្រូវបានបញ្ជូនពីអ្នកផ្គត់ផ្គង់ដែលមានទុនពីការសន្សំ ទៅអ្នកដែលត្រូវការទុនវិនិយោគ។ ទីផ្សារមូលធន ក៏ត្រូវបានបែងចែកជាពីរប្រភេទដែរ គឺ ទីផ្សារដំបូង និងទីផ្សារបន្ទាប់ ដែលឧបករណ៍ហិរញ្ញវត្ថុរយៈវែង លើសពី១ឆ្នាំ ត្រូវបានជួញដូរ។ ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានជួញដូរនៅក្នុងទីផ្សារមូលធន រួមមាន សញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន និងឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែងផ្សេងទៀត។

**ក. សញ្ញាប័ណ្ណ** (Bonds)

សញ្ញាប័ណ្ណ គឺជាមូលប័ត្របំណុលរយៈពេលវែង ត្រូវបានបោះផ្សាយដោយភ្នាក់ងាររដ្ឋាភិបាល ឬសាជីវកម្ម។ អ្នកបោះផ្សាយសញ្ញាប័ណ្ណមានកាតព្វកិច្ចចំណាយការប្រាក់ ឬចំណាយគូប៉ុង (coupon payments) ជាទៀងរាល់គ្រា ដូចជា ប្រចាំឆ្នាំ ឬឆមាស និងទូទាត់សងប្រាក់ដើម (par value payment) នៅពេលដល់ថ្ងៃកំណត់សង។ ម្យ៉ាងទៀត អ្នកបោះផ្សាយសញ្ញាប័ណ្ណ ត្រូវបង្ហាញពីលំហូរសាច់ប្រាក់នាពេលអនាគត ដើម្បីបញ្ជាក់ថា អ្នកបោះផ្សាយមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការសងការប្រាក់ និងប្រាក់ដើម ដល់ម្ចាស់សញ្ញាប័ណ្ណ។ វិនិយោគិននឹងពិចារណាទិញ

---

[26] Jeff Madura, *Financial Markets and Institutions*, 2015, Pp.135-143.

សញ្ញាប័ណ្ណណា ដែលគេសង្ឃឹមថា នឹងផ្តល់អត្រាចំណូលខ្ពស់ ដែលជានាក្នុងការទូទាត់សងហានិភ័យបាន។

**គំនូសបំព្រួញទី២.៨: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សារសញ្ញាប័ណ្ណ**




Source: Jeff Madura, *Financial Markets and Institutions*, 2015, P. 164.

សញ្ញាប័ណ្ណ អាចត្រូវបានបែងចែកជាប្រភេទផ្សេងគ្នា ដោយផ្អែកលើអ្នកបោះផ្សាយ ដូចជាសញ្ញាប័ណ្ណធនាគារ ឬសញ្ញាប័ណ្ណរដ្ឋាភិបាល បោះផ្សាយដោយរដ្ឋាភិបាល សញ្ញាប័ណ្ណក្រុង បោះផ្សាយដោយរដ្ឋឬក្រុង ឬ រដ្ឋាភិបាលថ្នាក់តំបន់ និងសញ្ញាប័ណ្ណសាជីវកម្ម បោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម។ នៅអាមេរិក សញ្ញាប័ណ្ណភាគច្រើនមានរយៈពេលពី១០ឆ្នាំទៅ៣០ឆ្នាំ។ សញ្ញាប័ណ្ណអាចត្រូវបានបែងចែកជាពីរទម្រង់ គឺ សញ្ញាប័ណ្ណកាន់កាប់ និងសញ្ញាប័ណ្ណចុះបញ្ជី។ សញ្ញាប័ណ្ណកាន់កាប់(bearer bonds) តម្រូវឱ្យម្ចាស់សញ្ញាប័ណ្ណ យកគូប៉ុងផ្ញើមកឱ្យអ្នកបោះផ្សាយជារៀងរាល់គ្រា ដើម្បីបើកការប្រាក់ជារៀងរាល់ធមាស ឬមួយឆ្នាំម្តង។ ចំណែកសញ្ញាប័ណ្ណចុះបញ្ជី (registered bonds) តម្រូវឱ្យអ្នកបោះផ្សាយសញ្ញាប័ណ្ណត្រូវកត់ត្រា និងរក្សាទុកទិន្នន័យរបស់

វិនិយោគិន និងត្រូវទូទាត់សងការប្រាក់ ឬគូប៉ុង ឱ្យម្ចាស់សញ្ញាប័ណ្ណដោយស្វ័យប្រវត្តិ តាមរយៈគណនីធនាគារ ឬ ដោយប្រើប្រព័ន្ធបញ្ជូនផ្ទេរអេឡិចត្រូនិកផ្សេងទៀត។

**អត្រាចំណូលពីសញ្ញាប័ណ្ណ** (Bond yields) គឺជាផលចំណូលពិតប្រាកដ ទទួលបាន ដោយផ្អែកលើទស្សនៈរបស់អ្នកបោះផ្សាយសញ្ញាប័ណ្ណ ដែលមានកាតព្វកិច្ចទូទាត់សងរហូតដល់ថ្ងៃកំណត់សង ឬផ្អែកលើទស្សនៈវិនិយោគិន ដែលទិញសញ្ញាប័ណ្ណ។ *តាមទស្សនៈរបស់អ្នកបោះផ្សាយ* គឺគិតពីថ្លៃដើមមូលធន ត្រូវបានវាស់វែងដោយអត្រាចំណូលដល់ថ្ងៃកំណត់សង (yield to maturity - ytm) ដែលជាអត្រាប្រចាំឆ្នាំត្រូវចំណាយដោយអ្នកបោះផ្សាយ ក្នុងអំឡុងអាយុកាលរបស់សញ្ញាប័ណ្ណ។ អត្រាចំណូលដល់ថ្ងៃកំណត់សង គឺជាអត្រាអប្បហារប្រចាំឆ្នាំ ដែលស្មើនឹងការចំណាយការប្រាក់ជារៀងរាល់គ្រានាពេលអនាគត និងការសងប្រាក់ដើម ដែលអ្នកបោះផ្សាយទទួលបាននៅគ្រាដំបូង នៅពេលលក់សញ្ញាប័ណ្ណ។ អត្រាចំណូលដល់ថ្ងៃកំណត់សង (ytm) គឺជាអត្រាដែលស្មើនឹងថ្លៃទិញ (P) ជាមួយនឹងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងអស់ ដែលទទួលបានពីសញ្ញាប័ណ្ណ (ធ្វើអប្បហារ) ត្រូវបានគណនាដូចមានក្នុងរូបមន្តខាងក្រោម៖

$$\mathrm{P} = \frac{\mathrm{CF}_1}{(1+ytm)^1} + \frac{\mathrm{CF}_2}{(1+ytm)^2} + \frac{\mathrm{CF}_3}{(1+ytm)^3} + \cdots$$

*តាមទស្សនៈវិនិយោគិន*វិញ គឺគេទិញសញ្ញាប័ណ្ណនៅពេលបោះផ្សាយ ហើយរក្សាទុករហូតដល់ផុតថ្ងៃកំណត់សង ពេលនោះ គេនឹងទទួលបានអត្រាចំណូលដល់ថ្ងៃកំណត់សង។ ប៉ុន្តែ វិនិយោគិនជាច្រើនមិនបានរក្សាទុកសញ្ញប័ណ្ណរហូតដល់ថ្ងៃផុតកំណត់សងទេ ហេតុនេះ គេត្រូវពិនិត្យមើលអត្រាចំណូលក្នុងរយៈពេលកាន់កាប់សញ្ញប័ណ្ណវិញ។ បើសិនជាវិនិយោគិនរក្សាទុកសញ្ញាប័ណ្ណ ក្នុងរយៈពេលណាមួយ គេត្រូវព្យាករណ៍អត្រាចំណូលក្នុងរយៈពេលកាន់កាប់ (holding period yield-hpy) នោះ។ អត្រាចំណូលក្នុងរយៈពេលកាន់កាប់ គឺជាអត្រាចំណូលដែលបានមកពីការវិនិយោគក្នុងរយៈពេលកាន់កាប់សញ្ញាប័ណ្ណជាក់ស្តែង[27]។ វាគឺជាអត្រាអប្បហារដែលស្មើនឹងថ្លៃទិញ ($P_0$) នៃសញ្ញាប័ណ្ណ ជាមួយនឹងការធ្វើអប្បហារលំហូរសាច់ប្រាក់

[27] Jeff Madura, *Financial Markets and Institutions*, 2015, Pp. 163-177.

ទាំងអស់ ដែលទទួលបានពីសញ្ញាប័ណ្ណ តាំងពីពេលទិញមករហូតដល់ថ្ងៃលក់ទៅវិញ (មានរយៈពេល n) ដែលត្រូវបានគណនា ដូចក្នុងរូបមន្តខាងក្រោម៖

$$P_0 = \frac{CF_1}{(1+hpy)^1} + \frac{CF_2}{(1+hpy)^2} + \cdots + \frac{CF_n}{(1+hpy)^n}$$

ខ. ប័ណ្ណភាគហ៊ុន (Stocks)

ទីផ្សារហ៊ុន បំពេញតួនាទីជាអ្នកសម្របសម្រួលការវិនិយោគភាគហ៊ុន របស់អង្គភាពអាជីវកម្ម ហើយដោះដូរក្នុងចំណោមវិនិយោគិន។

❖ **ភាគហ៊ុនឯកជន** (Private equity)

នៅពេលក្រុមហ៊ុនត្រូវបានបង្កើតដំបូង ស្ថាបនិកតែងតែវិនិយោគដោយប្រើមូលធនផ្ទាល់ខ្លួន។ ស្ថាបនិកក៏អាចអនុញ្ញាតឱ្យសាច់ញាតិ ឬមិត្តភ័ក្តិទិញភាគហ៊ុនបានដែរ។ ការចាប់ផ្តើមអាជីវកម្មបែបនេះ ហៅថា ភាគហ៊ុនឯកជន ពីព្រោះអាជីវកម្មដំណើរការជាឯកជន ហើយម្ចាស់ភាគហ៊ុនមិនអាចលក់ហ៊ុនទាំងនោះឱ្យសាធារណជនបានទេ។ អាជីវកម្មដែលទើបចាប់ផ្តើម អាចប្រើប្រាស់ហិរញ្ញប្បទានបំណុលពីគ្រឹះស្ថានហិរញ្ញវត្ថុ និងអាចទទួលបានឥណទានប្រសើរ ប្រសិនបើគេមានភាពរឹងមាំក្នុងការវិយោគភាគហ៊ុន។ បន្តបន្ទាប់មក អង្គភាពអាជីវកម្មអាចរក្សាទុកផលចំណេញដែលទទួលបានជារៀងរាល់ឆ្នាំ ហើយប្រើប្រាស់ទុនទាំងនោះដើម្បីគាំទ្រដល់ការពង្រីកអាជីវកម្ម។ នេះជាមធ្យោបាយមួយទៀត ក្នុងការបង្កើនមូលធនរបស់អង្គភាពអាជីវកម្ម។ ស្ថាបនិកនៃអង្គភាពអាជីវកម្មភាគច្រើន មានក្តីប្រាថ្នាចង់ឱ្យភាគហ៊ុនរបស់ខ្លួនលក់ជាសាធារណៈ ដែលធ្វើឱ្យគេអាចប្រមូលទុនបានច្រើន ដើម្បីគាំទ្រកំណើនរបស់អង្គភាពអាជីវកម្ម។ ស្ថាបនិកក៏សង្ឃឹមថា នឹងលក់ភាគហ៊ុនវិនិយោគដំបូងទៅឱ្យអ្នកដទៃផងដែរ។

❖ **ភាគហ៊ុនសាធារណៈ** (Public equity)

នៅពេលក្រុមហ៊ុនចូលក្នុងទីផ្សារជាសាធារណៈ នោះគេនឹងបោះផ្សាយប័ណ្ណភាគហ៊ុននៅក្នុងទីផ្សារដំបូង ដើម្បីប្រមូលទុនវិនិយោគ។ ធ្វើបែបនេះ មានន័យថា ត្រូវប្តូររចនាសម្ព័ន្ធម្ចាស់ភាគហ៊ុន ដោយបង្កើនចំនួនម្ចាស់ភាគហ៊ុន និងប្តូររចនាសម្ព័ន្ធ

មូលធនផងដែរ ដោយបង្កើនភាគហ៊ុនវិនិយោគ ដែលធ្វើឱ្យអង្គភាពអាជីវកម្ម អាចទូទាត់សងផ្តាច់បំណុលបាន និងគាំទ្រកំណើនរបស់សាជីវកម្ម។

ប័ណ្ណភាគហ៊ុន គឺជាវិញ្ញាបនប័ត្រតំណាងឱ្យចំណែកនៃភាគហ៊ុនរបស់ក្រុមហ៊ុន។ ស្រដៀងគ្នានឹងមូលប័ត្របំណុលដែរ ប័ណ្ណភាគហ៊ុនធម្មតា (common stock) ត្រូវបានបោះផ្សាយដោយក្រុមហ៊ុននៅក្នុងទីផ្សារដំបូង ដើម្បីទទួលបានទុនវិនិយោគរយៈពេលវែង ប៉ុន្តែ ខុសគ្នានៅត្រង់ថា ទិញប័ណ្ណភាគហ៊ុន គឺជាចំណែកនៃម្ចាស់ភាគហ៊ុន មិនមែនជាឥណទាយកទេ។ លក្ខណៈនៃភាពជាម្ចាស់ភាគហ៊ុននេះ ទាក់ទាញវិនិយោគិនជាច្រើន ដែលមានបំណងទទួលបានផលប្រយោជន៍ពីភាគហ៊ុន ប៉ុន្តែ មិនមានបំណងគ្រប់គ្រងក្រុមហ៊ុនទេ។ ម្ចាស់ភាគហ៊ុន អាចទទួលបានផលប្រយោជន៍ពីការកើនឡើងនៃតម្លៃរបស់ក្រុមហ៊ុន ហើយនឹងទទួលបានផលចំណេញច្រើនជាងឥណទានយកទៅទៀត។ ទោះជាយ៉ាងនេះក្តី ម្ចាស់ភាគហ៊ុន អាចទទួលរងការខាតបង់ច្រើន ដោយសារការធ្លាក់ចុះតម្លៃភាគហ៊ុននៅក្នុងគ្រាដ៏លំបាកណាមួយផងដែរ។

**គំនូសបំព្រួញទី២.៥: ការសម្របសម្រួលលំហូរមូលធនរបស់ទីផ្សារហ៊ុន**




Source: Jeff Madura, *Financial Markets and Institutions*, 2015, P. 252.

❖ **ប័ណ្ណភាគហ៊ុនធម្មតា** ( common stock )

ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនតូចៗជាទូទៅជាអ្នកគ្រប់គ្រង ប៉ុន្តែ ក្រុមហ៊ុនដែលលក់ភាគហ៊ុនជាសាធារណៈ ម្ចាស់ភាគហ៊ុនមិនមែនជាអ្នកគ្រប់គ្រងទេ។ ហេតុនេះ គេត្រូវពឹងផ្អែកលើអ្នកគ្រប់គ្រងធ្វើជាភ្នាក់ងារ និងសម្រេចចិត្តក្នុងផលប្រយោជន៍ប្រសើរបំផុត សម្រាប់ម្ចាស់ភាគហ៊ុន។ ភាពជាម្ចាស់នៃភាគហ៊ុនធម្មតា ( common stock ) មានសិទ្ធិបោះឆ្នោត ដើម្បីសម្រេចកិច្ចការមួយចំនួនរបស់ក្រុមហ៊ុន ដូចជា បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល បោះឆ្នោតអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណភាគហ៊ុនថ្មី បោះឆ្នោតធ្វើវិសោធនកម្មកតិកាសញ្ញារបស់ក្រុមហ៊ុន និងការអនុម័តលក្ខន្តិកៈ ជាដើម។ មានវិនិយោគិនជាច្រើនប្រគល់សិទ្ធិបោះឆ្នោតទៅឱ្យគណៈគ្រប់គ្រង តាមរយៈការប្រើសិទ្ធិប្រទាន ( Proxy ) និងម្ចាស់ភាគហ៊ុនជាច្រើនទៀត មិនខ្វល់ពីការបោះឆ្នោតឡើយ។ ជាលទ្ធផល អ្នកគ្រប់គ្រងតែងទទួលបានសម្លេងឆ្នោតភាគច្រើន និងអាចបោះឆ្នោតជ្រើសរើសបេក្ខជនខ្លួនឯងជាក្រុមប្រឹក្សាភិបាលទៀតផង។

❖ **ប័ណ្ណភាគហ៊ុនអាទិភាព** ( Preferred stock )

ប័ណ្ណភាគហ៊ុនអាទិភាពតំណាងឱ្យផលប្រយោជន៍នៅក្នុងក្រុមហ៊ុន ដែលជាទូទៅមិនអនុញ្ញាតឱ្យមានសិទ្ធិបោះឆ្នោត។ ម្ចាស់ភាគហ៊ុនអាទិភាព ចែករំលែកភាពជាម្ចាស់របស់ក្រុមហ៊ុនជាមួយម្ចាស់ភាគហ៊ុនធម្មតា។ ហេតុនេះ ម្ចាស់ភាគហ៊ុនអាទិភាពទទួលបានការទូទាត់ នៅពេលដែលក្រុមហ៊ុនមានផលចំណេញ។ ប្រសិនបើក្រុមហ៊ុនមិនមានផលចំណេញគ្រប់គ្រាន់ ដើម្បីបើកភាគលាភទេ គេអាចប្រកាសលុបចោលដោយមិនបែងចែកភាគលាភ នៅគ្រានោះ។ ប៉ុន្តែ នៅពេលមានផលចំណេញត្រូវបែងចែកភាគលាភ នោះត្រូវផ្តល់ភាគលាភសរុបសម្រាប់ភាគហ៊ុនអាទិភាព ដោយត្រូវបើកភាគលាភក្នុងគ្រាបច្ចុប្បន្ន រួមទាំងភាគលាភដែលខនខានមិនបានបើកកាលពីគ្រាមុន ត្រូវបូកសរុបដើម្បីទូទាត់ មុនពេលភាគលាភ ដែលត្រូវបើកឱ្យម្ចាស់ភាគហ៊ុនធម្មតា។ ម្ចាស់ភាគហ៊ុនអាទិភាព ជាទូទៅ មិនចូលរួមក្នុងការបែងចែងផលចំណេញរបស់ក្រុមហ៊ុនទេ ដោយសារភាគហ៊ុនអាទិភាព ត្រូវទទួលភាគលាភថេរ ជារៀងរាល់ឆ្នាំ[28]៕

---

[28] *Ibid.*, Pp. 249-253.

# ជំពូក២

# អត្រាការប្រាក់
និង
# ការគណនា

# មេរៀនទី៣

## ទ្រឹស្តីនៃអត្រាការប្រាក់

## ( Theory of Interest Rates )

### ១. សញ្ញាណទូទៅ

អត្រាការប្រាក់ គឺជាអញ្ញត្តិដែលគេតែងយកចិត្តទុកដាក់ជាងគេ នៅក្នុងសេដ្ឋកិច្ច-សង្គម។ ការប្រែប្រួលនៃអត្រាការប្រាក់ ត្រូវបានរាយការណ៍ស្ទើរតែជារៀងរាល់ពេល តាមប្រព័ន្ធផ្សព្វផ្សាយនានា ដោយសារ វាមានឥទ្ធិពលដោយផ្ទាល់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ អត្រាការប្រាក់មានឥទ្ធិពលដល់ការសម្រេចចិត្តរបស់បុគ្គល ឬគ្រួសារ ដូចជា ត្រូវចំណាយលើការប្រើប្រាស់ ឬត្រូវសន្សំ ត្រូវទិញផ្ទះ ឬទិញសញ្ញាប័ណ្ណ ឬក៏ត្រូវផ្ញើនៅធនាគារ។ អត្រាការប្រាក់ ក៏មានឥទ្ធិពលដល់ការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ចរបស់អង្គភាពអាជីវកម្ម ឬ គ្រួសារ ផងដែរ ដូចជា ត្រូវទិញឧបករណ៍ សម្ភារៈ សម្រាប់រោងចក្រសហគ្រាស ឬត្រូវផ្ញើនៅធនាគារ ជាដើម[29]។

អត្រាការប្រាក់ គឺជាផលចំណូល ដែលឥណទាយកត្រូវទទួល នៅពេលផ្តល់ឥណទាន ឬ ជាការចំណាយដែលអ្នកខ្ចីត្រូវសងនៅពេលខ្ចីប្រាក់ ឬជាតម្លៃដែលអ្នកខ្ចីត្រូវសងឱ្យឥណទាយក ដើម្បីទទួលបានឥណទាន ក្នុងគ្រាណាមួយជាកំណត់។ ការប្រែប្រួលនៃអត្រាការប្រាក់ មានឥទ្ធិពលដោយផ្ទាល់ទៅលើតម្លៃនៃមូលប័ត្របំណុលដូចជា មូលប័ត្រទីផ្សាររូបិយវត្ថុ សញ្ញាប័ណ្ណ និងបំណុលនិក្ខេប ប៉ុន្តែ វាមានឥទ្ធិពលដោយប្រយោលទៅលើតម្លៃនៃមូលប័ត្រភាគហ៊ុន ពីព្រោះវាអាចមានឥទ្ធិពលទៅលើផលចំណូលរបស់វិនិយោគិន ដែលវិនិយោគទៅលើមូលប័ត្រភាគហ៊ុនទាំងនោះ។ ហេតុនេះ អ្នកចូលរួមនៅក្នុងទីផ្សារហិរញ្ញវត្ថុត្រូវគិតទុកជាមុន ពីការប្រែប្រួលនៃអត្រាការប្រាក់ នៅពេលរៀបចំការវិនិយោគជាថ្មី។ ការប្រែប្រួលអត្រាការប្រាក់ក៏ជះឥទ្ធិពលទៅលើគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ ដោយសារវាជះឥទ្ធិពលទៅលើថ្លៃមូលធន និងការប្រាក់ដែលត្រូវទទួលពីការផ្តល់ឥណទាន។ម្យ៉ាងទៀត ដោយសារ គ្រឹះស្ថាន

---

[29] Frederic S. and Stanley G., *Financial Markets and Institutions*, 7th Edition, 2012, P. 37.

ហិរញ្ញវត្ថុ វិនិយោគទៅលើមូលប័ត្រ ដូចជា សញ្ញាប័ណ្ណ ដែលតម្លៃរបស់វាទទួលរង ឥទ្ធិពលពីការប្រែប្រួលអត្រាការប្រាក់។ ហេតុនេះ អ្នកគ្រប់គ្រងគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវធ្វើការប៉ាន់ស្មានការប្រែប្រួលនៃអត្រាការប្រាក់ និងត្រូវកែសម្រួលទ្រព្យសកម្ម និង បំណុល ដើម្បីទទួលបានប្រយោជន៍ឡើងវិញ ពីការរំពឹងទុករបស់ខ្លួន។ បុគ្គលម្នាក់ៗ ក៏ធ្វើការវាយតម្លៃការប្រែប្រួលអត្រាការប្រាក់ផងដែរ ដើម្បីតាមដានចំណាយលើការ ខ្ចីប្រាក់ ឬផលចំណូលដែលបានមកពីការវិនិយោគលើមូលប័ត្របំណុល។

## ២. ទ្រឹស្តីមូលធនដែលអាចផ្តល់ឱ្យខ្ចីបាន ( Loanable funds theory )

ទ្រឹស្តីមូលនិធិឥណទាន ត្រូវបានប្រើដើម្បីពន្យល់ពីការប្រែប្រួលនៃអត្រាការ ប្រាក់ ដោយបានលើកឡើងថា អត្រាការប្រាក់ទីផ្សារត្រូវបានកំណត់ដោយកត្តាពីរ គឺ តម្រូវការ និងការផ្គត់ផ្គង់មូលធនឥណទាន។ តម្រូវការឥណទានត្រូវបានប្រើប្រាស់ ទូលំទូលាយនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយផ្តោតលើសកម្មភាពខ្ចីប្រាក់របស់គ្រួសារ អង្គភាពអាជីវកម្ម និងរដ្ឋាភិបាល។ រីឯ ការផ្គត់ផ្គង់មូលធនឥណទានវិញ គឺជាការផ្តល់ ហិរញ្ញវត្ថុទៅក្នុងទីផ្សារ ដោយអ្នកសន្សំ។

### ២.១. តម្រូវការឥណទានរបស់គ្រួសារ

ជាទូទៅ គ្រួសារត្រូវការខ្ចីប្រាក់ ដើម្បីទិញផ្ទះ ទិញរថយន្ត និងតម្រូវការ គ្រួសារផ្សេងទៀត ក្នុងរូបភាពបង់រំលស់។ ប្រសិនបើ គេអាចប៉ាន់ស្មានបានបរិមាណ ឥណទាន ដែលត្រូវការក្នុងកម្រិតអត្រាការប្រាក់ណាមួយ នោះលទ្ធផលបង្ហាញថា វា មានទំនាក់ទំនងច្រាស រវាងអត្រាការប្រាក់ និងបរិមាណតម្រូវការឥណទាន។ មាន ន័យថា តម្រូវការឥណទានកើនឡើង នៅពេលដែលអត្រាការប្រាក់ថយចុះ និងផ្ទុយ មកវិញ តម្រូវការឥណទានថយចុះ នៅពេលដែលអត្រាការប្រាក់កើនឡើង។

មានកត្តាផ្សេងៗទៀត ដែលធ្វើឱ្យតម្រូវការឥណទានគ្រួសារប្រែប្រួល ហើយ ធ្វើឱ្យខ្សែកោងតម្រូវការឥណទានរំកិលទៅឆ្វេង ឬទៅស្តាំ។ ឧទាហរណ៍ៈ នៅពេលអត្រា ពន្ធលើចំណូលគ្រួសារថយចុះ គ្រួសារនីមួយៗជឿជាក់ថា គាត់មានលទ្ធភាពច្រើន ក្នុងការសងបំណុល។ ហេតុនេះ គ្រួសារនីមួយៗអាចខ្ចីប្រាក់ច្រើនជាងមុន ធ្វើឱ្យខ្សែ កោងតម្រូវការឥណទានរំកិលទៅស្តាំ ពី $D_h$ ទៅ $D'_h$។

### ក្រាហ្វិក៣.១: ទំនាក់ទំនងរវាងអត្រាការប្រាក់ និងតម្រូវការវិនិយោគ




ក្រាហ្វិក៣.១ បង្ហាញពីតម្រូវការវិនិយោគរបស់គ្រួសារ ប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់។ បើអត្រាការប្រាក់ $r_1$ តម្រូវការវិនិយោគ $Q_1$ បើអត្រាការប្រាក់ថយចុះមក $r_2$ តម្រូវការវិនិយោគកើនឡើងដល់ $Q_2$។

## ២.២. តម្រូវការវិនិយោគរបស់អង្គភាពអាជីវកម្ម

អង្គភាពអាជីវកម្ម មានតម្រូវការវិនិយោគសម្រាប់វិនិយោគលើទ្រព្យសកម្មរយៈពេលខ្លី និងរយៈពេលវែង។ បរិមាណតម្រូវការវិនិយោគរបស់អង្គភាពអាជីវកម្ម ផ្អែកលើគម្រោងអាជីវកម្មដែលត្រូវអនុវត្ត។ អង្គភាពអាជីវកម្មវាយតម្លៃគម្រោង ដោយប្រៀបធៀបតម្លៃបច្ចុប្បន្ននៃលំហូរមូលធនទាំងអស់ ជាមួយនឹងទុនវិនិយោគគ្រាដំបូង ដែលគេហៅថា តម្លៃបច្ចុប្បន្នសុទ្ធ (Net present value-NPV)។

$$NPV = -INV + \sum_{t=1}^{n} \frac{CF_t}{(1+r)^t}$$

ដែល NPV: តម្លៃបច្ចុប្បន្នសុទ្ធ

INV : ទុនវិនិយោគគ្រាដំបូង

$CF_t$ : លំហូរសាច់ប្រាក់ក្នុងគ្រាទី t

r : អត្រាចំណូលដែលចង់បាន

t : រយៈពេលកំណត់សង (ដូចជា ឆ្នាំ ឆមាស ត្រីមាស ឬខែ)

គម្រោងដែលមានតម្លៃបច្ចុប្បន្នសុទ្ធ (NPV) វិជ្ជមាន ជាគម្រោងអាចទទួលយកបាន ពីព្រោះតម្លៃបច្ចុប្បន្ននៃផលដែលទទួលបាន ខ្ពស់ជាងតម្លៃវិនិយោគនៅគ្រាដំបូង។ អត្រាចំណូលដែលត្រូវទទួលបាន ក្នុងការអនុវត្តលើគម្រោងណាមួយ នឹងថយចុះទាប ប្រសិនបើអត្រាការប្រាក់ធ្លាក់ចុះ។ ហេតុនេះ គម្រោងជាច្រើននឹងទទួលបាន NPVs វិជ្ជមាន ហើយអង្គភាពអាជីវកម្មនឹងត្រូវការទុនច្រើនសម្រាប់វិនិយោគ។

មានន័យថា បើប្រភពទុនផ្សេងទៀតមិនប្រែប្រួល អង្គភាពអាជីវកម្មនឹងត្រូវការឥណទានច្រើនជាងមុន នៅពេលដែលអត្រាការប្រាក់ថយចុះ។ ទំនាក់ទំនងនេះ ត្រូវបានបង្ហាញក្នុងក្រាហ្វិក៣.២។

**ក្រាហ្វិក៣.២: ទំនាក់ទំនងរវាងអត្រាការប្រាក់ និងតម្រូវការឥណទានរបស់អង្គភាពអាជីវកម្ម**




ក្រាហ្វិក៣.២ បង្ហាញពីតម្រូវការឥណទានរបស់អង្គភាពអាជីវកម្ម ប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់។ បើអត្រាការប្រាក់ $r_1$ តម្រូវការឥណទាន $Q_1$ បើអត្រាការប្រាក់ថយចុះមក $r_2$ តម្រូវការឥណទានកើនឡើងដល់ $Q_2$។

ម៉្យាងទៀត ក្រៅពីតម្រូវការទុនរយៈពេលវែង អង្គភាពអាជីវកម្មក៏ត្រូវការទុនរយៈពេលខ្លី ដើម្បីវិនិយោគលើទ្រព្យរយៈពេលខ្លីដែរ ដូចជា គណនីត្រូវទារ និងសន្និធិ ដើម្បីគាំទ្រនិរន្តរភាពប្រតិបត្តិការជាដើម។ ប្រភេទទុនរយៈពេលខ្លីនេះ មានការប្រែប្រួលស្របនឹងចំនួនគម្រោង ឬសកម្មភាពដែលត្រូវអនុវត្ត និងមានទំនាក់ទំនងប្រាសជាមួយអត្រាការប្រាក់ បើសិនជាកត្តាផ្សេងទៀតមិនប្រែប្រួល។ ថ្លៃឱកាសនៃការវិនិយោគលើទ្រព្យរយៈពេលខ្លីនឹងកើនឡើងខ្ពស់ នៅពេលដែលអត្រាការប្រាក់កើនឡើង។ ហេតុនេះ អង្គភាពអាជីវកម្ម ជាទូទៅព្យាយាមគាំទ្រដំណើរការប្រតិបត្តិ ដោយប្រើបរិមាណទុនតិច នៅពេលដែលអត្រាការប្រាក់កើនឡើងខ្ពស់។

ម៉្យាងទៀត នៅពេលលក្ខខណ្ឌសេដ្ឋកិច្ចអំណោយផល ការរំពឹងទុកនៃលំហូរសាច់ប្រាក់របស់គម្រោងនានា នឹងកើនឡើងខ្ពស់ ធ្វើឱ្យសំណើគម្រោងទាំងនោះ នឹងទទួលបានអត្រាចំណូលខ្ពស់ លើសពីអត្រាចំណូលដែលចង់បាន។ ហេតុនេះ គម្រោងជាច្រើននឹងអាចទទួលយកបាន ដោយសារលទ្ធផលនៃការព្យាករណ៍ថា ស្ថានភាពសេដ្ឋកិច្ចល្អប្រសើរ ធ្វើឲ្យកើនឡើងនូវតម្រូវការឥណទាន ហើយខ្សែកោងតម្រូវការទុនត្រូវរំកិលទៅស្តាំ ពី $D_b$ ទៅ $D'_b$។

## ២.៣. តម្រូវការឥណទានរបស់រដ្ឋាភិបាល

នៅពេលដែលផែនការចំណាយរបស់រដ្ឋាភិបាលមិនអាចធានាបាន ដោយចំណូលដែលបានមកពីការប្រមូលពន្ធ និងប្រភពចំណូលផ្សេងទៀត នោះរដ្ឋាភិបាលត្រូវការឥណទាន ដើម្បីបំពេញបន្ថែម។ រដ្ឋាភិបាលអាចបោះផ្សាយសញ្ញាប័ណ្ណ ដើម្បីទទួលបានមូលធន។ សញ្ញាប័ណ្ណទាំងនោះ គឺជាបំណុលរបស់រដ្ឋាភិបាល។ ការចំណាយរបស់រដ្ឋាភិបាល និងគោលនយោបាយសារពើពន្ធ ជាទូទៅត្រូវបានគិតថា មានភាពឯករាជ្យពីអត្រាការប្រាក់។ ហេតុនេះ តម្រូវការទុនរបស់រដ្ឋាភិបាល គឺ មិនមានភាពរួញលូត ឬមិនប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់ទេ។ ប៉ុន្តែ នៅពេលអត្រាការប្រាក់កើនឡើងខ្ពស់ពេក រដ្ឋាភិបាលអាចគិតពិចារណា ដើម្បីពន្យារពេលចំណាយលើគម្រោងមិនចាំបាច់មួយចំនួន មានន័យថា តម្រូវការឥណទានរបស់រដ្ឋាភិបាល អាចអាស្រ័យនឹងអត្រាការប្រាក់ក្នុងកម្រិតណាមួយ។

ដូចគ្នានឹងតម្រូវការឥណទានរបស់គ្រួសារ និងអង្គភាពអាជីវកម្មដែរ ខ្សែកោងតម្រូវការឥណទានរបស់រដ្ឋាភិបាល អាចរំកិលដោយសារហេតុការណ៍ផ្សេងៗ។ ឧទាហរណ៍: តម្រូវការឥណទានរបស់រដ្ឋាភិបាល តំណាងដោយ $D_{g1}$ ដូចក្នុងក្រាហ្វិក ៣.៣។ ប្រសិនបើការអនុម័តទៅលើកញ្ចប់ថវិកា ដោយសារ ការប្រឈមនឹងឱនភាពចំនួន២០០ប៊ីលានដុល្លារ នោះរដ្ឋាភិបាលត្រូវការឥណទានស្មើនឹង ២០០ប៊ីលានដុល្លារដែរ។ តម្រូវការឥណទានថ្មីនេះ ធ្វើឱ្យខ្សែកោង $D_{g1}$ រំកិលទៅ $D_{g2}$។

**ក្រាហ្វិក៣.៣: ឥទ្ធិពលនៃការកើនឡើងឱនភាពថវិកាទៅលើតម្រូវការឥណទាន**




ក្រាហ្វិក៣.៣ បង្ហាញថា ខ្សែកោងតម្រូវការឥណទានរបស់រដ្ឋាភិបាលស្របជាមួយនឹងអ័ក្សអត្រាការប្រាក់។ ហេតុនេះ ទោះបីជាខ្សែកោងតម្រូវការឥណទានរំកិលទៅឆ្វេង ឬទៅស្តាំក៏ដោយ អត្រាការប្រាក់មិនប្រែប្រួលទេ។

## ២.៤. តម្រូវការឥណទានពីបរទេស

តម្រូវការឥណទាននៅក្នុងទីផ្សារ ក៏ត្រូវរួមបញ្ចូលនូវតម្រូវការពីបរទេស ដោយរដ្ឋាភិបាល ឬសាជីវកម្ម ផងដែរ។ ឧទាហរណ៍ៈ រដ្ឋាភិបាលអង់គ្លេសអាចទទួលបានធនធានហិរញ្ញវត្ថុ ដោយបោះផ្សាយសញ្ញាប័ណ្ណរដ្ឋាភិបាល និងលក់ឱ្យវិនិយោគិនអាមេរិក មានន័យថា អង់គ្លេសមានតម្រូវការឥណទានពីសហរដ្ឋអាមេរិក។ ហេតុនេះ លំហូរមូលធនចេញពីប្រទេសមួយទៅប្រទេសមួយទៀត ដោយសារលំអៀងនៃអត្រាការប្រាក់របស់ប្រទេសទាំងពីរ។ ជាទូទៅ លំហូរមូលធនចេញពីប្រទេសដែលមានការប្រាក់ទាបទៅប្រទេសដែលមានការប្រាក់ខ្ពស់។ ហេតុដូច្នេះហើយ បានជាគេសង្កេតឃើញថាប្រទេសកំពុងអភិវឌ្ឍន៍ តែងទទួលបានលំហូរមូលធនវិនិយោគ ពីប្រទេសអភិវឌ្ឍន៍។

**ក្រាហ្វិក៣.៤: ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់នៅបរទេសទៅលើតម្រូវការឥណទានពីស.រ.អា**




ក្រាហ្វិក៣.៤ បង្ហាញពីតម្រូវការឥណទានពីបរទេស តាងដោយ $D_{f1}$។ ប្រសិនបើអត្រាការប្រាក់នៅបរទេសកើនឡើង ក្រុមហ៊ុន និងរដ្ឋាភិបាលបរទេស នឹងត្រូវការឥណទានពី ស.រ.អា ដែលធ្វើឱ្យខ្សែកោងរំកិលពី $D_{f1}$ ទៅ $D_{f2}$។

## ២.៥. តម្រូវការឥណទានសរុប

តម្រូវការឥណទានសរុប គឺជាការបូកបញ្ចូលគ្នានៃបរិមាណឥណទាន ដែលត្រូវការដោយវិស័យផ្សេងៗ នៅក្នុងកម្រិតអត្រាការប្រាក់ណាមួយ។ ដោយសារវិស័យទាំងនោះ ត្រូវការឥណទានកាន់តែច្រើន នៅពេលដែលអត្រាការប្រាក់ថយចុះកាន់តែទាប នោះមានន័យថា តម្រូវការឥណទានសរុបមានទំនាក់ទំនងច្រាសជាមួយនឹងអត្រាការប្រាក់។ នៅពេលដែលគម្រោងតម្រូវការឥណទាន ក្នុងវិស័យណាមួយប្រែប្រួល នោះនឹងធ្វើឱ្យតម្រូវការឥណទានសរុបក៏ទទួលរងឥទ្ធិពលដែរ។ ហេតុនេះ តម្រូវការឥណទានសរុប ($D_A$) អាចសង្ខេប ដូចមានក្នុងរូបមន្តខាងក្រោមៈ

$D_A = D_h + D_b + D_g + D_m + D_f$

$D_h$ : តម្រូវការឥណទានរបស់គ្រួសារ

$D_b$ : តម្រូវការឥណទានរបស់អង្គភាពអាជីវកម្ម

$D_g$ : តម្រូវការឥណទានរបស់រដ្ឋាភិបាល

$D_g$ : តម្រូវការឥណទានរបស់រដ្ឋាភិបាលខេត្ត ក្រុង

$D_f$ : តម្រូវការឥណទានរបស់បរទេស

## ២.៦. ការផ្គត់ផ្គង់ឥណទាន

ការផ្គត់ផ្គង់ឥណទាន សំដៅលើមូលធនដែលត្រូវបានផ្តល់ទៅទីផ្សារ ដោយអ្នកសន្សំ។ គ្រួសារគឺជាអ្នកផ្គត់ផ្គង់ធំជាងគេ ប៉ុន្តែ មូលធនផ្តល់ឱ្យខ្ចីក៏អាចត្រូវបានផ្តល់ដោយស្ថាប័នរដ្ឋាភិបាល ដែលទទួលបានចំណូលពន្ធច្រើនជាងចំណាយ ឬ ដោយអង្គភាពអាជីវកម្ម ដែលមានលំហូរចូលមូលធនច្រើនជាងលំហូរចេញ។ ទោះជាយ៉ាងនេះក្តី ជាទូទៅគ្រួសារ គឺជាក្រុមអ្នកផ្គត់ផ្គង់ឥណទាន ចំណែករដ្ឋាភិបាល និងអង្គភាពអាជីវកម្មវិញ គឺជាអ្នកមានតម្រូវការឥណទាន។ អ្នកផ្គត់ផ្គង់ឥណទាន មានបំណងផ្តល់ឱ្យខ្ចីកាន់តែច្រើន នៅពេលដែលអត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ ដោយឧបមាថា កត្តាផ្សេងមិនប្រែប្រួល។ ចំណែក គ្រួសារ រដ្ឋាភិបាល និងអង្គភាពអាជីវកម្ម បរទេសវិញ ជាទូទៅ ផ្គត់ផ្គង់មូលធននៅក្នុងទីផ្សារក្នុងស្រុក ដោយទិញមូលប័ត្រ នៅក្នុងស្រុក ដែលភាគច្រើនជាមូលប័ត្ររតនាគារ។ ប៉ុន្តែ លំហូរមូលធនអាចនឹងចេញទៅក្រៅប្រទេសបាន ដោយសារមូលហេតុពីរយ៉ាង គឺ អត្រានៃការសន្សំខ្ពស់ និងលំអៀងនៃអត្រាការប្រាក់របស់ប្រទេសទាំងពីរ។ មានន័យថា លំហូរមូលធននឹងចេញពីប្រទេសណាដែលមានការសន្សំខ្ពស់ និងការប្រាក់ទាប ទៅប្រទេសណាដែលមានការសន្សំទាប និងការប្រាក់ខ្ពស់។ ម្យ៉ាងទៀត ការផ្គត់ផ្គង់ឥណទានក៏អាស្រ័យផងដែរ ទៅលើគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ដែលធ្វើឱ្យមានឥទ្ធិពល (ធ្វើឱ្យប្រែប្រួល កើនឡើងឬថយចុះ) ទៅលើបរិមាណផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ អត្រាប្រាក់ ប្រាក់បញ្ញើ និងឥណទាន តាមរយៈការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុណាមួយ។ ជារួម ការផ្គត់ផ្គង់ឥណទាននៅក្នុងទីផ្សារហិរញ្ញវត្ថុមានទំនាក់ទំនងស្របជាមួយនឹងអត្រាការប្រាក់ មានន័យថា អត្រាការប្រាក់កើនឡើងជំរុញ និងលើកទឹកចិត្តឱ្យការផ្គត់ផ្គង់ឥណទានកើនឡើងដែរ។

### ក្រាហ្វិក៣.៤: ខ្សែកោងផ្គត់ផ្គង់សរុបនៃមូលធនដែលអាចផ្តល់ឥណទាន




ក្រាហ្វិក៣.៥: បង្ហាញពីការផ្គត់ផ្គង់ឥណទាន ដែលទំហំឥណទានប្រែប្រួលស្របនឹងការប្រែប្រួលនៃបរិមាណឥណទាន មានន័យថា បើ អត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ អ្នកមានទុនមានបំណងផ្តល់ឥណទានកាន់តែច្រើន។

## ២.៧. ការផ្គត់ផ្គង់សរុបនៃមូលធន

ការផ្គត់ផ្គង់សរុបនៃមូលធនដែលអាចផ្តល់ឥណទានបាន គឺជាការបូកបញ្ចូលគ្នានូវការផ្គត់ផ្គង់លើគ្រប់វិស័យទាំងអស់ ជាមួយនឹងការផ្គត់ផ្គង់មូលធន ដែលផ្តល់ដោយគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល និងប្រភពមូលធនផ្គត់ផ្គង់ពីបរទេសផង។ ហេតុនេះ ការផ្គត់ផ្គង់សរុបនៃមូលធនដែលអាចផ្តល់ឥណទានបាន ($S_A$) អាចសង្ខេប ដូចមានក្នុងរូបមន្តខាងក្រោម៖

$$S_A = S_h + S_b + S_g + S_m + S_f$$

$S_h$ : ផ្គត់ផ្គង់ឥណទានពីគ្រួសារ

$S_b$ : ផ្គត់ផ្គង់ឥណទានគ្រួសារពីអង្គភាពអាជីវកម្ម

$S_g$ : ផ្គត់ផ្គង់ឥណទានពីរដ្ឋាភិបាល

$S_g$ : ផ្គត់ផ្គង់ឥណទានពីរដ្ឋាភិបាលខេត្ត ក្រុង

$S_f$ : ផ្គត់ផ្គង់ឥណទានពីបរទេស

ឥណទានដែលត្រូវបានផ្គត់ផ្គង់នៅក្នុងវិស័យនីមួយៗនៃសេដ្ឋកិច្ច តែងតែប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់ ទោះជាក្នុងកម្រិតតិចឬច្រើនក្តី ទៅតាមវិស័យផ្សេងៗគ្នា។ ហេតុនេះ ការផ្គត់ផ្គង់សរុបនៃឥណទាន ប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់ដែរ ដូចបង្ហាញនៅក្នុងក្រាហ្វិក៣.៥ ខាងលើ។ ប៉ុន្តែ ជាទូទៅ បរិមាណឥណទានដែលត្រូវការ មានភាពរួញលូតអាស្រ័យនឹងអត្រាការប្រាក់ (interest elastic) ខ្លាំងជាងបរិមាណឥណទានដែលត្រូវផ្គត់ផ្គង់។ ខ្សែកោងផ្គត់ផ្គង់ឥណទានអាចរំកិលមកឆ្វេង ឬទៅស្តាំ អាស្រ័យនឹងកត្តាផ្សេងៗ។ ឧទាហរណ៍: នៅពេលដែលអត្រាពន្ធលើ

ចំណូលការប្រាក់ត្រូវបានកាត់បន្ថយ នោះខ្សែកោងផ្គត់ផ្គង់ឥណទាននឹងរំកិលទៅស្តាំ (កើនឡើង) ដោយសារគ្រួសារនីមួយៗអាចសន្សំប្រាក់បានច្រើន តាមកម្រិតអត្រាពន្ធដែលបានប្រែប្រួល។ ផ្ទុយទៅវិញ នៅពេលដែលអត្រាពន្ធលើចំណូលការប្រាក់ត្រូវបានបង្កើន នោះខ្សែកោងផ្គត់ផ្គង់ឥណទាន នឹងរំកិលមកឆ្វេង (ថយចុះ) ដោយសារគ្រួសារនីមួយៗអាចសន្សំប្រាក់បានតិចជាង តាមកម្រិតអត្រាពន្ធដែលប្រែប្រួល។ នៅក្នុងផ្នែកនេះ យើងមិនបានផ្តោតច្រើនទៅលើគ្រឹះស្ថានហិរញ្ញវត្ថុទេ ទោះបីជាគ្រឹះស្ថានហិរញ្ញវត្ថុ បានបំពេញតួនាទីជាអន្តរការិយកម្មយ៉ាងសំខាន់ ក្នុងការបញ្ជូន-ផ្ទេរមូលធនពីអ្នកសន្សំទៅវិនិយោគិនក៏ដោយ ប៉ុន្តែស្ថាប័នទាំងនោះមិនមែនជាប្រភពនៃអ្នកផ្គត់ផ្គង់មូលធនដំបូងទេ។ មានន័យថា ការប្រែប្រួលនៃការផ្គត់ផ្គង់មូលធនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ គឺជាលទ្ធផលពីការប្រែប្រួលជាក់ស្តែង នៃស្ថានភាពរបស់គ្រួសារនីមួយៗ អង្គភាពអាជីវកម្ម ឬរដ្ឋាភិបាល ដែលជាប្រភពដើមនៃអ្នកផ្គត់ផ្គង់មូលធនទាំងនោះ។

### ២.៨. តម្លៃសមាតាអត្រាការប្រាក់

ការយល់ដឹងពីចំណុចសមាតាអត្រាការប្រាក់ មានសារៈសំខាន់សម្រាប់វាយតម្លៃហេតុការណ៍ផ្សេងៗ ដែលអាចជះឥទ្ធិពលដល់អត្រាការប្រាក់។ ក្នុងការអនុវត្តជាក់ស្តែង មានប្រភេទអត្រាការប្រាក់ផ្សេងៗគ្នា ពីព្រោះមានអ្នកខ្ចីខ្លះអាចចំណាយការប្រាក់ខ្ពស់ជាងអ្នកផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី ការពន្យល់ក្នុងផ្នែកនេះ គឺផ្អែកលើកត្តាដែលធ្វើឱ្យអត្រាការប្រាក់ប្រែប្រួលជាទូទៅ ដោយសារ អត្រាការប្រាក់របស់អ្នកខ្ចី ប្រែប្រួលស្របជាមួយនឹងបរិមាណកម្ចី។ ហេតុនេះ ការកំណត់ចំណុចសមាតាអត្រាការប្រាក់ អាចបង្ហាញតាមពិជគណិត និងក្រាហ្វិក។ តាមទម្រង់ពិជគណិត តម្លៃសមាតាអត្រាការប្រាក់ គឺជាអត្រាការប្រាក់ដែលធ្វើឱ្យតម្រូវការសរុប ($D_A$) ស្មើនឹងការផ្គត់ផ្គង់សរុប ($S_A$) នៃឥណទាន ពោលគឺ $D_A = S_A$។ ប្រសិបើតម្រូវការសរុបនៃឥណទានកើនឡើង ដោយមិនមានការឆ្លើយតបពីកំណើននៃការផ្គត់ផ្គង់ឥណទានសរុបទេ នោះនឹងធ្វើឱ្យខ្វះមូលធន ដែលអាចផ្តល់ឥណទាន។ ក្នុងករណីនេះ អត្រាការប្រាក់នឹងកើនឡើងរហូតដល់មានការផ្គត់ផ្គង់បន្ថែមមូលធន ដែលអាចផ្តល់ឥណទានបានគ្រប់គ្រាន់តាមតម្រូវការ។ ផ្ទុយទៅវិញ ការកើនឡើងនូវការផ្គត់ផ្គង់សរុបនៃឥណទានដោយមិនមានការកើនឡើងនៃតម្រូវការសរុបនោះទេ នោះនឹងផ្តល់លទ្ធផលអតិរេកនៃមូលធន ដែលអាចផ្តល់ឥណទានបាន។ ក្នុងករណីនេះ អត្រាការប្រាក់នឹងថយចុះ

ហេតុដល់ពេលដែលការផ្គត់ផ្គង់មូលធន លែងលើសពីបរិមាណមូលធនដែលត្រូវការទៀត។ ក្នុងករណីជាច្រើន ការផ្គត់ផ្គង់ និងតម្រូវការនៃមូលធនផ្ដល់ឱ្យខ្ចីតែងតែប្រែប្រួល កើនឡើង ឬថយចុះ។ ឧទាហរណ៍: តម្លៃសមាតានៃអត្រាការប្រាក់កើនឡើងនៅពេលដែល $D_A > S_A$ ហើយតម្លៃសមាតាអត្រាការប្រាក់នឹងថយចុះវិញ នៅពេលដែល $D_A < S_A$។ ប៉ុន្តែ បើគេផ្គុំបញ្ចូលគ្នារវាងខ្សែកោងតម្រូវការសរុប និងការផ្គត់ផ្គង់សរុបនៃមូលធនដែលអាចផ្ដល់ឱ្យខ្ចីបាន ធ្វើឱ្យគេអាចធ្វើការប្រៀបធៀបបាននូវបរិមាណមូលធនសរុបដែលត្រូវការ ជាមួយនឹងបរិមាណមូលធនសរុបដែលផ្គត់ផ្គង់នៅក្នុងកម្រិតអត្រាការប្រាក់ណាមួយ[30]។

**ក្រាហ្វិក៣.៦: តម្លៃសមាតាអត្រាការប្រាក់**




ក្រាហ្វិក៣.៦ បង្ហាញថា ក្នុងតម្លៃសមាតាអត្រាការប្រាក់ i នោះ ការផ្គត់ផ្គង់មូលធនដែលអាចឱ្យខ្ចីបាន ស្មើនឹងតម្រូវការឥណទាន។ ក្នុងករណីអត្រាការប្រាក់កើនឡើងខ្ពស់ជាង i មានន័យថា មានអតិរេកមូលធនដែលអាចផ្ដល់ឱ្យខ្ចី និងផ្ទុយមកវិញ។ ចំណែក នៅត្រង់ចំណុចសមាតាអត្រាការប្រាក់ i មានន័យថា ជាការប្រសើរបំផុតសម្រាប់ភាគីទាំងពីរ។

## ៣. មុខងារ និងតួនាទីនៃអត្រាការប្រាក់

អត្រាការប្រាក់ តែងជះឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការប្រើប្រាស់ប្រាក់។ អត្រាការប្រាក់កើនឡើង លើកទឹកចិត្តដល់ការសន្សំរបស់គ្រួសារ និងការផ្ញើប្រាក់នៅធនាគារ។ ផ្ទុយទៅវិញ នៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះ នោះនឹងជំរុញឱ្យវិនិយោគិនខ្ចីប្រាក់កាន់តែច្រើនឡើង និងបង្កើនសកម្មភាពសេដ្ឋកិច្ច និងកំណើន។ ហេតុនេះ អត្រាការប្រាក់បំពេញតួនាទីជាអ្នកសម្របសម្រួល ដោយបានស្ដែងឱ្យឃើញនូវមុខងារសំខាន់ៗ នៅក្នុងសេដ្ឋកិច្ច ដូចតទៅ៖

ក. អត្រាការប្រាក់ជួយធានាថា ការសន្សំបច្ចុប្បន្ននឹងត្រូវបានបញ្ជូនផ្ទេរទៅកាន់ស្ថាប័នដែលត្រូវការទុន ដូចជា អង្គភាពអាជីវកម្ម រដ្ឋាភិបាល ឬគ្រួសារ ដើម្បីវិនិយោគ

[30] Jeff Madura, *Financial Markets and Institutions*, 2015, P. 29-36.

ពង្រីកអាជីវកម្ម និងប្រើប្រាស់ ព្រមទាំងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច។ បើមានកំណើនសេដ្ឋកិច្ច នោះវានឹងរួមចំណែកក្នុងការបង្កើតការងារថ្មី បង្កើនចំណូលអាជីវកម្ម និងចំណាយមូលធន លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង និងបង្កើនចំណូលពន្ធរបស់រដ្ឋាភិបាលផងដែរ។

ខ. អត្រាការប្រាក់មានតួនាទីកំណត់ទំហំឥណទានដែលត្រូវផ្គត់ផ្គង់ និងការផ្តល់ឥណទានទៅលើគម្រោងវិនិយោគនានា ជាមួយនឹងអត្រាការប្រាក់ខ្ពស់។ អត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ ជំរុញ និងលើកទឹកចិត្តឱ្យអ្នកមានទុន មានបំណងផ្តល់ឱ្យខ្ចីកាន់តែច្រើនឡើង។

គ. អត្រាការប្រាក់ធ្វើឱ្យមានតុល្យភាពរវាងការផ្គត់ផ្គង់ និងតម្រូវការសាច់ប្រាក់នៅក្នុងចរាចរណ៍។ លក្ខណៈពិសេសនៃការសម្របសម្រួលនេះ មានសារៈសំខាន់ណាស់ ក្នុងការផ្តល់ផលប្រយោជន៍ដល់គ្រប់ភាគីដែលបានចូលរួម ពីព្រោះនៅពេលដែលគេទទួលបានចំណុចសមាតានៃអត្រាការប្រាក់ នោះតម្លៃមូលធន (cost of capital) ត្រូវបានកំណត់ត្រឹមត្រូវដោយយន្តការទីផ្សារ ហើយសកម្មភាពនៃការខ្ចី និងការផ្តល់ឱ្យខ្ចី ត្រូវបានសម្របសម្រួលដោយរលូន និងផ្តល់ផលប្រយោជន៍ដល់អ្នកផ្តល់ឱ្យខ្ចីផង និងអ្នកខ្ចីផង។ នៅពេលដែលសាច់ប្រាក់ត្រូវបានបញ្ជូនពីអ្នកផ្ញើទៅឱ្យអ្នកខ្ចី អង្គភាពអាជីវកម្មនឹងប្រើប្រាស់មូលធនទាំងនោះ ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនតម្លៃសេដ្ឋកិច្ច ហើយសេដ្ឋកិច្ចទាំងមូលនឹងទទួលបានផលប្រយោជន៍ពីតួនាទីនេះ។

ឃ. អត្រាការប្រាក់ ជាឧបករណ៍សំខាន់នៃគោលនយោបាយរបស់រដ្ឋាភិបាល តាមរយៈការធ្វើឱ្យមានឥទ្ធិពលទៅលើទំហំនៃការសន្សំ និងការវិនិយោគ។ ប្រសិនបើសេដ្ឋកិច្ចកើនឡើងយឺតពេក ហើយអត្រាអត់ការងារធ្វើកើនឡើងខ្ពស់ នោះរដ្ឋាភិបាលអាចប្រើឧបករណ៍គោលនយោបាយ ដើម្បីបន្ទាបអត្រាការប្រាក់ ក្នុងគោលដៅបង្កើនការខ្ចី និងការវិនិយោគ។ ម៉្យាងទៀត ប្រសិនបើសេដ្ឋកិច្ចកំពុងជួបនឹងអត្រាអតិផរណាខ្ពស់ នោះរដ្ឋាភិបាលត្រូវដាក់ចេញនូវគោលនយោបាយបង្កើនអត្រាការប្រាក់ ដើម្បីកាត់បន្ថយការខ្ចី និងការចំណាយ ហើយលើកទឹកចិត្តឱ្យមានការសន្សំ[31]។

---

[31] Peter S. Rose, *Money and Capital Markets*, 2005.

សរុបសេចក្តីមក អត្រាការប្រាក់បំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការសម្របសម្រួលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។ ពីព្រោះ អត្រាការប្រាក់ប្រែប្រួល វានឹងធ្វើឱ្យប្រែប្រួលដល់ការផ្គត់ផ្គង់ និងតម្រូវការមូលធន ដែលជាកត្តាកំណត់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ អត្រាការជាឧបករណ៍នយោបាយរូបិយវត្ថុ ដែលអាចត្រូវបានប្រើដោយធនាគារកណ្តាលនៃប្រទេសនីមួយៗ ដើម្បីធ្វើអន្តរាគមន៍ នៅពេលស្ថានភាពសេដ្ឋកិច្ចមិនប្រសើរ ឬប្រឈមនឹងវិបត្តិណាមួយ៕

# មេរៀនទី៤

# ការគណនាអត្រាការប្រាក់ និងតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ

(Calculating Interest Rates and Financial Asset Prices)

## ១. សញ្ញាណទូទៅ

និយមន័យនៃអត្រាការប្រាក់ គឺជាសមាមាត្រជាភាគរយប្រចាំឆ្នាំ ដែលត្រូវយកពីភាគីអ្នកខ្ចី ដូចជា អង្គភាពអាជីវកម្ម ឬគ្រួសារ ដែលសម្រេចចិត្តខ្ចីប្រាក់ពីធនាគារ ឬពីប្រភពហិរញ្ញវត្ថុផ្សេងទៀត។ ហេតុនេះ អត្រាការប្រាក់គឺជាតម្លៃឥណទានដែលអ្នកខ្ចីត្រូវទូទាត់សងម្ចាស់បំណុល នៅក្នុងគ្រាណាមួយជាកំណត់។ អត្រាការប្រាក់មានតួនាទីសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច-សង្គម ពីព្រោះ វាជួយជំរុញឱ្យមានការសន្សំ និងការវិនិយោគ។ អត្រាការប្រាក់ប្រែប្រួល កើនឡើងឬថយចុះ វានឹងជះឥទ្ធិពលទៅដល់តម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ដោយប្រែប្រួលក្នុងទិសដៅផ្ទុយគ្នា។ មានន័យថា បើអត្រាការប្រាក់កើនឡើង នោះនឹងធ្វើឱ្យតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុធ្លាក់ចុះ និងផ្ទុយមកវិញ បើអត្រាការប្រាក់ថយចុះ នោះនឹងធ្វើឱ្យតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុកើនឡើង។ ប៉ុន្តែ គោលដៅនៃគោលនយោបាយរូបិយវត្ថុ ឬគោលនយោបាយសេដ្ឋកិច្ច គឺរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលក្នុងនោះក៏មានស្ថិរភាពនៃអត្រាការប្រាក់ និងស្ថិរភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ រួមទាំងស្ថិរភាពនៃទំនិញទូទៅ ដែលត្រូវបានទិញ-លក់នៅក្នុងទីផ្សារផលិតផល និងទីផ្សារហិរញ្ញវត្ថុ ផងដែរ។

ហេតុនេះ ការគណនាអត្រាការប្រាក់ និងតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ក្នុងពេលបច្ចុប្បន្ន និងការវាយតម្លៃការប្រែប្រួលតម្លៃនាពេលអនាគត មានសារៈសំខាន់សម្រាប់អង្គភាពអាជីវកម្ម និងវិនិយោគិន ក្នុងការសម្រេចចិត្តលើគម្រោងវិនិយោគផ្សេងៗ នៅក្នុងសេដ្ឋកិច្ច-សង្គមក្តី នៅក្នុងទីផ្សារហិរញ្ញវត្ថុក្តី។ នៅក្នុងមេរៀននេះ យើងនឹងលើកយកវិធីសាស្ត្រផ្សេងៗ ក្នុងការគណនាអត្រាការប្រាក់ និងតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ព្រមទាំងវិធីគណនាផ្សេងៗទៀត ដែលធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងស្ថាប័នផ្សេងទៀត កំពុងប្រើប្រាស់នាពេបច្ចុប្បន្ន។

## ២. វិធីសាស្ត្រនៃការគណនាអត្រាការប្រាក់

### ២.១. អត្រាការប្រាក់

តាមនិយមន័យនៃអត្រាការប្រាក់ ដែលបានលើកឡើងខាងលើ យើងអាចគណនាអត្រាការប្រាក់ តាមរូបមន្តខាងក្រោម៖

$$\text{អត្រាការប្រាក់} = \frac{\text{តម្រៃដែលអ្នកផ្តល់ឱ្យខ្ចី តម្រូវឱ្យអ្នកខ្ចីត្រង់បង់ ដើម្បីទទួលបានឥណទាន}}{\text{បរិមាណឥណទានដែលត្រូវផ្តល់ឱ្យខ្ចី}}$$

ជាទូទៅ បើគេនិយាយថា អត្រាការប្រាក់១២% ដោយមិនបញ្ជាក់ពីពេលវេលាច្បាស់លាស់ទេ គឺមានន័យថា អត្រា១២ភាគរយក្នុងរយៈពេលមួយឆ្នាំ ដោយយោងតាមនិយមន័យនៃអត្រាការប្រាក់។ ក្រៅពីនេះ យើងត្រូវបញ្ជាក់ច្បាស់លាស់ពីរយៈពេលរបស់វា។ ឧទាហរណ៍ៈ អត្រាការប្រាក់ ១% ក្នុងមួយខែ អត្រាការប្រាក់ ៣% ក្នុងមួយត្រីមាស ឬ អត្រាការប្រាក់ ៦% ក្នុងមួយឆមាស ជាដើម។

ក. ការប្រាក់ធម្មតា (Simple Interest)

ការប្រាក់ធម្មតា ជាវិធីនៃការគណនាការប្រាក់ ដែលការប្រាក់នៅក្នុងគ្រានីមួយៗ មិនត្រូវបានប្រើក្នុងការវិនិយោគឡើងវិញ នៅគ្រាបន្តបន្ទាប់ទេ។ ពោលគឺការប្រាក់ត្រូវបានគណនាធៀបនឹងប្រាក់ដើមតែប៉ុណ្ណោះ។ ការប្រាក់ធម្មតា ត្រូវបានគណនា ដោយប្រើរូបមន្តដូចខាងក្រោម៖

$$I = P \times r \times t \Rightarrow r = I/Pt$$

រីឯ តម្លៃសរុបទាំងដើមទាំងការ ដែលត្រូវទទួលក្នុងគ្រាទី $t$ ត្រូវបានគណនា៖

$$A = P(1 + rt)$$

ដែល $A$ : តម្លៃសរុបទាំងដើមទាំងការ នៅគ្រាកំណត់សង

$I$ : ការប្រាក់សរុប

$P$ : ប្រាក់ដើម

$r$ : អត្រាការប្រាក់

$t$ : រយៈពេលកំណត់សង

ខ. ការប្រាក់ផ្គួប ឬការប្រាក់សមាច្ច័យ (Compound Interest)

ការប្រាក់ផ្គួប ឬការប្រាក់សមាច្ច័យ គឺជាការប្រាក់បង្គរ ដែលអាចជាវិធីសាស្ត្រនៃការគណនាការប្រាក់ ដោយការប្រាក់ដែលទទួលបាននៅក្នុងគ្រានីមួយៗ ត្រូវបានប្រើប្រាស់សម្រាប់វិនិយោគនៅគ្រាបន្តបន្ទាប់ មានន័យ ការប្រាក់ដែលទទួលបាននៅគ្រាទី១ ត្រូវបានប្រើក្នុងការវិនិយោគនៅគ្រាទី២ ហើយការប្រាក់នៅគ្រាទី១និងទី២បញ្ចូលគ្នា ត្រូវបានប្រើក្នុងការវិនិយោគនៅគ្រាទី៣ និងនៅគ្រាបន្តបន្ទាប់ទៀត ដោយឧបមាថា អត្រាការប្រាក់នៃការវិនិយោគឡើងវិញ នៅគ្រាបន្តបន្ទាប់ ស្មើនឹងអត្រាការប្រាក់ក្នុងការវិនិយោគនៅគ្រាដំបូង។ ឥទ្ធិពលនៃការប្រាក់ផ្គួប ធ្វើឱ្យតម្លៃអនាគត (Future value) នឹងកើនឡើងកាន់តែខ្ពស់។ វិធីសាស្ត្រនៃគណនាតាមការប្រាក់ផ្គួបនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយធនាគារ ក្រុមហ៊ុន និងការវិនិយោគផ្សេងទៀត។ អត្រាការប្រាក់ផ្គួប ត្រូវបានគណនាដោយប្រើរូបមន្តដូចខាងក្រោម៖

$$\text{អត្រាការប្រាក់ផ្គួប} = \left(\frac{FV}{PV}\right)^{1/n} - 1$$

ចំណែក តម្លៃអនាគត FV ត្រូវបានគណនា ដោយប្រើរូបមន្តដូចខាងក្រោម៖

$$FV = PV(1+r)^n$$

ដែល FV : តម្លៃអនាគត (តម្លៃចុងគ្រា)

PV : តម្លៃបច្ចុប្បន្ន (តម្លៃដើមគ្រា)

r : អត្រាការប្រាក់

n : រយៈពេលកំណត់សង

## ២.២. ការគណនាតម្លៃសន្លឹកហ៊ុន

ប័ណ្ណភាគហ៊ុន ត្រូវបានបែងចែកជាពីរប្រភេទ គឺ ប័ណ្ណភាគហ៊ុនធម្មតា (Common stock) និងប័ណ្ណភាគហ៊ុនអាទិភាព (Preferred stock) ត្រូវបានវាស់វែងដោយឯកតារូបិយវត្ថុ ដូចជា ដុល្លារ ហ្វ្រង់ រៀល ជាដើម។ តម្លៃរបស់វាតែងប្រែប្រួលអាស្រ័យនឹងអត្រាការប្រាក់ ហើយនៅក្នុងទំនាក់ទំនងច្រាស ឬ ផ្ទុយគ្នា។ តម្លៃសន្លឹកហ៊ុនត្រូវបានគណនា តាមរូបមន្តខាងក្រោម៖

$$P_0 = \sum_{t=0}^{\infty} \frac{E(D_t)}{(1+r)^t}$$

ដែល $P_0$ : តម្លៃទីផ្សារនៃសន្លឹកហ៊ុនក្នុងគ្រាបច្ចុប្បន្ន

$E(D_t)$ : ភាគលាភដែលសង្ឃឹមថានឹងទទួលបានក្នុងគ្រាទី t

r : អត្រាការប្រាក់ទីផ្សារ

t : គ្រា ឬចំនួនពេលវេលា ដែលត្រូវបែងចែកភាគលាភ

ក្នុងករណីការព្យាករណ៍បង្ហាញថា នាពេលអនាគត ភាគលាភនឹងកើនឡើងក្នុងអត្រាថេរ (g) នោះគេអាចគណនាតម្លៃទីផ្សារនៃសន្លឹកហ៊ុនបច្ចុប្បន្នបាន ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$P_0 = \frac{D_0(1+g)}{r - g} = \frac{D_1}{r - g}$$

ហើយយើងក៏អាចគណនាអត្រាការប្រាក់បានផងដែរ ដោយប្រើរូបមន្តខាងក្រោម៖

$$r = \frac{D_0(1+g)}{P_0} + g = \frac{D_1}{P_0} + g$$

ដែល $P_0$ : តម្លៃទីផ្សារនៃសន្លឹកហ៊ុនក្នុងគ្រាបច្ចុប្បន្ន

$D_0$ : ភាគលាភក្នុងគ្រាទីសូន្យ (បច្ចុប្បន្ន)

$D_1$ : ភាគលាភក្នុងគ្រាទី១

r : អត្រាការប្រាក់ទីផ្សារ

g : អត្រាកំណើនភាគលាភថេរ

## ២.៣. ការគណនាតម្លៃសញ្ញាប័ណ្ណ

សញ្ញាប័ណ្ណជាប្រភេទប័ណ្ណបំណុល មានរយៈពេលវែងលើសពីមួយឆ្នាំ ត្រូវបានបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម ឬរដ្ឋាភិបាល ដើម្បីខ្ចីប្រាក់ពីសាធារណជន ឬវិនិយោគិននៅក្នុងទីផ្សារហិរញ្ញវត្ថុ។ បុគ្គលដែលបានទិញសញ្ញាប័ណ្ណនៅក្នុងទីផ្សារហិរញ្ញវត្ថុ មានន័យថា បានផ្តល់ប្រាក់ឱ្យខ្ចី ចំពោះក្រុមហ៊ុនសាជីវកម្ម ឬរដ្ឋាភិបាល។

តម្លៃសញ្ញាប័ណ្ណអាចប្រែប្រួល កើនឡើងឬថយចុះ អាស្រ័យលើការប្រែប្រួលនៃអត្រាការប្រាក់នៅក្នុងទីផ្សារ ឬ អត្រាចំណូលនៃគម្រោងវិនិយោគផ្សេងទៀត។ ដោយសារសញ្ញាប័ណ្ណមានលក្ខណៈពិសេសបីយ៉ាង គឺ ទី១) ទទួលបានការប្រាក់ ឬ គូប៉ុងថេរជារៀងរាល់គ្រា ទី២) ការប្រាក់ទទួលបានយ៉ាងទៀងទាត់ (ដូចជា មួយឆ្នាំម្តង ឬ មួយឆមាសម្តង) និងទី៣ មានពេលវេលាកំណត់សងជាក់លាក់ ដែលត្រូវនឹងនិយមន័យនៃលំហូរសាច់ប្រាក់ដែលមានលក្ខណៈជា "អនុសំវច្ឆរគ្គ" (Annuities)[32]។ ហេតុនេះ យើងអាចគណនាតម្លៃសញ្ញាប័ណ្ណ ដោយប្រើរូបមន្តពិសេស ដូចខាងក្រោម៖

$$Po = C\left[\frac{1-\frac{1}{(1+r)^t}}{r}\right]+\frac{F}{(1+r)^t}$$

ដែល $P_0$: តម្លៃសញ្ញាប័ណ្ណក្នុងគ្រាបច្ចុប្បន្ន (គ្រាទី0)

C : បរិមាណការប្រាក់ថេរដែលត្រូវទទួលជារៀងរាល់គ្រា

r : អត្រាការប្រាក់ទីផ្សារ ឬអត្រាចំណូលដល់ថ្ងៃកំណត់សង(YTM)

t : រយៈពេលកំណត់សង

F : តម្លៃបោះផ្សាយ (Face value)

យើងមានការលំបាក ក្នុងការគណនាអត្រាការប្រាក់ ឬហៅថា អត្រាចំណូលដល់ថ្ងៃកំណត់សងរបស់សញ្ញាប័ណ្ណ ដោយសារជាប់ស្វ័យគុណ t មិនអាចដោះស្រាយបាន។ ប៉ុន្តែ យើងអាចគណនាអត្រាចំណូលដល់ថ្ងៃកំណត់សងរបស់សញ្ញាប័ណ្ណបានក្នុងតម្លៃប្រហាក់ប្រហែល ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$YTM = \frac{\frac{C+F+P}{n}}{\frac{F+P}{2}}$$

---

[32] អនុសំវច្ឆរគ្គ គឺជាការផ្តល់ចំណូលថេរជារៀងរាល់គ្រា (ឬធនលាភប្រចាំឆ្នាំ) ជាពិសេសនៅពេលដល់អាយុចូលនិវត្តន៍។ នៅក្នុងប្រទេសរីកចម្រើន ប្រជាពលរដ្ឋ អាចទិញសេវា "ផែនការសោធន" នៅពេលមិនទាន់ដល់អាយុចូលនិវត្តន៍ ដោយបង់ប្រាក់ថេរជារៀងរាល់គ្រា (ជាទូទៅត្រូវបង់ប្រចាំខែ) ដើម្បីទទួលប្រាក់ចូលនិវត្តន៍ (ជាទូទៅត្រូវទទួលប្រចាំខែ) នៅពេលដល់អាយុចូលនិវត្តន៍ កំណត់ដោយច្បាប់របស់ប្រទេសនីមួយៗ។

ដែល YTM: អត្រាចំណូលដល់ថ្ងៃកំណត់សង

C : ការប្រាក់ដែលត្រូវទទួលជារៀងរាល់គ្រា (Coupon payment)

F : តម្លៃបោះផ្សាយ

P : ថ្លៃទីផ្សារបច្ចុប្បន្ន

n : រយៈពេលកំណត់សង

## ២.៤. ការគណនាតម្លៃបង់រំលស់អចលនទ្រព្យ

ជាទូទៅ ការទិញអចលនទ្រព្យ អតិថិជនតែងបង់រំលស់ប្រចាំខែ ក្នុងរយៈពេលវែង។ ហេតុនេះ ដើម្បីគណនាតម្លៃសរុបដែលត្រូវបង់ប្រចាំខែ រួមមានទាំងប្រាក់ដើម និងការប្រាក់ផង ត្រូវបានគណនាដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$\text{តម្លៃសរុបត្រូវបង់ប្រចាំខែ} = \mathrm{L} \times \frac{r/12 \times \left(1 + r/12\right)^{t \times 12}}{\left(1 + r/12\right)^{t \times 12} - 1}$$

ដែល L : បរិមាណឥណទាន

r : អត្រាការប្រាក់ប្រចាំឆ្នាំ

t : រយៈពេលកំណត់សង (ឆ្នាំ)

សរុបសេចក្តីមក យើងមានរូបមន្តផ្សេងៗជាច្រើន សម្រាប់គណនាការប្រាក់ និងកត្តាពាក់ព័ន្ធផ្សេងទៀត ដែលធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងវិនិយោគិន អាចប្រើប្រាស់បាន។ ប៉ុន្តែ គួរកត់សម្គាល់ថា ក្នុងការអនុវត្តជាក់ស្តែង គេកម្រនឹងប្រើប្រាស់អត្រាការប្រាក់ធម្មតាណាស់ ពោលគឺ គេតែងតែប្រើអត្រាការប្រាក់ផ្គួប ដែលធ្វើឱ្យតម្លៃអនាគត នឹងកើនឡើងកាន់តែខ្ពស់ នៅពេលដែលឥទ្ធិពលនៃអត្រាការប្រាក់ផ្គួបកាន់តែខ្លាំង៕

# ជំពូក៣

# ការគ្រប់គ្រងធនាគារ និង
# គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ

# មេរៀនទី៥

## ការគ្រប់គ្រងធនាគារពាណិជ្ជ និង សេវាកម្ម

## ( Commercial Bank Management and Services )

### ១. សញ្ញាណទូទៅ

ធនាគារពាណិជ្ជ ជាផ្នែកមួយនៃគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានតួនាទីសំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនៃប្រទេសនីមួយៗ។ ធនាគារពាណិជ្ជបានផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងទូលំទូលាយ ដូចជា ទទួលប្រាក់បញ្ញើ ផ្តល់ឥណទាន និងបម្រើសេវាបញ្ជូនផ្ទេរ ឬទូទាត់ ព្រមទាំងសេវាកម្មផ្សេងៗទៀត ដែលបានរួមចំណែកក្នុងការសម្របសម្រួលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ ដើម្បីជួយលើកស្ទួយស្តង់ដាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ និងជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច ឱ្យមានសន្ទុះរីកចម្រើនកាន់តែខ្លាំងក្លាឡើង។ សេវាកម្មរបស់ធនាគារពាណិជ្ជមានការវិវត្តិប្រែប្រួលជាបន្តបន្ទាប់ ដែលធ្វើឱ្យការប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើង។ ធនាគារពាណិជ្ជបានបង្កើតសេវាកម្មថ្មីៗ ដោយភ្ជាប់ជាមួយនឹងការអភិវឌ្ឍបច្ចេកវិទ្យា ព្រមទាំងពង្រឹង និងពង្រីកធនាគារឱ្យកាន់តែមានទំហំធំ និងមានភាពរឹងមាំ ដោយចងសម្ព័ន្ធគ្នារវាងធនាគារពីរ ឬច្រើន ដើម្បីបង្កើតបានជាធនាគារធំមួយ ដែលមានលទ្ធភាពខ្ពស់ ក្នុងការពង្រីកសាខាទៅតាមទីតាំងភូមិសាស្ត្រ ទាំងនៅក្នុងស្រុក និងបង្កើតសាខាទៅក្រៅប្រទេស។ ម៉្យាងទៀត ដើម្បីទទួលបានជោគជ័យនៅក្នុងប្រតិបត្តិការរបស់ធនាគារយើងក៏សិក្សាពីលទ្ធផលនៃប្រតិបត្តិការ តាមរយៈការពិនិត្យ និងវិភាគរបាយការណ៍ហិរញ្ញវត្ថុ និងវិធីសាស្ត្រវាយតម្លៃផ្សេងទៀត។ គោលបំណងនៃការវាយតម្លៃនេះ គឺរកឱ្យឃើញនូវលទ្ធផលអាក្រក់ ឬល្អ ធ្វើជាមូលដ្ឋានក្នុងការពិចារណា និងរកយុទ្ធសាស្ត្រកែលម្អ ដើម្បីឱ្យប្រតិបត្តិការនាពេលអនាគត កាន់តែប្រសើរឡើង។

### ២. មុខងារ និងតួនាទីរបស់ធនាគារពាណិជ្ជ

#### ២.១. មុខងារអន្តរការីយកម្ម ( Intermediation Role )

អន្តរការីយកម្ម គឺជាមុខងាររបស់ធនាគារដែលធ្វើសកម្មភាព ដោយឈរកណ្តាលរវាងភាគីពីរ ដើម្បីជួយសម្របសម្រួលកិច្ចការជំនួយ ឬការវិនិយោគ រួម

ចំណែកកាត់បន្ថយនូវអសុក្រិតភាពនៃទីផ្សារ ដែលបង្កើតឡើងដោយទំហំសេដ្ឋកិច្ចកាន់តែធំ និងស្មុគ្រស្មាញ ពាក់ព័ន្ធនឹងការបញ្ជូនផ្ទេរ ឬទូទាត់ នៅក្នុងទីផ្សារ និងជាការប្រមូលព័ត៌មាន រួមទាំងការគ្រប់គ្រងការវិនិយោគទៅលើមូលប័ត្រ នៅក្នុងទីផ្សារហិរញ្ញវត្ថុផង។ អន្តរការីយកម្មហិរញ្ញវត្ថុ គឺជាមុខងារដ៏មានសារៈសំខាន់របស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដោយបំពេញតួនាទីជាអ្នកបញ្ជូនផ្ទេរមូលធនពីអ្នកមានទុនទំនេរ ឬអ្នកសន្សំ ទៅអ្នកដែលត្រូវការទុនវិនិយោគ ដូចជា អង្គភាពអាជីវកម្ម រដ្ឋាភិបាល ឬគ្រួសារ និងបម្រើសេវាកម្មហិរញ្ញវត្ថុផ្សេងៗជាច្រើនទៀត។

### **២.២. មុខងារទូទាត់** (Payment Role)

គោលបំណងនៃមុខងារទូទាត់របស់ធនាគារ គឺជានាំឱ្យការទូទាត់ប្រព្រឹត្តិទៅបានរលូន និងឆាប់រហ័សរវាងធនាគារ និងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ ហេតុនេះ មុខងារទូទាត់ គឺជាយន្តការដ៏មានសារៈសំខាន់ ក្នុងការសម្របសម្រួលដោយរលូន និងប្រកបដោយសុវត្ថិភាព រវាងអ្នកលក់ និងអ្នកទិញ តាមរយៈប្រព័ន្ធធនាគារ ដោយបញ្ជូនផ្ទេរមូលធន ពីអ្នកទិញទៅអ្នកលក់ ឬជាការបញ្ជូន-ផ្ទេរមូលធនដើម្បីបំពេញតម្រូវការវិនិយោគ។ បើយើងគ្មានយន្តការទូទាត់របស់ធនាគារទេ នោះនឹងធ្វើឱ្យពាណិជ្ជកម្ម និងការវិនិយោគ ប្រាកដជាជួបការលំបាកធ្ងន់ធ្ងរ ដោយបញ្ជូនទុនមិនទាន់ពេលវេលា ឬ រាំងស្ទះដល់ដំណើរការប្រតិបត្តិរបស់ភាគីពាក់ព័ន្ធ។ ដើម្បីសម្រេចគោលដៅនេះ ធនាគារត្រូវមានមធ្យោបាយទូទាត់គ្រប់បែបយ៉ាង តាមរយៈការបង្កើតសេវាកម្មហិរញ្ញវត្ថុថ្មីៗ ទំនើប ដោយប្រើប្រាស់បច្ចេកវិទ្យាក្នុងការបញ្ជូនផ្ទេរ ឬ ទូទាត់។

### **២.៣. មុខងារជាអ្នកធានា** (Guarantor Role)[33]

នៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ជាពិសេស ពាណិជ្ជកម្មអន្តរជាតិ គេតែងទទួលការបញ្ជាទិញទំនិញ ឬសេវាកម្ម ទៅវិញទៅមក។ ពាណិជ្ជកម្មអន្តរជាតិប្រឈមនឹងហានិភ័យខ្ពស់ ដោយសារ អ្នកនាំចូលអាចមិនទូទាត់ប្រាក់ ក្រោយពីទទួលបានទំនិញ ហើយអ្នកនាំចេញអាចមិនបញ្ជូនទំនិញ ប្រសិនបើអ្នកនាំចូលទូទាត់មុន។

---

[33] Tim S. & Friederike N, *The role of bank guarantees in international trade,* 2014, https://voxeu.org/article/role-bank-guarantees-international-trade

ហេតុនេះ ដើម្បីកាត់បន្ថយហានិភ័យនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ធនាគារបានបង្កើតសេវាកម្មពិសេសមួយ ហៅថា "ផលិតផលហិរញ្ញវត្ថុពាណិជ្ជកម្ម" ហើយពេញនិយមជាងគេបំផុតនោះ គឺ "លិខិតឥណទាន"(Letters of credit-LCs)។ តើលិខិតឥណទានផ្តល់ការធានាយ៉ាងដូចម្តេច នៅក្នុងពាណិជ្ជកម្មអន្តរជាតិ?

គំនូសបំព្រួញ៥.១ បង្ហាញពីដំណើរការរបស់ LCs។ ធនាគារប្រទេសនាំចូលបោះផ្សាយ LCs ហើយផ្ញើឱ្យប្រទេសនាំចេញ។ តាមរយៈ LCs ធនាគារសន្យាថា នឹងទូទាត់ឱ្យអ្នកនាំចេញ នៅពេលដែលអ្នកនាំចេញបង្ហាញឯកសារមួយឈុត មានដូចជា វិក្កយបត្រ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម និងឯកសារដឹកជញ្ជូន ជាដើម។ ប៉ុន្តែហានិភ័យនៅតែអាចកើតឡើង ដោយសារ ធនាគារបោះផ្សាយ LCs មិនទូទាត់នៅគ្រាចុងក្រោយបំផុតនោះទេ។ ធនាគារប្រទេសនាំចេញ អះអាងតាមបែបបទ LCs ហើយធានាក្នុងការទូទាត់តែម្តង។ ហេតុនេះ LCs ជានិមិត្តរូប ក្នុងការធានាការទូទាត់សម្រាប់អ្នកនាំចេញ។ ម្យ៉ាងទៀត LCs ជំរុញឱ្យអ្នកនាំចូលត្រូវទូទាត់ប្រាក់ នៅពេលដែលទទួលបានឯកសារពីធនាគារ ហើយត្រូវរង់ចាំទទួលទំនិញជាក្រោយ។ លើសពីនោះទៀត អ្នកនាំចូលអាចតម្រូវឱ្យតម្កល់ប្រាក់នៅធនាគារ ឬដាក់វត្ថុបញ្ចាំ ដើម្បីទទួលបាន LCs ទៀតផង។

**គំនូសបំព្រួញ៥.១: ដំណើរការលិខិតឥណទាន** (LCs)



## ២.៤. មុខងារគ្រប់គ្រងហានិភ័យ ( Risk Management Role )

ការគ្រប់គ្រងហានិភ័យនៅក្នុងវិស័យធនាគារ គឺជា "ផែនការអភិវឌ្ឍន៍ និង ប្រតិបត្តិ" សមស្រប ដើម្បីដោះស្រាយការខាតបង់ដែលអាចកើតមានឡើង ឬ ដើម្បី ការពារតម្លៃទ្រព្យសម្បត្តិរបស់ធនាគារ។ ហេតុនេះ ការគ្រប់គ្រងហានិភ័យ ពាក់ព័ន្ធ នឹងការកំណត់ហានិភ័យឱ្យបានច្បាស់លាស់ ការជះឥទ្ធិពលរបស់វា និងស្វែងរក មធ្យោបាយដើម្បីកាត់បន្ថយ ឬទប់ទល់។ ការគ្រប់គ្រងហានិភ័យ រួមចំណែក ជួយ ថ្នាក់ងារគ្រប់គ្រង ដើម្បីសម្រេចគោលដៅអាជីវកម្ម និងការពារមូលធនវិនិយោគ ដោយកំណត់ វាយតម្លៃ និងដាក់កម្រិតហានិភ័យ ព្រមទាំងធ្វើឱ្យមានប្រសិទ្ធភាពនៃ ដំណើរការអាជីវកម្ម ដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។

## ២.៥. មុខងារជាអ្នកពិគ្រោះយោបល់ហិរញ្ញវត្ថុ ( Financial Advisor Role )

អ្នកពិគ្រោះយោបល់ហិរញ្ញវត្ថុ គឺជាអ្នកជំនាញហិរញ្ញវត្ថុ ដែលផ្តល់សេវា ពិគ្រោះយោបល់ ចំពោះបុគ្គល ឬស្ថាប័ន អំពីស្ថានភាពហិរញ្ញវត្ថុ ដែលអាចជួយ បុគ្គល និងស្ថាប័ននោះ ឱ្យសម្រេចគោលដៅហិរញ្ញវត្ថុបានឆាប់រហ័ស ដោយផ្តល់ឱ្យ អតិថិជននូវយុទ្ធសាស្ត្រ និងមធ្យោបាយ ដើម្បីបង្កើនទ្រព្យ កាត់បន្ថយការចំណាយ និងប្រាក់បំណុល។ ចំពោះបុគ្គល ការផ្តល់យោបល់ស៊ីជម្រៅពាក់ព័ន្ធនឹងការសន្សំ និងបង្កើនទ្រព្យ ដោយបង្ហាញអំពីការវិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុ សមស្របនឹង គោលបំណងរបស់អតិថិជន។ អតិថិជនខ្លះនិយមប្រឈមនឹងហានិភ័យខ្ពស់ ដើម្បី ទទួលបានអត្រាចំណូលខ្ពស់ ប៉ុន្តែ មានអតិថិជនខ្លះទៀតមិនចង់ប្រឈមនឹងហានិភ័យ ខ្ពស់ទេ ទោះជាគាត់ដឹងថា ត្រូវទទួលបានអត្រាចំណូលទាបក៏ដោយ។

ចំពោះក្រុមហ៊ុនវិញ ការពិគ្រោះយោបល់ហិរញ្ញវត្ថុ គឺ អាស្រ័យលើទិសដៅនៃ គម្រោងអភិវឌ្ឍន៍របស់សាជីវកម្ម។ ឧទាហរណ៍ៈ បើក្រុមហ៊ុនកំពុងគិតពិចារណា ដើម្បីពង្រីកប្រតិបត្តិការ ដោយកសាងរោងចក្រថ្មី នោះអ្នកពិគ្រោះហិរញ្ញវត្ថុ ត្រូវវាយ តម្លៃពីកម្រិតនៃផលចំណេញរបស់គម្រោងថ្មី ដោយធ្វើការសិក្សា វិភាគ និងវាយតម្លៃ ហើយផ្តល់លទ្ធផលនៃការវិភាគទៅឱ្យថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនវិញ។ ក្នុងករណីត្រូវ លក់ក្រុមហ៊ុន ឬចងសម្ព័ន្ធគ្នា អ្នកពិគ្រោះយោបល់ ត្រូវវាយតម្លៃក្រុមហ៊ុន ឬធនាគារ

តាមតម្លៃទីផ្សារ ដែលអាចឱ្យគេកំណត់បាន តម្លៃដែលត្រូវលក់ ឬសមាមាត្រភាគរយ ដែលអាចទទួលបាននៅពេលចងសម្ព័ន្ធ។

**២.៦. មុខងាររក្សាសុវត្ថិភាពទ្រព្យសម្បត្តិមានតម្លៃ** ( Safekeeping of valuable Role )

ជាទូទៅ គ្រឹះស្ថានហិរញ្ញវត្ថុ ជាអ្នកថែរក្សា និងទទួលខុសត្រូវផ្លូវច្បាប់ ចំពោះទ្រព្យសម្បត្តិដែលត្រូវថែរក្សា។ ការរក្សាសុវត្ថិភាព គឺជាការទុកដាក់ទ្រព្យសម្បត្តិ ឬវត្ថុមានតម្លៃផ្សេងទៀត នៅទីកន្លែង ដែលមានសុវត្ថិភាព ដោយចេញវិញ្ញាបនបត្របញ្ជាក់ពីអ្នកថែរក្សា ឬ គ្រឹះស្ថានហិរញ្ញវត្ថុ។ វិញ្ញាបនបត្ររក្សាទុកបញ្ជាក់ថា ទ្រព្យសម្បត្តិរបស់បុគ្គល មិនអាចក្លាយជាទ្រព្យសម្បត្តិរបស់អ្នករក្សាទុកបានទេ ហើយស្ថាប័ននោះ ត្រូវប្រគល់ទ្រព្យសម្បត្តិឱ្យម្ចាស់ដើមវិញ នៅពេលមានការស្នើសុំ។ ស្ថាប័នរក្សាទុក ជាធម្មតា យកថ្លៃសេវាពីការថែរក្សានេះ។ ប៉ុន្តែ បុគ្គលម្នាក់ៗ ឬក្រុមហ៊ុននីមួយៗ អាចមានជម្រើសក្នុងការថែរក្សាសុវត្ថិភាពទ្រព្យសម្បត្តិរបស់ខ្លួន ឬមួយរក្សាទុកដោយខ្លួនឯង ឬមួយប្រើប្រាស់សេវាកម្មថែរក្សា ដោយគ្រឹះស្ថានហិរញ្ញវត្ថុ។

**២.៧. មុខងារជាភ្នាក់ងារ**( Agency Role )

មុខងារជាភ្នាក់ងាររបស់ធនាគារ គឺជាប្រតិបត្តិការបម្រើសេវា ឬធ្វើសកម្មភាពតំណាងឱ្យបុគ្គល ឬស្ថាប័នណាមួយ។ មុខងារជាភ្នាក់ងារ អាចប្រែប្រួលអាស្រ័យនឹងការរៀបចំតាមតម្រូវការអតិថិជន។ ធនាគារក៏អាចបំពេញតួនាទីជំនួសអតិថិជន ក្នុងការគ្រប់គ្រងប្រាក់បញ្ញើ និងសម្របសម្រួលចំពោះអតិថិជន ឬធនាគារផ្សេងទៀត ក្នុងការផ្ទេរប្រាក់ ឬសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត និងគាំទ្រដល់ដំណើរការបោះផ្សាយលិខិតឥណទាន ឬ ពន្ធារឥណទានថ្មី ជាដើម។

**២.៨. មុខងារគោលនយោបាយ** ( Policy Role )

មុខងារគោលនយោបាយនៅក្នុងស្ថាប័នមួយ គឺជាការណែនាំទូទៅអំពីបេសកកម្មរបស់ស្ថាប័ន ណែនាំពីយុទ្ធសាស្ត្រអនុវត្ត និងយន្តការត្រួតពិនិត្យ ដើម្បីសម្រេចគោលដៅនៃគោលនយោបាយ។ ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត តែងទទួលយកការណែនាំ និងគោលនយោបាយពីធនាគារកណ្តាល ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវ និងឈានទៅសម្រេចគោលដៅរបស់ធនាគារកណ្តាល ក៏ដូចជា សម្រេចគោលដៅកំណើនសេដ្ឋកិច្ច ផងដែរ។

## ៣. សេវាកម្មធនាគារពាណិជ្ជ

ក្នុងប្រវត្តិសាស្ត្ររីកចម្រើនដ៏យូរលង់របស់ធនាគារ បង្ហាញពីសេវាកម្មផ្សេងៗជាច្រើន ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដែលប្រែប្រួលតាមការវិវត្តិរីកចម្រើននៃសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងសង្គមផងដែរ។ សេវាទាំងនោះ ត្រូវបានបែងចែកជាពីរផ្នែកសំខាន់ៗ គឺសេវាកម្មដែលមានលក្ខណៈជាប្រពៃណីយ៍ និងសេវាកម្មបច្ចុប្បន្ន ដែលត្រូវបានបង្កើត និងអភិវឌ្ឍនាពេលថ្មីៗនេះ ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច សង្គម នាពេលបច្ចុប្បន្ន និងជំរុញសមត្ថភាពប្រកួតប្រជែងផង។

### ៣.១. សេវាកម្មជាប្រពៃណីយ៍

ធនាគារពាណិជ្ជ បានបង្កើត និងបម្រើសេវាកម្មហិរញ្ញវត្ថុ ជាយូរយារណាស់មកហើយ នៅក្នុងប្រវត្តិសាស្ត្រ។ សេវាកម្មហិរញ្ញវត្ថុទាំងនោះ បានវិវត្តិប្រែប្រួលឥតឈប់ឈរ ពីសម័យកាលមួយទៅសម័យកាលមួយទៀត ដើម្បីបំពេញតម្រូវការពាណិជ្ជកម្ម ឬការជួញដូរ នៅក្នុងក្របខ័ណ្ឌកាន់តែទូលំទូលាយ។ ហេតុនេះ ទើបធ្វើឱ្យមានសេវាកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈជាប្រពៃណីយ៍ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។

ក. ការប្តូរប្រាក់ ( Exchange of currency )

សកម្មភាពប្តូរប្រាក់ បានកកើត និងរីកចម្រើនឡើង ស្របនឹងការរីកលូតលាស់ខាងពាណិជ្ជកម្ម ឬកិច្ចការជំនួញ ដែលចល័តពីតំបន់មួយទៅតំបន់មួយ ធ្វើឱ្យពួកគេត្រូវការរូបិយវត្ថុនៅតំបន់នោះ ដើម្បីប្រើប្រាស់ក្នុងការទូទាត់។ ការប្តូរប្រាក់ គឺជាអាជីវកម្មដែលមានអាជ្ញាប័ណ្ណ និងមានសិទ្ធិផ្លូវច្បាប់ក្នុងការប្តូរប្រាក់ ពីប្រភេទរូបិយវត្ថុមួយ ទៅរូបិយវត្ថុមួយទៀត។ បច្ចុប្បន្ន ការប្តូរប្រាក់មានសារៈសំខាន់សម្រាប់កិច្ចការជំនួញធំ-តូច ជាពិសេសពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគពីបរទេស។ មិនតែប៉ុណ្ណោះ ការប្តូរប្រាក់ក៏មានប្រយោជន៍សម្រាប់ភ្ញៀវទេសចរណ៍អន្តរជាតិ ដែលតែងតែធ្វើដំណើរកំសាន្តញឹកញាប់ផងដែរ។

ខ. ផលប័ត្រពាណិជ្ជកម្ម ( Commercial paper )

ផលប័ត្រពាណិជ្ជកម្ម ជាប្រភេទប័ណ្ណបំណុលរយៈពេលខ្លី ដែលជាទូទៅមិនលើសពី២៧០ថ្ងៃ ហើយត្រូវបានបោះផ្សាយដោយធនាគារពាណិជ្ជ ឬ ក្រុមហ៊ុនសាជីវកម្ម ដើម្បីបំពេញតម្រូវការប្រាក់រយៈពេលខ្លី ដូចជា ប្រាក់ខែ គណនីត្រូវសងសន្និធិ និងសងបំណុលរយៈពេលខ្លី ជាដើម។ ការបោះផ្សាយផលប័ត្រពាណិជ្ជកម្មមិនតម្រូវឱ្យមានវត្ថុធានាទេ ប៉ុន្តែ ក្រុមហ៊ុនដែលមានការវាយតម្លៃកម្រិតគុណភាពបំណុលខ្ពស់ ទើបត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

គ. សេវាប្រាក់បញ្ញើសន្សំ និងគណនីចរន្ត ( Savings deposits & Current accounts )

ប្រាក់បញ្ញើសន្សំ គឺជាប្រភេទគណនីប្រាក់បញ្ញើនៅធនាគារពាណិជ្ជ ឬគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលផ្តល់ការប្រាក់នៅក្នុងគណនីដោយផ្ទាល់ និងតម្រូវឱ្យរក្សាបរិមាណប្រាក់អប្បបរិមា នៅក្នុងគណនីតាមការកំណត់របស់ធនាគារនីមួយៗ។ ម្ចាស់គណនីអាចផ្ញើ ឬដកប្រាក់បានតាមតម្រូវការ និងគ្រប់ពេលវេលា។ ជាទូទៅ ប្រាក់បញ្ញើសន្សំផ្តល់ការប្រាក់ទាប ធៀបគណនីផ្សេងទៀត ហើយធនាគារមានសិទ្ធិកែប្រែអត្រាការប្រាក់ ដោយមិនចាំបាច់ជូនដំណឹងជាមុន។

ចំណែកគណនីចរន្តវិញ គឺជាប្រភេទប្រាក់បញ្ញើ ត្រូវបានបង្កើតឡើងសម្រាប់អង្គភាពអាជីវកម្មប្រើប្រាស់ក្នុងការបញ្ជូនផ្ទេរ ដើម្បីទូទាត់តាមគណនីធនាគារ និងទូទាត់ដោយប្រើមូលប្បទានប័ត្រ ឬ ទូទាត់ដោយសាច់ប្រាក់តែម្តង។ ដោយសារគណនីចរន្ត ផ្តល់សេវាផ្សេងៗជាច្រើន ធ្វើគណនីនេះ មិនបានផ្តល់ការប្រាក់ដូចប្រាក់បញ្ញើសន្សំទេ។

ឃ. រក្សាសុវត្ថិភាពទ្រព្យសម្បត្តិមានតម្លៃ ( Safekeeping of valuables )

ដូចបានរៀបរាប់នៅក្នុងមុខងាររក្សាសុវត្ថិភាពទ្រព្យសម្បត្តិមានតម្លៃហើយ ហេតុនេះ ធនាគារត្រូវទទួលបម្រើសេវានេះចំពោះអតិថិជន។

ង. គាំទ្រសកម្មភាពរដ្ឋាភិបាលដោយផ្តល់ឥណទាន (Supporting government activities with credit)

រដ្ឋាភិបាលនៃប្រទេសនីមួយៗ តែងត្រូវការទុនវិយោគលើសពីលទ្ធភាពចំណូលដែលទទួលបាន។ ដើម្បីបំពេញតម្រូវការទុននេះ រដ្ឋាភិបាលបោះផ្សាយប័ណ្ណរតនាគារ ឬសញ្ញាប័ណ្ណ ដើម្បីលក់នៅក្នុងទីផ្សារហិរញ្ញវត្ថុ ឬ ខ្ចីប្រាក់ពីសាធារណជនតាមរយៈទីផ្សារហិរញ្ញវត្ថុ។ ចំណែក ធនាគារពាណិជ្ជវិញ ទទួលប្រាក់បញ្ញើពីសាធារណជន និងប្រមូលផ្តុំបានទៅជាប្រភពទុនយ៉ាងច្រើនសម្បើម និងប្រើប្រាស់មូលធនទាំងនោះក្នុងការផ្តល់ឥណទាន និងវិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយទិញប័ណ្ណរតនាគារ ឬសញ្ញាប័ណ្ណរបស់រដ្ឋាបាល មានន័យថា ធនាគារពាណិជ្ជបានផ្តល់ឱ្យរដ្ឋាភិបាលខ្ចី ឬគាំទ្រសកម្មភាពរបស់រដ្ឋាភិបាល តាមរយៈការផ្តល់ឥណទាន។

## ៣.២. សេវាកម្មបច្ចុប្បន្ន

### ក. ឥណទានសម្រាប់ប្រើប្រាស់ (Consumer loans)

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការផ្តល់ឥណទានសម្រាប់អ្នកប្រើប្រាស់កាន់តែមានសារៈសំខាន់ និងបានរីកចម្រើនឡើងជាបន្តបន្ទាប់។ ឥណទានសម្រាប់អ្នកប្រើប្រាស់ សំខាន់ជាងគេ គឺ ការទិញជឿ ដោយបង់រំលស់ក្នុងរយៈពេលណាមួយ។ ហេតុនេះ ឥណទានសម្រាប់អ្នកប្រើប្រាស់មានប្រយោជន៍សម្រាប់ឧស្សាហកម្មផង និងអ្នកប្រើប្រាស់ផង។ ចំពោះឧស្សាហកម្ម ការផ្តល់ឥណទានប្រភេទនេះ ជួយជំរុញឱ្យការលក់ផលិតផលបានកាន់តែច្រើន ពីព្រោះ ទោះបីជាអតិថិជនមិនមានប្រាក់គ្រប់គ្រាន់ក៏ដោយ ក៏អាចទិញទំនិញបានដោយបង់រំលស់។ រីឯអ្នកប្រើប្រាស់វិញ មានផលប្រយោជន៍ក្នុងការលើកស្ទួយជីវភាពរស់នៅ នាពេលបច្ចុប្បន្នឱ្យបានប្រសើរឡើង ដោយប្រើប្រាស់ចំណូលនាពេលអនាគត ឬអាចនិយាយថា ឥណទានសម្រាប់អ្នកប្រើប្រាស់ ជួយលើកកម្ពស់ស្តង់ដាជីភាពរស់នៅ នាពេលបច្ចុប្បន្នឱ្យប្រសើរឡើង ដោយប្រើប្រាស់ចំណូលនាពេលអនាគត។

### ខ. ពិគ្រោះយោបល់ហិរញ្ញវត្ថុ (Financial Advice)

ក្នុងករណីជាច្រើន ដែលយើងតែងជួបការលំបាក ក្នុងការសម្រេចចិត្ត ដើម្បីប្រើប្រាស់ទុនសម្រាប់វិនិយោគនាពេលអនាគត។ នៅក្នុងសេដ្ឋកិច្ច-សង្គម មានគម្រោង

អាជីវកម្ម និងការវិនិយោគ ជាច្រើន ដែលធ្វើឱ្យយើងមានការលំបាកក្នុងការជ្រើសរើស។ ហេតុនេះ ការពិគ្រោះយោបល់ហិរញ្ញវត្ថុ ជាមួយស្ថាប័នជំនាញ គឺជាការចាំបាច់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ ការពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញ រួមមានៈ ផែនការសោធន ការវិនិយោគ ឬសន្សំ ទិញទ្រព្យសម្បត្តិ ឬទិញផ្ទះដោយបង់រំលស់ ជាដើម។

**គ. ការគ្រប់គ្រងសាច់ប្រាក់** ( Cash Management )

ការគ្រប់គ្រងសាច់ប្រាក់ គឺជាដំណើរការនៃការគ្រប់គ្រងលំហូរសាច់ប្រាក់ ដែលមានសារៈសំខាន់សម្រាប់បុគ្គល និងក្រុមហ៊ុន។ លំហូរសាច់ប្រាក់ ត្រូវបានបែងចែកជាពីរផ្នែក គឺ លំហូរចូល និងលំហូរចេញនៃសាច់ប្រាក់។ គោលដៅចំបងនៃការគ្រប់គ្រងសាច់ប្រាក់ គឺធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងលំហូរចូល និងលំហូរចេញនៃសាច់ប្រាក់។ បើធ្វើបានបែបនេះ មានន័យថា "មានសាច់ប្រាក់ល្មមគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការ"។ បើលំហូរចូលសាច់ប្រាក់ធំជាងលំហូរចេញសាច់ប្រាក់ គេហៅថា អតិរេកសាច់ប្រាក់ មានន័យថា ក្រុមហ៊ុននៅសល់សាច់ប្រាក់ ដោយមិនបានប្រើប្រាស់វាក្នុងការវិនិយោគឱ្យអស់លទ្ធភាព ដើម្បីទទួលបានផលប្រយោជន៍ដល់កម្រិតអតិបរមា។ ផ្ទុយទៅវិញ បើលំហូរចូលសាច់ប្រាក់តូចជាងលំហូរចេញសាច់ប្រាក់ គេហៅថា ឱនភាពសាច់ប្រាក់ បានន័យថា ក្រុមហ៊ុនខ្វះសាច់ប្រាក់ មិនអាចបំពេញតម្រូវការបានគ្រប់គ្រាន់។ ហេតុនេះ ក្រុមហ៊ុនត្រូវស្វែងរកប្រភពទុនបន្ថែម ដើម្បីបំពេញតម្រូវការឱ្យបានគ្រប់គ្រាន់ ជៀសវាងការរាំងស្ទះដល់ដំណើរការអាជីវកម្ម។

**ឃ. ជួលឧបករណ៍សម្ភារៈ** ( Equipment Leasing )

ការជួលសម្ភារៈ គឺជាការផ្តល់សិទ្ធិប្រើប្រាស់ទ្រព្យសម្ភារៈ ដូចជា ម៉ាស៊ីន យានជំនិះ និងឧបករណ៍សម្ភារៈផ្សេងទៀត ទៅឱ្យបុគ្គលម្នាក់ទៀត ឬក្រុមហ៊ុនណាមួយ។ ធ្វើបែបនេះ គេអាចជៀសវាងបាននូវការវិនិយោគមូលធនទៅលើឧបករណ៍សម្ភារៈ។ ចំពោះកម្មសិទ្ធិឧបករណ៍សម្ភារៈវិញ ស្ថិតនៅក្នុងដៃរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ឬក្រុមហ៊ុនជួលឧបករណ៍សម្ភារៈទាំងនោះ។ ចំណែក អ្នកជួលវិញ ទទួលសិទ្ធិប្រើប្រាស់ជាក់ស្តែង ក្នុងរយៈពេលកំណត់មួយ។

**ង. ឥណទានមូលធនចាប់ផ្តើម** ( Venture Capital Loans )

គំនិតអាជីវកម្មដែលអាចទទួលបានផលចំណេញ ដោយមានផែនការអាជីវកម្មល្អ គឺជាកត្តាដ៏មានសារៈសំខាន់ណាស់ ប៉ុន្តែ ពួកគេមិនទាន់បានអនុវត្តជាក់ស្តែង និងទទួលបានលទ្ធផលបែបណានៅឡើយទេ។ ដើម្បីចាប់ផ្តើមដំណើរការអាជីវកម្ម ដែលត្រូវការចាំបាច់នូវធនធានមនុស្ស ប្រកបដោយសមត្ថភាព និងសម្ភារៈបរិក្ខារ ហើយបញ្ហាសំខាន់បំផុតនោះ គឺ តម្រូវទុនវិនិយោគ ដែលអាចមានជម្រើសពីប្រភពផ្សេងៗ។ ប្រសិនបើ ធនាគារពាណិជ្ជយល់ព្រមផ្តល់មូលធន ដើម្បីចាប់ផ្តើមដំណើរការអនុវត្តគម្រោងអាជីវកម្មថ្មីបែបនេះ គេហៅថា ឥណទានមូលធនចាប់ផ្តើម។ ឥណទានមូលធនចាប់ផ្តើម មានលក្ខណៈប្រថុយប្រថានខ្ពស់ ដោយសារជាគម្រោងថ្មី គ្រាន់តែជាគំនិតផ្តួចផ្តើម និងមិនទាន់មានបទពិសោធន៍ទទួលជោគជ័យនៅឡើយ។ ប៉ុន្តែ គេសង្ឃឹមថា គម្រោងនោះនឹងទទួលបានជោគជ័យ ជាមួយនឹងផលចំណេញខ្ពស់។

**ច. លក់ផលិតផលធានារ៉ាប់រង** ( Selling Insurance Products )

នៅបណ្តាប្រទេសអភិវឌ្ឍន៍ ធនាគារពាណិជ្ជត្រូវបានអនុញ្ញាតឱ្យលក់ផលិតផលធានារ៉ាប់រង ដូចក្រុមហ៊ុនធានារ៉ាប់រងដែរ ដូចជា ធានារ៉ាប់រងសុខភាព ធានារ៉ាប់រងជីវិត ធានារ៉ាប់រងអគ្គីភ័យ ធានារ៉ាប់រងរថយន្ត ជាដើម។ ប៉ុន្តែ នៅកម្ពុជា ច្បាប់មិនអនុញ្ញាតបែបទេ ដោយបែងចែកមុខងារ និងតួនាទី ដាច់ពីគ្នា រវាងធនាគារពាណិជ្ជ និងក្រុមហ៊ុនធានារ៉ាប់រង។

**ឆ. ការធានាទិញមូលប័ត្រ និងជើងសារជំនួញ** ( Security underwriting and Brokerage services )

ក៏ដូចការលក់ផលិតផលធានារ៉ាប់រងដែរ ធនាគារពាណិជ្ជ ត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មនៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយបំពេញតួនាទីជាអ្នកធានាទិញមូលប័ត្រ ជួញដូរមូលប័ត្រ និងជើងសារជំនួញ ដូចក្រុមហ៊ុនមូលប័ត្រដែរ។ ប៉ុន្តែ នៅកម្ពុជា ច្បាប់មិនអនុញ្ញាតឱ្យធនាគារពាណិជ្ជ និងក្រុមហ៊ុនមូលប័ត្រ បំពេញតួនាទីច្របូកច្របល់គ្នាទេ ពោលគឺ បែងចែកដាច់ពីគ្នារវាងតួនាទីរបស់ធនាគារពាណិជ្ជ និងក្រុមហ៊ុនមូលប័ត្រ។

ជ. មូលនិធិទៅវិញទៅមក និងអនុសំវច្ឆរត្ត (Mutual funds and Annuities)

មូលនិធិទៅវិញទៅមក គឺជាមធ្យោបាយគៀរគរហិរញ្ញវត្ថុ ដោយបង្កើតជាមូលនិធិមួយ ដើម្បីប្រមូលទុនពីវិនិយោគិនជាច្រើន និងវិនិយោគទុនទាំងនោះទៅលើមូលប័ត្រ មានដូចជា ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ ឧបករណ៍ទីផ្សាររូបិយវត្ថុ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ មូលនិធិទៅវិញទៅមក ត្រូវបានធ្វើប្រតិបត្តិការ ដោយអ្នកគ្រប់គ្រងជំនាញ ដែលនឹងប្រើប្រាស់មូលធនទាំងនោះ ដើម្បីវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ហើយសង្ឃឹមថា នឹងទទួលបានផលចំណេញមូលធន ឬចំណូលសម្រាប់វិនិយោគិនដែលជាម្ចាស់មូលនិធិ។ មូលនិធិទៅវិញទៅមក ផ្តល់ឱ្យវិនិយោគិនម្នាក់ៗ អាចចូលមើលការគ្រប់គ្រងមូលធនវិនិយោគបាន ដូចជា ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ និងមូលប័ត្រផ្សេងទៀត។ ហេតុនេះ ម្ចាស់ភាគហ៊ុនម្នាក់ៗ ត្រូវចូលរួមចំណែកទទួលស្មើៗគ្នា ជាផលចំណេញ ឬខាត នៃមូលធនវិនិយោគ[34]។

ចំណែក អនុសំវច្ឆរត្ត ឬធនលាភវិញ គឺជាកិច្ចសន្យារវាងបុគ្គល និងក្រុមហ៊ុនធានារ៉ាប់រង ដែលបុគ្គលនោះត្រូវចំណាយសរុប ឬចំណាយជាសេរី ហើយត្រូវទទួលការទូទាត់សងវិញ ជារៀងរាល់គ្រា ដោយចាប់ពីពេលណាមួយ នៅពេលអនាគត។ មានន័យថា បុគ្គលនោះត្រូវបង់ឱ្យក្រុមហ៊ុនធានារ៉ាប់រងលើសេវាសោធន ហើយនឹងទទួលបានការទូទាត់សងវិញនូវប្រាក់ចូលនិវត្តន៍ (ជាទូទៅជារៀងរាល់ខែ) នៅពេលដល់អាយុចូលនិវត្តន៍។

ឈ. សេវាធនាគារជំនួញ (Merchant Banking Services)

ធនាគារជំនួញ សំដៅលើគ្រឹះស្ថានហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការដោយធានាទិញមូលប័ត្រ ផ្តល់សេវាឥណទាន ពិគ្រោះយោបល់ហិរញ្ញវត្ថុ និងផ្តល់សេវារៃអង្គាសឬបង្កើនទុនសម្រាប់សាជីវកម្មធំៗ និងបុគ្គលដែលមានទ្រព្យធនច្រើន។ ខុសពីធានាគារតូចៗ ឬ ធនាគារពាណិជ្ជ ធនាគារជំនួញមិនបម្រើសេវាហិរញ្ញវត្ថុទូទៅ ចំពោះសាធារណជនទេ។

---

34 *What Is a Mutual Fund*? https://www.investopedia.com/terms/m/mutualfund.asp

## ៤. និន្នាការប្រែប្រួលរបស់ធនាគារ

### ៤.១. ការរីកសាយនៃសេវា (Service Proliferation)

ការរីកសាយនៃសេវា គឺជាការបង្កើតសេវាថ្មីៗ ទំនើបបន្ថែមទៀត ដើម្បីបំពេញតម្រូវការរីកចម្រើននៃសេដ្ឋកិច្ច-សង្គម ជាពិសេស សេវាកម្មហិរញ្ញវត្ថុ ដែលភ្ជាប់ជាមួយនឹងការវិវត្តិរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទំនើប នាពេលបច្ចុប្បន្ន។ ការបង្កើតសេវាកម្មនេះ នឹងជំរុញឱ្យមានលទ្ធភាពក្នុងការប្រកួតប្រជែង កាន់តែខ្លាំងក្លាបន្ថែមទៀត។

### ៤.២. ការប្រកួតប្រជែង (Competition)

នៅពេលដែលការរីកសាយនៃសេវាកាន់តែរីកចម្រើនឡើង នោះនឹងជំរុញឱ្យការប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើង។ ផ្ទុយទៅវិញ នៅពេលដែលការប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើង នោះនឹងជំរុញឱ្យការបង្កើតសេវាថ្មី ទំនើប កាន់តែច្រើន ដើម្បីឈររឹងមាំក្នុងការប្រកួតប្រជែង។ បើមិនដូច្នោះទេ អង្គភាពអាជីវកម្មនឹងជួលរលំដោយសារការប្រកួតប្រជែង។ ជារួម ការប្រកួតប្រជែង ផ្អែកលើកត្តាសំខាន់ៗ ដូចជា ប្រភេទសេវាកម្ម គុណភាពសេវាកម្ម និងថ្លៃសេវាកម្ម ព្រមទាំងជំនឿទុកពីអតិថិជនផងដែរ។

### ៤.៣. បដិប្បញ្ញត្តិ (Deregulation)

ច្បាប់ និងបទប្បញ្ញត្តិនៅក្នុងវិស័យធនាគារ បានវិវត្តិប្រែប្រួលពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត។ ក្នុងដំណាក់កាលដំបូង ច្បាប់មានភាពតឹងរឹងដោយមិនអនុញ្ញាតឱ្យធនាគារមានសិទ្ធិសេរីភាពច្រើនទេ ពោលគឺ ត្រូវអនុវត្តតាមខ្លឹមសារដែលមានចែងនៅក្នុងច្បាប់។ ជាក់ស្តែង អត្រាការប្រាក់ត្រូវបានកំណត់ដោយច្បាប់ ហើយបង្ខំឱ្យធនាគារត្រូវតែអនុវត្ត។ ឧទាហរណ៍ៈ ច្បាប់បានដាក់កម្រិតអត្រាការប្រាក់ "មិនឱ្យទាបជាងកម្រិតអប្បបរិមា និងមិនឱ្យខ្ពស់ជាងកម្រិតអតិបរិមា" ហើយធនាគារពាណិជ្ជ មិនអាចកំណត់អត្រាការប្រាក់ទាបជាងអត្រាអប្បបរិមា និងមិនឱ្យខ្ពស់ជាងកម្រិតអតិបរិមា។ ប៉ុន្តែ ដោយយល់ឃើញថា ការដាក់កម្រិតអប្បបរិមា មិនមានប្រសិទ្ធភាពក្នុងការអនុវត្តទេ ពីព្រោះ នៅពេលដែលអត្រាការប្រាក់កាន់តែទាប វានឹងជំរុញឱ្យការវិនិយោគកាន់តែខ្លាំងក្លាឡើង។ ហេតុនេះ ខ្លឹមសារច្បាប់ត្រូវបានកែសម្រួល ដោយលុបចោលកម្រិតអប្បបរិមានៃអត្រាការប្រាក់ ប៉ុន្តែ នៅរក្សាទុកកម្រិត

អតិបរិមាឱ្យនៅដដែល។ អំណឹះក្រោយមក គេសង្កេតឃើញថា ការដាក់ពិដានអត្រាការប្រាក់ មិនអាចអនុវត្តបន្តទៀតទេ ពីព្រោះ ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត បានប្រឹងប្រែងអស់លទ្ធភាពហើយ ក្នុងការគៀរគរមូលធននៅក្នុងស្រុកតាមរយៈការទទួលប្រាក់បញ្ញើពីសាធារណជន ប៉ុន្តែ នៅតែមិនអាចបំពេញតម្រូវការវិនិយោគបាន ធ្វើឱ្យអត្រាការប្រាក់កើនឡើង។ ហេតុនេះ ទោះបីជាច្បាប់បានដាក់កម្រិតពិដានអត្រាការប្រាក់ ដោយមិនឱ្យធនាគារបង្កើនការប្រាក់លើសពីច្បាប់កំណត់ក៏ដោយ ក៏ការផ្តល់ឲ្យណទានមិនអាចកើនឡើងបានដែរ ដោយសារមិនមានទុនគ្រប់គ្រាន់នៅក្នុងសេដ្ឋកិច្ច-សង្គម។ ដូច្នេះ ការដាក់ពិដានអត្រាការប្រាក់ ក៏ត្រូវបានលុបចោល ដោយទុកឱ្យទីផ្សារ ឬការផ្គត់ផ្គង់ និងតម្រូវការ ជាអ្នកកំណត់អត្រាការប្រាក់វិញ។

### ៤.៤. ការកើនឡើងនៃថ្លៃមូលធន (Rising funds costs)

ការអនុញ្ញាតឱ្យទីផ្សារ មានតួនាទីកំណត់អត្រាការប្រាក់ ធ្វើឱ្យអត្រាការប្រាក់នៅលើទីផ្សារអាចនឹងកើនឡើងខ្ពស់ ដែលអាចធ្វើឱ្យកើនឡើងថ្លៃមូលធនផងដែរ។ ជាទូទៅ ថ្លៃមូលធន គឺជាការប្រាក់ និងថ្លៃសេវាផ្សេងៗទៀត ដែលត្រូវចំណាយនៅពេលដែលទទួលបានឥណទាន។ម៉្យាងទៀត ថ្លៃមូលធនក៏អាចជាថ្លៃឱកាសផងដែរ។ ឧទាហរណ៍ៈ អ្នកមានទុនវិនិយោគផ្ទាល់ខ្លួន មិនមែនមានន័យថា មិនមានថ្លៃមូលធនទេ។ ក្នុងករណីនេះ ថ្លៃមូលធន គឺជា "ថ្លៃឱកាស" ដែលម្ចាស់ទុនអាចប្រើប្រាស់ទុនទាំងនោះ ដោយផ្ញើនៅគណនីសន្សំ ឬសេវាសន្សំផ្សេងទៀតរបស់ធនាគារ ដើម្បីទទួលបានការប្រាក់។ បើការវិនិយោគ មិនទទួលបានចំណូលខ្ពស់ជាងអត្រាការប្រាក់នៅធនាគារទេ នោះគេមិនចាំបាច់ប្រថុយនឹងហានិភ័យ ក្នុងការវិនិយោគឡើយ។

### ៤.៥. ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់ (Increased interest rate sensitivity)

អត្រាការប្រាក់កើនឡើងខ្ពស់ ជាឧបសគ្គរាំងដល់ការវិនិយោគ ឬដោយសារនៅក្នុងសេដ្ឋកិច្ច-សង្គម មិនមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការ។ ក្នុងស្ថានភាពបែបនេះ ធនាគារកណ្តាលត្រូវធ្វើអន្តរាគមន៍ ដោយបញ្ចេញសាច់ប្រាក់ដើម្បីផ្គត់ផ្គង់នៅក្នុងចរាចរណ៍ឱ្យបានគ្រប់គ្រាន់ ពីព្រោះ បើមិនធ្វើដូច្នោះទេ វានឹងធ្វើឱ្យមានដំណើរធ្លាក់ចុះខ្លាំងនៃសេដ្ឋកិច្ច (Econmic recession)។

### ៤.៦. បច្ចេកវិទ្យា (Technology)

ដូចបានរៀបរាប់ខាងលើ បច្ចេកវិទ្យាជួយឱ្យការបង្កើតសេវាថ្មីទំនើបបន្ថែមទៀត ជំរុញការប្រកួតប្រជែងឱ្យកាន់តែខ្លាំងក្លាឡើង និងសម្របសម្រួលឱ្យការងារបម្រើសេវា កាន់តែមានភាពងាយស្រួល រលូន ឆាប់រហ័ស ថ្លៃសេវាថោក និងប្រកបដោយសុវត្ថិភាព។ បើគ្មានបច្ចេកវិទ្យាទេ ការសន្សំ ឥណទាន និងសេវាទូទាត់ ឬបញ្ជូនផ្ទេរ នឹងជួបការលំបាកស្មុគ្រស្មាញ ហើយធ្វើឱ្យរាំងស្ទះដល់ដំណើរការប្រតិបត្តិរបស់អង្គភាពអាជីវកម្ម។

### ៤.៧. ការពង្រឹង និងពង្រីកទៅតាមទីតាំងភូមិសាស្ត្រ (Consolidation and geographic expansion)

នៅពេលដែលនិន្នាការនៃសេវាកម្ម ដែលបានរៀបរាប់ខាងលើ ទទួលបានជោគជ័យ នោះនឹងធ្វើឱ្យធនាគារកាន់តែរឹងមាំ មានទំហំកាន់តែធំ ដែលមានលទ្ធភាពកាន់តែខ្ពស់ក្នុងការប្រកួតប្រជែង។ ហេតុនេះ ធនាគារក៏មានឱកាសពង្រីកអាជីវកម្មរបស់ខ្លួន ដោយបង្កើតសាខាថ្មីបន្ថែមនៅក្នុងស្រុក និងនៅក្រៅប្រទេសថែមទៀត។ ម៉្យាងទៀត ដើម្បីឱ្យធនាគារមានភាពរឹងមាំកាន់តែឆាប់រហ័ស ដើម្បីជំរុញការប្រកួតប្រជែង ធនាគារពីរ ឬច្រើនអាចចងសម្ព័ន្ធគ្នា ដើម្បីបង្កើតបានជាធនាគារធំមួយ មានភាពរឹងមាំ បង្កើនសមត្ថភាពប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើង ទាំងនៅក្នុងស្រុក និងអន្តរជាតិ។ នេះជានិន្នាការ ដែលតែងតែកើតឡើងនៅក្នុងប្រទេសអភិវឌ្ឍន៍ជាយូរយារណាស់មកហើយ ដូចជា នៅចក្រភពអង់គ្លេស ជប៉ុន និងសហរដ្ឋអាមេរិក ជាដើម។

### ៤.៨. ការកើនឡើងនូវហានិភ័យក្ស័យធន (Increased risk of failure)

ជាលទ្ធផល និន្នាការនៃការវិវត្តិខាងលើ ក្រៅពីភាពរឹងមាំដែលទទួលបានដោយធនាគារធំៗមួយចំនួន ក៏មានធនាគារតូចៗ ដែលមិនអាចពង្រឹង និងពង្រីកខ្លួនបាន ហើយមិនអាចស្វែងរកដៃគូដើម្បីចងសម្ព័ន្ធបាន ធ្វើឱ្យធនាគារតូចៗទាំងនោះ ប្រឈមនឹងហានិភ័យខ្ពស់ និងទទួលបរាជ័យនៅក្នុងអាជីវកម្ម មិនអាចបន្តដំណើរទៅមុខទៀតបាន ហើយទីបំផុត បង្ខំចិត្តត្រូវប្រកាសក្ស័យធន៕

# មេរៀនទី៦

## គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និង តួនាទី

## ( International Financial Institutions and Roles )

### ១. សញ្ញាណទូទៅ

ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្នុងប្រទេសនីមួយៗ ដែលបានបម្រើសេវា និងបំពេញតួនាទីដ៏មានសារៈសំខាន់ក្នុងការគៀរគរមូលធន ដើម្បីគាំទ្រដល់ការវិនិយោគ ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយស្តង់ដាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនោះ ក៏មានគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិជាច្រើនត្រូវបានបង្កើតឡើង ក្នុងគោលដៅផ្សេងៗគ្នា និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្របន្ថែមទៀតដល់ប្រទេសនានា ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងរួមចំណែកយ៉ាងសំខាន់ ក្នុងការដោះស្រាយបញ្ហាប្រឈមនានា នៅក្នុងប្រទេសនីមួយៗ។ គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗ រួមមាន៖ ធនាគារពិភពលោក (World Bank-WB) មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Funds-IMF) ធនាគារអភិវឌ្ឍន៍អាស៊ី Asian Development Bank-ADB) ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank-AIIB) និងធនាគារអភិវឌ្ឍន៍ថ្មី (New Development Bank-NDB) របស់ BRICS[35]។

### ២. ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ

ធនាគារពិភពលោក (WB) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលគេតែងហៅថា ស្ថាប័ន Bretton Woods ដោយសារជាទីកន្លែងបង្កើតស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពីរ ក្រោយពីសន្និសីទរូបិយវត្ថុ ដែលមានគណៈប្រតិភូចំនួន៤៤ប្រទេសចូលរួម នៅខែកក្កដា ឆ្នាំ១៩៤៤។ WB និង IMF គឺជាសសរស្តម្ភទ្វេរនៃអន្តររដ្ឋាភិបាលដែលគាំទ្ររចនាសម្ព័ន្ធសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់ហិរញ្ញវត្ថុពិភពលោក។ ស្ថាប័ន

[35] BRICS រួមមាន៥ប្រទេស គឺ Brazil, Russia, India, China and South Africa.

ទាំងពីរភ្ជាប់ខ្លួនទៅនឹងបញ្ហាសេដ្ឋកិច្ច និងយកចិត្តទុកដាក់ក្នុងការពង្រឹង និងពង្រីកសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក។ បុគ្គលិកស្ថាប័នទាំងពីរ តែងលេចមុខនៅក្នុងសន្និសីទអន្តរជាតិ ដោយលើកឡើងក្នុងភាសាតែមួយ អំពីបញ្ហាសេដ្ឋកិច្ច និងការអភិវឌ្ឍ ឬរាយការណ៍តាមសារព័ត៌មាន ស្តីពីការចរចាពាក់ព័ន្ធនឹងការសម្របសម្រួលកម្មវិធីសេដ្ឋកិច្ចជាមួយរដ្ឋមន្ត្រីហិរញ្ញវត្ថុ ឬជាមួយនឹងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលផ្សេងទៀត។ ស្ថាប័នទាំងពីរមានការិយាល័យកណ្តាល នៅវ៉ាស៊ីនតោន និងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរួមគ្នា ដោយមានអ្នកសារព័ត៌មានផ្សព្វផ្សាយយ៉ាងទូលំទូលាយ។

ទោះជាយ៉ាងនេះក្តី WB និង IMF ក៏ចំណុចខុសគ្នាផងដែរ។ ភាពខុសគ្នាជាសំខាន់នោះគឺ៖ WB គឺជាស្ថាប័នអភិវឌ្ឍន៍ ចំណែក IMF គឺជាស្ថាប័នសហប្រតិបត្តិការដែលខិតខំការពារប្រព័ន្ធទូទាត់ និងវិក្កយបត្រត្រឹមត្រូវ រវាងរដ្ឋ និងរដ្ឋ។ ស្ថាប័ននីមួយៗ មានគោលបំណង រចនាសម្ព័ន្ធ និងទទួលបានមូលនិធិ ដែលមានប្រភពខុសគ្នា ជួយប្រទេសជាសមាជិកទៅលើផ្នែកផ្សេងគ្នា ហើយប្រឹងប្រែង ដើម្បីសម្រេចគោលដៅផ្សេងគ្នា និងតាមវិធីសាស្ត្រផ្សេងគ្នា[36]។

## ២.១. តួនាទី និងរចនាសម្ព័ន្ធរបស់ធនាគារពិភពលោក

ធនាគារពិភពលោក (WB) ត្រូវបានបង្កើតឡើង តាមរយៈកិច្ចព្រមព្រៀង Bretton Woodsនៅឆ្នាំ១៩៤៤។ គោលបំណងដំបូងរបស់ WB គឺជួយកសាងឡើងវិញ បណ្តាប្រទេសនៅអឺរ៉ុប ដែលត្រូវបានបំផ្លាញដោយសង្គ្រាមលោកលើកទី២។ ការផ្តល់ឱ្យខ្ចីដំបូងគេ គឺបណ្តាប្រទេសនៅអឺរ៉ុប ជាពិសេស ប្រទេសបារាំង ដែលទទួលបានកម្ចី នៅឆ្នាំ១៩៤៧។ បន្ទាប់មក មានសកម្មភាពផ្សេងៗទៀត ជាច្រើនលើសពីតួនាទីគាំទ្របណ្តាប្រទេស ដែលត្រូវបានបំផ្លាញដោយសង្គ្រាម។ ហេតុនេះ WB បានបង្វែរការយកចិត្តទុកដាក់ ដោយបំពេញតម្រូវការរបស់ប្រទេសជាសមាជិក ដូចជា នៅអាមេរិកឡាទីន អាហ្វ្រិក និងអាស៊ី ជាដើម។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង៦០ ការផ្តល់ហិរញ្ញប្បទានទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗជាច្រើន ដូចជាកសាងទំនប់ បណ្តាញអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ និងផ្លូវថ្នល់ ដែលជាគោលដៅ

---

[36] David D., *The IMF and the World Bank, How Do They Differ?*
https://www.imf.org/external/pubs/ft/exrp/differ/differ.htm

អាទិភាពរបស់ WB។ ម្យ៉ាងទៀត សកម្មភាពការងារនៃជំនួយការបច្ចេកទេស ដែលបានផ្តល់ឱ្យប្រទេសនីមួយៗ នូវធនធានបច្ចេកទេស និងការបណ្តុះបណ្តាលចាំបាច់មួយចំនួន ដើម្បីប្រើប្រាស់ឥណទានរបស់ធនាគារ ប្រកបដោយប្រសិទ្ធភាព។ ជារួម WB មានគោលបំណងរួម គឺ ជំរុញសេដ្ឋកិច្ច និងសង្គម នៅប្រទេសកំពុងអភិវឌ្ឍន៍ឱ្យមានការរីកចម្រើន ដោយបង្កើនទិន្នផលផលិតកម្ម ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ WB បានបង្វែរការយកចិត្តទុកដាក់ ទៅលើការកាត់ឫសគល់នៃភាពក្រីក្រ។ ហេតុនេះ គម្រោងអភិវឌ្ឍន៍នានា បានផ្តោតលើគោលដៅប្រជាពលរដ្ឋជាសំខាន់ ដូចជា គម្រោងពាក់ព័ន្ធនឹងផលិតផលអាហារ ការអភិវឌ្ឍជនបទនិងទីក្រុង ប្រជាភិវឌ្ឍន៍ សុខភាព និងអាហារបំប៉ន ត្រូវបានរៀបចំឡើង ដើម្បីឱ្យជំនួយ ឬកម្ចីទាំងនោះ ផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្រីក្រដោយផ្ទាល់។ ប្រតិបត្តិការរបស់ WB ក៏បានយកចិត្តទុកដាក់ទៅលើការកំណត់ និងជំរុញគោលនយោបាយ យុទ្ធសាស្រ្ត និងពង្រឹងស្ថាប័ន ដែលជួយប្រទេសនីមួយៗឱ្យទទួលបានជោគជ័យ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ WB បានបន្តពង្រីកការយកចិត្តទុកដាក់ទៅលើបញ្ហាអភិវឌ្ឍសង្គមដូចជា វិស័យអប់រំ ទំនាក់ទំនង អភិរក្សវប្បធម៌ និងអភិបាលកិច្ចល្អជាដើម។ ជាលទ្ធផលនៃការពង្រីកប្រតិបត្តិការនេះ ធ្វើឱ្យ WB មានអ្នកជំនាញជាច្រើន ដូចជា វិស្វករ សេដ្ឋវិទូ អ្នកវិភាគហិរញ្ញវត្ថុ អ្នកជំនាញខាងនយោបាយសាធារណៈ អ្នកជំនាញក្នុងវិស័យនានា និងអ្នកវិទ្យាសាស្រ្តសង្គម ជាដើម ដើម្បីជំរុញសកម្មភាពប្រតិបត្តិការកាន់តែខ្លាំងក្លាឡើង និងប្រកបដោយប្រសិទ្ធភាព។

នៅពេល WB ត្រូវបានបង្កើតឡើងដំបូង មានស្ថាប័នពីរជាចំណុះ គឺធនាគារអន្តរជាតិសម្រាប់កសាងឡើងវិញ និងអភិវឌ្ឍន៍ដែលមានតួនាទីផ្តល់ឥណទាន និងជំនួយ និងទី២គឺ សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ ដែលមានតួនាទីផ្តល់ឥណទានដោយមានការប្រាក់ទាប ឬគ្មានការប្រាក់ និងផ្តល់ជំនួយ សម្រាប់ប្រទេសដែលមានចំណូលទាប។ បន្ទាប់មក WB ធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នបីផ្សេងទៀត នៅក្នុងក្រុម WB មានដូចជា៖ ទី១ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation-IFC) ដែលមានតួនាទីផ្តល់ការគាំទ្រទៅលើការវិនិយោគ ផ្តល់

មតិយោបល់កែលម្អ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងរដ្ឋាភិបាល។ ទី២ ភ្នាក់ងារធានាការវិនិយោគពហុភាគី (Multilateral Investment Guarantee Agency (MIGA) មានតួនាទីក្នុងការធានា "អ្នកផ្តល់ឱ្យខ្ចី" និងវិនិយោគិន ទប់ទល់នឹងហានិភ័យនយោបាយ ដូចជា សង្គ្រាម និងភាពវឹកវរនៅក្នុងសង្គម ជាដើម។ ទី៣ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ដោះស្រាយទំនាស់វិនិយោគ (International Centre for the Settlement of Investment Disputes-ICSID) មានតួនាទីក្នុងការដោះស្រាយទំនាស់វិនិយោគ រវាងវិនិយោគិន ជាមួយប្រទេស ឬរដ្ឋាភិបាល។

បច្ចុប្បន្ននេះ ក្រុមធនាគារពិភពលោក (World Bank Groups) ធ្វើការងារស្ទើរគ្រប់វិស័យ ដែលសារៈសំខាន់ក្នុងការប្រយុទ្ធទប់ទល់នឹងភាពក្រីក្រ គាំទ្រកំណើនសេដ្ឋកិច្ច និងទទួលបានផលប្រកបដោយស្ថិរភាព និងគុណភាពជីវិតរស់នៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្រុម WB បានទទួលស្គាល់ថា មានកត្តាជាច្រើនដែលឈានទៅទទួលជោគជ័យ ដូចជា ស្ថាប័នប្រកបដោយប្រសិទ្ធភាព មានគោលនយោបាយត្រឹមត្រូវ បន្តរៀនសូត្រ ឬបណ្តុះបណ្តាល តាមរយៈការវាយតម្លៃ និងចែករំលែកចំណេះដឹង និងភាពជាដៃគូ រួមទាំងវិស័យឯកជនផង។ ក្រុម WB មានបទពិសោធន៍ ដោយមានទំនាក់ទំនងរយៈពេលវែងជាមួយប្រទេសជាសមាជិកជាង១៨០ ហើយបានចាប់អារម្មណ៍ចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការអភិវឌ្ឍ ដែលជាបញ្ហាប្រឈមសកល ត្រូវដោះស្រាយរួមគ្នា។ ឧទាហរណ៍ៈ បញ្ហាបម្រែបម្រួលអាកាសធាតុ បញ្ហាជំងឺឆ្លង និងទេសន្តប្រវេសន៍ដោយបង្ខំ ដែលធ្វើឱ្យក្រុម WB បំពេញតួនាទីឈានមុខគេ ដោយសារក្រុម WB អាចប្រជុំពិភាក្សាជាមួយបណ្តាប្រទេសជាសមាជិក និងដៃគូទូលំទូលាយផ្សេងទៀត ដើម្បីស្វែងរកដំណោះស្រាយឱ្យបានសមស្រប[37]។

## ២.២. តួនាទី និងរចនាសម្ព័ន្ធរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

IMF ត្រូវបានបង្កើតឡើង ដើម្បីជួយស្តារស្ថិរភាពសេដ្ឋកិច្ច និងកំណើនក្រោយពីការធ្លាក់ចុះសេដ្ឋកិច្ចសកលយ៉ាងធ្ងន់ធ្ងរ និងក្រោយពីសង្គ្រាមពិភពលោក។ មធ្យោបាយដោះស្រាយ គឺ តម្រូវឱ្យប្រទេសទាំងអស់ទទួលយកគោលដៅសេដ្ឋកិច្ចជាមូលដ្ឋាន ដូចជា ត្រូវមានការងារធ្វើកម្រិតខ្ពស់ និងទទួលបានចំណូលខ្ពស់ ហើយ

[37] The World Bank, *History*, https://www.worldbank.org/en/about/history

ប្រទេសនីមួយៗអាចសម្រេចគោលដៅនេះបាន ដោយមានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចត្រឹមត្រូវ បើកចំហសេដ្ឋកិច្ច ទទួលយកពាណិជ្ជកម្មអន្តរជាតិ និងធ្វើការរួមគ្នាដើម្បីធ្វើឱ្យមុខងារប្រព័ន្ធរូបិយវត្ថុអន្តរជាតិដំណើរការទៅបានរលូន[38]។ ជារួម IMF មានគោលបំណងសំខាន់ៗ គឺកាត់បន្ថយភាពក្រីក្រសកល ជំរុញពាណិជ្ជកម្មអន្តរជាតិ និងគាំទ្រឱ្យមានស្ថិរភាពហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច។ IMF មានមុខងារសំខាន់ៗបីដូចខាងក្រោម៖

**ក. តាមដានសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក**

ការងារចំបងរបស់ IMF គឺជំរុញឱ្យមានស្ថិរភាពប្រព័ន្ធរូបិយវត្ថុសកល។ ហេតុនេះ មុខងារដំបូងរបស់ IMF គឺតាមដានសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកទាំង១៩០។ សកម្មភាពនេះ ហៅថា "ការឃ្លាំមើលសេដ្ឋកិច្ច" ដែលកើតឡើងក្នុងកម្រិតប្រទេសនីមួយៗផង និងកម្រិតពិភពលោកផង។ តាមរយៈការឃ្លាំមើលសេដ្ឋកិច្ចនេះ IMF អាចត្រួតពិនិត្យដំណើរការអភិវឌ្ឍន៍ ដែលមានឥទ្ធិពលដល់សេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកផង និងមានឥទ្ធិពលដល់សេដ្ឋកិច្ចពិភពលោកទាំងមូលផង។ បណ្តាប្រទេសជាសមាជិក ត្រូវរិះរកគោលនយោបាយសេដ្ឋកិច្ច ឱ្យសមស្របទៅនឹងគោលដៅរបស់ IMF។ IMF ធ្វើការពិនិត្យ តាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុរបស់បណ្តាប្រទេសជាសមាជិក ពីស្ថិរភាពសេដ្ឋកិច្ច ការប្រឈមហានិភ័យ និងផ្តល់មតិយោបល់ ដើម្បីកែលម្អ។

**ខ. ផ្តល់ឱ្យខ្ចីដល់ប្រទេសជាសមាជិក**

IMF ផ្តល់ប្រាក់ឱ្យខ្ចីទៅលើការអប់រំរបស់បណ្តាប្រទេសជាសមាជិក និងធ្វើឱ្យមានតុល្យភាពជញ្ជីងទូទាត់អន្តរជាតិ។ ជំនួយនេះ ដើម្បីបំពេញបន្ថែមទៅលើធនបម្រុងអន្តរជាតិ រក្សាស្ថិរភាពរូបិយវត្ថុ និងពង្រឹងលក្ខខណ្ឌសម្រាប់កំណើនសេដ្ឋកិច្ច។ IMF សង្ឃឹមថា ប្រទេសនីមួយៗនឹងប្រើប្រាស់មូលធនទាំងនោះ ប្រកបដោយប្រសិទ្ធភាព និងចាប់ផ្តើមដំណើរការកែសម្រួលគោលនយោបាយ និងរចនាសម្ព័ន្ធ ដោយការត្រួត

---

[38] *The Role of the IMF: Past, Present, and Future*--Remarks by Michel Camdessus, https://www.imf.org/en/News/Articles/2015/09/28/04/53/sp021398

ពិនិត្យពី IMF។ នៅទីបញ្ចប់ IMF សង្ឃឹមថា បណ្តាប្រទេសទាំងនោះ នឹងទទួលបាន ជោគជ័យក្នុងការធ្វើកំណែទម្រង់ និងមានលទ្ធភាពសងប្រាក់វិញជាមិនខាន។

ការផ្តល់ឱ្យខ្ចីតាមរយៈ IMF មានពីរប្រភេទគឺ៖ កម្ចីមិនមែនសម្បទាន និង កម្ចីសម្បទាន។ កម្ចីសម្បទាន ត្រូវបានផ្តល់ដល់ប្រទេសដែលមានចំណូលទាប ហើយ មានអត្រាការប្រាក់ទាបបំផុត ឬគ្មានការប្រាក់តែម្តង។ ចំណែក កម្ចីមិនមែនសម្បទាន ជាទូទៅមានការប្រាក់ខ្ពស់ជាង។

### គ. ជួយប្រទេសជាសមាជិកធ្វើទំនើបកម្មសេដ្ឋកិច្ច

មុខងារចុងក្រោយរបស់ IMF គឺ តាមរយៈការអភិវឌ្ឍសមត្ថភាព ដោយផ្តល់ ជំនាញការ ដែលអាចផ្តល់មតិយោបល់ទៅលើគោលនយោបាយ និងការបណ្តុះបណ្តាល តាមរយៈកម្មវិធីជាច្រើន។ IMF ក៏ផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសជាសមាជិកលើ វិស័យមួយចំនួន ដូចខាងក្រោម៖

- គោលនយោបាយសារពើពន្ធ
- គោលនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់
- ការគ្រប់គ្រង និងបទប្បញ្ញត្តិ សម្រាប់ប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារ

មុខងារនេះ មានគោលដៅពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដែលមានសារៈសំខាន់សម្រាប់ប្រទេសនីមួយៗ ជាពិសេស ប្រទេសដែលធ្លាប់ជួប ការបរាជ័យនៃគោលនយោបាយ ស្ថាប័ននៅខ្សោយ ឬខ្វះធនធាន។ តាមរយៈការ អភិវឌ្ឍសមត្ថភាព បណ្តាប្រទេសជាសមាជិក អាចពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវ កំណើនសេដ្ឋកិច្ច និងបង្កើតការងារ[39]។

## ៣. ធនាគារអភិវឌ្ឍន៍អាស៊ី

គំនិតផ្តួចផ្តើមបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចាប់ផ្តើមឡើង កាលពីដើមទសវត្សរ៍ឆ្នាំ១៩៦០ ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានលក្ខណៈអាស៊ី

---

[39] *How Does the International Monetary Fund Function*? https://www.investopedia.com/ask/answers/051415/how-does-international-monetary-fund-function.

ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ដែលក្រីក្រជាងគេនៅលើពិភពលោក។ សេចក្តីសម្រេចបានឆ្លងការអនុម័តនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១ ស្តីពី "កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច" រៀបចំឡើងដោយគណៈកម្មាធិការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ សម្រាប់អាស៊ី និងចុងបូព៌ា នៅឆ្នាំ១៩៦៣។ បន្ទាប់មក ADB ត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៦៦ រៀបចំឡើងនៅទីក្រុងម៉ានិល ប្រទេសហ្វីលីពីន ដែលមានសមាជិកចំនួន៣១ប្រទេស និងមាន Takeshi Watanabe ជាប្រធានទី១ (ដំបូងគេ)។ នៅពេលចាប់ផ្តើមដំណើរការ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ADB បានផ្តោតលើការផ្តល់ជំនួយក្នុងផ្នែកផលិតផលអាហារ និងអភិវឌ្ឍន៍ជនបទ។

នៅឆ្នាំ១៩៧៣ ពិភពលោកប្រឈមនឹងវិបត្តិប្រេងលើកទី១ ធ្វើឱ្យ ADB បង្កើនការគាំទ្រទៅលើគម្រោងថាមពល ជាពិសេស ជំរុញការអភិវឌ្ឍប្រភពថាមពល នៅក្នុងប្រទេសជាសមាជិក។ ADB បានបង្កើនទុនតាមរយៈការបោះផ្សាយសញ្ញាប័ណ្ណលើកទី១នៅអាស៊ី ដែលមានតម្លៃ១៦,៧លានដុល្លារ និងបោះផ្សាយនៅជប៉ុន នៅក្នុងឆ្នាំ១៩៧០។ មកដល់ឆ្នាំ១៩៧៤ ADB បានផ្តល់ឥណទានដែលមានការប្រាក់ទាបទៅឱ្យប្រទេសជាសមាជិកដែលក្រីក្រជាងគេ។

ក្រោយមក វិបត្តិប្រេងលើកទី២ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ធ្វើឱ្យ ADB បន្តគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស លើគម្រោងថាមពល។ ADB ក៏បានបង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា គម្រោងពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុ បរិស្ថាន អប់រំ ផែនការអភិវឌ្ឍន៍ទីក្រុង បញ្ហាសុខភាព និងជួយដល់ស្ត្រី និងកុមារី។ មកដល់ឆ្នាំ១៩៨២ ADB បានបង្កើតការិយាល័យទី១ នៅបង់ក្លាដែស ដើម្បីដឹកនាំប្រតិបត្តិការឱ្យនៅកាន់កៀកនឹងប្រជាពលរដ្ឋ។ បន្ទាប់មក ADB បានធ្វើការងារជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយក្រុមងាយរងគ្រោះ។

នៅឆ្នាំ១៩៩៥ គោលនយោបាយអភិបាលកិច្ចរបស់ ADB ទទួលបានការអនុម័តជាលើកដំបូងពីក្រុមប្រឹក្សាភិបាល ដើម្បីធានាថា ជំនួយអភិវឌ្ឍន៍មានប្រយោជន៍ពេញលេញសម្រាប់ប្រជាជនក្រីក្រ។ សមាជិក ADB បន្តកើនបន្ថែមពីប្រទេសមួយចំនួននៅអាស៊ីកណ្តាល ក្រោយពីបញ្ចប់សង្គ្រាមត្រជាក់។ នៅពាក់កណ្តាលឆ្នាំ១៩៩៧ វិបត្តិហិរញ្ញវត្ថុបានវាយប្រហារនៅក្នុងតំបន់ ធ្វើឱ្យ ADB ឆ្លើយតបជាមួយគម្រោង និងកម្មវិធីមួយចំនួន ដើម្បីពង្រឹងវិស័យហិរញ្ញវត្ថុ និងបង្កើតប្រព័ន្ធសំណាញ់

សុវត្ថិភាពសង្គមសម្រាប់ប្រជាជនក្រីក្រ។ បន្ទាប់មក ADB បានសម្រេចឥណទានគ្រាអាសន្នដ៏ធំមួយ ដែលមានទឹកប្រាក់ប្រមាណ៤ប៊ីលានដុល្លារ ទៅសាធារណរដ្ឋកូរ៉េ ហើយបង្កើត"សេវាដ្ឋានគាំទ្រវិបត្តិរូបិយវត្ថុអាស៊ី" ដើម្បីបង្កើនល្បឿននៃការផ្តល់ជំនួយ។

នៅក្នុងសតវត្សរ៍ថ្មីៗនេះ ADB បានជួយប្រទេសជាសមាជិក ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។ មកដល់ឆ្នាំ២០០៣ ការរីករាលដាលនៃជំងឺសារ ដែលទាមទារឱ្យមានកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ ធ្វើឱ្យ ADB ចាប់ផ្តើមផ្តល់ការគាំទ្រក្នុងកម្រិតជាតិ និងកម្រិតតំបន់ ដើម្បីជួយប្រទេសផ្សេងៗ ឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះផ្តាសាយបក្សី និងកំណើននៃការគម្រាមកំហែងនៃជំងឺអេដស៍។

ADB ក៏បានឆ្លើយតបចំពោះគ្រោះធម្មជាតិ ដែលសន្យានូវចំនួនទឹកប្រាក់ជាង ៨៥០លានដុល្លារសម្រាប់ស្តារឡើងវិញ នៅប្រទេសឥណ្ឌា ឥណ្ឌូណេស៊ី ម៉ាលឌីវ និងស្រីលង្កា ដែលវាយប្រហារដោយរលកយក្សស៊ូណាមិ នៅឆ្នាំ២០០៤ និង១ប៊ីលានដុល្លារទៀត សម្រាប់ជួយជនរងគ្រោះ ដោយសាររញ្ជួយផែនដីនៅប៉ាគីស្ថាន ក្នុងឆ្នាំ២០០៥។ មកដល់ឆ្នាំ២០០៩ ក្រុមប្រឹក្សាភិបាលបានសម្រេចបង្កើនមូលធនគុណនឹងបី ដោយកើនពី៥៥ប៊ីលានដុល្លារ ដល់១៦៥ប៊ីលានដុល្លារ ដើម្បីមានទុនច្រើនជាងមុន ឆ្លើយតបទៅនឹងវិបត្តិសេដកិច្ចសកល[40]។

សរុបសេចក្តីមក ADB បន្តគាំទ្របណ្តាប្រទេសជាសមាជិក ដើម្បីទទួលបានកំណើនប្រកបដោយបរិយាប័ន្ន តាមរយៈមុខងាររបស់ ADB។ មុខងារសំខាន់ៗរបស់ ADB ជាសង្ខេប រួមមាន៖

- ផ្តល់ឥណទានសម្រាប់វឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមនៃប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក
- ផ្តល់ជំនួយបច្ចេកទេសសម្រាប់រៀបចំ និងប្រតិបត្តិការនៃគម្រោង និងកម្មវិធីអភិវឌ្ឍន៍ និងសេវាពិគ្រោះយោបល់
- គាំទ្រការវិនិយោគនៃមូលធនសាធារណៈ និងឯកជនក្នុងគោលដៅអភិវឌ្ឍន៍
- ឆ្លើយតបតាមសំណើសម្រាប់ជំនួយ ក្នុងកិច្ចសម្របសម្រួលគោលនយោបាយអភិវឌ្ឍន៍ និងផែនការរបស់បណ្តាប្រទេសជាសមាជិក។

[40] *ADB History*, https://www.adb.org/about/history#accordion-0-0

## ៤. ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងធនាគារអភិវឌ្ឍន៍ថ្មី

ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) គឺជាធនាគារអភិវឌ្ឍន៍ពហុជាតិ ដែលមានការិយាល័យកណ្តាលនៅទីក្រុងប៉េកាំង និងមានបេសកកម្មចំបង គឺ ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសេដ្ឋកិច្ច-សង្គម នៅតំបន់អាស៊ី តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ AIIB ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់សាធារណរដ្ឋប្រជាមានិត្យចិន ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ និងចាប់ផ្តើមប្រតិបត្តិការ ចាប់ពីខែមករា ឆ្នាំ២០១៦មក។ មកដល់ពេលនេះ AIIB មានសមាជិកចំនួន១០៣ប្រទេស នៅពាសពេញពិភពលោក។ AIIB បានវិនិយោគទៅលើហេដ្ឋារចនាសមន្ព័ន្ធ និងវិស័យផលិតកម្មផ្សេងៗទៀតនៅអាស៊ី និងនៅតំបន់ផ្សេងទៀត ដើម្បីធ្វើឱ្យទំនាក់ទំនងរវាងប្រជាជន និងប្រជាជន សេវាកម្ម និងទីផ្សារកាន់តែប្រសើរឡើង និងជះឥទ្ធិពលទៅជីវិតរស់នៅរបស់ប្រជាជនរាប់ពាន់លាននាក់ និងធ្វើឱ្យអនាគត កាន់តែប្រសើរឡើង។ ក្រៅពីផលប្រយោជន៍ទាំងនេះ តើអ្វីផ្សេងទៀតជាមូលហេតុសំខាន់ ធ្វើឱ្យប្រទេសចិនបង្កើត AIIB នេះឡើង?

### ៤.១. សាវតា

បទពិសោធន៍នៃវិបត្តិហិរញ្ញវត្ថុសកល កាលពីឆ្នាំ២០០៨-២០០៩ កន្លងទៅបង្ហាញថា គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិមួយចំនួន ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) មានការលំបាកជាច្រើន និងមានភាពយឺតយ៉ាវក្នុងការជួយប្រទេសផ្សេងៗ ឱ្យជៀសផុតពីការប្រឈមនៃវិបត្តិ និងស្តារសេដ្ឋកិច្ចឡើងវិញឱ្យបានទាន់ពេលវេលា។ ការលំបាក និងភាពយឺតយ៉ាវនេះ គឺ ដោយសារបញ្ហានយោបាយ និងការមិនយល់ពីតម្រូវការចាំបាច់របស់ប្រទេសកំពុងអភិវឌ្ឍន៍ និងម្យ៉ាងទៀត គឺ ដោយសារ សេដ្ឋកិច្ចអាស៊ី និងប្រទេសរីកចម្រើនថ្មីមួយចំនួន មានទំហំកាន់តែធំ រីកលូតលាស់ខ្លាំង និងមានតួនាទីកាន់តែទូលំទូលាយ នៅលើឆាកអន្តរជាតិ។ លើសពីនោះទៀត ដើម្បីកាត់បន្ថយគម្លាតនៃការតភ្ជាប់នៅក្នុងតំបន់ គម្លាតនៃតម្រូវការមូលធន និងតម្រូវការនៃការអភិវឌ្ឍ ធ្វើឱ្យប្រទេសចិនមានគំនិតផ្តួចផ្តើមបង្កើត ធនាគារ AIIB និង ធនាគារអភិវឌ្ឍន៍ថ្មី (New Development Bank-NDB) របស់ BRICS នេះឡើង។

ក្រោយពីមើលឃើញពីសន្ទុះរីកចម្រើនខ្លាំងនៃសេដ្ឋកិច្ចអាស៊ី និងមើលឃើញពីតម្រូវការចាំបាច់ក្នុងការកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតំបន់អាស៊ី បម្រើឱ្យការតភ្ជាប់នៅក្នុងតំបន់កាន់តែប្រសើរឡើង ដើម្បីជំរុញទំនាក់ទំនងពាណិជ្ជកម្ម និងបង្កើនការវិនិយោគ ប្រទេសចិនមានគំនិតផ្តួចផ្តើម បង្កើតធនាគារ AIIB ដែលត្រូវបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) បង្កើតជាផ្លូវការ នៅទីក្រុងប៉េកាំង កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ដោយមានប្រទេសចំនួន២១ ចូលរួមក្នុងនោះ មានប្រទេសកម្ពុជាផងដែរ[41]។ AIIB ជាធនាគារពហុជាតិ មានមូលដ្ឋាននៅតំបន់អាស៊ី ដែលមានការិយាល័យកណ្តាលនៅប្រទេសចិន បានទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំង និងមានប្រទេសជាសមាជិកស្ថាបនិកចំនួន៥៧ មកពីទ្វីបផ្សេងៗនៅលើសកលលោក[42]។ មកដល់ពេលនេះ សមាជិករបស់ AIIB បានកើនឡើងដល់ ១០៣ប្រទេសហើយ។

ចំណែក NDB វិញ ត្រូវបានឯកភាពគ្នា និងចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) នៅឯកិច្ចប្រជុំកំពូល BRICS លើកទី៦ ក្នុងទីក្រុង Fortaleza ប្រទេសប្រេស៊ីល កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ដែលមានមូលធនចាប់ផ្តើម ១០០ប៊ីលានដុល្លារ និងមានការិយាល័យកណ្តាល នៅទីក្រុងសៀងហៃ។ ឥណ្ឌាបានធ្វើជាប្រធានក្នុងអាណត្តិទី១ ដែលមានរយៈពេល៦ឆ្នាំ។ បន្ទាប់មក ប្រទេសប្រេស៊ីល និងរុស្ស៊ី ត្រូវធ្វើជាប្រធានប្តូរវេន ក្នុងរយៈពេល៥ឆ្នាំម្តង។ ធនាគារនេះ បានចាប់ផ្តើម

---

[41] *21 Asian countries sign MOU on establishing Asian Infrastructure Investment Bank*, October 24, 2014, http://news.xinhuanet.com/english/business/2014-10/24/c_133740149.htm )

[42] *57 nations approved as founder members of China-led AIIB*, 27 April, 2015, http://www.scmp.com/news/ china/diplomacy-defence/article/1766970/57-nations-approved-founder-members-china-led-aiib )

ដំណើរការ នៅដើមឆ្នាំ២០១៦ ដោយសារត្រូវរង់ចាំការអនុម័តយល់ព្រមពីប្រទេសជាសមាជិក ជាមុនសិន[43]។

### ៤.២. តួនាទីរបស់ AIIB និង NDB

ការបង្កើតធនាគារ AIIB នេះ ស្របនឹងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិផ្សេងៗទៀត ដូចជា IMF, WB និង ADB ដែលកំពុងធ្វើប្រតិបត្តិការ នាពេលបច្ចុប្បន្ន។ ហេតុនេះ ទើបមានអ្នកវិភាគខ្លះយល់ថា នេះជាការប្រកួតប្រជែងរវាងសហរដ្ឋអាមេរិក ដែលមានសិទ្ធិអំណាចទៅលើ IMF និង WB ហើយប្រទេសជប៉ុនមានសិទ្ធិអំណាចទៅលើ ADB។ ចំណែកប្រទេសចិន ដែលជាអ្នកផ្តួចផ្តើមគំនិតបង្កើត AIIB និង NDB ដើម្បីឱ្យប្រទេសចិនមានអំណាចខាងហិរញ្ញវត្ថុ។ ប៉ុន្តែ ប្រទេសចិនវិញ បានពន្យល់ថា វាជាការបំពេញបន្ថែមទៅលើគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ ដែលមានស្រាប់ ពីព្រោះបណ្តាប្រទេសនៅអាស៊ី និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត កំពុងប្រឈមនឹងកង្វះហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធយ៉ាងសម្បើម។ តាមការសិក្សារបស់ ADB នៅឆ្នាំ២០០៩ បានបង្ហាញថា អាស៊ីមានតម្រូវការមូលធនប្រហែល៨ទ្រីលានដុល្លារ ក្នុងរវាងពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០។ ប៉ុន្តែ គ្រឹះស្ថានហិរញ្ញវត្ថុដែលមានស្រាប់ មិនអាចបំពេញតម្រូវការនេះបានទេ ដូចជា ADB មានតែជាង១៦០ប៊ីលានដុល្លារ និង WB មានតែ២២៣ប៊ីលានដុល្លារ ប៉ុណ្ណោះ។ ចំណែក AIIB វិញ បានចាប់ផ្តើមដំណើរការនៅដើមឆ្នាំ២០១៦ ដោយមានមូលធន១០០ប៊ីលានដុល្លារ។ ម្យ៉ាងទៀត ADB និង WB បានផ្តល់ឥណទានលើគម្រោងជាច្រើន រាប់តាំងពីការការពារបរិស្ថាន រហូតដល់សមភាពយេនឌ័រ។ រីឯ AIIB វិញ យកចិត្តទុកដាក់តែទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ។ ហេតុនេះ ADB និង WB ជាផ្លូវការ បានស្វាគមន៍ដោយប្រយ័ត្នប្រយែង ចំពោះធនាគារថ្មី ដែលដឹកនាំដោយប្រទេសចិននេះ ដោយលើកឡើងពីឱកាសក្នុងការធ្វើកិច្ចសហប្រតិបត្តិការទៅវិញទៅមក។

---

[43] *BRICS Bank should be made operational by December 2015, says PM Modi*, November 16, 2014, http://www.saharasamay.com/world-news/676564799/brics-bank-should-be-made-operational-by-december-2015-says-pm-m.html

ប៉ុន្តែ ជាក់ស្តែង គំនិតផ្តួចផ្តើមរបស់ចិន ក្នុងការបង្កើតធនាគារ AIIB នេះ បានធ្វើឱ្យឡើងកម្តៅនៅក្នុងសមរភូមិការទូត។ សហរដ្ឋអាមេរិក បានបញ្ចុះបញ្ចូលបណ្តាប្រទេស ដែលជាសម្ព័ន្ធមិត្ត កុំឱ្យចូលរួមជាមួយធនាគារថ្មីនេះ។ ចំណែកលោក Jin Liqun ដែលត្រូវបានតែងតាំងជាអគ្គនាយកនៃ AIIB តាំងពីគ្រាដំបូង បានធ្វើដំណើរទៅពាសពេញពិភពលោក ដើម្បីពន្យល់ និងបញ្ចុះបញ្ចូលប្រទេសផ្សេងៗជាច្រើនឱ្យចូលរួមជាមួយ AIIB ទៅវិញ។ សហរដ្ឋអាមេរិក និងប្រទេសដែលមិនចូលរួម បានរិះគន់ពីកង្វះតម្លាភាពក្នុងអភិបាលកិច្ច និងមិនបំពេញបាននូវស្តង់ដាបរិស្ថាន កម្លាំងពលកម្ម និងលទ្ធកម្ម ដែលជាមូលដ្ឋានគ្រឹះ សម្រាប់បេសកកម្មនៃការផ្តល់កម្ចីអភិវឌ្ឍន៍។ ប៉ុន្តែ ប្រទេសចិនបានអះអាងថា AIIB នឹងធ្វើការងារដោយម៉ឺងម៉ាត់ និងអនុវត្តឱ្យបានល្អបំផុត ដូចគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិនានា។

មានអ្នកវិភាគខ្លះបានពន្យល់ថា ប្រទេសចិននឹងប្រើធនាគារ AIIB ថ្មីនេះ ដើម្បីពង្រីកឥទ្ធិពលរបស់ខ្លួន ទប់ទល់នឹងសហរដ្ឋអាមេរិក និងជប៉ុន ដែលកំពុងពង្រីកអំណាចនៅអាស៊ី និងបង្កើនទម្ងន់ ចំពោះដំណើរការកំណែទម្រង់អភិបាលកិច្ចសេដ្ឋកិច្ចពិភពលោក។ ការបង្កើតធនាគារ AIIB និងយុទ្ធសាស្ត្រផ្លូវសូត្រសមុទ្រ ដែលបច្ចុប្បន្នហៅថា "ខ្សែក្រវ៉ាត់មួយ ផ្លូវមួយ" ក៏ដូចជា NDB របស់ BRICS ផងដែរ គឺ ដើម្បីពង្រឹងអំណាចរបស់ចិននៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ និងដើម្បីបង្កើនសម្ពាធចំពោះកំណែទម្រង់របស់ IMF ដែលត្រូវកែសម្រួលការផ្តល់កូតា (សិទ្ធិសម្រេច) កាន់តែច្រើនដល់បណ្តាប្រទេសរីកចម្រើនថ្មីនៅអាស៊ី និងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត ដែលបានអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំមកហើយ[44]។

គួរកត់សម្គាល់ថា គោលបំណងសំខាន់នៃការបង្កើតធនាគារ NDB គឺ ដើម្បីប្រមូលធនធានសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងបណ្តាប្រទេស BRICS ប្រទេសរីកចម្រើនថ្មីមួយចំនួន និងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត។ ម្យ៉ាងទៀត NDB ក៏ជួយបំពេញបន្ថែមទៅលើការខិតខំរបស់គ្រឹះស្ថានហិរញ្ញវត្ថុពហុភាគី(អន្តរជាតិ) និងតំបន់ សម្រាប់កំណើនសកល និងការ

---

[44] *The Economist explains: Why China is creating a new "World Bank" for Asia*, November 11, 2014, http://www.economist.com/blogs/economist-explains/2014/11/economist-explains-6

អភិវឌ្ឍផងដែរ។ លើសពីនោះទៀត NDB នឹងជួយពង្រឹងទំនាក់ទំនងកាន់តែជិតស្និទ្ធ និងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត នៅក្នុងចំណោមប្រទេស BRICS និងនៅក្នុងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត។

សរុបសេចក្តីមក ការបង្កើតធនាគារថ្មី AIIB និង NDB របស់ BRICS ដែលផ្តួចផ្តើមគំនិតដោយប្រទេសចិន ពិតជាមានតួនាទីសំខាន់ណាស់ ក្នុងការគាំទ្រប្រទេសរីកចម្រើនថ្មី និងប្រទេសកំពុងអភិវឌ្ឍ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ជំរុញការវិនិយោគ និងពាណិជ្ជកម្ម រួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ឱ្យកាន់តែមានសន្ទុះរីកចម្រើនបន្ថែមទៀត។ មានន័យថា AIIB និង NDB គឺជាការបំពេញបន្ថែមទៅលើតួនាទីរបស់គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិដែលមានស្រាប់ ដូចជា IMF, WB និង ADB ជាដើម។ ប៉ុន្តែ ទន្ទឹមនឹងនោះ វាក៏ជាការប្រកួតប្រជែងរវាងសហរដ្ឋអាមេរិក និងជប៉ុន ជាមួយប្រទេសចិន ដើម្បីដណ្តើមឥទ្ធិពលអំណាចនៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិផងដែរ ពីព្រោះ AIIB និង NDB នឹងបំពេញតួនាទីក្នុងការផ្តល់ហិរញ្ញប្បទានដល់ប្រទេស ដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង និងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត លើគម្រោងវិនិយោគជាច្រើន ដូច IMF, WB និង ADB ផងដែរ។

នៅពេលដែលពិភពលោក កំពុងប្រឈមនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ AIIB បានបង្កើត "សេវាដ្ឋានស្តារវិបត្តិ" ដើម្បីគាំទ្របណ្តាប្រទេសជាសមាជិក និងអតិថិជនផ្សេងទៀត ក្នុងការកាត់បន្ថយ និងសម្រាលសម្ពាធសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសុខភាពសាធារណៈ ដែលកើតឡើង ដោយសារការរីករាលដាលនៃជំងឺរាតត្បាត នាពេលបច្ចុប្បន្ន។ គម្រោងដែលបានលើកឡើង មានទឹកប្រាក់១៣ប៊ីលានដុល្លារអាមេរិក ដែលត្រូវអនុវត្តក្នុងរយៈពេល១៨ខែ ដោយចាប់ផ្តើមពីខែមេសា ឆ្នាំ២០២០ ដល់ខែតុលា ឆ្នាំ២០២១ សម្រាប់ផ្តល់ហិរញ្ញប្បទានទៅឱ្យស្ថាប័នក្នុងវិស័យសាធាណៈ និងឯកជន នៅក្នុងបណ្តាលប្រទេសជាសមាជិក ដែលប្រឈម និងទទួលរងឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរ។ គម្រោងនេះ ត្រូវបានប្រើប្រាស់លើវិស័យសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ❖ ផ្តល់ហិរញ្ញប្បទានទៅលើតម្រូវការបន្ទាន់ ក្នុងវិស័យសុខភាពភាពសាធារណៈ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពក្នុងប្រព័ន្ធសុខាភិបាល ផ្តល់សម្ភារៈ

បរិក្ខារចាំបាច់ ដែលត្រូវប្រើប្រាស់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងវិស័យសុខាភិបាល និងការផ្តល់ហិរញ្ញប្បទានទៅលើការចាក់វ៉ាក់សាំងផងដែរ។

- ❖ ស្តារសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកឡើងវិញ ដោយផ្តល់ហិរញ្ញប្បទានបន្ថែមទៅលើការចំណាយរបស់រដ្ឋាភិបាល ដើម្បីគាំទ្រសង្គម និងសេដ្ឋកិច្ចដែលទទួលរងឥទ្ធិពលពីវិបត្តិ ដូចជា វិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ និងកសាងសេដ្ឋកិច្ច សង្គម ដោយការពារការខូចខាតរយៈពេលវែងទៅលើសមត្ថភាពផលិតនៃសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពធនធានមនុស្សផងដែរ។
- ❖ ផ្តល់ហិរញ្ញប្បទានទៅលើបញ្ហាសន្ទនីយភាព ចំពោះអតិថិជនក្នុងវិស័យហេដ្ឋរចនាសម្ព័ន្ធ និងវិស័យផលិតកម្មផ្សេងទៀត ដើម្បីធានាប្រតិបត្តិការប្រព្រឹត្តិទៅបានរលូន ដោយគ្មានការកាត់បន្ថយគម្រោង និងគ្មានការពន្យារពេល[45]។

រយៈពេលកន្លងទៅ ចាប់ពីឆ្នាំ២០១៦មក AIIB បានដំណើរការប្រកបដោយភាពស្វាហាប់ និងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ នៅឆ្នាំទី១ AIIB បានអនុម័តគម្រោងចំនួន៨ ដែលមានទឹកប្រាក់១,៦៩ប៊ីលានដុល្លារ នៅឆ្នាំ២០១៦ និងបានកើនឡើងដល់២៣គម្រោង ដែលមានទឹកប្រាក់ចំនួន៤,១៩ប៊ីលានដុល្លារ។ នៅឆ្នាំ២០១៨ មាន៣៥គម្រោងដែលមានទឹកប្រាក់៧,៥០ប៊ីលានដុល្លារ ហើយបន្តកើនឡើងដល់៦៣គម្រោង ដែលមានទឹកប្រាក់ចំនួន១២,០៤ប៊ីលានដុល្លារ នៅឆ្នាំ២០១៩។ ចំនួនបុគ្គលិកជំនាញរបស់ AIIB បានកើនឡើងដល់ ២៧៩ នាក់ នៅក្នុង២០១៩។

ភាគច្រើននៃគម្រោងវិនិយោគ គឺផ្តល់អាទិភាពលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាពិសេស នៅតំបន់អាស៊ី ដែលមានផលប្រយោជន៍សម្រាប់គាំទ្រដល់ស្ថិរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងទទួលស្គាល់ដោយសង្គម។ ម្យ៉ាងទៀត ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឆ្លងព្រំដែន បានបង្កើតបាននូវទំនាក់ទំនង ដោយតភ្ជាប់រវាងសេដ្ឋកិច្ច ពាណិជ្ជកម្ម

---

[45] *COVID-19 Crisis Recovery Facility*, https://www.aiib.org/en/policies-strategies/COVID-19-Crisis-Recovery-Facility/index.html

ទីផ្សារ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន នៅក្នុងតំបន់កាន់តែជិតស្និទ្ធ និងទូលំទូលាយបន្ថែមទៀត[46]៕

.

[46] *2019 AIIB Annual Report and Financials*, https://www.aiib.org/en/news-events/annual-report/2019/_common/pdf/2019-aiib-annual-report-and-financials.pdf

# ជំពូក៤

# របាយការណ៍ហិរញ្ញវត្ថុ
# ការវិភាគ និងវាយតម្លៃ

# មេរៀនទី៧

## របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ

## (Financial Statements of a Bank)

### ១. សញ្ញាណទូទៅ

សេវាកម្មពិសេសដែលគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗជ្រើសរើស ដើម្បីបម្រើចំពោះអតិថិជន និងទំហំផ្សេងគ្នានៃគ្រឹះស្ថានហិរញ្ញវត្ថុ ឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ របាយការណ៍ហិរញ្ញវត្ថុ គឺជាផែនទីបង្ហាញផ្លូវ ប្រាប់ឱ្យយើងដឹងថា គ្រឹះស្ថានហិរញ្ញវត្ថុនេះ មកពីទីណាកាលពីអតីតកាល បច្ចុប្បន្ននៅត្រង់ចំណុចណា ហើយប្រហែលអាចដឹងថា នៅពេលអនាគតនឹងទៅណា។ វាជាការបង្ហាញផ្លូវដែលមិនអាចខ្វះបាន ដែលបង្ហាញឱ្យយើងដឹងពីសញ្ញាល្អ ឬប្រឈមនឹងគ្រោះថ្នាក់ ប្រសិនបើរបាយការណ៍នោះ រៀបចំបានល្អ និងបកស្រាយបានត្រឹមត្រូវ។ ផ្ទុយទៅវិញ បញ្ហានឹងកើតឡើង ប្រសិនបើ របាយការណ៍ភូតកុហក ដែលធ្វើឱ្យយល់ខុសពីស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថានហិរញ្ញវត្ថុទៅវិញ។

របាយការណ៍ហិរញ្ញវត្ថុពីរសំខាន់ ដែលអ្នកគ្រប់គ្រង អតិថិជន ជាពិសេសអ្នកផ្ញើប្រាក់ធំៗ និងរដ្ឋអំណាចទទួលខុសត្រូវ តែងផ្តោតជាសំខាន់នោះ គឺ តារាងតុល្យការ (Balance sheet or Report of Conditions) និងរបាយការណ៍ចំណេញ-ខាត (Income Statement or Report of Income)។ យើងនឹងពិនិត្យមើលឱ្យបានស៊ីជម្រៅ ទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងពីរ ដោយបង្ហាញពីលក្ខណៈពិសេសនៃរបាយការណ៍នីមួយៗ និងសមាសធាតុរបស់វា។ ទន្ទឹមនឹងនោះ នៅក្នុងមេរៀននេះ នឹងលើកយករបាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flows) មកសិក្សាផងដែរ ដើម្បីស្វែងយល់ពីស្ថានភាពសាច់ប្រាក់របស់គ្រឹះស្ថានហិរញ្ញវត្ថុ។

### ២. តារាងតុល្យការ

តារាងតុល្យការ គឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងពីសកម្មភាពប្រតិបត្តិការរបស់ អង្គភាពធនាគារ ដោយបង្ហាញពីទ្រព្យ បំណុល និងមូលធនផ្ទាល់

នៅក្នុងថ្ងៃណាមួយជាកំណត់ (any given date)។ គេអាចធ្វើការបូកសរុបតារាងតុល្យការក្នុងគ្រាផ្សេងៗ ដូចជា ជារៀងរាល់ខែ ត្រីមាស ឆមាស ឬប្រចាំឆ្នាំ។ តារាងតុល្យការ បង្ហាញឱ្យយើងដឹងថា តើអង្គភាពធនាគារបានប្រភពទុនពីណាមក? ជាមូលធនផ្ទាល់ ឬ ជាបំណុល? ហើយប្រើប្រាស់មូលធនទាំងនោះ ដើម្បីវិនិយោគលើគម្រោងណាខ្លះ? ឬ ចំណាយទៅលើទ្រព្យសកម្មអ្វីខ្លះ?

តារាងតុល្យការត្រូវបានបែងចែកជាពីរផ្នែក គឺប្រភពទុន និងការប្រើប្រាស់ទុន។ ប្រភពទុនបានមកពីមូលធនផ្ទាល់ ឬលក់ប័ណ្ណភាគហ៊ុន និងបំណុល ដែលបានមកពីការទទួលប្រាក់បញ្ញើពីអតិថិជន និងកម្ចីមិនមែនប្រាក់បញ្ញើ។ ចំពោះធនាគារពាណិជ្ជ បំណុលជាប្រភពទុនសំខាន់បំផុត និងមានសមាមាត្រធំជាងគេ។ ចំណែក ទ្រព្យសកម្ម ឬការប្រើប្រាស់ទុនវិញ គឺជាការវិនិយោគ ដោយទិញអចលនទ្រព្យ ឧបករណ៍ សម្ភារៈ វត្ថុធាតុដើម និងចំណាយប្រតិបត្តិការ។ តាមគោលការណ៍គណនេយ្យ យើងបានទ្រព្យសកម្ម ស្មើនឹងផលបូកនៃមូលធនផ្ទាល់ និងបំណុល ដូចមានក្នុងរូបមន្តខាងក្រោម៖

ទ្រព្យសកម្ម = បំណុល + មូលធន

## ២.១. ទ្រព្យសកម្ម (Assets)

គេអាចបែងចែកទ្រព្យសកម្ម នៅក្នុងតារាងតុល្យការរបស់ធនាគារពាណិជ្ជជាបួនផ្នែកធំៗ គឺ ទ្រព្យជាសាច់ប្រាក់ វិនិយោគលើមូលប័ត្រ ឥណទាន និងទ្រព្យផ្សេងៗទៀត។

### ក. ទ្រព្យសកម្មជាសាច់ប្រាក់ (Cash assets)

ទ្រព្យសកម្មជាសាច់ប្រាក់ គឺជាខ្ទង់ប្រាក់ចាំបាច់សម្រាប់បំពេញតម្រូវការសន្ទនីយភាព ដូចជា តម្រូវការចំណាយភ្លាមៗ តម្រូវការដកប្រាក់របស់អ្នកផ្ញើ តម្រូវការឥណទានរបស់អតិថិជន និងតម្រូវឥតគ្រោងទុកផ្សេងទៀត។ ទ្រព្យជាសាច់ប្រាក់រួមមាន សាច់ប្រាក់នៅក្នុងទូដែក និងប្រាក់បញ្ញើនៅធនាគារផ្សេងទៀត។

ខ. វិនិយោគមូលប័ត្រ (Security investment)

វិនិយោគមូលប័ត្រ គឺជាការវិនិយោគដោយទិញមូលប័ត្រនៅក្នុងទីផ្សារបើកចំហ។ វិនិយោគមូលប័ត្រ រួមមានមូលប័ត្រសាជីវកម្ម ឬឯកជន និងមូលប័ត្ររដ្ឋាភិបាល ដែលមានអត្រាគូប៉ុង ឬ អត្រាការប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។ ការវិយោគមូលប័ត្រនេះ ជាប្រភពទទួលបានប្រាក់ចំណូលផង និងជាប្រភពធានាសន្ទនីយភាពផង ដែលគេអាចបំពេញតម្រូវការសាច់ប្រាក់បានភ្លាមៗ ដោយលក់វានៅក្នុងទីផ្សារបន្ទាប់ ឬ រង់ចាំថ្ងៃកំណត់ បើសិនជា មិនមានតម្រូវការសាច់ប្រាក់បន្ទាន់ទេ។

គ. ឥណទាន (Loans)

ឥណទាន គឺជាការផ្តល់ឱ្យខ្ចីចំពោះអតិថិជន វិនិយោគិន ហើយជាប្រភពផ្តល់ចំណូលសំខាន់របស់ធនាគារ។ ឥណទាន មានច្រើនប្រភេទ ដែលអាចបែងចែកដោយផ្អែកលើកម្មវត្ថុដែលផ្តល់ឱ្យខ្ចី ដូចជា ឥណទានអាជីវកម្ម ឥណទានអចលនទ្រព្យ ឥណទានផលិតផលកសិកម្ម ឥណទានសម្រាប់អ្នកប្រើប្រាស់ ជាដើម។

ឃ. ទ្រព្យសកម្មផ្សេងទៀត

ក្រៅពីទ្រព្យសកម្មដែលបានរៀបរាប់ខាងលើ ធនាគារមានទ្រព្យសកម្មផ្សេងៗទៀត។ ទ្រព្យសកម្មផ្សេងៗ ដែលសំខាន់ និងមានសមាមាត្រធំជាងគេ គឺទ្រព្យសកម្មរយៈពេលវែង ដូចជា ដី អាគារ និងឧបករណ៍សម្ភារៈ និងវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ព្រមទាំងទ្រព្យសកម្មផ្សេងៗទៀត។

**២.២. បំណុល (Liabiliies)**

បំណុលរបស់ធនាគារ ត្រូវបានបែងចែកជាផ្នែកសំខាន់ៗ៖ ប្រាក់បញ្ញើ និងកម្ចីមិនមែនប្រាក់បញ្ញើ ដែលបានពីទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន។ ប្រាក់បញ្ញើ គឺជាប្រភពទុនសំខាន់បំផុតរបស់ ធនាគារ។ ចំណែក កម្ចីមិនមែនប្រាក់បញ្ញើវិញ គឺជាខ្ទង់បំពេញបន្ថែមទៅលើប្រភពដែលបានមកពីប្រាក់បញ្ញើ និងជួយគាំទ្រដល់សន្ទនីយភាព ដូចជា សាច់ប្រាក់ និងមូលប័ត្រ ដែលមិនអាចបំពេញតម្រូវការបានគ្រប់គ្រាន់។

### ២.៣. មូលធនផ្ទាល់ (Equity)

មូលធនផ្ទាល់ គឺជាប្រភពបានមកពីការរួមចំណែករបស់ម្ចាស់ទុន តំណាងឱ្យប្រភពទុនរយៈពេលវែង ប្រកបដោយស្ថិរភាព ដើម្បីគាំទ្រហិរញ្ញវត្ថុក្នុងសកម្មភាពប្រតិបត្តិការ និងការវិនិយោគ ដែលជាមូលដ្ឋានកំណើន និងធានាចំណាយលើការខាតបង់ដែលអាចកើតមាន។

ម៉្យាងទៀត គេអាចស្វែងយល់ពីលក្ខណៈនៃតារាងតុល្យការ ដោយកត់សំគាល់ថា បំណុល និងមូលធន តំណាងឱ្យផលបូកសរុបនៃប្រភពទុន ដែលបំពេញតម្រូវការអំណាចទិញ ដើម្បីទទួលបានទ្រព្យ។ ចំណែកទ្រព្យរបស់ធនាគារវិញ គឺជាផលបូកសរុបនៃការប្រើប្រាស់ទុន ដែលជាអ្នកបង្កើតចំណូលសម្រាប់ម្ចាស់ភាគហ៊ុន ចំណាយការប្រាក់ឱ្យអ្នកផ្ញើ និងចំណាយទៅលើបុគ្គលិក ដែលជាកម្លាំងពលកម្មនិងអ្នកជំនាញ និងចំណាយប្រតិបត្តិការផ្សេងទៀត។ ហេតុនេះ តារាងតុល្យការ អាចបង្ហាញក្នុងទម្រង់ ដូចខាងក្រោម៖

| ផលបូកសរុបនៃការប្រើប្រាស់ទុន<br>(ទ្រព្យសកម្ម) | = | ផលបូកសរុបនៃប្រភពទុន<br>(បំណុល និងមូលធន) |
|---|---|---|

**តារាង៧.១: គំរូ តារាងតុល្យការ**

| ទ្រព្យសកម្ម (Assets) | 31/12/20xx | 31/12/20xx |
|---|---|---|
| សាច់ប្រាក់ និងប្រាក់បញ្ញើនៅស្ថាប័នសន្សំផ្សេងទៀត | $xxx | $xxx |
| វិនិយោគលើមូលប័ត្រ | xxx | xxx |
| ឥណទានសរុប និងការជួលទ្រព្យ | xxx | xxx |
| (ដក) សំវិធានធនសម្រាប់បំណុលខាត | xxx | xxx |
| (ដក) ចំណូលមិនទាន់ទទួលស្គាល់ | xxx | xxx |
| បំណុល និងការជួលទ្រព្យ (សុទ្ធ) | xxx | xxx |
| គណនីជួញដូរមូលប័ត្រ | xxx | xxx |
| ដី អាគារ និងឧបករណ៍សម្ភារៈ | xxx | xxx |
| អចលនទ្រព្យផ្សេងទៀត | xxx | xxx |
| កម្មសិទ្ធបញ្ញា និងទព្យអរូបិយ៍ផ្សេងទៀត | xxx | xxx |

| | | |
|---|---|---|
| ទ្រព្យផ្សេងៗទៀត | xxx | xxx |
| **ទ្រព្យសរុប** | $xxxx | $xxxx |

| **បំណុល និងមូលធន** (Liabilities and Capital) | 31/12/20xx | 31/12/20xx |
|---|---|---|
| ប្រាក់បញ្ញើសរុប | $xxx | $xxx |
| ការជួញដូរបំណុល | xxx | xxx |
| កម្ចីផ្សេងៗ | xxx | xxx |
| ប័ណ្ណបំណុល (Subordinated debt) | xxx | xxx |
| បំណុលផ្សេងទៀត | xxx | xxx |
| **បំណុលសរុប** | xxx | xxx |
| មូលធន | xxx | xxx |
| ប័ណ្ណភាគហ៊ុនអាទិភាព | xxx | xxx |
| ប័ណ្ណភាគហ៊ុនធម្មតា | xxx | xxx |
| អតិរេកមូលធន (Capital surplus) | xxx | xxx |
| ផលចំណេញរក្សាទុក ឬ ផលចំណេញមិនបែងចែក | xxx | xxx |
| **បំណុល និងមូលធនសរុប** | $xxxx | $xxxx |

*សមាសធាតុផ្សេងៗ នៅក្នុងតារាងតុល្យការ មានខ្លឹមសារ ដូចខាងក្រោម៖*

ក. ទ្រព្យសកម្ម (Assets)

- **សាច់ប្រាក់ និងប្រាក់បញ្ញើនៅស្ថាប័នសន្សំផ្សេងទៀត៖** គឺជាសាច់ប្រាក់នៅក្នុងទូដែករបស់ធនាគារ ប្រាក់បញ្ញើរក្សាទុននៅគ្រឹះស្ថានសន្សំផ្សេងទៀត ឬហៅថាគណនីប្រាក់បញ្ញើទំនាក់ទំនង ប្រាក់កំពុងដំណើរការប្រមូល ជាពិសេស មូលប្បទានប័ត្រមិនទាន់ទទួលប្រាក់ និងទុនបម្រុងដែលរក្សាទុកនៅធនាគារកណ្តាល។ គេអាចហៅខ្ទង់នេះថា ទុនបម្រុងដំបូង (Primary reserves) ដោយសារ វាអាចបំពេញតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា។ ធនាគារពាណិជ្ជតែងរក្សាទុកខ្ទង់នេះឱ្យនៅតិចបំផុត តាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយសារ ខ្ទង់ទាំងនេះមានចំណូលទាប ឬគ្មានចំណូលការប្រាក់តែម្តង។

- **វិនិយោគលើមូលប័ត្រ** (ផ្នែកសន្ទនីយភាព)៖ ខ្ទង់បម្រុងទី២ សម្រាប់បំពេញតម្រូវការសាច់ប្រាក់ គឺការវិនិយោគលើមូលប័ត្រដែលមានសន្ទនីយភាពខ្ពស់ ឬហៅថា ទុនបម្រុងបន្ទាប់(Secondary reserves)។ ខ្ទង់ទាំងនេះ រួមមាន មូលប័ត្ររដ្ឋាភិបាលរយៈពេលខ្លី មូលប័ត្រទីផ្សាររូបិយវត្ថុឯកជន ប្រាក់បញ្ញើមានកាលកំណត់ផ្ញើនៅធនាគារផ្សេងទៀត និងផលប័ត្រពាណិជ្ជកម្ម។ ទុនបម្រុងបន្ទាប់ ស្ថិតនៅកណ្តាល រវាងគណនីសាច់ប្រាក់ និងឥណទាន ដែលអាចទទួលបានចំណូលការប្រាក់ខ្លះ ប៉ុន្តែ គោលបំណងសំខាន់ គឺ អាចបំប្លែងទៅជាសាច់ប្រាក់ដោយងាយក្នុងរយៈពេលខ្លី។
- **វិនិយោគលើមូលប័ត្រ** (ផ្នែកបង្កើតចំណូល)៖ គឺជាការវិនិយោគ ដើម្បីបង្កើតចំណូល ដូចជា សញ្ញាប័ណ្ណ និងមូលប័ត្រផ្សេងទៀត។ នៅស.រ.អា គេអាចចែកសញ្ញាប័ណ្ណនេះជាពីរគឺ មូលប័ត្រជាប់ពន្ធ មានដូចជា សញ្ញាប័ណ្ណរដ្ឋាភិបាលអាមេរិក សញ្ញាប័ណ្ណបោះផ្សាយដោយភ្នាក់ងាររដ្ឋាភិបាល និងសញ្ញាប័ណ្ណសាជីវកម្ម។ ទី២ មូលប័ត្រលើកលែងពន្ធ មានដូចជា សញ្ញាប័ណ្ណបោះផ្សាយដោយរដ្ឋនានា ឬរដ្ឋាភិបាលថ្នាក់តំបន់ មានន័យថា មិនត្រូវបង់ពន្ធលើការប្រាក់ដែលទទួលបានពីសញ្ញាប័ណ្ណទេ។
- **គណនីជួញដូរមូលប័ត្រ**៖ គឺជាការទិញ-លក់មូលប័ត្រ ដោយរក្សាទុកក្នុងរយៈពេលខ្លី ដើម្បីទទួលបានផលចំណេញ លំអៀងរវាងថ្លៃលក់ និងថ្លៃទិញ។ តម្លៃដែលត្រូវកត់ត្រាសម្រាប់ប្រភេទគណនីនេះ គឺ តម្លៃទីផ្សារ។
- **ឥណទាន និងការជួល៖** គឺជាការផ្តល់ឱ្យខ្ចី និងជួលទ្រព្យសម្បត្តិឱ្យអតិថិជនដែលមានសមាមាត្រធំជាងគេ នៅក្នុងទ្រព្យផ្សេងៗទៀតរបស់ធនាគារ។ ឥណទាន ត្រូវបានបែកចែកដោយផ្អែកលើគោលបំណងនៃការប្រើប្រាស់របស់អ្នកខ្ចី ដូចជា ឥណទានពាណិជ្ជកម្ម និងឧស្សាហកម្ម ឬហៅថា ឥណទានអាជីវកម្ម ឥណទានសម្រាប់អ្នកប្រើប្រាស់ ឥណទានអចលនទ្រព្យ ឥណទានសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ឥណទានផលិតផលកសិកម្ម។ល។ ចំណែក ការជួលវិញ គឺ ធនាគារទិញឧបករណ៍ សម្ភារៈ សម្រាប់ជួលឱ្យអតិថិជន អង្គភាពអាជិវកម្ម ក្នុងរយៈពេលណាមួយ។

- **បំណុលខាត និងធនបម្រុងសម្រាប់បំណុលខាត:** បំណុលខាតទាំងបច្ចុប្បន្ន និងការរំពឹងទុក ត្រូវបានអនុញ្ញាតឱ្យដកចេញពីបំណុលសរុប និងបង្កើត "ធនបម្រុងសម្រាប់បំណុលខាត" ដោយដកចេញពីចំណូលក្នុងគ្រាប្រតិបត្តិ ហើយទំហំនៃធនបម្រុង គឺផ្អែកលើបទពិសោធន៍កន្លងទៅ។ ធនបម្រុងសម្រាប់បំណុលខាត គឺជាខ្ទង់អវិជ្ជមាន ដែលធ្វើឱ្យបរិមាណទ្រព្យសកម្ម នៅក្នុងតារាងតុល្យការថយចុះ។ នៅពេលមានបំណុលខាតកើតឡើង គេត្រូវដកពីធនបម្រុងសម្រាប់បំណុលខាត ដើម្បីបំពេញខាត។ ហេតុនេះ បំណុលខាត មិនជះឥទ្ធិពលដល់ផលចំណេញរបស់ធនាគារដោយផ្ទាល់ទេ។
- **ចំណូលមិនទាន់ទទួលស្គាល់:** មានដូចជា ចំណូលការប្រាក់ទទួលពីអតិថិជនក្នុងការផ្តល់ឥណទាន ប៉ុន្តែ មិនទាន់ត្រូវបានទទួលស្គាល់ជាចំណូល តាមប្រព័ន្ធគណនេយ្យបង្គរ ពីព្រោះអតិថិជនមិនទាន់បានប្រើឥណទានរហូតដល់គ្រាកំណត់ណាមួយ។ ក្នុងពេលវេលាជាបន្តបន្ទាប់ក្នុងអាយុកាលឥណទាន ធនាគារទទួលបានចំណូលការប្រាក់ ដោយផ្ទេរពីចំណូលមិនទាន់ទទួលស្គាល់ មកជាចំណូលការប្រាក់វិញ។
- **ឥណទានគ្មានសកម្មភាព** (Nonperforming loans): គឺជាប្រភេទឥណទាន ដែលមិនមានការប្រាក់ត្រូវបានកត់ត្រាតាមប្រព័ន្ធបង្គរទៀតទេ ឬ ជាឥណទានត្រូវរៀបចំឡើងវិញ ដើម្បីបំពេញតម្រូវចិត្តអតិថិជនដោយកែប្រែលក្ខខណ្ឌមួយចំនួន។ ឥណទានដែលត្រូវបានចាត់ទុកថាគ្មានសកម្មភាព លុះត្រាតែឥណទាននោះ ហួសថ្ងៃកំណត់សង លើសពី ៩០ថ្ងៃ។ នៅពេលដែលមានឥណទានគ្មានសកម្មភាពកើតឡើង ការប្រាក់ត្រូវបានកត់ត្រានៅក្នុងបញ្ជី ប៉ុន្តែ មិនទទួលស្គាល់ជាចំណូលការប្រាក់ទេ។
- **អាគារ និងអចលនទ្រព្យផ្សេងទៀត:** គឺជាទ្រព្យសកម្មរយៈពេលវែង មានដូចជា ដីធ្លី អាគារ និងឧបករណ៍ សម្ភារៈផ្សេងទៀត ដែលមានភាគរយទាប ធៀបនឹងទ្រព្យសកម្មផ្សេងទៀតរបស់ធនាគារ។
- **មូលធនពាណិជ្ជកម្ម (Goodwill) និងទ្រព្យសកម្មអរូបីផ្សេងទៀត:** ជាទូទៅធនាគារទិញទ្រព្យសកម្មផ្សេងទៀតដែលខ្វះពីក្រុមហ៊ុនផ្សេងទៀត។

មូលធនពាណិជ្ជកម្ម អាចកើតឡើងនៅពេលដែលក្រុមហ៊ុនមួយ ទិញក្រុមហ៊ុនមួយទៀត ហើយត្រូវចំណាយខ្ពស់ជាងតម្លៃទីផ្សារ នៃទ្រព្យសកម្មសុទ្ធ (ទ្រព្យសកម្ម – បំណុល)។ ចំណែក ទ្រព្យសកម្មអរូបីផ្សេងទៀត រួមមាន សិទ្ធិបម្រើសេវាក្នុងវិស័យនិក្ខេប និងទិញប្រព័ន្ធទំនាក់ទំនងប័ណ្ណឥណទាន ជាដើម។

- **ទ្រព្យសកម្មផ្សេងទៀតៈ** គឺជាទ្រព្យសកម្មដែលមិនបានរៀបរាប់ខាងលើ មានដូចជា ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ បំណុលអតិថិជនដែលបានទទួល (Customers' liability on acceptances)[47]។ល។

ខ. **បំណុល** (Liabilities)

- **ប្រាក់បញ្ញើៈ** ជាប្រភពទុនសំខាន់របស់ធនាគារ និងជាបំណុលចម្បងដែលទទួលពីគ្រួសារ អង្គភាពអាជីវកម្ម និងរដ្ឋាភិបាល។ ប្រាក់បញ្ញើត្រូវបានបែងចែកជាប្រភេទផ្សេងៗ ដូចជា ប្រាក់បញ្ញើមានការប្រាក់ ប្រាក់បញ្ញើសន្សំ គណនីប្រាក់បញ្ញើទីផ្សាររូបិយវត្ថុ ប្រាក់បញ្ញើមានកាលកំណត់ វិញ្ញាបនបត្រប្រាក់បញ្ញើ និងប្រាក់ដែលបានទទួល (Acceptances outstanding)។ល។
- **កម្ចីមិនមែនប្រាក់បញ្ញើៈ** គឺជាខ្ចីប្រាក់ពីទីផ្សារហិរញ្ញវត្ថុ ឬពីប្រភពផ្សេងទៀត ដើម្បីបំពេញតម្រូវការសាច់ប្រាក់បន្ថែម ពីព្រោះ វាតម្រូវឱ្យរក្សាបម្រុងនៅធនាគារកណ្តាល បង់ធានាថ្លៃរ៉ាប់រង និងមានភាពងាយស្រួលក្នុងការសម្របសម្រួល។ ប៉ុន្តែ កម្ចីមិនមែនប្រាក់បញ្ញើមានគុណវិបត្តិនៅត្រង់ថា អត្រាងាយប្រែប្រួល ហើយនៅពេលស្ថានភាពសេដ្ឋកិច្ចមិនប្រសើរ អ្នកឱ្យខ្ចី ងាយនឹងបដិសេធ។

---

[47] Customers' liability on acceptances គឺជាប្រាក់ដែលទទួលពីអតិថិជន ក្នុងបំណងបញ្ជូនផ្ទេរ ឬទូទាត់ឱ្យអតិថិជនម្នាក់ទៀត។ Customers' liability on acceptances ត្រូវកត់ត្រាក្នុងពេលទន្ទឹមគ្នាជាមួយផ្នែកបំណុល ដែលមានឈ្មោះថា ប្រាក់ដែលបានទទួល (Acceptances outstanding) ហើយត្រូវមានបរិមាណប្រាក់ស្មើគ្នា។

គ. **មូលធនផ្ទាល់** (Equity capital)

មូលធនផ្ទាល់ គឺជាភាគហ៊ុនតំណាងមដោយម្ចាស់ក្រុមហ៊ុន ដែលត្រូវមានដើមទុនក្នុងកម្រិតណាមួយ (អប្បបរិមា) ដើម្បីចាប់ផ្តើមអាជីវកម្ម។ បន្ទាប់មក បង្កើនទុន ដោយទទួលប្រាក់បញ្ញើពីសាធារណជន ខ្ចីបន្ថែមពីទីផ្សារហិរញ្ញវត្ថុ។ ជាក់ស្តែង ធនាគារ គឺជាស្ថាប័នដែលមានគំនាស់ហិរញ្ញវត្ថុ(Financial leverage) ខ្ពស់ជាងគេ (ហិរញ្ញប្បទានដោយប្រើបំណុល)។ ជាទូទៅ ធនាគារពាណិជ្ជ មានមូលធនផ្ទាល់តិចជាង១០% នៃទ្រព្យសរុប។ មូលធនផ្ទាល់ រួមមាន តម្លៃបោះផ្សាយ (Par value) សរុបនៃប័ណ្ណភាហ៊ុនធម្មតា។ នៅពេលប័ណ្ណភាគហ៊ុនលក់បានលើសពីតម្លៃបោះផ្សាយ នោះនឹងត្រូវកត់ត្រាជា អតិរេកមូលធន (Capital surplus)។ ធនាគារពាណិជ្ជមួយចំនួន បោះផ្សាយប័ណ្ណភាគហ៊ុនអាទិភាព (Preferred stock) ដោយធានាម្ចាស់ហ៊ុនថា នឹងផ្តល់ភាគលាភប្រចាំឆ្នាំ មុនពេលម្ចាស់ហ៊ុនធម្មតាទទួលភាគលាភ។

## ៣. របាយការណ៍ចំណេញ-ខាត

របាយការណ៍ចំណេញ-ខាត គឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលកត់ត្រាបរិមាណចំណូលដែលទទួលបាន និងចំណាយដែលបានកើតឡើង **ក្នុងអំឡុងពេលវេលាពិសេសមួយជាកំណត់** ដូចជា ប្រចាំខែ ប្រចាំឆ្នាំ ជាដើម ដែលផ្ទុយពីតារាងតុល្យការ ដែលកត់ត្រាអំពីទ្រព្យសកម្ម បំណុល និងមូលធនផ្ទាល់ **ក្នុងថ្ងៃណាមួយជាក់លាក់**។ ហេតុនេះ របាយការណ៍ចំណេញ-ខាត គឺបង្ហាញពីលំហូរចេញហិរញ្ញវត្ថុ (expenses) និងលំហូរចូលហិរញ្ញវត្ថុ (revenues)។ របាយណ៍ចំណេញ-ខាត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយតារាងតុល្យការ ពីព្រោះ ចំណូលបង្កើតពីទ្រព្យសកម្ម (ដូចជា វិនិយោគមូលប័ត្រ ផ្តល់ឥណទាន)។ បើទ្រព្យនៅក្នុងតារាងតុល្យការប្រែប្រួល នោះនឹងធ្វើឱ្យចំណូលប្រែប្រួលដែរ។ ចំពោះចំណាយ ក៏ដូចគ្នាដែរ ប្រែប្រួលអាស្រ័យលើបំណុលកើនឡើង ឬថយចុះ ពីព្រោះ ចំណាយធំជាងគេ គឺចំណាយការប្រាក់។

តារាង៧.២: គំរូ របាយការណ៍ចំណេញ-ខាត

| បរិយាយ | 31-12-20xx | 31-12-20xx |
|---|---|---|
| ចំណូលការប្រាក់សរុប | $xxx | $xxx |
| ចំណាយការប្រាក់សរុប | xxx | xxx |
| **ចំណូលការប្រាក់សុទ្ធ** | xxx | xxx |
| សំវិធានធនសម្រាប់បំណុលនិងការជួលខាត | xxx | xxx |
| **ចំណូលមិនមែនការប្រាក់សរុប** | xxx | xxx |
| ចំណូលពីថ្លៃសេវាប្រាក់បញ្ញើ | xxx | xxx |
| ចំណេញ-ខាតពីគណនីជួញដូរ | xxx | xxx |
| ចំណូលមិនមែនការប្រាក់ផ្សេងទៀត | xxx | xxx |
| **ចំណាយមិនមែនការប្រាក់សរុប** | xxx | xxx |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ថែម | xxx | xxx |
| ចំណាយទៅលើអចលនទ្រព្យ | xxx | xxx |
| ចំណាយមិនមែនការប្រាក់ផ្សេងទៀត | xxx | xxx |
| ចំណូលប្រតិបត្តិការសុទ្ធមុនបង់ពន្ធ | xxx | xxx |
| ចំណេញ ឬខាតមូលធន (មូលប័ត្រ) | xxx | xxx |
| ប្រាក់ពន្ធត្រូវបង់ | xxx | xxx |
| ចំណូលមុនកាត់កងខ្ទង់ពិសេស | xxx | xxx |
| ចំណេញ-ខាតខ្ទង់ពិសេស (សុទ្ធ) | xxx | xxx |
| **ចំណេញសុទ្ធ** | $xxxx | $xxxx |

### ៣.១. ចំណូលការប្រាក់

ចំណូលការប្រាក់ គឺជាការប្រាក់បានមកពីការផ្តល់ឥណទាន និងការវិនិយោគលើមូលប័ត្រ ដែលមានសមាមាត្រធំជាងគេ ក្នុងចំណូលសរុបរបស់ធនាគារ។

### ៣.២. ចំណាយការប្រាក់

ចំណាយការប្រាក់ គឺជាខ្ទង់ចំណាយធំជាងគេ ជាពិសេស ការចំណាយការប្រាក់ទៅលើប្រាក់បញ្ញើដែលទទួលពីអតិថិជន និងការប្រាក់ទៅលើកម្ចីរយៈពេលខ្លីនៅក្នុងទីផ្សាររូបិយវត្ថុ ឬកម្ចីពីស្ថាប័នសន្សំផ្សេងទៀត។ ចំណាយការប្រាក់ក៏មានផង

ដែរ សម្រាប់បំណុលរយៈពេលវែង ដូចជា បំណុលនិក្ខេប (mortgages) និងប័ណ្ណបំណុល (bank debenture) ជាដើម។

### ៣.៣. ចំណូលការប្រាក់សុទ្ធ

ចំណូលការប្រាក់សុទ្ធ គឺជាផលសងនៃចំណូលការប្រាក់ និងចំណាយការប្រាក់ ដែលជាគន្លឹះក្នុងការកំណត់ប្រាក់ចំណេញរបស់ធនាគារ។

### ៣.៤. ចំណាយលើបំណុលខាត

ចំណាយលើបំណុលខាត ដូចបានបញ្ជាក់រួចមកហើយ ធនាគារអាចកាត់ចំណូលបច្ចុប្បន្ន មុនការបង់ពន្ធ ដើម្បីបង្វែរទៅសំវិធានធនសម្រាប់បំណុលខាត។ ខ្ទង់បម្រុងនេះ ត្រូវបានចាត់ទុកជាការចំណាយ ដោយសារច្បាប់អនុញ្ញាត ប៉ុន្តែ ជាការចំណាយមិនមែនសាច់ប្រាក់ (non-cash expense)។ គោលបំណងសំខាន់ក្នុងការចាត់ទុកសំវិធានធននេះ ជាចំណាយ គឺដើម្បីការពារចំណូលបច្ចុប្បន្នពីការបង់ពន្ធ។

### ៣.៥. ចំណូលមិនមែនការប្រាក់

ចំណូលមិនមែនការប្រាក់ គឺជាចំណូលបានមកពីការបម្រើសេវាផ្សេងៗ ដូចជា សកម្មភាពទំនុកចិត្ត (សេវាត្រាស្ត៍) ថ្លៃសេវាយកពីគណនីប្រាក់បញ្ញើ ចំណេញមូលធន និងថ្លៃសេវាពីការជួញដូរ និងចំណូលមិនមែនការប្រាក់ផ្សេងទៀត ដូចជា ចំណូលពីធនាគារវិនិយោគ ដើងសារជំនួញមូលប័ត្រ និងចំណូលពីគារបម្រើសេវាធានារ៉ាប់រង ជាដើម។

***សេវាត្រាស៍*** គឺជាការគ្រប់គ្រងទ្រព្យសម្បត្តិរបស់អតិថិជន ដូចជា សាច់ប្រាក់ មូលប័ត្រ ដីធ្លី ឬអាគារ គឺជាទ្រព្យដែលអាចបង្កើតចំណូល និងត្រូវបានផ្តល់សេវាដោយគ្រឹះស្ថានហិរញ្ញវត្ថុ។

### ៣.៦. ចំណាយមិនមែនការប្រាក់

ចំណាយមិនមែនការប្រាក់ គឺជាចំណាយប្រតិបត្តិការ ដូចជា ប្រាក់ឈ្នួលប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ថែមសម្រាប់បុគ្គលិក ចំណាយថែរក្សាទ្រព្យ

សម្បត្តិ ចំណាយទិញគ្រឿងសង្ហារឹម និងឧបករណ៍សម្ភារៈ ចំណាយជួលការិយាល័យ (ដែលបង្ហាញក្នុងចំណាយអចលនទ្រព្យ និងឧបករណ៍សម្ភារៈ) និងការចំណាយទៅលើឧបករណ៍ប្រើប្រាស់តូចតាចផ្សេងទៀត។

### ៣.៧. ចំណូលប្រតិបត្តិការសុទ្ធ និងចំណូលសុទ្ធ

ចំណូលប្រតិបត្តិការសុទ្ធ និងចំណូលសុទ្ធ គឺជាផលបូកនៃចំណូលការប្រាក់សុទ្ធ និងចំណូលមិនមែនការប្រាក់សុទ្ធ ឬហៅថា ចំណូលប្រតិបត្តិការសុទ្ធមុនបង់ពន្ធ។ ផ្អែកតាមច្បាប់ពន្ធនៅសហរដ្ឋអាមេរិក ត្រូវបានអនុវត្តដោយយកចំណូលប្រតិបត្តិការសុទ្ធមុនបង់ពន្ធ បូកនឹង ចំណេញ ឬខាតមូលធន ដើម្បីបានចំណូលមុនកាត់កងខ្ទង់ពិសេស ហើយចុងក្រោយ នឹងទទួលបានចំណូសុទ្ធ[48]។

## ៤. របាយការណ៍លំហូរសាច់ប្រាក់

របាយការណ៍លំហូរសាច់ប្រាក់ គឺជារបាយការណ៍ហិរញ្ញវត្ថុ ដែលសង្ខេបពីបរិមាណសាច់ប្រាក់និងសមមូលសាច់ប្រាក់ ដែលចូលមកក្នុងធនាគារ និងចេញពីធនាគារទៅវិញ។ សមាសធាតុសំខាន់ៗនៃលំហូរសាច់ប្រាក់ គឺ លំហូរចូលសាច់ប្រាក់ និងលំហូរចេញសាច់ប្រាក់។

គោលបំណងសំខាន់នៃរបាយការណ៍លំហូរសាច់ប្រាក់ គឺបង្ហាញពីស្ថានភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ធនាគារ ជាពិសេស ផ្តល់ព័ត៌មានថា តើធនាគារអាចបង្កើតចំណូលសាច់ប្រាក់បានគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចទូទាត់បំណុល សងអ្នកផ្ញើដែលត្រូវដកប្រាក់វិញ បំពេញតម្រូវការសំណើឥណទានថ្មីរបស់អតិថិជន និងចំណាយប្រតិបត្តិការផ្សេងទៀតបានដែរឬទេ? ផ្អែកលើលទ្ធផលនៃរបាយការណ៍នេះធ្វើឱ្យធនាគារចាត់វិធានការបានទាន់ពេលវេលា និងសមស្របទៅនឹងស្ថានភាពសាច់ប្រាក់ដែលកំពុងប្រឈម។ របាយការណ៍លំហូរសាច់ប្រាក់ មានសារៈសំខាន់ ដើម្បីបំពេញបន្ថែមទៅលើព័ត៌មាន ដែលបង្ហាញនៅក្នុងតារាងតុល្យការ និងរបាយការណ៍ចំណេញ-ខាតរបស់ធនាគារ។ របាយការណ៍លំហូរសាច់ប្រាក់ អាចត្រូវបានបែងចែកជាពីរផ្នែក និងមានធាតុផ្សំសំខាន់ៗ ដូចមានក្នុងតារាងខាងក្រោម៖

---

[48] Peter S. Rose, *Bank Managemnt & Financial Services*, Seventh Edition, 2008.

តារាង៧.៣: លំហូរសាច់ប្រាក់សង្ខេប

| ប្រភពទុន (លំហូរចូលសាច់ប្រាក់) | ការប្រើប្រាស់ទុន (លំហូរចេញសាច់ប្រាក់) |
|---|---|
| ▪ ចំណេញសុទ្ធ<br>▪ ចំណាយមិនមែនការប្រាក់<br>▪ ការថយចុះទ្រព្យ<br>▪ ការកើនឡើងបំណុល<br>▪ ការកើនឡើងមូលធន | ▪ ខាតសុទ្ធ<br>▪ ចំណាយភាគលាភ<br>▪ ការកើនឡើងទ្រព្យ<br>▪ ការថយចុះបំណុល<br>▪ ការថយចុះមូលធន |
| ប្រភពទុនសរុប ឬ<br>( លំហូរចូលសាច់ប្រាក់សរុប ) | ការប្រើប្រាស់ទុនសរុប ឬ<br>( លំហូរចេញសាច់ប្រាក់សរុប ) |

**សន្ទនីយភាពសុទ្ធ = លំហូរចូលសាច់ប្រាក់សរុប – លំហូរចេញសាច់ប្រាក់សរុប**

ក្នុងការអនុវត្តជាក់ស្តែង សន្ទនីយភាពសុទ្ធ អាចមានលទ្ធផលបីយ៉ាង៖

- បើសន្ទនីយភាពសុទ្ធ វិជ្ជមាន មានន័យថា ធនាគារមានសាច់ប្រាក់នៅក្នុងដៃ។ បើបរិមាណប្រាក់នៅសល់ក្នុងកម្រិតសមល្មម ដើម្បីបំពេញតម្រូវការនោះមិនមានបញ្ហាសម្រាប់ធនាគារទេ។ ប៉ុន្តែ បើបរិមាណប្រាក់នៅសល់ច្រើនពេក លើសពីតម្រូវការ មានន័យថា ធនាគារសល់សាច់ប្រាក់ទំនេរ។ ហេតុនេះ ធនាគារត្រូវប្រើប្រាស់សាច់ប្រាក់ទាំងនោះក្នុងការវិនិយោគ ដើម្បីទទួលបានចំណូលការប្រាក់។
- ផ្ទុយទៅវិញ បើសន្ទនីយភាពសុទ្ធ អវិជ្ជមាន មានន័យថា ធនាគារមិនមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវទេ។ ហេតុនេះ ធនាគារត្រូវរិះរកមធ្យោបាយដោះស្រាយ ដូចជា ខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ឬ លក់ទ្រព្យរយៈពេលខ្លី (ប័ណ្ណរតនាគារ ផលប័ត្រពាណិជ្ជកម្ម) ដើម្បីបំពេញតម្រូវកង្វះខាតសាច់ប្រាក់នោះ។

- បើសន្ទនីយភាពសុទ្ធ ស្មើសូន្យ មានន័យថា ធនាគារមានសាច់ប្រាក់ល្មម គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង សន្ទនីយភាពសុទ្ធស្មើសូន្យ កម្រនឹងកើតឡើងណាស់។ ហេតុនេះ គេអាចនិយាយបាន ត្រឹមថា ធនាគារមានតុល្យភាពសាច់ប្រាក់[49]៕

[49] Peter S. Rose, *Commercial Bank Managemnt*, 2003.

# មេរៀនទី៨

# ការវាស់វែង និងវាយតម្លៃប្រតិបត្តិការរបស់ធនាគារ

# ( Measuring and Evaluating Performamnce of Banks )

## ១. សញ្ញាណទូទៅ

នៅក្នុងមេរៀនទី៧ យើងបានសិក្សាអំពីរបាយការណ៍ហិរញ្ញវត្ថុ ដែលជាលទ្ធផលនៃប្រតិបត្តិការរបស់អង្គភាពធនាគារ។ នៅក្នុងមេរៀននេះ យើងនឹងលើកយករបាយការណ៍ហិរញ្ញវត្ថុទាំងនោះ ដើម្បីសិក្សាបន្ត ដោយប្រើប្រាស់ឧបករណ៍វិភាគ និងវាយតម្លៃទៅលើលទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ។ គោលបំណងសំខាន់នៃការវិភាគ និងវាយតម្លៃនេះ គឺដើម្បីផ្តល់ឱ្យអ្នកគ្រប់គ្រង អាចកំណត់បានច្បាស់នូវបញ្ហាគន្លឹះ និងរិះរកមធ្យោបាយសមស្រប សម្រាប់ដោះស្រាយបញ្ហាប្រឈម និងឈានទៅសម្រេចបានលទ្ធផលកាន់តែប្រសើរឡើង នាពេលអនាគត។ លទ្ធផលនៃការវិភាគ និងដំណោះស្រាយនេះ ក៏មានសារៈសំខាន់ សម្រាប់ភាគីពាក់ព័ន្ធផ្សេងទៀត ដូចជា វិនិយោគិន អ្នកផ្គត់ផ្គង់ និងសាធារណជន យកទៅពិចារណា និងធ្វើសេចក្តីសម្រេចចិត្តថា តើត្រូវបន្តវិនិយោគជាមួយ ឬផ្គត់ផ្គង់ឱ្យ ធនាគារទៀត ឬយ៉ាងណា?

គេអាចវិភាគរបាយការណ៍ហិរញ្ញវត្ថុ តាមមធ្យោបាយផ្សេងៗ ដូចជា វិភាគតាមខ្សែឈរ និងខ្សែដេក វិភាគដោយវាយតម្លៃសន្លឹកហ៊ុន និង វិភាគដោយប្រើអនុបាតហិរញ្ញវត្ថុ។

## ២. វិភាគតាមខ្សែឈរ និងខ្សែដេក

### ២.១. វិភាគតាមខ្សែឈរ ( Vertical analysis )

វិភាគតាមខ្សែឈរ គឺជាការប្រៀបធៀប ដោយពិនិត្យមើលរបាយការណ៍ចំណេញ-ខាត ពីលើចុះក្រោម ដើម្បីធ្វើការប្រៀបធៀបខ្ទង់ផ្សេងៗ ជាមួយនឹងចំណូល ដោយគិតជាភាគរយ។ ធ្វើបែបនេះ យើងអាចដឹងបានថា ចំណាយក្នុងគ្រានីមួយៗ កើនឡើង ឬថយចុះ ធៀបនឹងចំណូល។

តារាង៨.១ បង្ហាញពីចំណូល ចំណាយ និងចំណេញ-ខាត ក្នុងរយៈពេលបីឆ្នាំ (ក្នុងតារាងផ្នែកខាងឆ្វេង)។ ផ្អែកតាមតារាងនេះ យើងអាចគណនាខ្ទង់ចំណូល និងចំណាយទាំងអស់ធៀបនឹងចំណូលសរុប។ ហេតុនេះ យើងបានលទ្ធផលជាអត្រាភាគរយធៀបនឹងចំណូល ដូចមាននៅក្នុងតារាងផ្នែកខាងស្តាំ។ ក្នុងចំណូល១០០ដុល្លារ គេត្រូវចំណាយទៅលើថ្លៃដើមទំនិញដែលបានលក់ចេញ៦០ដុល្លារ សម្រាប់ឆ្នាំ២០២០ ប៉ុន្តែ គេត្រូវចំណាយរហូតដល់ ៦៩ដុល្លារ សម្រាប់ឆ្នាំ២០១៩ និង ៨៣ ដុល្លារ សម្រាប់ឆ្នាំ២០១៨។ ចំពោះ ចំណេញដុលវិញ យើងសង្កេតឃើញថា ក្នុងចំណូល១០០ដុល្លារ គេអាចទទួលបានចំណេញដុល ចំនួន៤០ដុល្លារ សម្រាប់ឆ្នាំ២០២០ ប៉ុន្តែ គេទទួលបានតែ ៣១ដុល្លារប៉ុណ្ណោះ សម្រាប់ឆ្នាំ២០១៩ និង ១៧ ដុល្លារ សម្រាប់ឆ្នាំ២០១៨។ លទ្ធផលនេះ មានន័យថា ក្នុងឆ្នាំ២០២០ ការគ្រប់គ្រងចំណាយថ្លៃដើមបានល្អប្រសើរ ឬមានប្រសិទ្ធភាពជាង ធៀបនឹងឆ្នាំ២០១៩ និងឆ្នាំ២០១៨។

ខ្ទង់ចុងក្រោយគេ គឺ ចំណេញសុទ្ធ។ ក្នុងចំណូល១០០ដុល្លារ គេអាចទទួលបានចំណេញសុទ្ធ១៦ដុល្លារ បើធៀបនឹងឆ្នាំ២០១៩ ក្នុងចំណូល១០០ដុល្លារ គេទទួលបានតែ៧ដុល្លារប៉ុណ្ណោះ។ រីឯ ឆ្នាំ២០១៨ ក្នុងចំណូល១០០ដុល្លារ គេទទួលរងការខាតបង់៧ដុល្លារ។

**តារាង៨.១: របាយការណ៍ចំណេញ-ខាត និងការវិភាគតាមខ្សែឈរ**

| (គិតជាលានដុល្លារ) | នៅចុងឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ២០២០ | ២០១៩ | ២០១៨ | នៅចុងឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|---|---|---|
| ចំណូល | 6,500 | 4,500 | 3,500 | 100% | 100% | 100% |
| ចំណាយថ្លៃដើមទំនិញដែលបានលក់ចេញ | (3,900) | (3,100) | (2,900) | -60% | -69% | -83% |
| ចំណេញដុល | 2,600 | 1,400 | 600 | 40% | 31% | 17% |
| រំលស់ | (600) | (510) | (430) | -9% | -11% | -12% |
| ចំណាយរដ្ឋបាល | (350) | (350) | (350) | -5% | -8% | -10% |
| ចំណាយការប្រាក់ | (55) | (55) | (55) | -0.8% | -1% | -2% |
| ចំណេញមុនបង់ពន្ធ | 1,595 | 485 | -235 | 24.5% | 10.8% | -7% |
| ប្រាក់ពន្ធ | (558) | (170) | 00 | -8.6% | -3.8% | 0% |
| ចំណេញសុទ្ធ | 1,037 | 315 | -235 | 16% | 7% | -7% |

## ២.២. វិភាគតាមខ្សែដេក ( Horizontal analysis )

វិភាគតាមខ្សែដេក គឺជាការប្រៀបធៀបរវាងឆ្នាំថ្មី និងឆ្នាំចាស់ ដើម្បីរកឃើញកំណើនពីមួយឆ្នាំទៅមួយឆ្នាំ។ ដើម្បីគណនា យើងត្រូវយកតម្លៃនៃគ្រាទីN ចែកនឹងតម្លៃនៃគារទី N-1 បន្ទាប់មក យកលទ្ធផលនៃផលចែកនោះ ដកនឹង១។ យើងនឹងបានលទ្ធផល បម្រែបម្រួលជាភាគរយ ដូចក្នុងតារាង៦.២ ផ្នែកខាងស្តាំ។

លទ្ធផលបង្ហាញថា ចំណូលឆ្នាំ២០២០ បានកើនឡើង៤៤% ធៀបនឹងឆ្នាំ២០១៩ ហើយឆ្នាំ២០១៩ បានកើនឡើង២៩% ធៀបនឹងឆ្នាំ២០១៨។ ចំណែកចំណាយថ្លៃដើមទំនិញដែលបានលក់វិញ ក្នុងឆ្នាំ២០២០ បានកើនឡើង២៦% ធៀបនឹងឆ្នាំ២០១៩ ហើយឆ្នាំ២០១៩ បានកើនឡើង០.៧% ធៀបនឹងឆ្នាំ២០១៨។ តួលេខចុងក្រោយគេ គឺចំណេញសុទ្ធ នៅឆ្នាំ២០២០ បានកើនឡើង២២៩% ធៀបនឹងឆ្នាំ២០១៩ ហើយឆ្នាំ២០១៩ បានកើនឡើង២៣៤% ធៀបនឹងឆ្នាំ២០១៨។ រីឯឆ្នាំ២០១៨ យើងមិនមានឆ្នាំគោល ២០១៧ ដើម្បីធ្វើការប្រៀបធៀបទេ។

**តារាង៨.២: របាយការណ៍ចំណេញ-ខាត និងការវិភាគតាមខ្សែដេក**

| (គិតជាលានដុល្លារ) | នៅចុងឆ្នាំ ថ្ងៃទី៣១ ខែធ្នូ | | | នៅចុងឆ្នាំ ថ្ងៃទី៣១ ខែធ្នូ | | |
|---|---|---|---|---|---|---|
| | ២០២០ | ២០១៩ | ២០១៨ | ២០២០ | ២០១៩ | ២០១៨ |
| ចំណូល | 6,500 | 4,500 | 3,500 | 44% | 29% | na |
| ចំណាយថ្លៃដើមទំនិញដែលបានលក់ | (3,900) | (3,100) | (2,900) | 26% | 0.7% | na |
| ចំណេញដុល | 2,600 | 1,400 | 600 | 86% | 133% | na |
| រំលស់ | (600) | (510) | (430) | 18% | 19% | na |
| ចំណាយរដ្ឋបាល | (350) | (350) | (350) | 0% | 0% | na |
| ចំណាយការប្រាក់ | (55) | (55) | (55) | 0% | 0% | na |
| ចំណេញមុនបង់ពន្ធ | 1,595 | 485 | -235 | 229% | 306% | na |
| ប្រាក់ពន្ធ | (558) | (170) | 00 | 228% | na | na |
| ចំណេញសុទ្ធ | 1,037 | 315 | -235 | 229% | 234% | na |

## ៣. វិភាគអនុបាតហិរញ្ញវត្ថុ

ការវិភាគដោយប្រើអនុបាតហិរញ្ញវត្ថុ គេអាចចែកជាបួនផ្នែកសំខាន់ៗ ដូចជា អនុបាតចំណេញ អនុបាតសន្ទនីយភាព អនុបាតសកម្មភាព ឬអនុបាតប្រើប្រាស់ទ្រព្យ និងអនុបាតបំណុល។

### ៣.១. អនុបាតចំណេញ

អនុបាតចំណេញ គឺជាអនុបាតវាស់វែងពីសកម្មភាពប្រតិបត្តិការរបស់ធនាគារ ដើម្បីបង្កើតផលចំណេញ។ អនុបាតចំណេញ រួមមាន៖

$$\text{Return on equity (ROE)} = \frac{\text{Net income (NI)}}{\text{Total equity capital}}$$

ROE ជាអត្រាផលចំណេញសុទ្ធធៀបនឹងមូលធនផ្ទាល់។ ម្ចាស់ក្រុមហ៊ុន ឬម្ចាស់ភាគហ៊ុន យកចិត្តទុកដាក់ចំពោះអនុបាតនេះ ពីព្រោះ វាទាក់ទងនឹងការបែងចែកផលចំណេញ ឬបែងចែកភាគលាភរបស់ក្រុមហ៊ុន។

$$\text{Return on assets (ROA)} = \frac{\text{Net income (NI)}}{\text{Assets}}$$

ROA គឺជាអត្រាផលចំណេញសុទ្ធធៀបនឹងទ្រព្យសកម្មសរុប ដែលឆ្លុះពីការបែងចែក និងប្រើប្រាស់ទ្រព្យក្នុងការវិយោគ ប្រកបដោយប្រសិទ្ធភាពដែរ ឬទេ? បើធនាគារបែងចែកទុនវិនិយោគបានសមស្រប នោះនឹងធ្វើឱ្យ ROA កើនឡើង។

$$\text{Net interest margin (NIM)} = \frac{\text{Interest income} - \text{Interest expenses}}{\text{Total assets}}$$

NIM គឺជាកម្រិតចំណូលការប្រាក់សុទ្ធ ធៀបនឹងទ្រព្យសកម្មសរុប ដែលបង្ហាញពីចំណូលការប្រាក់ដែលទទួលបាន ដើម្បីធានាទៅលើការចំណាយការប្រាក់។ បើ NIM វិជ្ជមាន មានន័យថា ចំណូលការប្រាក់គ្រប់គ្រាន់ ដើម្បីចំណាយសងការប្រាក់ និងនៅសល់ជាផលចំណេញសម្រាប់ធនាគារផង។

$$\text{Net non-interest margin (NNIM)} = \frac{\text{Non-interest revenues} - \text{Non-int. expenses}}{\text{Total assets}}$$

NNIM គឺជាកម្រិតចំណូលមិនមែនការប្រាក់សុទ្ធ ធៀបនឹងទ្រព្យសកម្មសរុប បង្ហាញពីចំណូលដែលទទួលបានពីការបម្រើសេវាផ្សេងៗ ដើម្បីជានាទូទាត់ចំណាយមិនមែនការប្រាក់។ ជាទូទៅ កម្រិតចំណូលមិនមែនការប្រាក់សុទ្ធ អវិជ្ជមាន ដោយសារ ចំណូលមិនមែនការប្រាក់ដែលទទួលបាន មិនគ្រប់គ្រាន់ ដើម្បីជានាចំណាយទៅលើប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ និងចំណាយមិនមែនការប្រាក់ផ្សេងទៀតបានទេ។

$$\text{Net operating margin (NOM)} = \frac{\text{Operating revenues} - \text{Operating expenses}}{\text{Total assets}}$$

NOM គឺជាកម្រិតចំណូលប្រតិបត្តិការសុទ្ធ ធៀបនឹងទ្រព្យសកម្មសរុប បង្ហាញពីចំណូលសរុបដែលទទួលបានពីចំណូលការប្រាក់ និងចំណូលមិនមែនការប្រាក់ ដើម្បីជានាលើចំណាយប្រតិបត្តិការទាំងមូលរបស់ធនាគារ។

$$\text{Earning per share (EPS)} = \frac{\text{Net income}}{\text{Common equity share outstanding}}$$

EPS គឺជាប្រាក់ចំណេញសុទ្ធ ដែលធនាគារទទួលបាន សម្រាប់១ភាគហ៊ុន។ ប្រាក់ចំណេញក្នុង១ភាគហ៊ុន ត្រូវបានបែងចែកជាពីរ គឺ ភាគលាភក្នុង១ភាគហ៊ុន និងប្រាក់ចំណេញដែលត្រូវរក្សាទុក ឬប្រាក់ចំណេញមិនបែងចែក ក្នុង១ភាគហ៊ុន។

$$\text{Earning spread (ESP)} = \frac{\text{Total interest income}}{\text{Total earning assets}} - \frac{\text{Total interest expenses}}{\text{Total int.-bearing}}$$

កម្រិតចំណេញ (ESP) វាស់វែងអំពីប្រសិទ្ធភាពរបស់ធនាគារ ក្នុងការបំពេញតួនាទីជាអន្តរការីយកម្ម ដោយខ្ចីប្រាក់ ឬទទួលប្រាក់បញ្ញើ និងផ្តល់ឱ្យខ្ចី ព្រមទាំងជំរុញការប្រកួតប្រជែងនៅក្នុងទីផ្សារ។ ការប្រកួតប្រជែងកាន់តែខ្លាំងក្លាឡើង នោះនឹងធ្វើឱ្យភាពខុសគ្នា រវាងអត្រាចំណូលមធ្យមពីទ្រព្យសកម្ម និងអត្រាចំណាយមធ្យមទៅលើបំណុលកាន់តែខ្លាំងដែរ។ ឧបមាថា បើកត្តាផ្សេងៗមិនមានឥទ្ធិពលទេនោះ ESP នឹងថយចុះកាន់តែទាប នៅពេលដែលការប្រកួតប្រជែងកាន់តែខ្លាំងឡើង បង្ខំឱ្យអ្នកគ្រប់គ្រងត្រូវរកមធ្យោបាយ ដើម្បីបង្កើតចំណូលពីសេវាកម្មថ្មីៗ បំពេញទៅលើ ESP ដែលរួញថយ។

យោងលើទ្រឹស្តីនៃប្រភាគ គេអាចគុណជាមួយនឹងភាគយក និងភាគបែង ដោយចំនួនមួយដូចគ្នា ធ្វើឱ្យប្រភាគនោះនៅរក្សាតម្លៃដើមរបស់វាដដែល។ ហេតុនេះ យើងបាន៖

$$ROE = \frac{\text{Net income}}{\text{Equity capital}} \times \frac{\text{Total operating revenues}}{\text{Total operating revenues}} \times \frac{\text{Total assets}}{\text{Total assets}}$$

បន្ទាប់មក ប្តូរទីតាំងអង្គទាំងបីនៃប្រភាគ យើងបាន៖

$$ROE = \frac{\text{Net income}}{\text{Total operating revenues}} \times \frac{\text{Total operating revenues}}{\text{Total assets}} \times \frac{\text{Total assets}}{\text{Equity caoital}}$$

ROE = Net profit margin x Asset utilization x Equity multiplier

សរុបមក យើងបានរូបមន្តបីផ្សេងទៀត ដែលជាអនុបាតបំបែកពី ROE ធ្វើឱ្យវិភាគ និងវាយតម្លៃបានកាន់តែលម្អិត ទៅលើប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ធនាគារ។

$$NPM = \frac{\text{Net income}}{\text{Total operating revenues}}$$

$$AU = \frac{\text{Total operating revenues}}{\text{Total assets}}$$

$$EM = \frac{\text{Total assets}}{\text{Equity}}$$

អនុបាតទាំងបីខាងលើ អាចបកស្រាយក្នុងអត្ថន័យនៃប្រសិទ្ធភាពគ្រប់គ្រងដូចខាងក្រោម៖

- NPM បង្ហាញពីប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ និងគោលនយោបាយកំណត់ថ្លៃសេវា។ បើ NPM កើនឡើង បញ្ជាក់ថា ការគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាព។ ផ្ទុយទៅវិញ បើ NPM ថយចុះ មានន័យថា ការគ្រប់គ្រងចំណាយមិនប្រសើរទេ ដែលធនាគារត្រូវពិនិត្យមើលខ្ទង់ចំណាយ

ផ្សេងៗឡើងវិញ តើមានខ្ទង់ចំណាយណាមិនប្រក្រតី ហើយកើនឡើងខ្ពស់ ដែលត្រូវកែលម្រួល។

- AU បង្ហាញពីគោលនយោបាយគ្រប់គ្រងការវិនិយោគ ឬ បែងចែកមូលធន វិនិយោគ ជាពិសេស ការវិនិយោគចម្រុះ (investment in mixes) ដែល មានអត្រាចំណូលផ្សេងៗគ្នា ហើយកម្រិតហានិភ័យដែលប្រឈមក៏ផ្សេងគ្នា។ ធ្វើបែបនេះ ដើម្បីបញ្ចៀសមិនឱ្យធនាគារប្រឈមនឹងហានិភ័យខ្ពស់ពេក។ ប៉ុន្តែ បើមិនប្រឈមនឹងហានិភ័យសោះ នោះធនាគារក៏មិនងាយនឹងទទួល ជោគជ័យដែរ ពីព្រោះទទួលបានចំណូលទាប។ បើ AU កើនឡើង មានន័យ ថា ការបែងចែកមូលធនវិនិយោគសមស្រប ពីព្រោះ ចំណូលប្រតិបត្តិការ កើនឡើងធៀបនឹងទ្រព្យសរុប។ ផ្ទុយមកវិញ បើ AU ថយចុះ បញ្ជាក់ថា ការ បែងចែកមូលធនវិនិយោគមិនទាន់ប្រសើរនៅឡើយ ដែលធនាគារត្រូវពិនិត្យ មើលការវិនិយោគទាំងនោះឡើងវិញ ដើម្បីកែសម្រួល។
- EM បង្ហាញពីគំនាស់ហិរញ្ញវត្ថុ ឬគោលនយោបាយផ្តល់ហិរញ្ញប្បទាន ដោយ សម្រេចចិត្តជ្រើសយកប្រភពទុន ដើម្បីបង្កើតការវិនិយោគ។ មធ្យោបាយពីរ យ៉ាង ដែលធនាគារអាចជ្រើសរើសបាន គឺ បង្កើនការវិនិយោគ ដោយប្រើ ប្រាស់បំណុល ឬ មូលធន។ បើ EM កើនឡើង មានន័យថា ធនាគារបង្កើន ការវិនិយោគ ដោយប្រើបំណុល។ បើបំណុលកើនឡើងកាន់តែខ្ពស់ នោះ ការប្រឈមហានិភ័យក៏កាន់តែខ្ពស់ ប៉ុន្តែ លទ្ធភាពទទួលបានចំណូលក៏ខ្ពស់ ដែរ។ ផ្ទុយមកវិញ បើ EM ថយចុះកាន់តែទាប បញ្ជាក់ថា ធនាគារបង្កើនកា រវិនិយោគ ដោយបង្កើនមូលធន ធ្វើឱ្យ សមាមាត្របំណុលធៀបនឹងទ្រព្យ ថយចុះ។ បើបំណុលថយចុះ មានន័យថា ការប្រឈមហានិភ័យទាប ប៉ុន្តែ លទ្ធភាពទទួលចំណូលក៏ថយចុះទាបដែរ (High risks high returns, low risks low returns)៕

# ជំពូក៥

# ធនាគារកណ្ដាល និង
# គោលនយោបាយរូបិយវត្ថុ

# មេរៀនទី៩

## ធនាគារកណ្ដាល និងតួនាទី

## ( Central Bank and Roles )

### ១. សញ្ញាណទូទៅ

ក្នុងចំណោមភាគីសំខាន់ៗ ដែលចូលរួមធ្វើសកម្មភាពនៅក្នុងទីផ្សារហិរញ្ញវត្ថុ និងនៅក្នុងវិស័យសេដ្ឋកិច្ច គឺមានធនាគារកណ្តាល ដែលជាស្ថាប័នរដ្ឋាភិបាល ទទួលបន្ទុកគោលនយោបាយរូបិយវត្ថុ។ ធនាគារកណ្តាល គឺជាអាជ្ញាធរជាតិឯករាជ្យ ដោយកាត់ផ្តាច់ពីតួនាទីរបស់អ្នកនយោបាយ ឬរដ្ឋាភិបាល ហើយមានភារកិច្ចដឹកនាំ និងធ្វើប្រតិបត្តិការគោលនយោបាយរូបិយវត្ថុ គ្រប់គ្រងធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត និងផ្តល់សេវាកម្មហិរញ្ញវត្ថុ រួមទាំងការសិក្សាស្រាវជ្រាវនៅក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចជាតិទាំងមូល។ ធនាគារកណ្តាល ជាភ្នាក់ងាររបស់រដ្ឋាភិបាល ដែលមានតួនាទីក្នុងការផ្តល់អាជ្ញាប័ណ្ណ និងអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងវិស័យធនាគារ ព្រមទាំងត្រួតពិនិត្យ និងតាមដានប្រតិបត្តិការរបស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ សកម្មភាពចម្បងរបស់ធនាគារកណ្តាល គឺធ្វើអន្តរាគមន៍ទៅលើអត្រាការប្រាក់ ទំហំឥណទាន និងការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ដែលកត្តាទាំងនេះ នឹងធ្វើឱ្យមានឥទ្ធិពលដោយផ្ទាល់ទៅលើទីផ្សារហិរញ្ញវត្ថុ ផលិតផលសង្គមសរុប និងអត្រាអតិផរណា។ ធនាគារកណ្តាលជាអ្នកដាក់ចេញនូវគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានផ្សេងៗទៀត ដើម្បីឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ទទួលយកទៅអនុវត្ត និងរាយការណ៍ជាប្រចាំពីសកម្មភាពប្រតិបត្តិការរបស់ខ្លួន តាមការកំណត់របស់ធនាគារកណ្តាល។

ធនាគារកណ្តាល ធ្វើប្រតិបត្តិការតាមរចនាសម្ព័ន្ធពីរផ្សេងគ្នា គឺ ប្រព័ន្ធធនាគារដែលមានមួយថ្នាក់ និងប្រព័ន្ធធនាគារដែលមានពីរថ្នាក់។ *ប្រព័ន្ធធនាគារមួយថ្នាក់* ( mono-banking system ) គឺជាប្រព័ន្ធធនាគារ ដែលមានធនាគារមួយបំពេញតួនាទីជាធនាគារកណ្តាលផង និងបំពេញតួនាទីជាធនាគារពាណិជ្ជផង។ ចំណែក *ប្រព័ន្ធធនាគារពីរថ្នាក់* ( two-tier banking system ) គឺជាការបែងចែក

ដាច់ពីគ្នា រវាងតួនាទីរបស់ធនាគារកណ្តាល និងតួនាទីរបស់ធនាគារពាណិជ្ជ។ ពោល គឺ ធនាគារកណ្តាលមិនត្រូវបានអនុញ្ញាតឱ្យបម្រើសេវាហិរញ្ញវត្ថុ ចំពោះអតិថិជនដោយផ្ទាល់បានទេ ប៉ុន្តែ ធនាគារកណ្តាលមានសិទ្ធិផ្តល់ឱ្យខ្ចីចំពោះធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយក៏អាចឱ្យរដ្ឋាភិបាលខ្ចីបានដែរ នៅពេលមានតម្រូវការសាច់ប្រាក់។

## ២. តួនាទីរបស់ធនាគារកណ្តាល

ជាទូទៅ នៅក្នុងប្រទេសនីមួយៗ តែងមានគោលនយោបាយធំៗពីរ គឺគោលនយោបាយសារពើពន្ធ និងគោនយោបាយរូបិយវត្ថុ។ គោលនយោបាយសារពើពន្ធជាឧបករណ៍គោលនយោបាយ ដ៏មានសារៈសំខាន់បំផុតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណែក គោលនយោបាយរូបិយវត្ថុវិញ ស្ថិតនៅក្រោមការត្រួតត្រារបស់ធនាគារកណ្តាល។ គោលនយោបាយទាំងពីរ មានគោលដៅរួមដូចគ្នា គឺ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមមធ្យោបាយផ្សេងគ្នា។ ក្នុងផ្នែកនេះ យើងលើកយកតែតួនាទីរបស់ធនាគារកណ្តាល ដែលមានភារកិច្ចក្នុងការដាក់ចេញ និងតាមដានការអនុវត្តគោលនយោបាយរូបិយវត្ថុ មកអធិប្បាយពន្យល់។ ធនាគារកណ្តាលនៃប្រទេសនីមួយៗ មានតួនាទីសំខាន់ៗ៥យ៉ាងដូចតទៅ៖

### ២.១. ការគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ ( Control of the money supply )

បរិមាណប្រាក់កំពុងប្រើប្រាស់នៅក្នុងចរាចរណ៍ មានឥទ្ធិពលក្នុងក្របខ័ណ្ឌមីក្រូសេដ្ឋកិច្ចផង និងម៉ាក្រូសេដ្ឋកិច្ចផង។ នៅក្នុងកម្រិតមីក្រូសេដ្ឋកិច្ច ការផ្គត់ផ្គង់ប្រាក់កាន់តែច្រើន ធ្វើឱ្យការចំណាយរបស់ប្រជាពលរដ្ឋ និងអាជីវកម្ម កើនឡើងកាន់តែខ្ពស់។ បុគ្គលម្នាក់ៗមានភាពងាយស្រួល ក្នុងការទទួលបានឥណទាន ដូចជាឥណទានរថយន្ត ឥណទាននិក្ខេប ជាដើម។ ក្រុមហ៊ុនក៏មានភាពងាយស្រួលក្នុងការធានាហិរញ្ញប្បទានពីអង្គភាពធនាគារផងដែរ។ ចំណែក នៅក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ចវិញ បរិមាណប្រាក់កំពុងធ្វើចរាចរណ៍នៅក្នុងសេដ្ឋកិច្ច មានឥទ្ធិពលទៅលើចំណូលក្នុងស្រុកសរុប កំណើនប្រកបដោយបរិយាប័ណ្ណ អត្រាការប្រាក់ និងអត្រានិកម្មភាព។ ធនាគារកណ្តាលមានតួនាទី ក្នុងការកំណត់បរិមាណប្រាក់នៅក្នុងចរាចរណ៍ឱ្យសម

ល្មម ដើម្បីសម្រេចគោលដៅសេដ្ឋកិច្ច និងមានឥទ្ធិពលទៅលើគោលនយោបាយរូបិយវត្ថុ។ ការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសកម្មភាពសេដ្ឋកិច្ច និងអតិផរណា។ បើការផ្គត់ផ្គង់ប្រាក់ច្រើនពេក លើសពីតម្រូវការនៃសកម្មភាពសេដ្ឋកិច្ច នោះនឹងធ្វើឱ្យតម្លៃក្រដាសប្រាក់ចុះថោក ទំនិញនៅក្នុងទីផ្សារឡើងថ្លៃ និងបង្កឱ្យមានអត្រាអតិផរណាខ្ពស់។ ផ្ទុយទៅវិញ បើការផ្គត់ផ្គង់ក្រដាសប្រាក់នៅក្នុងចរាចរណ៍តិចពេកវិញ មិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការសកម្មភាពសេដ្ឋកិច្ច នោះនឹងធ្វើឱ្យប្រឈមនឹងដំណើរធ្លាក់ចុះខ្លាំង នៃសេដ្ឋកិច្ច (Economic recession)។ ប៉ុន្តែ ការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍កើនឡើង មិនមែនសុទ្ធតែធ្វើឱ្យមានអត្រាអតិផរណាខ្ពស់នោះទេ បើការផ្គត់ផ្គង់នោះ ស្របនឹងការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច នោះមិនត្រឹមតែធ្វើឱ្យគ្មានអតិផរណាខ្ពស់ប៉ុណ្ណោះទេ ថែមទាំងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចទៀតផង។ ហេតុនេះ គោលដៅប្រសើរបំផុតនៃការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ គឺធ្វើយ៉ាងណាឱ្យមានសាច់ប្រាក់ល្មមគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការ នោះនឹងជួយជំរុញសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនឡើង និងមិនជំរុញកំណើនអតិផរណាទេ។

### ២.២. ធ្វើឱ្យមានស្ថិរភាពទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន (Stabilizing the money and capital markets)

ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារដែលទិញ ឬលក់ឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី (មិនលើសពីមួយឆ្នាំ)។ ឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី រួមមាន ប័ណ្ណរតនាគារ ផលប័ត្រពាណិជ្ជកម្ម វិញ្ញាបនប័ត្រប្រាក់បញ្ញើ ជាដើម។ ចំណែក ទីផ្សារមូលធនវិញ គឺជាទីផ្សារដែលទិញ ឬលក់ឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែង (លើសពីមួយឆ្នាំ) មានដូចជា ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណ និងប័ណ្ណបំណុលផ្សេងទៀត។ ហេតុនេះ ទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន គឺជាមធ្យោបាយគៀរគរមូលធន ទាំងរយៈពេលខ្លី និងរយៈពេលវែង ពីសាធារណជនដែលមានទុនទំនេរបានមកពីការសន្សំ ដើម្បីបំពេញតម្រូវការវិនិយោគរបស់អង្គភាពអាជីវកម្ម។ អង្គភាពអាជីវកម្មដែលត្រូវការទុនវិនិយោគ មានជម្រើសពីរក្នុងការធ្វើសេចក្តីសម្រេចចិត្តៈ ខ្ចីប្រាក់ពីធនាគារ ឬ បោះផ្សាយមូលប័ត្រ ដើម្បីលក់នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ ចំណែកវិនិយោគិនវិញ មានបំណងទិញឧបករណ៍ហិរញ្ញវត្ថុដើម្បីទទួលបានចំណូលការប្រាក់ ឬភាគលាភខ្ពស់ពីការវិនិយោគ ហើយសង្ឃឹមថា

តម្លៃរបស់វានឹងកើនឡើងនាពេលអនាគត ដែលធ្វើឱ្យទទួលបាននូវចំណេញមូលធន (Capital gains)។ ហេតុនេះ ការធ្វើឱ្យមានស្ថិរភាពទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន គឺជាការការពារផលប្រយោជន៍របស់វិនិយោគិន ដែលបណ្តាក់ទុននៅក្នុងទីផ្សារហិរញ្ញវត្ថុ និងជំរុញលំហូរមូលធនឱ្យមានសកម្មភាពកាន់តែខ្លាំង តាមរយៈទីផ្សារហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ បើទីផ្សារហិរញ្ញវត្ថុមិនមានស្ថិរភាពទេ នោះនឹងធ្វើឱ្យវិនិយោគិនប្រឈមនឹងការខាតបង់ ដោយសារការធ្លាក់ចុះតម្លៃមូលប័ត្រ។ បើប្រឈមនឹងការខាតបង់បែបនេះ វិនិយោគិននឹងមិនវិនិយោគនៅក្នុងទីផ្សារហិរញ្ញវត្ថុទៀតទេ។ ហេតុនេះ ទីផ្សារហិរញ្ញវត្ថុមិនអាចបំពេញតួនាទីបានល្អក្នុងការទាក់ទាញវិនិយោគិន និងមិនអាចគៀគរមូលធន ដើម្បីបំពេញតម្រូវការវិនិយោគរបស់អង្គភាពអាជីវកម្ម និងរដ្ឋាភិបាល បានប្រសើរទេ។

### **២.៣. អ្នកផ្តល់ឱ្យខ្ចីចុងក្រោយ** (Lender of last resort)

ប្រព័ន្ធធនាគារដែលមានពីរថ្នាក់ ត្រូវបានបែងចែកដាច់ពីគ្នា រវាងតួនាទីរបស់ធនាគារកណ្តាល និងធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ ហេតុនេះ ធនាគារកណ្តាល មិនអាចធ្វើសកម្មភាពបម្រើសេវា ដូចជា ទទួលប្រាក់បញ្ញើ ផ្តល់ឥណទាន និងបម្រើសេវាទូទាត់ ចំពោះអតិថិជនដោយផ្ទាល់បានទេ ប៉ុន្តែ មានសិទ្ធិត្រឹមតែផ្តល់ឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ខ្ចីប៉ុណ្ណោះ។ ក្រោយពីទទួលបានអាជ្ញាប័ណ្ណ ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ត្រូវបំពេញភារកិច្ចស្នូលរបស់ខ្លួន ជាពិសេស ការទទួលប្រាក់បញ្ញើពីអតិថិជន ដែលជាប្រភពទុនចម្បង និងមានសមាមាត្រធំ ដើម្បីប្រើប្រាស់ក្នុងការផ្តល់ឥណទាន ឬវិនិយោគមូលប័ត្រ។ បើការប្រមូលទុនតាមរយៈការទទួលប្រាក់បញ្ញើនេះ មិនអាចបំពេញតម្រូវការវិនិយោគបានគ្រប់គ្រាន់ទេ ហើយធនាគារពាណិជ្ជមានសម្ពាធអំពីតម្រូវការសាច់ប្រាក់ ដោយសារ បរិមាណប្រាក់នៅក្នុងចរាចរណ៍មិនគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការនៅក្នុងសេដ្ឋកិច្ច នោះជម្រើសចុងក្រោយ ធនាគារកណ្តាលត្រូវបង្កើនការផ្គត់ផ្គង់ប្រាក់ទៅក្នុងចរាចរណ៍ ដោយផ្តល់ឱ្យខ្ចីចំពោះធនាគារពាណិជ្ជ តាមរយៈអត្រាអប្បហារ (Discount rate) របស់ធនាគារកណ្តាល។ បង្កើនការផ្តល់ឱ្យខ្ចីបែបនេះ នឹងធ្វើឱ្យបរិមាណប្រាក់នៅក្នុងចរាចរណ៍កើនឡើង អត្រាការប្រាក់ធ្លាក់ចុះ និងជំរុញការវិនិយោគ នោះនឹងធ្វើឱ្យសេដ្ឋកិច្ច កាន់តែមានសន្ទុះរីកចម្រើនថែមទៀត។

### ២.៤. អ្នកត្រួតពិនិត្យប្រព័ន្ធធនាគារ ( Supervisor of the banking system )

ធនាគារកណ្តាល មានតួនាទីក្នុងការត្រួតពិនិត្យ វាយតម្លៃការស្នើសុំ និងផ្តល់អាជ្ញាប័ណ្ណដល់ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដើម្បីបម្រើសេវាហិរញ្ញវត្ថុ នៅក្នុងប្រទេសនីមួយៗ។ ម៉្យាងទៀត ធនាគារកណ្តាល ក៏មានតួនាទីក្នុងដាក់ចេញនូវច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយផ្សេងៗ ដើម្បីឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថាហិរញ្ញវត្ថុផ្សេងៗអនុវត្ត។ ជាទូទៅ ច្បាប់ បទប្បញ្ញត្តិ បានចែងពីភារកិច្ចដែលតម្រូវឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុនៅក្រោមឱវាទ រាយការណ៍ជាប្រចាំទៅធនាគារកណ្តាល ដើម្បីពិនិត្យមើល ថាតើ ដំណើរការប្រតិបត្តិរបស់ធនាគារពាណិជ្ជ និងគ្រឹស្ថានហិរញ្ញវត្ថុ បានប្រព្រឹត្តទៅត្រឹមត្រូវដែរឬទេ? បើមានការសង្ស័យថា អាចមានហេតុការណ៍មិនប្រក្រតីកើតឡើង ធនាគារកណ្តាល មានសិទ្ធិចុះទៅត្រួតពិនិត្យដល់ទីកន្លែង ដើម្បីឱ្យប្រាកដថា ហេតុការណ៍នោះកើតឡើងរបៀបណា។ ជារួម យើងអាចនិយាយបានថា ធនាគារកណ្តាលនៃប្រទេសនីមួយៗ ជាធនាគារអាណាព្យាបាល ចំពោះធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ ដែលស្ថិតនៅក្រោមឱវាតរបស់ខ្លួន។

### ២.៥. ថែទាំ និងធ្វើឱ្យប្រសើរឡើងនូវយន្តការទូទាត់ ( Maintaining and improving the payments mechanism )

កំណើននៃការបញ្ជូនផ្ទេរមូលធន ទាំងក្នុងនិងក្រៅប្រទេស គឺ ដោយសារការកើនឡើងនៃកិច្ចការជំនួញ ឆ្លងកាត់ទីផ្សារហិរញ្ញវត្ថុ ក្នុងតំបន់ និងសកលលោក ដែលត្រូវបានធ្វើសមាហរណកម្ម បានបង្កើនបន្ថែមទៀតនូវសារៈសំខាន់នៃប្រព័ន្ធទូទាត់។ ប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងប្រសិទ្ធភាព សមស្របទៅនឹងស្តង់ដាអន្តរជាតិ ដែលធានាបាននូវភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ដោយកាត់បន្ថយហានិភ័យឱ្យនៅកម្រិតអប្បបរមា។ ដោយសារ កិច្ចការនេះ ជួយគាំទ្រដល់គោលនយោបាយរូបិយវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ធនាគារកណ្តាលបំពេញតួនាទីនេះ ដោយធានាភាពរលូន និងជឿជាក់នៃប្រព័ន្ធទូទាត់។ ហេតុនេះ ធនាគារកណ្តាល មានតួនាទីដូចតទៅ៖

- ❖ បង្កើត និងធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ឱ្យបានច្បាស់លាស់ និងមានលក្ខណៈជាប្រព័ន្ធ។
- ❖ ត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធទូទាត់ទាំងអស់ដែលត្រូវបានទទួលស្គាល់ថាជាមុខងាររបស់ធនាគារកណ្តាល ដោយដាក់ចេញនូវចំណុចគន្លឹះ សេចក្តីណែនាំ និងគោលការណ៍ផ្សេងៗ ពាក់ព័ន្ធនឹងការទូទាត់។
- ❖ ដាក់ចេញនូវច្បាប់ឬបទបញ្ញា ដែលពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់ ដោយធានាបាននូវភាពរលូន សុវត្ថិភាព សក្តិសិទ្ធភាព និងប្រសិទ្ធភាព នៃមុខងារប្រព័ន្ធទូទាត់ ដែលធនាគារកណ្តាលត្រូវបានផ្តល់អំណាច និងទទួលខុសត្រូវ ក្នុងការបង្កើតច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

## ៣. គោលដៅរបស់ធនាគារកណ្តាល

គោលដៅសំខាន់ នៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល គឺធ្វើឱ្យមានស្ថិរភាពថ្លៃទំនិញនៅក្នុងទីផ្សារ បង្កើតការងារថ្មី បង្កើនចំណូល កាត់បន្ថយភាពក្រីក្រ ឬជារួម គឺធ្វើឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

### ៣.១. ប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព

ធនធានក្នុងបរិបទនេះ គឺ សំដៅលើធនធានគ្រប់ប្រភេទដែលសង្គមមាន។ ធនធានទាំងនោះ រួមមាន៖ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និង ធនធានផ្សេងទៀត ដូចជា គ្រឿងម៉ាស៊ីន ឧបករណ៍ សម្ភារៈ វត្ថុធាតុដើម ដែលជាកត្តាចាំបាច់មិនអាចខ្វះបាន ដើម្បីបំពេញតម្រូវការរបស់អង្គភាពអាជីវកម្ម ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ច។

#### ក. ធនធានមនុស្ស

ធនធានមនុស្សមានតួនាទីសំខាន់បំផុត ដើម្បីបង្កើតបាននូវធនធានផ្សេងទៀត។ ធនធានមនុស្សគឺជាតម្រូវការចាំបាច់ ដើម្បីដំណើរការសកម្មភាពអាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគ។ បើគ្មានធនធានមនុស្សទេ មិនអាចមានសកម្មភាពផ្សេងៗនៅក្នុងសេដ្ឋកិច្ច សង្គមបានទេ។ ដើម្បីធានាឱ្យមានគំនិតច្នៃប្រឌិត នវានុវត្តន៍ ធនធានមនុស្សត្រូវតែប្រកបដោយគុណភាព និងសមត្ថភាព ដែលទាមទារចាំបាច់

ត្រូវមានការបណ្តុះបណ្តាលច្បាស់លាស់ ទៅតាមវិស័យ ជំនាញ និងបច្ចេកទេស។ ការទាញយកម្លាំងពលកម្មឱ្យចូលបម្រើការងារអស់សក្តានុពល មានន័យថា សេដ្ឋកិច្ច មានសកម្មភាពខ្លាំងក្លា បង្កើតការងារថ្មី និងសម្បូរបែប ដែលជួយបង្កើនកំណើន សេដ្ឋកិច្ច និងលើកស្ទួយកម្រិតស្តង់ដាជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

**ខ. ធនធានហិរញ្ញវត្ថុ**

ធនធានហិរញ្ញវត្ថុ ជាកត្តាសំខាន់មួយទៀតនៅក្នុងសេដ្ឋកិច្ច សង្គម។ យើង ត្រូវការធនធានហិរញ្ញវត្ថុជាចាំបាច់ ដើម្បីបំពេញតម្រូវការវិនិយោគ និងសកម្មភាព សេដ្ឋកិច្ច ផ្សេងទៀត។ បើយើងមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងទាន់ពេល វេលា ដើម្បីបំពេញតម្រូវការវិនិយោគទេ នោះវានឹងធ្វើឱ្យរាំងស្ទះដល់សកម្មភាពសេដ្ឋកិច្ច ប៉ះពាល់ដល់ការងារ និងចំណូល ដែលនឹងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជួបការលំបាក។

**គ. ធនធានផ្សេងទៀត**

បើមានតែធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ប៉ុន្តែ មិនមានគ្រឿងម៉ាស៊ីន ឧបករណ៍ សម្ភារៈ វត្ថុធាតុដើម និងធាតុចូលផ្សេងទៀតទេ ក៏មិនអាចធ្វើឱ្យអង្គភាព អាជីវកម្ម និងការវិនិយោគ អាចដំណើរការបានដែរ ពោលគឺ ត្រូវមានធនធានទាំងបី ផ្នែក ក្នុងពេលទន្ទឹមគ្នា ទើបធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចការវិនិយោគ អាចដំណើរការ ទៅបាន។

ជារួម គោលដៅនេះ គឺធ្វើយ៉ាងណាឱ្យយើងអាចស្រូបយកធនធានទាំងអស់ ដែលសង្គមមាន មកប្រើប្រាស់ឱ្យអស់លទ្ធភាព ដើម្បីទទួលបានផលប្រយោជន៍ សម្រាប់សេដ្ឋកិច្ច សង្គម ដល់កម្រិតខ្ពស់តាមលទ្ធភាពដែលអាចធ្វើទៅបាន។

## ៣.២. រក្សាស្ថិរភាពថ្លៃទីផ្សារ

ការរក្សាស្ថិរភាពថ្លៃទីផ្សារ គឺជាផ្នែកមួយសំខាន់នៅក្នុងគោលនយោបាយម៉ាក្រូ សេដ្ឋកិច្ច។ បើថ្លៃទំនិញនៅក្នុងទីផ្សារគ្មានស្ថិរភាព នោះវានឹងធ្វើឱ្យប៉ះពាល់ដល់ ផែនការសេដ្ឋកិច្ច ការវិនិយោគ និងអាជីវកម្មផ្សេងទៀត ព្រមទាំងជីវភាពរស់នៅ ទូទៅរបស់ប្រជាពលរដ្ឋផងដែរ។ ធនាគារកណ្តាលអាចសម្រេចបានគោលដៅនេះ

ក្នុងរយៈពេលខ្លី និងរយៈពេលវែង។ ក្នុងរយៈពេលខ្លី ធនាគារកណ្តាលត្រូវធ្វើអន្តរាគមន៍ តាមរយៈការគ្រប់គ្រងបរិមាណប្រាក់ផ្គត់ផ្គង់នៅក្នុងចរាចរណ៍ ឱ្យបានសមស្រប ដោយប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុណាមួយ។ ឧទាហរណ៍ៈ នៅពេលដែលថ្លៃទំនិញនៅក្នុងទីផ្សារកើនឡើង ធនាគារជាតិនៃកម្ពុជា តែងធ្វើអន្តរាគមន៍ តាមរយៈការដាក់ដេញថ្លៃលក់ប្រាក់ដុល្លារ ដើម្បីប្រមូលប្រាក់ចូលទៅក្នុងធនាគារជាតិនៃកម្ពុជាវិញ។ ជាលទ្ធផល បរិមាណប្រាក់រៀលនៅក្នុងចរាចរណ៍ថយចុះ តម្លៃប្រាក់រៀលកើនឡើង ថ្លៃទំនិញនៅក្នុងទីផ្សារនឹងវិលមកស្ថានភាពដើមវិញ ហើយអត្រាប្តូរប្រាក់ក៏មានស្ថិរភាពផងដែរ។

### ៣.៣. កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព

ដើម្បីសម្រេចគោលដៅនេះ ស្ថានភាពសេដ្ឋកិច្ចត្រូវតែល្អប្រសើរលើគ្រប់វិស័យ។ ការប្រើប្រាស់ធនធានសង្គមប្រកបដោយប្រសិទ្ធភាព សកម្មភាពវិនិយោគ ផលិតកម្ម អាជីវកម្ម និងសេវាកម្ម មានសកម្មភាពរីកចម្រើន គឺជាកត្តាចំបងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។ កត្តាផ្សេងទៀត ដូចជា បរិយាកាសសេដ្ឋកិច្ចពិភពលោក គោលនយោបាយក្នុងស្រុកសមស្រប ក៏ជាកត្តាសំខាន់ រួមចំណែកយ៉ាងខ្លាំងក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ប្រកបដោយស្ថិរភាពផងដែរ។ ឧទាហរណ៍ៈ មុនវិបត្តិហិរញ្ញវត្ថុសកល ឆ្នាំ២០០៨-២០០៩ សេដ្ឋកិច្ចកម្ពុជាមានកំណើនពីរខ្ទង់ ជាមធ្យម ១០% ប្រកបដោយស្ថិរភាព ក្នុងរយៈពេលជាងមួយទសវត្សរ៍ ជាពិសេស នៅឆ្នាំ ២០០៥ កំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ គឺលើសពី១៣%។ កំណើននេះ ត្រូវបានកាត់ផ្តាច់ ដោយសារឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសកល ធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាទទួលបានតែ ០,១% ប៉ុណ្ណោះ នៅឆ្នាំ២០០៩។ ក្រោយមកទៀត កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព ដំណាក់កាលទី២ ដែលមានកំណើនជាមធ្យម ៧% ចាប់ពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៩។ ក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថា នឹងធ្លាក់ចុះប្រហែល -២% ដោយសារឥទ្ធិពលអវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ-១៩។

### ៣.៤. ធ្វើឱ្យមានតុល្យភាពជញ្ជីងពាណិជ្ជកម្មអន្តរជាតិ

ជញ្ជីងពាណិជ្ជកម្មអន្តរជាតិ គឺជាការវាយតម្លៃ ដោយធ្វើការប្រៀបធៀប រវាងការនាំចេញ និងនាំចូលរបស់ប្រទេសនីមួយៗ។ ហេតុនេះ តុល្យភាពជញ្ជីងពាណិជ្ជកម្ម

អន្តរជាតិ មានន័យថា តម្លៃនៃការនាំចេញ និងនាំចូល ប្រហាក់ប្រហែលគ្នា។ ដើម្បីទទួលបានលទ្ធផលតុល្យភាពនេះ ការអភិវឌ្ឍសេដ្ឋកិច្ច ផលិតកម្ម អាជីវកម្ម និងការវិនិយោគ ត្រូវមានសកម្មភាពខ្លាំងក្លា ផលិតបាននូវផលិតផលសម្បូរបែប ដើម្បីបំពេញតម្រូវការក្នុងស្រុកផង និងអាចមានលទ្ធភាពនាំចេញផងដែរ។ ជាទូទៅប្រទេសកំពុងអភិវឌ្ឍ តែងប្រឈមនឹងឱនភាពពាណិជ្ជកម្មអន្តរជាតិ មានន័យថា ការនាំចូលទំនិញពីបរទេសច្រើនជាងការនាំចេញ ធ្វើឱ្យប្រទេសនោះ ទទួលរងការខាតបង់រូបិយប័ណ្ណអន្តរជាតិ ដោយសារត្រូវចំណាយទូទាត់ទំនិញដែលបាននាំចូល។ ឧទាហរណ៍ៈ ការផ្ទុះឡើងនូវសង្គ្រាមពាណិជ្ជកម្ម រវាងសហរដ្ឋអាមេរិក និងប្រទេសចិន គឺដោយសារ អាមេរិកប្រឈមនឹងឱនភាពពាណិជ្ជកម្មជាមួយនឹងប្រទេសចិន ធ្វើឱ្យអាមេរិកទទួលរងការខាតបង់។ សហរដ្ឋអាមេរិក បានចោទប្រកាន់ប្រទេសចិនថា បានប្រើគោលនយោបាយបញ្ចុះតម្លៃប្រាក់យ៉ាន់ ដើម្បីកេងចំណេញពីការនាំចេញ ឬធ្វើពាណិជ្ជកម្មមិនស្មើភាព។ ទំនាស់បានកើតឡើងជាបន្តបន្ទាប់ តាំងពីទសវត្សរ៍ ឆ្នាំ ១៩៩០មកម្លេះ។ ប៉ុន្តែ ប្រទេសចិនតែងតែបដិសេធចំពោះការចោទប្រកាន់នេះ។

ទំនាស់នេះត្រូវបានបញ្ឆេះឡើង នៅក្នុងអាណត្តិរបស់ប្រធានាធិបតីដូណាល់ត្រាំ ដោយបានដំឡើងពន្ធនាំចូលពីប្រទេសចិន លើទំនិញសំខាន់ៗមួយចំនួន ដែលមានតម្លៃរាប់ប៊ីលានដុល្លារ។ ប៉ុន្តែ ប្រទេសចិនមិននៅស្ងៀមទេ ពោលគឺបានឆ្លើយតបវិញ ដោយដំឡើងពន្ធលើទំនិញនាំចូលពីសហរដ្ឋអាមេរិក រាប់ប៊ីលានដុល្លារដូចគ្នា ដែលធ្វើឱ្យខូចប្រយោជន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ប្រទេសទាំងពីរផង ហើយថែមទាំង ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកទៀតផង។ ហេតុនេះ ទើបធ្វើឱ្យមានសេចក្តីអំពាវនាវដល់ប្រទេសទាំងពីរ ឱ្យងាកមករកផ្លូវចរចា ដើម្បីដោះស្រាយបញ្ហាជម្លោះ និងឈានទៅបញ្ចប់សង្គ្រាមពាណិជ្ជកម្មនេះឱ្យបានឆាប់ ពីព្រោះ វាជាផលប្រយោជន៍របស់ប្រទេសទាំងពីរផង និងជាផលប្រយោជន៍នៃសេដ្ឋកិច្ចពិភពលោកផង។

គំនូសបំព្រួញ៩.១: បណ្ដាញដែលធនាគារកណ្ដាលដំណើរការ




ប្រភព: Peter S. Rose, *Money and Capital Markets*, 2005.

## ៤. រចនាសម្ព័ន្ធធនាគារកណ្ដាលរបស់ប្រទេសមួយចំនួន

រចនាសម្ព័ន្ធរបស់ធនាគារកណ្ដាល អាចមានខុសៗគ្នាទៅតាមលក្ខណៈពិសេស និងច្បាប់នៃប្រទេសនីមួយៗ។ ហេតុនេះ ក្នុងផ្នែកនេះ អ្នករៀបរៀងនឹងលើកយកមកពន្យល់ពីរចនាសម្ព័ន្ធរបស់ធនាគារកណ្ដាលជាទូទៅ នៅក្នុងប្រទេសសំខាន់ៗមួយចំនួន ដើម្បីឱ្យប្រិយមិត្តអ្នកអាន បានយល់ដឹងកាន់តែទូលំទូលាយ។

## ៤.១. ប្រព័ន្ធធនបម្រុងសហព័ន្ធ (Federal Reserve System)

ប្រព័ន្ធធនបម្រុងសហព័ន្ធ គឺជាប្រព័ន្ធធនាគារកណ្ដាលរបស់សហរដ្ឋអាមេរិក ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៨១៣ ដោយប្រធានាធិបតី Woodrow Wilson ក្រោយពីបានចុះហត្ថ-លេខាលើច្បាប់ធនបម្រុងសហព័ន្ធ និងដាក់ឱ្យចូលជាធរមានមក។ ប្រព័ន្ធធនបម្រុងសហព័ន្ធត្រូវបានបែងចែកជា៖ ធនាគារធនបម្រុងសហព័ន្ធ (Federal Reserve banks) ក្រុមប្រឹក្សាអភិបាលកិច្ច (Board of Governors) នៃប្រព័ន្ធធនបម្រុងសហព័ន្ធ គណៈកម្មាធិការទីផ្សារបើកចំហសហព័ន្ធ (Federal Open Market Committee-FOMC) ក្រុមប្រឹក្សាពិគ្រោះយោបល់សហព័ន្ធ (Federal Advisory Council) និងមានធនាគារពាណិជ្ជ ប្រហែល២.៥០០ ជាសមាជិក។

### ក. ធនាគារធនបម្រុងសហព័ន្ធ (Federal Reserve Banks)

**ផែនទី៩.១: ផែនទីបង្ហាញទីតាំងធនាគារធនបម្រុងសហព័ន្ធនៅក្នុងតំបន់ និងសាខានៅក្នុងទីក្រុងផ្សេងៗ**




Souce: *Education*, https://www.frbsf.org/education/publications/doctor-econ/2001/may/federal-reserve-districts/

ប្រព័ន្ធធនបម្រុងសហព័ន្ធ នៅសហរដ្ឋអាមេរិក ត្រូវបានបែងចែកជា១២តំបន់ ដែលក្នុងតំបន់នីមួយៗ មានធនាគារធនបម្រុងសហព័ន្ធគោលមួយ និងអាចមានសាខា នៅទីក្រុងផ្សេងៗ ក្នុងតំបន់របស់ខ្លួន ដូចមាននៅក្នុងផែនទីខាងលើ។ ក្នុងចំណោម នោះ មានធនាគារធនបម្រុងសហព័ន្ធធំជាងគេចំនួនបី គឺ នៅញូវយ៉ក ឈីកាហ្គោ និងសាន់ហ្វ្រាន់ស៊ីស្កូ ដែលមានទ្រព្យសរុបជាង ៥០% នៃទ្រព្យសរុបរបស់ប្រព័ន្ធធន បម្រុងសហព័ន្ធទាំងមូល ហើយក្នុងនោះ ធនាគារញូយ៉កមានទ្រព្យច្រើនជាងគេបំផុត គឺ ស្មើនឹង ១/៣ នៃទ្រព្យទាំងអស់របស់ប្រព័ន្ធធនបម្រុងសហព័ន្ធ។

ធនាគារធនបម្រុងសហព័ន្ធនីមួយៗ គឺជាស្ថាប័ននិមិត្តសាធារណៈ[50] (មាន ផ្នែកឯកជន និងផ្នែករដ្ឋ) ដែលជាកម្មសិទ្ធិរបស់ធនាគារពាណិជ្ជឯកជន នៅក្នុង តំបន់នីមួយៗ និងជាសមាជិកនៃប្រព័ន្ធធនបម្រុងសហព័ន្ធ។ ធនាគារជាសមាជិក ទាំងនោះ ត្រូវទិញភាគហ៊ុនរបស់ធនាគារធនបម្រុងសហព័ន្ធ តំបន់ (ដែលជាការ តម្រូវរបស់សមាជិកភាព) ហើយភាគលាភដែលនឹងបែងចែក ត្រូវបានដាក់កម្រិត ដោយច្បាប់ គឺ ៦% ក្នុងមួយឆ្នាំ។ ធនាគារជាសមាជិក ត្រូវបោះឆ្នោតជ្រើសរើស នាយក៦រូប ក្នុងតំបន់នីមួយៗ និង៣រូបទៀត ត្រូវបានតែងតាំងដោយក្រុមប្រឹក្សា អភិបាលកិច្ច។ នាយកនៅក្នុងតំបន់នីមួយៗ ត្រូវបានបែងចែកជាបីក្រុម គឺ A, B និង C។ នាយកបីរូបក្នុងក្រុម A ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិក ដែលជា *ធនាគាររិកជំនាញ* និងនាយកបីរូបទៀត នៅក្នុងក្រុម B ត្រូវជ្រើសរើសដោយការ បោះឆ្នោតដែរ ដែលជា*អ្នកដឹកនាំជាន់ខ្ពស់* លើវិស័យឧស្សាហកម្ម ពលកម្ម កសិកម្ម និងអ្នកប្រើប្រាស់។ ចំណែក នាយកបីរូបទៀត ក្នុងក្រុម C ត្រូវបានតែងតាំងដោយ ក្រុមប្រឹក្សាអភិបាលកិច្ច ដែលជា *តំណាងឱ្យផលប្រយោជន៍សាធារណៈ* និងមិនអាច ជាមន្ត្រី និយោជិត ឬម្ចាស់ភាគហ៊ុនរបស់ធនាគារបានទេ។ តួនាទីរបស់នាយកទាំង អស់ គឺត្រួតពិនិត្យសកម្មភាពធនាគារនៅក្នុងតំបន់ ប៉ុន្តែ ការងារសំខាន់ជាងគេ គឺ តែងតាំងប្រធានធនាគារធនបម្រុងសហព័ន្ធ ដែលជាការយល់ព្រមអនុម័តដោយក្រុម ប្រឹក្សាអភិបាលកិច្ច។ រហូតមកដល់ឆ្នាំ២០១០ នាយកទាំង៩រូប ចូលរួមក្នុងការ សម្រេចចិត្តជ្រើសរើសប្រធានធនាគារធនបម្រុងសហព័ន្ធ ប៉ុន្តែ នៅខែកក្កដា ឆ្នាំ

---

[50] ស្ថាប័ននិមិត្តសាធារណៈ (quasi-public institution) គឺជាស្ថាប័ននៅក្នុងវិស័យឯកជន ដែល គាំទ្រដោយរដ្ឋាភិបាល និងត្រូវបានផ្តល់អាណត្តិសាធារណៈ ដើម្បីបម្រើសេវាមួយចំនួន។

២០១០ ច្បាប់ Dodd-Frank បានដកចេញនាយកបីរូបក្នុងក្រុម A មិនឱ្យពាក់ព័ន្ធក្នុងការជ្រើសរើសប្រធានធនាគារទៀតទេ ដោយសារ សមាជ (Congress) ឬ សភាទាំងពីរថ្នាក់ មើលឃើញថា មិនមានលក្ខណៈសមស្របសម្រាប់ធនាគារិក ដែលជាប់ពាក់ព័ន្ធនឹងការជ្រើសរើសប្រធានធនាគារធនបម្រុងសហព័ន្ធ ដែលត្រូវមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យមើលដំណើរការប្រតិបត្តិរបស់ធនាគារទាំងនោះ។

ធនាគារធនបម្រុងសហព័ន្ធទាំង១២ ដែលបានបោះទីតាំងនៅក្នុងតំបន់នីមួយៗ បំពេញតួនាទីពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ តាមវិធីផ្សេងៗគ្នា៖

- ❖ នាយកធ្វើនិទស្សន៍អត្រាការប្រាក់អប្បហារ ទោះបីជាអត្រាអប្បហារនៅតំបន់នីមួយៗ ត្រូវបានពិនិត្យមើល និងកំណត់ដោយក្រុមប្រឹក្សាអភិបាលកិច្ច។
- ❖ ពួកគេធ្វើការសម្រេចថា ធនាគារណា (ជាសមាជិក និងមិនមែនជាសមាជិក) អាចទទួលបានឥណទានអប្បហារពីធនាគារធនបម្រុងសហព័ន្ធ។
- ❖ នាយកជ្រើសរើសធនាគារិកម្នាក់ពីធនាគារពាណិជ្ជនីមួយៗ ក្នុងតំបន់ដើម្បីបំពេញមុខងារជាក្រុមប្រឹក្សាពិគ្រោះយោបល់សហព័ន្ធ ដែលត្រូវពិភាក្សាជាមួយនឹងក្រុមប្រឹក្សាអភិបាលកិច្ច និងផ្តល់ព័ត៌មាន ដែលអាចជួយដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។
- ❖ ប្រធាន៥រូប ក្នុងចំណោម១២រូប ដែលម្នាក់ៗមានមួយសម្លេងនៅក្នុងគណៈកម្មាធិការ ទីផ្សារបើកចំហសហព័ន្ធ ដែលដឹកនាំទីផ្សារបើកចំហដើម្បីសម្រេចថា ត្រូវទិញ ឬ លក់មូលប័ត្ររដ្ឋាភិបាល ដែលមានឥទ្ធិពលទៅលើអត្រាការប្រាក់ និងបរិមាណធនបម្រុង នៅក្នុងប្រព័ន្ធធនាគារ។ ក្នុងនោះ ប្រធានធនាគារធនបម្រុងសហព័ន្ធក្រុងញូយ៉ក មានតួនាទីពិសេសជាងគេ គឺជាសមាជិកអចិន្ត្រៃយ៍ នៅក្នុងគណៈកម្មាធិការទីផ្សារបើកចំហសហព័ន្ធ (FOMC) ដែលប្រធាន ជានិច្ចកាលត្រូវមានមួយសម្លេងនៅក្នុង FOMC។ ចំណែក សម្លេងបួនទៀត ត្រូវបានបែងចែកទៅធនាគារតំបន់ ដោយប្តូរវេនគ្នាជារៀងរាល់ឆ្នាំ ក្នុងចំណោមប្រធានធនាគារទាំង១១ ដែលនៅសល់។

**គំនូសបំព្រួញ៩.២: រចនាសម្ព័ន្ធ និងការទទួលខុសត្រូវលើឧបករណ៍គោលនយោបាយ នៅក្នុងប្រព័ន្ធធនបម្រុងសហព័ន្ធ**




Souce: Frederic S. (2013), *The Economics of Money, Banking, and Financial Markets*, p. 304.

ធនាគារធនបម្រុងសហព័ន្ធទាំង១២ បំពេញមុខងារដូចក្រោម៖

- ❖ ទូទាត់មូលប្បទានប័ត្រ
- ❖ បោះផ្សាយក្រដាសប្រាក់ថ្មី និងដកយកក្រដាសប្រាក់ខូចពីទីផ្សារ ដើម្បីបំផ្លាញចោល
- ❖ គ្រប់គ្រង និងផ្ដល់ឥណទានឱ្យធនាគារនៅក្នុងតំបន់របស់ខ្លួន
- ❖ វាយតម្លៃសំណើសុំរួមបញ្ចូលគ្នា សម្រាប់ធនាគារ ដើម្បីពង្រីកសកម្មភាពប្រតិបត្តិការ

- ធ្វើសកម្មភាពជាសម្ព័ន្ធរវាងសហគមន៍អាជីវកម្ម និងប្រព័ន្ធធនបម្រុងសហព័ន្ធ
- ពិនិត្យមើលក្រុមហ៊ុនមេ កាន់កាប់ធនាគារ និងធនាគារជាសមាជិក ដែលទទួលបានអាជ្ញា-ប័ណ្ណពីរដ្ឋនីមួយៗ
- ប្រមូលទិន្នន័យពីស្ថានភាពអាជីវកម្មនៅក្នុងតំបន់
- ប្រើបុគ្គលិកដែលជាអ្នកជំនាញសេដ្ឋកិច្ច ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទ ពាក់ព័ន្ធនឹងការអនុវត្តគោនយោបាយរូបិយវត្ថុ។

ខ. **ធនាគារជាសមាជិក** (Member banks)

ធនាគារជាតិទាំងអស់ (ធនាគារពាណិជ្ជដែលផ្តល់អាជ្ញាប័ណ្ណ ដោយការិយាល័យត្រួតពិនិត្យរូបិយវត្ថុ) តម្រូវឱ្យជាសមាជិកនៃប្រព័ន្ធធនបម្រុងសហព័ន្ធ។ ចំណែក ធនាគារពាណិជ្ជណា ដែលផ្តល់អាជ្ញាប័ណ្ណដោយរដ្ឋផ្សេងៗ មិនតម្រូវឱ្យជាសមាជិកទេ ប៉ុន្តែ គេអាចចូលរួមជាសមាជិកបាន។ បច្ចុប្បន្ន ប្រហែល១ភាគបី នៃធនាគារពាណិជ្ជនៅសហរដ្ឋអាមេរិក ជាសមាជិកនៃប្រព័ន្ធធនបម្រុងសហព័ន្ធ ពោលគឺ បានថយចុះពីកម្រិតខ្ពស់ជាងគេ ៤៩% នៅឆ្នាំ១៩៤៧។

មុនឆ្នាំ១៩៨០ មានតែធនាគារជាសមាជិកទេ ដែលតម្រូវឱ្យរក្សាទុនបម្រុងជាប្រាក់បញ្ញើ នៅធនាគារធនបម្រុងសហព័ន្ធ។ ចំណែក ធនាគារមិនមែនជាសមាជិក ជាកម្មវត្ថុត្រូវរក្សាទុនបម្រុងកាតព្វកិច្ច ដែលកំណត់ដោយរដ្ឋនីមួយៗ ធ្វើឱ្យគេអាចរក្សាទុកទុនបម្រុងច្រើន ក្នុងទម្រង់ជាមូលប័ត្រមានការប្រាក់។ ដោយសារនៅពេលនោះ ទុនបម្រុងដែលផ្ញើនៅធនាគារធនបម្រុងសហព័ន្ធ មិនផ្តល់ការប្រាក់ទេ ធ្វើឱ្យធនាគារជាសមាជិកត្រូវខាតបង់ច្រើន ជាពិសេស នៅពេលអត្រាការប្រាក់កើនឡើង ធ្វើឱ្យធនាគារជាសមាជិកទទួលរងការខាតបង់កាន់តែច្រើនទៀត។ ហេតុផលនេះហើយ ដែលធ្វើឱ្យធនាគារជាសមាជិកបានចាកចេញកាន់តែច្រើនឡើង។

ការធ្លាក់ចុះចំនួនសមាជិកនៃប្រព័ន្ធធនបម្រុងសហព័ន្ធ ក៏ពាក់ព័ន្ធនឹងក្រុមប្រឹក្សាអភិបាលកិច្ចផងដែរ។ ហេតុផលសំខាន់ គឺ ការធ្លាក់ចុះនៃការត្រួតពិនិត្យរបស់ប្រព័ន្ធធនបម្រុងសហព័ន្ធ ទៅលើការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ធ្វើឱ្យមានការលំបាកសម្រាប់ប្រព័ន្ធធនបម្រុងសហព័ន្ធ ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ហេតុនេះ ប្រធានក្រុមប្រឹក្សាអភិបាលកិច្ចបានស្នើម្តងហើយម្តងទៀតនូវច្បាប់ថ្មី ដែល

តម្រូវឱ្យធនាគារពាណិជ្ជទាំងអស់ ត្រូវតែជាសមាជិកនៃប្រព័ន្ធធនបម្រុងសហព័ន្ធ។ លទ្ធផលនៃការដាក់សម្ពាធរបស់ប្រព័ន្ធធនបម្រុងសហព័ន្ធ ទៅលើសមាជ (សភាទាំងពីរថ្នាក់) ធ្វើឱ្យច្បាប់ស្តីពី អនិយតកម្មស្ថាប័នទទួលប្រាក់ និងការគ្រប់គ្រងរូបិយវត្ថុ ឆ្នាំ១៩៨០ ដែលចែងថា ស្ថាប័នទទួលប្រាក់ទាំងអស់ក្លាយជាកម្មវត្ថុ (ចាប់ពីឆ្នាំ ១៩៨៧មក) ដែលមានកាតព្វកិច្ចដូចគ្នា ក្នុងរក្សាទុកប្រាក់បញ្ញើនៅប្រព័ន្ធធនបម្រុងសហព័ន្ធ។ ហេតុនេះ ធនាគារជាសមាជិកក្តី និងធនាគារមិនមែនជាសមាជិកក្តី តម្រូវឱ្យមានទុនបម្រុងកាតព្វកិច្ច ដូចគ្នា។ ម៉្យាងទៀត ស្ថាប័នទទួលប្រាក់ទាំងអស់ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សេវាកម្មរបស់ធនបម្រុងសហព័ន្ធ ដូចជា ខ្ចីប្រាក់ពីធនាគារធនបម្រុងសហព័ន្ធ ឬទូទាត់ជម្រះមូលប្បទានប័ត្រ ដោយស្មើភាពគ្នា។ ច្បាប់នេះ បានបញ្ចប់នូវការធ្លាក់ចុះសមាជិកភាពរបស់ប្រព័ន្ធធនបម្រុងសហព័ន្ធ និងកាត់បន្ថយភាពខុសគ្នារវាងធនាគារជាសមាជិក និងធនាគារមិនមែនជាសមាជិក។

**គ. ក្រុមប្រឹក្សាអភិបាលកិច្ចនៃប្រព័ន្ធធនបម្រុងសហព័ន្ធ** (Board of Governors of the Fed.)

ប្រព័ន្ធធនបម្រុងសហព័ន្ធ ដឹកនាំដោយសមាជិក៧រូប នៅក្នុងក្រុមប្រឹក្សាអភិបាលកិច្ច។ សមាជិកម្នាក់ៗរបស់ក្រុមប្រឹក្សាអភិបាលកិច្ច ត្រូវបានតែងតាំងដោយប្រធានាធិបតីសហរដ្ឋអាមេរិក និងផ្តល់សច្ចានុម័តដោយព្រឹទ្ធសភា។ ដើម្បីដាក់កំហិតប្រធានាធិបតីក្នុងការត្រួតត្រាទៅលើប្រព័ន្ធធនបម្រុងសហព័ន្ធ និងកាត់ផ្តាច់ប្រព័ន្ធធនបម្រុងសហព័ន្ធពីសម្ពាធនយោបាយ ក្រុមប្រឹក្សាអភិបាលកិច្ចអាចបម្រើការងារពេញលេញ ដោយគ្មានការផ្លាស់ប្តូរថ្មី ក្នុងរយៈពេល១៤ឆ្នាំ បូកបន្ថែមរយៈពេលដែលសមាជិកក្រុមប្រឹក្សាអភិបាលកិច្ចម្នាក់ៗ ត្រូវផុតអាណត្តិជារៀងរាល់ថ្ងៃទី ០១ ខែមករា។ សមាជិកក្រុមប្រឹក្សាអភិបាលកិច្ច ដែលភាគច្រើន គឺជាអ្នកជំនាញសេដ្ឋកិច្ច តម្រូវឱ្យជ្រើសរើសពីធនបម្រុងសហព័ន្ធតំបន់ខុសៗគ្នា ដើម្បីការពារផលប្រយោជន៍តំបន់ ដែលបុគ្គលនោះជាតំណាង។ ប្រធានក្រុមប្រឹក្សាអភិបាលកិច្ច ត្រូវបានជ្រើសរើសក្នុងចំណោមសមាជិកទាំង៧រូប ហើយបំពេញតួនាទីក្នុងអាណត្តិ៤ឆ្នាំ។ នៅពេលដែលប្រធានត្រូវបានជ្រើសរើស ប្រធានចាស់ត្រូវលាលែងពីក្រុមប្រឹក្សាអភិបាលកិច្ច ទោះបីជាអាណត្តិជាសមាជិករបស់គាត់នៅសល់ច្រើនឆ្នាំទៀតក៏ដោយ។

ក្រុមប្រឹក្សាអភិបាលកិច្ច ជាប់ពាក់ព័ន្ធយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ តាមវិធីសាស្ត្រ ដូចតទៅ៖

❖ សមាជិកក្រុមប្រឹក្សាអភិបាលកិច្ចទាំង៧រូប ជាសមាជិក FOMC និងបោះឆ្នោតទៅលើការអនុវត្តប្រតិបត្តិការទីផ្សារបើកចំហ (Open market operations)។ ដោយសារ មានអ្នកបោះឆ្នោតតែ១២រូប ដែល៧រូបជាសមាជិកក្រុមប្រឹក្សាអភិបាលកិច្ច និង៥រូបទៀត ជាប្រធានធនាគារតំបន់ ហេតុនេះ ក្រុមប្រឹក្សាអភិបាលកិច្ច មានសម្លេងភាគច្រើន។
❖ ក្រុមប្រឹក្សាអភិបាលកិច្ច កំណត់ទុនបម្រុងកាតព្វកិច្ច ជាមួយនឹងកម្រិតដែលកំណត់ដោយច្បាប់។
❖ ក្រុមប្រឹក្សាអភិបាលកិច្ច គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវអត្រាអប្បហារ ដោយដំណើរការពិនិត្យ និងធ្វើសេចក្តីសម្រេចថា យល់ព្រម ឬមិនយល់ព្រម ទៅលើអត្រាអប្បហារ ដែលធ្វើនិទស្សន៍ដោយធនាគារធនបម្រុងសហព័ន្ធ។
❖ ប្រធានក្រុមប្រឹក្សាអភិបាលកិច្ច មានភារកិច្ចផ្តល់យោបល់ជូនប្រធានាធិបតីសហរដ្ឋអាមេរិកអំពីគោលនយោបាយសេដ្ឋកិច្ច ផ្តល់ភស្តុតាងនៅក្នុងសមាជ និងថ្លែងសារក្នុងនាមប្រព័ន្ធធនបម្រុងសហព័ន្ធ តាមប្រព័ន្ធផ្សព្វផ្សាយនានា។

ផ្អែកលើខ្លឹមសារច្បាប់ ក្រុមប្រឹក្សាអភិបាលកិច្ច តែងត្រូវបានផ្តល់ភារកិច្ចមិនផ្ទាល់ ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលមានខ្លឹមសារ ដូចខាងក្រោម៖

❖ កំណត់ "កម្រិតតម្រូវ"[51] (margin requirements) ជាអត្រាភាគរយនៃថ្លៃទិញមូលប័ត្រ ដែលអ្នកវិនិយោគត្រូវទូទាត់ដោយសាច់ប្រាក់ផ្ទាល់ គឺមិនមែនដោយជំពាក់ នោះទេ។

---

[51] កម្រិតតម្រូវ គឺជាអត្រាភាគរយនៃតម្លៃមូលប័ត្រ ដែលវិនិយោគិនត្រូវទូទាត់ជាសាច់ប្រាក់ផ្ទាល់។ កម្រិតតម្រូវ ត្រូវបានបែងចែកជាពីរផ្នែក គឺ កម្រិតតម្រូវគ្រាដំបូង (initial margin requirement): ផ្អែកលើបទប្បញ្ញត្តិ T នៃក្រុមប្រឹក្សាធនបម្រុងសហព័ន្ធ កម្រិតតម្រូវគ្រាដំបូងសម្រាប់ភាគហ៊ុន គឺស្មើនឹង ៥០% និងកម្រិតតម្រូវរក្សាបម្រុង (Maintenance Margin Requirement) ស្មើនឹង ៣០%។

- ❖ កំណត់ប្រាក់ខែសម្រាប់ប្រធាន និងមន្ត្រីទាំងអស់ នៅធនាគារធនបម្រុងសហព័ន្ធនីមួយៗ និងពិនិត្យមើលថវិការបស់ធនាគារនីមួយៗ។
- ❖ ផ្តល់ការយល់ព្រមលើការស្នើសុំ ចងសម្ព័ន្ធគ្នារបស់ធនាគារសម្រាប់សកម្មភាពថ្មី បញ្ជាក់ពីសកម្មភាព ដែលអនុញ្ញាតឱ្យក្រុមហ៊ុនកាន់កាប់ធនាគារ និងគ្រប់គ្រងសកម្មភាពរបស់ធនាគារបរទេសនៅសហរដ្ឋអាមេរិក។
- ❖ ត្រូវមានបុគ្គលិកដែលមានជំនាញសេដ្ឋកិច្ច ដែលអាចផ្តល់ការវិភាគសេដ្ឋកិច្ចសម្រាប់ក្រុមប្រឹក្សាអភិបាលកិច្ច ដើម្បីធ្វើសេចក្តីសម្រេចចិត្ត។

### ឃ. គណៈកម្មាធិការទីផ្សារបើកចំហសហព័ន្ធ (Federal Open Market Committee - FOMC)

FOMC ជាទូទៅជួបប្រជុំគ្នា៨ដងក្នុងមួយឆ្នាំ (ប្រហែល៦សប្តាហ៍ម្តង) និងធ្វើការសម្រេចចិត្ត ពាក់ព័ន្ធនឹងការអនុវត្តប្រតិបត្តិការទីផ្សារបើកចំហ និងកំណត់គោលនយោបាយអត្រាការប្រាក់ ឬហៅថា អត្រាមូលធនសហព័ន្ធ (federal funds rate) ដែលជាអត្រាការប្រាក់សម្រាប់ឥណទានរយៈពេលមួយយប់ (overnight loans) ពីធនាគារមួយទៅធនាគារមួយទៀត។ FOMC មានសមាជិក១២រូប ដែល ៧រូបមកពីក្រុមប្រឹក្សាអភិបាលកិច្ច និង១រូបមកពីធនាគារធនបមករុងសហព័ន្ធក្រុងញូយ៉ក និង ៤រូបទៀតមកពីធនាគារធនបម្រុងងសហព័ន្ធផ្សេងទៀត។ ប្រធានក្រុមប្រឹក្សាអភិបាលកិច្ចធ្វើជាអធិបតី ដូចជា ប្រធាន FOMC។ ទោះបីជាប្រធានធនាគារធនបម្រុងសហព័ន្ធតែ៥រូប ជាសមាជិកបោះឆ្នោតនៅក្នុង FOMC ប៉ុន្តែ ប្រធានធនាគារតំបន់៧រូបទៀត ក៏ចូលរួមប្រជុំ និងពិភាក្សា នៅក្នុង FOMC ដែរ។ ហេតុនេះពួកគេអាចផ្តល់ធាតុចូលសម្រាប់ការសម្រេចចិត្តរបស់ FOMC។

ដោយសារប្រតិបត្តិការទីផ្សារបើកចំហ គឺជាឧបករណ៍គោលនយោបាយសំខាន់ជាងគេ ដែលប្រព័ន្ធធនបម្រុងសហព័ន្ធប្រើប្រាស់ សម្រាប់គ្រប់គ្រងការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ដោយសារ ការសម្រេចចិត្តក្នុងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ (បង្កើនអត្រាមូលធនសហព័ន្ធ) ឬបន្ធូរគោលនយោបាយរូបិយវត្ថុ (បន្ទាបអត្រាមូលធនសហព័ន្ធ) ត្រូវបានធ្វើឡើងដោយ FOMC។ ទោះបីជា ទុនបម្រុង

---

(See: *Margin Requirement*, https://www.firstrade.com/content/en-us/education/margin/marginrequirements/)

កាតព្វកិច្ច និងអត្រាអប្បហារ មិនមែនកំណត់ដោយ FOMC ក៏ដោយ ក៏ការសម្រេចចិត្ត ពាក់ព័ន្ធគោលនយោបាយទាំងនេះ ត្រូវធ្វើប្រកបដោយប្រសិទ្ធភាព។ ហេតុនេះបានជានៅក្នុងគំនូសបំព្រួញ៩.២ មានសញ្ញាព្រួញចុចៗ បញ្ជាក់ថា FOMC ផ្តល់យោបល់ពាក់ព័ន្ធនឹងការកំណត់ទុនបម្រុងកាតព្វកិច្ច និងអត្រាអប្បហារ។ តាមពិត FOMC មិនបានទិញ ឬលក់មូលប័ត្រដោយផ្ទាល់ ផ្ទុយទៅវិញ FOMC ចេញសេចក្តីណែនាំទៅការិល័យជួញដូរ នៅធនាគារធនបម្រុងសហព័ន្ធក្រុងញូយ៉ក ដែលជាអ្នកគ្រប់គ្រងប្រតិបត្តិការទីផ្សារបើកចំហក្នុងស្រុក និងគ្រប់គ្រងយ៉ាងទូលំទូលាយចំពោះប្រជាពលរដ្ឋដែលចង់ទិញ ឬលក់ មូលប័ត្ររដ្ឋាភិបាល ឬមូលប័ត្រភ្នាក់ងារ។ អ្នកគ្រប់គ្រងផ្លាស់ប្តូរយោបល់ជារៀងរាល់ថ្ងៃជាមួយសមាជិក FOMC និងបុគ្គលិកទាក់ទងនឹងសកម្មភាពរបស់ការិយាល័យជួញដូរ។

### ៤.២. ធនគារកណ្តាលសហភាពអឺរ៉ុប (European Central Bank-ECB)

រយៈកាលកន្លងទៅ ប្រព័ន្ធធនបម្រុងសហព័ន្ធរបស់សហរដ្ឋអាមេរិក គ្មានគូប្រជែងទេ ក្នុងន័យសំដៅទៅលើសារៈសំខាន់របស់ធនាគារកណ្តាលពិភពលោក។ ប៉ុន្តែ មកដល់ខែមករា ឆ្នាំ១៩៩៩ ជាមួយនឹងការចាប់ផ្តើមធនាគារកណ្តាលអឺរ៉ុប (ECB) និងប្រព័ន្ធធនាគារកណ្តាលអឺរ៉ុប (European System of Central Banks-ESCB) ដែលបច្ចុប្បន្ន អនុវត្តគោលនយោបាយរូបិយវត្ថុសម្រាប់បណ្តាលប្រទេសជាសមាជិកនៃសហភាពរូបិយវត្ថុអឺរ៉ុប (European Monetary Union)។ ប្រទេសទាំងនេះ ទទួលស្គាល់ថា ចំនួនប្រជាជនបានកើនឡើងលើសសហរដ្ឋអាមេរិក ហើយចំណូលក្នុងស្រុកសរុប (GDP) ក៏អាចប្រៀបធៀបបានជាមួយសហរដ្ឋអាមេរិកផងដែរ។ សន្ធិសញ្ញា Maastricht ដែលបានបង្កើតធនាគារកណ្តាលអឺរ៉ុប និងប្រព័ន្ធធនាគារកណ្តាលអឺរ៉ុប ដោយយកលំនាំតាមប្រព័ន្ធធនបម្រុងសហព័ន្ធ ដូចជាធនាគារកណ្តាលរបស់ប្រទេសនីមួយៗ(សំដៅទៅលើធនាគារកណ្តាលជាតិ) ដែលមានតួនាទីដូចទៅនឹងធនាគារធនបម្រុងសហព័ន្ធ។ ធនាគារកណ្តាលអឺរ៉ុប ដែលមានទីតាំងនៅ Frankfurt ប្រទេសអាល្លឺម៉ង់ មានក្រុមប្រឹក្សាប្រតិបត្តិ (Executive Board) ដែលមានរចនាសម្ព័ន្ធដូចក្រុមប្រឹក្សាអភិបាលកិច្ចរបស់ប្រព័ន្ធធនបម្រុងសហព័ន្ធ ដែលមានសមាសភាព ប្រធាន អនុប្រធាន និងសមាជិក៤រូបទៀត ដែលត្រូវបានតែងតាំងក្នុងអាណត្តិ៨ឆ្នាំ និងមិនអាចតែងតាំងឡើវិញបានទេ។ ចំណែក

ក្រុមប្រឹក្សាភិបាលវិញ រួមមានក្រុមប្រឹក្សាប្រតិបត្តិ និងប្រធានធនាគារកណ្តាលជាតិ (របស់ប្រទេសនីមួយៗ) ដែលដូចគ្នានឹង FOMC ដែរ ដោយធ្វើការសម្រេចចិត្តទៅលើគោលនយោបាយ រូបិយវត្ថុ។ ចំពោះ ប្រធានធនាគារកណ្តាលជាតិនីមួយៗ ត្រូវបានតែងតាំងដោយរដ្ឋាភិបាលនៃប្រទេសរៀងៗខ្លួន ហើយសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ត្រូវបានតែងតាំងដោយគណៈកម្មាធិការមួយ (ដែលមានប្រមុខរដ្ឋនៃប្រទេសទាំងអស់) ដែលជាផ្នែកមួយនៃសហភាពរូបិយវត្ថុអឺរ៉ុប។

## ក. ការប្រៀបធៀបរវាងប្រព័ន្ធធនាគារកណ្តាលអឺរ៉ុប និងប្រព័ន្ធធនបម្រុងសហព័ន្ធ

កាលណាគេនិយាយពីប្រព័ន្ធធនាគារកណ្តាលអឺរ៉ុប គឺគេចង់និយាយពី"ធនាគារកណ្តាលអឺរ៉ុប" ទោះបីជាគេដឹងថា គេចង់និយាយអំពីប្រព័ន្ធអឺរ៉ូ (Eurosystem) ក៏ដោយ។ ចំណែក រចនាសម្ព័ន្ធរបស់ប្រព័ន្ធអឺរ៉ូវិញ ដូចគ្នានឹងប្រព័ន្ធធនបម្រុងសហព័ន្ធ ប៉ុន្តែ ខុសគ្នាទៅលើពីរចំណុចសំខាន់៖

- ថវិការបស់ប្រព័ន្ធធនបម្រុងសហព័ន្ធ ត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាអភិបាលកិច្ច ប៉ុន្តែ នៅក្នុងប្រព័ន្ធអឺរ៉ូ ធនាគារកណ្តាលជាតិ (របស់ប្រទេស) នីមួយៗ គ្រប់គ្រងថវិកាផ្ទាល់ខ្លួន និងថវិការបស់ធនាគារកណ្តាលអឺរ៉ុប នៅ Frankfurt។ ហេតុនេះ ធនាគារកណ្តាលអឺរ៉ុបនៅក្នុងប្រព័ន្ធអឺរ៉ូ មានអំណាចតិចជាង បើធៀបនឹងក្រុមប្រឹក្សាអភិបាលកិច្ច នៅក្នុងប្រព័ន្ធធនបម្រុងសហព័ន្ធ។
- ប្រតិបត្តិការរូបិយវត្ថុនៅក្នុងប្រព័ន្ធអឺរ៉ូ ត្រូវបានអនុវត្តដោយធនាគារកណ្តាលជាតិ នៅក្នុងប្រទេសនីមួយៗ។ ហេតុនេះ ប្រតិបត្តិការរូបិយវត្ថុមិនបានធ្វើមជ្ឈការ (ប្រមូលផ្តុំ) ដូចប្រព័ន្ធធនបម្រុងសហព័ន្ធទេ។
- ផ្ទុយពីប្រព័ន្ធធនបម្រុងសហព័ន្ធ ធនាគារកណ្តាលអឺរ៉ុប មិនពាក់ព័ន្ធនឹងការគ្រប់គ្រង និងដាក់ចេញបទបញ្ជា ទៅលើគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទេ ប៉ុន្តែ ទុកភារកិច្ចនេះ ឱ្យប្រទេសនីមួយៗ នៅក្នុងសហភាពរូបិយវត្ថុអឺរ៉ុប ជាអ្នកទទួលខុសត្រូវវិញ។

ខ. ក្រុមប្រឹក្សាភិបាល ( Governing Council )

កិច្ចប្រជុំរបស់ FOMC នៅសហរដ្ឋអាមេរិក ក៏ដូចគ្នានឹងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៅអឺរ៉ុបដែរ ដែលត្រូវជួបជុំគ្នាជារៀងរាល់ខែ នៅធនាគារកណ្តាលអឺរ៉ុប នៅ Frankfurt ដើម្បីធ្វើសេចក្តីសម្រេចទៅលើគោលនយោបាយរូបិយវត្ថុ។ បច្ចុប្បន្ននេះ មានប្រទេស១៧ ជាសមាជិកសហភាពរូបិយវត្ថុអឺរ៉ុប ហើយថ្នាក់ដឹកនាំម្នាក់ៗនៃធនាគារកណ្តាលជាតិទាំង១៧ មានសន្លឹកឆ្នោតមួយសម្លេងនៅក្នុងក្រុមប្រឹក្សាភិបាល និងសមាជិក៦រូប នៅក្នុងក្រុមប្រឹក្សាប្រតិបត្តិ ដែលម្នាក់ៗក៏មានសន្លឹកឆ្នោតមួយសម្លេងផងដែរ។ ផ្ទុយពីកិច្ចប្រជុំរបស់ FOMC ដែលមានបុគ្គលិកមកពីក្រុមប្រឹក្សាអភិបាលកិច្ច និងធនាគារធនបម្រុងសហព័ន្ធនីមួយៗចូលរួម។ ចំណែក កិច្ចប្រជុំក្រុមប្រឹក្សាធនាគារកណ្តាលអឺរ៉ុប មានតែសមាជិក២៣រូប មកពីក្រុមប្រឹក្សាភិបាល ដោយគ្មានបុគ្គលិកចូលរួមទេ។ ក្រុមប្រឹក្សាភិបាល ធ្វើការសម្រេចថា ទោះបីជាសមាជិកមានសិទ្ធិស្របច្បាប់ក្នុងការបោះឆ្នោតក៏ដោយ ប៉ុន្តែ មិនដែលមានការបោះឆ្នោតកើតឡើងជាក់ស្តែងទេ។ ជាជំនួសវិញ ក្រុមប្រឹក្សាភិបាល ធ្វើការងារតាមរយៈកុងសង់ស៊ុស។ ហេតុផលសំខាន់ដែលក្រុមប្រឹក្សាភិបាលសម្រេចមិនធ្វើការបោះឆ្នោត ដោយសារ មានការព្រួយបារម្ភថា ការបោះឆ្នោតរបស់បុគ្គលម្នាក់ៗ ដែលជាប្រមុខដឹកនាំធនាគារកណ្តាលជាតិនៃប្រទេសនីមួយៗ តែងតែគាំទ្រគោលនយោបាយរូបិយវត្ថុដែលសមស្របសម្រាប់ប្រទេសរៀងៗខ្លួន ប៉ុន្តែ មិនចាំបាច់សម្រាប់ប្រទេសនៅក្នុងសហភាពរូបិយវត្ថុអឺរ៉ុប ជារួម។ បញ្ហានេះ មានការប្រឈមតិចណាស់សម្រាប់ប្រព័ន្ធធនបម្រុងសហព័ន្ធ ទោះបីជាប្រធានធនាគារបម្រុងសហព័ន្ធ រស់នៅតំបន់ផ្សេងគ្នាពាសពេញផ្ទៃប្រទេសក៏ដោយ ប៉ុន្តែ ពួកគេមានសញ្ជាតិដូចគ្នា ហើយពួកគេហាក់ដូចជាយកទស្សនៈជាតិជាធំ លើគោលនយោបាយរូបិយវត្ថុ ជាជាងយកទស្សនៈតំបន់មកពិចារណា។

## ៤.៣. ធនាគារកណ្តាលរបស់ប្រទេសផ្សេងៗ ( Other countries' central banks )

ក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលធនាគារកណ្តាលរបស់ប្រទេសសំខាន់ៗមួយចំនួន ដើម្បីស្វែងយល់ពីភាពខុសគ្នា អំពីរចនាសម្ព័ន្ធ មុខងារ និងតួនាទី របស់

ធនាគារកណ្តាលនៃប្រទេសនីមួយៗ ដែលជាបទពិសោធន៍សំខាន់សម្រាប់ត្រិះរិះពិចារណា។

**ក. ធនាគារកាណាដា** ( Bank of Canada )

ធនាគារកាណាដា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣៤ ក្រោមច្បាប់ធនាគារកាណាដា ដែលមានតួនាទីក្នុងការបង្កើតគោលនយោបាយរូបិយវត្ថុ។ ទេសាភិបាលត្រូវបានតែងតាំងដោយរដ្ឋាភិបាលក្នុងអាណត្តិ៧ឆ្នាំ ប៉ុន្តែ ច្បាប់មិនផ្តល់សិទ្ធិដោយផ្ទាល់ដល់រដ្ឋាភិបាលក្នុងដកទេសាភិបាលមុនអាណត្តិបានទេ។ ធនាគារកាណាដាត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល (governing council) រួមមាន ទេសាភិបាលរង៤រូប និងទេសាភិបាល ដែលជាតួអង្គជាន់ខ្ពស់ បង្កើតគោលនយោបាយដែលស្រដៀងទៅនឹង FOMC របស់សហរដ្ឋអាមេរិក ដែលធ្វើការសម្រេចចិត្ត ស្តីពីគោលនយោបាយរូបិយវត្ថុ។

ចំណែក អង្គប្រតិបត្តិវិញ មានក្រុមប្រឹក្សាភិបាល (Board of Director) ដែលមានទេសាភិបាល ទេសាភិបាលរងជាន់ខ្ពស់ និងនាយកឯករាជ្យចំនួន១២រូបទៀតត្រូវបានតែងតាំងក្នុងអាណត្តិបីឆ្នាំ និងអាចតែងតាំងឡើងវិញបាន។ ក្រុមប្រឹក្សាភិបាលមានតួនាទីត្រួតពិនិត្យមើលការគ្រប់គ្រង និងរដ្ឋបាលរបស់ធនាគារ ដោយអនុលោមតាមផែនការយុទ្ធសាស្ត្រ បញ្ហាហិរញ្ញវត្ថុ និងគណនេយ្យ គ្រប់គ្រងហានិភ័យគ្រប់គ្រងធនធានមនុស្ស និងគោលនយោបាយផ្ទៃក្នុងផ្សេងទៀត។

ច្បាប់ធនាគារដែលបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៦៧ បានផ្តល់អំណាចឱ្យធនាគារកាណាដាមានភារកិច្ចទទួលខុសត្រូវ ទៅលើគោលនយោបាយរូបិយវត្ថុរបស់រដ្ឋាភិបាល។ ហេតុនេះ នៅក្នុងច្បាប់ធនាគារកាណាដា មិនមានភាពឯករាជ្យ ដូចធនាគារកណ្តាលសហរដ្ឋអាមេរិកទេ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង ធនាគារកាណាដាបំពេញតួនាទីដ៏មានសារៈសំខាន់ ក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ។ ប្រសិនបើមិនមានភាពចុះសម្រុងរវាងធនាគារ និងរដ្ឋាភិបាល រដ្ឋមន្ត្រីហិរញ្ញវត្ថុ អាចដាក់ចេញនូវសេចក្តីបង្គាប់ទៅធនាគារកាណាដា ដែលត្រូវតែអនុវត្តតាម (ក្នុងការអនុវត្តជាក់ស្តែងមិនមានករណីបែបនេះកើតឡើងទេ មកដល់ពេលបច្ចុប្បន្ននេះ)។ ទោះជាយ៉ាងនេះក្តី សេចក្តីបង្គាប់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ដែលមានភាពច្បាស់លាស់ និងអាចអនុវត្តបាន ក្នុងពេលវេលាជាក់លាក់មួយ។ គោលដៅនៃ

គោលនយោបាយរូបិយវត្ថុ គឺតម្រង់ទិសដៅអតិផរណា ត្រូវបានកំណត់រួមគ្នា ដោយធនាគារកាណាដា និងរដ្ឋាភិបាល។ ហេតុនេះ ធនាគារកាណាដាមានភាពឯករាជ្យតិចជាង ធៀបនឹងប្រព័ន្ធធនបម្រុងសហព័ន្ធ។

**ខ. ធនាគារអង់គ្លេស** ( Bank of England )

ធនាគារអង់គ្លេសត្រូវបានបង្កើតឡើងនៅឆ្នាំ១៦៩៤ ដែលជាធនាគារកណ្តាលដែលមានវ័យចំណាស់ជាងគេ។ ច្បាប់ធនាគារឆ្នាំ១៩៤៦ បានផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចផ្លូវច្បាប់ទៅលើធនាគារអង់គ្លេស។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារអង់គ្លេសត្រូវបានបង្កើតឡើងដោយ ទេសាភិបាល និងទេសាភិបាលរង២រូបទៀត ដែលត្រូវបានតែងតាំងក្នុងអាណត្តិ៥ឆ្នាំ និងនាយក ដែលមិនមែនជានីតិ-ប្រតិបត្តិ ត្រូវបានតែងតាំងក្នុងអាណត្តិ៣ឆ្នាំ។

មកដល់ឆ្នាំ១៩៩៧ ធនាគារអង់គ្លេស ជាធនាគារកណ្តាល ដែលមានភាពឯករាជ្យតិចតួច ដោយសារការសម្រេចចិត្តក្នុងការបង្កើន ឬបន្ថយអត្រាអប្បហារ មិននៅក្នុងដៃធនាគារអង់គ្លេសទេ ប៉ុន្តែ ឋិតនៅក្នុងដៃអធិការបតីនៃរតនាគារ ( Chancellor of the Exchequer) ទៅវិញ។ ហេតុការណ៍នេះ បានផ្លាស់ប្តូរនៅពេលដែលរដ្ឋាភិបាលថ្មីរបស់គណបក្សពលករ ចូលកាន់តំណែង នៅខែឧសភា ឆ្នាំ១៩៩៧ ហើយលោក Gordon Brown ជាអធិការបតីនៃរតនាគារបានប្រកាសគួរឱ្យភ្ញាក់ផ្អើលថា ពីពេលនេះតទៅ ធនាគារអង់គ្លេសមានអំណាច ក្នុងការកំណត់អត្រាអប្បហារ។ ទោះជាយ៉ាងនេះក្តី ធនាគារអង់គ្លេសមិនទាន់ត្រូវបានផ្តល់មធ្យោបាយពេញលេញ ដែលមានលក្ខណៈឯករាជ្យនៅឡើយទេ។ រដ្ឋាភិបាលអាចគ្រប់សង្កត់ធនាគារ និងកំណត់អត្រាអប្បហារ ក្នុងស្ថានភាពសេដ្ឋកិច្ចលំបាកខ្លាំង និងក្នុងចន្លោះពេលកំណត់ណាមួយ។ ទោះជាយ៉ាងនេះក្តី ដូចនៅក្នុងប្រទេសកាណាដាដែរ ដោយសារអំណាចគ្រប់សង្កត់ទៅលើធនាគារមានលក្ខណៈជាសាធារណៈ និងកើតឡើងក្នុងស្ថានភាពមិនប្រក្រតី និងក្នុងកម្រិតពេលវេលាជាក់លាក់បែបនេះ។ ប៉ុន្តែ ជាក់ស្តែង វាកម្រនឹងកើតឡើងណាស់។

ដោយសារតែចក្រភពអង់គ្លេស មិនមែនជាសមាជិកសហភាពរូបិយវត្ថុអឺរ៉ុប ធនាគារអង់គ្លេសសម្រេចនូវគោលនយោបាយរូបិយវត្ថុ ដោយឯករាជ្យពីធនាគារកណ្តាលសហភាពអឺរ៉ុប។ ការសម្រេចចិត្តក្នុងការកំណត់អត្រាអប្បហារ ជាតួនាទី

របស់គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ ដែលបង្កើតឡើងដោយមានទេសាភិបាល១រូប ទេសាភិបាលរង២រូប និងសមាជិក២រូបទៀត តែងតាំងដោយទេសាភិបាល ក្រោយពីការពិគ្រោះយោបល់ជាមួយអធិការបតី (ដែលជាទូទៅ ជាមន្ត្រីរបស់ធនាគារកណ្ដាល) បូកនឹងអ្នកជំនាញសេដ្ឋកិច្ចពីក្រៅចំនួន៤រូបទៀត ត្រូវបានតែងតាំងដំបូងដោយអធិការបតី។ រយៈពេលកន្លងមក ក្នុងចំណោមអ្នកជំនាញខាងក្រៅទាំង៤រូប អាចមិនមែនជាជនជាតិអង់គ្លេស ដូចជា ជនជាតិហុលឡង់ និងអាមេរិក ជាដើម ធ្លាប់ត្រូវបានតែងតាំងជាសមាជិកគណៈកម្មា-ធិការនេះ។ ចំណែកគោលដៅនៃអត្រាអតិផរណា ត្រូវបានកំណត់ដោយអធិការបតីនៃរតនាគារ ដែលបញ្ជាក់ថា ធនាគារអង់គ្លេស មានភាពឯករាជ្យទាប ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

**គ. ធនាគារជប៉ុន** (Bank of Japan)

ធនាគារជប៉ុន (Nippon Ginko) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៨២ ក្នុងកំឡុងរជ្ជកាលម៉េជី (Meiji)។ គោលនយោបាយរូបិយវត្ថុ ត្រូវបានកំណត់ដោយក្រុមប្រឹក្សាគោលនយោបាយ ដែលមានសមាសភាព ដូចជា ទេសាភិបាល១រូប ទេសាភិបាលរង២រូប និងសមាជិកខាងក្រៅ៦រូបទៀត ត្រូវបានតែងតាំងដោយគណៈរដ្ឋមន្ត្រី និងផ្ដល់សច្ចានុម័តដោយសភា ដែលមានអាណត្តិ៥ឆ្នាំ។

ក្នុងរយៈពេលកន្លងទៅ ធនាគារជប៉ុនមិនមានភាពឯករាជ្យពីរដ្ឋាភិបាលទេ ដោយសារអំណាចចុងក្រោយឋិតនៅលើក្រសួងហិរញ្ញវត្ថុ។ ប៉ុន្តែ ដោយផ្អែកលើច្បាប់ធនាគារជប៉ុន ដែលចូលជាធរមាន នៅខែមេសា ឆ្នាំ១៩៩៨ ដែលជាការប្រែប្រួលដំបូង ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ធនាគារជប៉ុន ក្នុងរយៈពេល៥៥ឆ្នាំ។ បន្ថែមលើលក្ខខណ្ឌដែលចែងអំពីគោលដៅនៃគោលនយោបាយរូបិយវត្ថុ គឺរក្សាបាននូវស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ ច្បាប់ក៏បានផ្ដល់ភាពឯករាជ្យ ក្នុងការកំណត់គោលដៅរបស់ធនាគារជប៉ុន។ កាលពីអតីតកាល រដ្ឋាភិបាលមានសមាជិកបោះឆ្នោត២រូប នៅក្នុងក្រុមប្រឹក្សាគោលនយោបាយ ដែល១រូប មកពីក្រសួងហិរញ្ញវត្ថុ និង១រូបទៀត មកពីភ្នាក់ងារផែនការសេដ្ឋកិច្ច។ ប៉ុន្តែ បច្ចុប្បន្ន រដ្ឋាភិបាលអាចបញ្ជូនតំណាង២រូប មកពីស្ថាប័នទាំងពីរខាងលើ ឱ្យចូលរួមប្រជុំជាមួយក្រុមប្រឹក្សាគោលនយោបាយ ប៉ុន្តែ ពួកគេមិនមានសិទ្ធបោះឆ្នោតទៀតទេ ទោះបីជា ពួកគេមាសិទ្ធិស្នើសុំពន្យារពេល ក្នុងការសម្រេចចិត្តលើគោលនយោបាយរូបិយវត្ថុក៏ដោយ។ ម្យ៉ាងទៀត ក្រសួងហិរញ្ញវត្ថុ

បាត់បង់អំណាចក្នុងការត្រួតពិនិត្យទៅលើប្រតិបត្តិការជាច្រើនរបស់ធនាគារកណ្តាល ជាពិសេស សិទ្ធិបណ្តេញចេញមន្ត្រីជាន់ខ្ពស់ ជាដើម។ ទោះជាយ៉ាងនេះក៏ដោយ ក្រសួងហិរញ្ញវត្ថុ បន្តមានអំណាចលើផ្នែកខ្លះនៃថវិការបស់ធនាគារកណ្តាល ដែលមិនពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ។ ហេតុការណ៍នេះ ជាការដាក់កំហិតទៅលើភាពឯករាជ្យនៅក្នុងកម្រិតណាមួយទៅលើធនាគារកណ្តាលជប៉ុន[52]។

## ៥. ប្រវត្តិ និងការរីកចម្រើនប្រព័ន្ធធនាគារនៅកម្ពុជា

### ៥.១. ឯករាជ្យភាព និងការបង្កើតឡើងវិញ (១៩៥៤-១៩៦៤)

ក្រោយពីបានទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង ក្នុងឆ្នាំ១៩៥៤ ធនាគារជាតិនៃកម្ពុជា ត្រូវបានបង្កើតឡើង នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ហើយបានដំណើរការពេញលេញ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៥។ ម៉្យាងទៀត ក្រោយពីវិទ្យាស្ថានបោះផ្សាយប្រាក់ឥណ្ឌូចិន ដែលមាន តួនាទីក្នុងការបោះផ្សាយក្រដាសប្រាក់ សម្រាប់ប្រើប្រាស់នៅក្នុងឥណ្ឌូចិន រួមមានៈ កម្ពុជា វៀតណាម ឡាវ ត្រូវបានបិទទ្វារ ធនាគារជាតិនៃកម្ពុជាមានតួនាទីផ្តាច់មុខ ក្នុងការបោះផ្សាយក្រដាសប្រាក់រៀល ដែលជារូបិយប័ណ្ណជាតិ និងដាក់ឱ្យធ្វើចរាចរណ៍ជាផ្លូវការ នៅថ្ងៃទី០១ខែមករា ឆ្នាំ១៩៥៥ ដើម្បីបំពេញអធិបតេយ្យភាព និងរក្សាស្ថិរភាពរូបិយវត្ថុ និងជួយកសាងអត្តសញ្ញាណជាតិ។ ក្នុងពេលនោះដែរ ប្រព័ន្ធធនាគារនៅក្នុងស្រុក ត្រូវបានកសាងឡើងវិញ ដែលមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា។ នៅឆ្នាំ១៩៦៤ ក្រោមរបបសង្គមរាស្ត្រនិយម ប្រព័ន្ធធនាគារនៅកម្ពុជាត្រូវបានកែទម្រង់ ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ច និងការអភិវឌ្ឍនាសម័យនោះ។ ធនាគារជាតិនៃកម្ពុជា បានប្រែក្លាយពីទម្រង់ធនាគារពាក់កណ្តាលស្វ័យយ័ត ទៅជាធនាគារក្រោមទម្រង់សាធារណៈ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។ ទន្ទឹមនឹងនោះ ធនាគារសាធារណៈ និងឯកជនជាច្រើនត្រូវបានបិទទ្វារ ហើយរាជរដ្ឋាភិបាលបានកសាងធនាគារ ដែលគ្រប់គ្រងដោយរដ្ឋមួយចំនួន ដូចជា ធនាគារឥណទានសម្រាប់ការអភិវឌ្ឍ និងធនាគារកសិកម្មជនបទ ជាដើម។

---

[52] Frederic S. ( 2013 ), *The Economics of Money, Banking, and Financial Markets*, Pp. 303-322.

## ៥.២. របបខ្មែរក្រហម (១៩៧៥-១៩៧៩)

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម បានឡើងកាន់អំណាច ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ អាគារធនាគារជាតិនៃកម្ពុជា ត្រូវបានកម្ទេចចោល រូបិយវត្ថុជាតិត្រូវបានលុបបំបាត់ លែងឱ្យមានការចាយវាយក្រដាសប្រាក់ ហើយរចនាសម្ព័ន្ធធនាគារ និងសេដ្ឋកិច្ច ត្រូវបានបំផ្លាញចោលទាំងស្រុង។ ប្រជាជននៅក្នុងទីក្រុងនានា ត្រូវបានជន្លៀសឱ្យទៅរស់នៅឯជនបទ ប្រមូលផ្តុំជាសហករ បំពេញការងារជាកសិករ ធ្វើស្រែចំការ លើកទំនប់ជីកប្រឡាយ ហើយគ្មានរចនាសម្ព័ន្ធដោះដូរ និងពាណិជ្ជកម្មឡើយ។

## ៥.៣. កសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម បានឡើងកាន់អំណាច ពីថ្ងៃទី១៧ ខែមេសា បន្ទាប់មក ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម នៅឆ្នាំ១៩៧៩ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ ដែលចាប់ផ្តើមកសាងពីចំណុចសូន្យដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ដែលមានឈ្មោះថា "ធនាគារជាតិនៃប្រជាជនកម្ពុជា" ដែលជាធនាគារកណ្តាលរបស់ប្រទេស បំពេញតួនាទីជាអាជ្ញាធររូបិយវត្ថុ រតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារ ដែលរួមមាន សេវាឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់។ មកដល់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ទើបធនាគារជាតិនៃប្រជាជនកម្ពុជា បានបោះផ្សាយក្រដាសប្រាក់រៀលឡើងវិញ និងដាក់ឱ្យធ្វើចរាចរណ៍ ប្រើប្រាស់ក្នុងការទូទាត់ទំនិញ និងបើកប្រាក់ខែជូនមន្ត្រីរដ្ឋការស៊ីវិល។ បន្ទាប់មក នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ រដ្ឋសភាកម្ពុជា បានអនុម័តច្បាប់ស្តីពីការប្តូរឈ្មោះពី "ធនាគារជាតិនៃប្រជាជនកម្ពុជា" ទៅជា "ធនាគារជាតិនៃកម្ពុជា" វិញ ដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋ នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២[53]។

[53] Youtube, *ប្រវត្តិធនាគារកម្ពុជា ដោយចាប់ផ្តើមកសាងឡើងវិញពីចំណុចសូន្យ*, March 24, 2021, https://www.youtube.com/watch?v=qmfcvWjH0Eo

## ៥.៤. ទំនើបភាវូបនីយកម្មប្រព័ន្ធធនាគារ (១៩៩៣-បច្ចុប្បន្ន)

ប្រព័ន្ធធនាគារនៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០មក នៅពេលដែលមានកំណែទម្រង់ ដោយប្ដូរពីសេដ្ឋកិច្ចផែនការ ទៅជាសេដ្ឋកិច្ចទីផ្សារសេរី និងកំណែទម្រង់វិស័យធនាគារ ស្របពេលដែលច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្ដីពីធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិដទៃទៀត ត្រូវបានបង្កើតឡើង និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។

កំណែទម្រង់សេដ្ឋកិច្ចកម្ពុជា បានចាប់ផ្ដើមតាំងពីឆ្នាំ១៩៨៩ នៅពេលដែលកម្មសិទ្ធិឯកជនត្រូវបានបង្កើតឡើងវិញ និងលុបបំបាត់ការគ្រប់គ្រងថ្លៃទំនិញនៅលើទីផ្សារ។ សហគ្រាសសាធារណៈត្រូវបានធ្វើឯកជននីយកម្ម ហើយក្រុមហ៊ុនឯកជនត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ តាមរយៈគោលនយោបាយជំរុញ និងលើកទឹកចិត្តចំពោះការវិនិយោគ ទាំងក្នុងនិងក្រៅប្រទេស។ ដំណាក់កាលនៃការធ្វើកំណែទម្រង់នេះ គឺជាការរៀបចំខ្លួនជាមុន ដើម្បីឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅឆ្នាំ១៩៩១ ជាការបិទបញ្ចប់សង្គ្រាមស៊ីវិល ដែលអូសបន្លាយជាងមួយទសវត្សរ៍ និងរៀបចំស្តារសេដ្ឋកិច្ចឡើងវិញ។ ក្រោយពីការបោះឆ្នោតសកល ឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាថ្មី ត្រូវបានបង្កើតឡើងវិញ ជាមួយនឹងកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច និងរចនាសម្ព័ន្ធ ដើម្បីសម្រេចបានជោគជ័យក្នុងការធ្វើឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។

សេដ្ឋកិច្ចកម្ពុជាបានពង្រីកខ្លួនយ៉ាងលឿន ក្រោយការបោះឆ្នោតនៅឆ្នាំ១៩៩៣ នៅពេលដែលអត្រាអតិផរណាត្រូវបានកាត់បន្ថយ ឱ្យនៅកម្រិតទាបគួរឱ្យកត់សំគាល់។ ប្រព័ន្ធធនាគារក៏ត្រូវបានធ្វើកំណែទម្រង់ ដោយប្ដូរពីប្រព័ន្ធធនាគារមួយថ្នាក់ មកជាប្រព័ន្ធធនាគារពីរថ្នាក់វិញ ហើយក្រដាសប្រាក់ដែលមានទំហំទឹកប្រាក់ធំត្រូវបានបោះផ្សាយ និងដាក់ឱ្យធ្វើចរាចរណ៍ ដើម្បីជំរុញបដិដូល្លារនីយកម្ម។ ម្យ៉ាងទៀត របាំងមិនមែនពន្ធត្រូវបានលុបបំបាត់ចោល ហើយប្រព័ន្ធពន្ធត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង និងច្បាប់វិនិយោគដែលផ្ដល់សិទ្ធិសេរីភាពដល់វិនិយោគបរទេស ត្រូវបានដាក់ឱ្យប្រើប្រាស់។ ចាប់តាំងពីពេលនោះមក កម្ពុជាបានបោះជាជំហានៗ បង្កើតឱ្យមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច ហើយបានធ្វើសមាហរណកម្ម

ទៅក្នុងសហគមន៍អន្តរជាតិ។ ទោះដោយយ៉ាងនេះក្តី រដ្ឋាភិបាលយល់ឃើញថា សេដ្ឋកិច្ច មិនទាន់សម្រេចបាននូវសក្តានុពលកំណើន និងការអភិវឌ្ឍបានគ្រប់គ្រាន់នៅឡើយទេ បើគ្មានសកម្មភាពចូលរួមពីវិស័យហិរញ្ញវត្ថុ ធនាគារ។ ហេតុនេះ រដ្ឋាភិបាលបានប្តេជ្ញាចិត្តពង្រឹងវិស័យហិរញ្ញវត្ថុ ធនាគារ ហើយបានដាក់ចេញនូវច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ បង្កើតស្ថាប័ន និងដាក់ចេញនូវវិធីសាស្ត្រផ្សេងៗ ពាក់ព័ន្ធនឹងកំណែទម្រង់វិស័យហិរញ្ញវត្ថុ ធនាគារ ក្នុងគោលដៅជំរុញឱ្យមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស។

ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ សម្រាប់បង្កើនល្បឿន និងទិសដៅកំណើនសេដ្ឋកិច្ច ដោយសារ ការបំពេញមុខងារខ្លាំងក្លា និងត្រឹមត្រូវរបស់វិស័យហិរញ្ញវត្ថុ ជំរុញឱ្យការគៀរគរធនធានហិរញ្ញវត្ថុដែលនៅទំនេរ សម្រាប់បំពេញតម្រូវការវិនិយោគ។ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងការសន្សំ វិនិយោគ និងកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុត្រូវតែបោះជំហានទៅមុខ ដោយផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍក្នុងវិស័យឯកជន និងកំណែទម្រង់អភិបាលកិច្ច ដោយបង្កើតបាននូវ សសរស្តម្ភបី ដើម្បីគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតកំណើន ដែលជាមធ្យោបាយសំខាន់បំផុយ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ចំណែក វិស័យធនាគារក៏ត្រូវពង្រឹងឱ្យរឹងមាំផងដែរ ដោយសារនៅមានការអភិវឌ្ឍក្នុងកម្រិតទាបនៅឡើយ។ ប្រព័ន្ធធនាគារនៅកម្ពុជា ត្រូវបានកែទម្រង់ទៅជាប្រព័ន្ធធនាគារពីរថ្នាក់ ដោយចែកដាច់ពីគ្នារវាងមុខងាររបស់ធនាគារកណ្តាល និងសកម្មភាពរបស់ធនាគារពាណិជ្ជ។ ដើម្បីគាំទ្រកំណែទម្រង់នេះ គម្រោងច្បាប់ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយបង្កើតឱ្យមានច្បាប់ធនាគារកណ្តាល ដែលប្រកាសឱ្យប្រើជាផ្លូវការ នៅខែមករា ឆ្នាំ១៩៩៦ ដោយបញ្ជាក់ច្បាស់ពីលក្ខខណ្ឌរបស់ធនាគារ កម្មសិទ្ធិ រចនាសម្ព័ន្ធមូលធន និងមានមូលដ្ឋានរឹងមាំសម្រាប់ធ្វើប្រតិបត្តិការ។

ជាមួយនឹងការកំណត់ឡើងវិញនូវតួនាទីថ្មីរបស់ធនាគារជាតិនៃកម្ពុជា រដ្ឋាភិបាលយល់យ៉ាងច្បាស់ថា កម្ពុជាត្រូវការចាំបាច់នូវប្រព័ន្ធហិរញ្ញវត្ថុទំនើប និងប្រកបដោយប្រសិទ្ធភាព។ ហេតុនេះ ច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ បានចូលជាធរមាន នៅខែវិច្ឆិកា ឆ្នាំ១៩៩៩ ដើម្បីឆ្លើយតបទៅនឹងការជំរុញ ធ្វើឱ្យរឹងមាំរចនាសម្ព័ន្ធ

ហិរញ្ញវត្ថុ និងធ្វើឱ្យមានសណ្តាប់ធ្នាប់ទីផ្សារហិរញ្ញវត្ថុ ដោយបង្កើតឱ្យមានច្បាប់ ក្នុងការផ្តល់អាជ្ញាប័ណ្ណ បង្កើតរចនាសម្ព័ន្ធ ធ្វើប្រតិបត្តិការ និងគ្រប់គ្រង ក្នុងក្របខ័ណ្ឌទូលាយទៅលើក្រុមហ៊ុនសេវាកម្មហិរញ្ញវត្ថុ។ ម្យ៉ាងទៀត ដើម្បីពង្រឹងប្រព័ន្ធធនាគារនៅកម្ពុជា នៅដើមទសវត្សរ៍ ឆ្នាំ២០០០ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់ធនាគារ ដោយតម្រូវឱ្យធនាគារដែលមានស្រាប់ បង្កើនដើមទុន និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ជាលទ្ធផល នៅខែវិច្ឆិកា ឆ្នាំ២០០០ ធនាគារចំនួន១៩ ត្រូវបានអនុញ្ញាតឱ្យបន្តប្រតិបត្តិការ និងធនាគារចំនួន១២ផ្សេងទៀត ត្រូវបានដកអាជ្ញាប័ណ្ណ ហើយត្រូវធ្វើការជម្រះបញ្ជី។ សកម្មភាពកំណែទម្រង់បែបនេះ ដើម្បីធ្វើឱ្យធនាគារដែលមានស្រាប់ មានស្តង់ដាកាន់តែខ្ពស់ជាងមុន មានភាពរឹងមាំ និងបង្កើនភាពជឿជាក់ទៅលើប្រព័ន្ធធនាគារ និងកសាងបាននូវជំនឿទុកចិត្តពីសាធារណជន ជាតិ និងអន្តរជាតិ។

ទោះបីជាកំណែទម្រង់វិស័យហិរញ្ញវត្ថុមានការរីកចម្រើនជាបន្តបន្ទាប់ ប៉ុន្តែ នៅមានការងារជាច្រើនទៀតត្រូវធ្វើ ដើម្បីគាំទ្រដល់ការវិនិយោគ និងកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយនិរន្តរភាព។ ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុទំនើប និងប្រកបដោយប្រសិទ្ធភាពមិនមែនជាការងាយស្រួលទេ។ រដ្ឋាភិបាលត្រូវស្វែងយល់ឱ្យបានច្បាស់ថាយើងត្រូវការអ្វីខ្លះ ហើយត្រូវដើរទៅតាមទិសដៅណា និងទៅដោយមធ្យោបាយណា? ហេតុនេះ រដ្ឋាភិបាលកម្ពុជាបានស្នើសុំធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ឱ្យជួយរៀបចំផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់កម្ពុជា។ ADB ក៏បានចាប់ផ្តើមសិក្សាដើម្បីអភិវឌ្ឍគោលបំណងយុទ្ធសាស្ត្រ និងកំណត់បញ្ហាគន្លឹះនៅក្នុងវិស័យហិរញ្ញវត្ថុ។ ក្រោយពីបានសិក្សាចប់ សេចក្តីព្រាងផែនទីបង្ហាញផ្លូវវិស័យហិរញ្ញវត្ថុ ត្រូវបានដាក់ចេញ នៅខែមិថុនា ឆ្នាំ១៩៩៩។ បន្ទាប់មក នៅខែធ្នូ ឆ្នាំ២០០០ ADB បានរៀបចំគម្រោងជំនួយបច្ចេកទេស ដើម្បីជួយរដ្ឋាភិបាលក្នុងការបង្កើតផែនការមេ សម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក្នុងរយៈពេល ១០ ឆ្នាំ។ ក្នុងពេលនោះដែរ រដ្ឋាភិបាលក៏បានបង្កើត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅខែមិថុនា ឆ្នាំ១៩៩៧ ហើយធនាគារជាតិនៃកម្ពុជាធ្វើជាភ្នាក់ងារ និងជាអ្នកសម្របសម្រួលជាមួយ ADB។ សេចក្តីព្រាងផែនការ ដែលមានឈ្មោះថា ទស្សនៈវិស័យ និងផែនការ

អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០១-២០១០ ត្រូវអនុម័ត នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ ២០០១។

ផែនការអភិវឌ្ឍនេះ ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់រយៈពេលវែង ដើម្បីឆ្ពោះទៅសេដ្ឋកិច្ច ទីផ្សារ មានលក្ខណៈបើកចំហ និងវិស័យឯកជនដឹកនាំសេដ្ឋកិច្ច។ លទ្ធផលរំពឹងទុក ដែលនឹងទទួលបានពីគោលនយោបាយនេះ រួមមាន៖

ក) ប្រព័ន្ធធនាគារ ដែលភាពប្រកួតប្រជែង សមាហរណកម្ម និងប្រកបដោយប្រសិទ្ធភាព ដោយមានការគ្រប់គ្រងត្រឹមត្រូវ និងជំរុញការសន្សំ ដើម្បីផ្តល់ហិរញ្ញវត្ថុក្នុងការគាំទ្រកំណើនក្នុងវិស័យឯកជន ប្រព័ន្ធទូទាត់ប្រកបដោយភាពជឿជាក់ និងប្រព័ន្ធសំណាញ់សុវត្ថិភាពសម្រាប់ធនាគារ។

ខ) មានប្រព័ន្ធហិរញ្ញវត្ថុជនបទ ប្រកបដោយប្រសិទ្ធភាព និងទប់ទល់នឹងភាពក្រីក្រ ដោយផ្តល់សេវាកម្មហិរញ្ញវត្ថុ ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពបង្កើតចំណូលនៅជនបទ និងកាត់បន្ថយភាពក្រីក្រ។

គ) មានវិស័យធានារ៉ាប់រង ដែលអាចការពារក្រុមហ៊ុន និងបុគ្គល ពីគ្រោះមហន្តរាយផ្សេងៗ និងប្រព័ន្ធសោធន ដែលធានាដល់ការបើកប្រាក់សោធននិវត្តន៍ ហើយក្រុមហ៊ុនធានារ៉ាប់រង ក៏អាចផ្តល់មូលធនរយៈពេលវែងសម្រាប់វិនិយោគក្នុងវិស័យមួយចំនួនផងដែរ។

ឃ) ផ្តល់នូវសេវាកម្មមិនមែនហិរញ្ញវត្ថុ និងបង្កើតស្ថាប័នមិនមែនហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យមានតុល្យភាពនូវរចនាសម្ព័ន្ធហិរញ្ញវត្ថុ បង្កើនភាពរឹងមាំនៃទីផ្សារហិរញ្ញវត្ថុ និងជំរុញការប្រកួតប្រជែង។ ស្ថាប័នទាំងនោះ រួមមាន៖ ស្ថាប័នភតិសន្យា អន្តរការីកម្ម ទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន និងការអភិវឌ្ឍស្ថាប័នហិរញ្ញវត្ថុ។

ង) ទីផ្សាររូបិយវត្ថុ អនុញ្ញាតឱ្យទីផ្សារអន្តរធនាគារ ដែលផ្តល់ឱ្យធនាគារ ក្រុមហ៊ុន និងបុគ្គល ជាមួយនឹងមធ្យោបាយគ្រប់គ្រងសន្ទនីយភាព ប្រកបដោយប្រសិទ្ធភាព។

ច) ទីផ្សារមូលធនដែលមានតម្លាភាព និងប្រសិទ្ធភាព ជាមួយនឹងអ្នកបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុ ដើម្បីគៀរគរមូលធនសម្រាប់វិនិយោគរយៈពេលវែង។

ធ) មានប្រព័ន្ធគណនេយ្យផ្លូវការមួយ ដែលអាចជំរុញការអនុវត្តត្រឹមត្រូវតាមច្បាប់ ក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ហើយគាំទ្រអភិបាលកិច្ចល្អ ដោយផ្អែកលើគោលការណ៍តម្លាភាព គណនេយ្យភាព និងអាចព្យាករណ៍បាន។

ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុក៏បានលើកឡើងផងដែរ ដោយបន្ថែមលើការពង្រឹងស្ថាប័ន និងប្រព័ន្ធច្បាប់ គឺត្រូវការអភិវឌ្ឍប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុដែលជឿទុកចិត្តបាន និងដាក់ចេញនូវយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការកសាងសមត្ថភាពធនធានមនុស្ស ដើម្បីទប់ទល់នឹងការប្រឈមនាពេលអនាគត។ ដើម្បីធានាការអនុវត្តប្រកបដោយជោគជ័យ គោលនយោបាយក៏បានដាក់ចេញនូវផែនការ ជាជំហានៗផងដែរ។ កម្មវិធីកំណែទម្រង់រយៈពេលមធ្យម ត្រូវបានបង្កើតឡើង ដើម្បីកំណត់វិធានការដាក់ស្តែង ហើយកំណត់លទ្ធផល និងជំហានដែលត្រូវអនុវត្តបន្តបន្ទាប់។ លក្ខណៈពិសេសមួយទៀត កម្មវិធីកំណែទម្រង់ដែលមានភាពបត់បែន ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាល កែសម្រួលគោលនយោបាយចាំបាច់ ស្របជាមួយការរីកចម្រើន និងការកែប្រែលក្ខខណ្ឌផ្សេងៗ[54]។

បន្ទាប់ពីគោលនយោបាយកំណែទម្រង់វិស័យហិរញ្ញវត្ថុ ទទួលបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយដ៏មានសារៈសំខាន់មួយទៀត គឺគោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលតម្រង់ទិស និងបង្កើតលក្ខខណ្ឌទីផ្សារអំណោយផល ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម។

គោលនយោបាយទាំងពីរទាំងពីរខាងលើ ជាមូលដ្ឋានដ៏មានសារៈសំខាន់នេះ ដែលធ្វើឱ្យកំណែទម្រង់វិស័យហិរញ្ញវត្ថុ ធនាគារ សេវាកម្មឧស្សាហកម្ម និងសេដ្ឋកិច្ចនៅកម្ពុជា ទទួលបានជោគជ័យ មានកំណើនសេដ្ឋកិច្ចខ្ពស់ ជីវភាពរស់នៅកាន់តែប្រសើរ កាត់បន្ថយភាពក្រីក្រ និងប្រែប្រួលមុខមាត់ថ្មីយ៉ាងឆាប់រហ័ស នៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។

---

[54] Byoung-Jo C. et al., *Financial Sector Blueprint for 2001-2010*, ADB 2001.

## ៦. រចនាសម្ព័ន្ធធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា ដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលជាគណៈគ្រប់គ្រងជាន់ខ្ពស់ មានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងដាក់ចេញនូវគោលនយោបាយ ដែលជាត្រីវិស័យនៅក្នុងប្រតិបត្តិការ។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារជាតិនៃកម្ពុជា មានសមាសភាពចំនួន ៧ រូប រួមមាន ទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងមជ្ឈដ្ឋានឧត្តមសិក្សា តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា។ ទេសាភិបាលជាប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជា ជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយ និងប្រតិបត្តិការប្រចាំថ្ងៃ។ ទេសាភិបាលត្រូវបានតែងតាំង ដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យ ដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល។

ក្នុងកម្រិតបច្ចេកទេស ធនាគារជាតិនៃកម្ពុជាមានប្រាំអគ្គនាយកដ្ឋាន គឺអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និងអគ្គាធិការដ្ឋាន ដែលក្នុងនោះរួមមាន២១ នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋាន ។ នាយកដ្ឋាន និងអគ្គនាយកដ្ឋាន មានតួនាទី ទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា[55]។

---

[55] ធនាគារជាតិនៃកម្ពុជា *រចនាសម្ព័ន្ធ* https://www.nbc.org.kh/about_the_bank/structure_of_nbc.php

## គំនូសបំព្រួញ៩.៣: រចនាសម្ព័ន្ធធនាគារជាតិនៃកម្ពុជា




ប្រភព: ធនាគារជាតិនៃកម្ពុជា *រចនាសម្ព័ន្ធ*, https://www.nbc.org.kh/

# មេរៀនទី១០

# ឧបករណ៍គោលនយោបាយរូបិយវត្ថុ

## (Tools of Monetary Policy)

## ១. សញ្ញាណទូទៅ

នៅក្នុងមេរៀននេះ យើងនឹងពិនិត្យមើលពីឧបករណ៍គោលនយោបាយរូបិយវត្ថុ ដែលធនាគារ កណ្តាលនៃប្រទេសនីមួយៗប្រើ ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ និងអត្រាការប្រាក់។ ពីព្រោះឧបករណ៍គោលនយោបាយទាំងនេះ មានឥទ្ធិពលសំខាន់ណាស់ ទៅលើអត្រាការប្រាក់ និងសកម្មភាពសេដ្ឋកិច្ច។ ម្យ៉ាងទៀត ធនាគារកណ្តាលបំពេញតួនាទីជាធនាគារអាណាព្យាបាល គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវសកម្មភាពប្រតិបត្តិការរបស់ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដើម្បីឱ្យប្រាកដថា គ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះបានបំពេញតួនាទី និងអនុវត្តបានត្រឹមត្រូវតាមច្បាប់ បទប្បញ្ញត្តិ ដែលមានជាធរមាន។ ចំណែក ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុវិញ បំពេញតួនាទីយ៉ាងសំខាន់នៅក្នុងទីផ្សារហិរញ្ញវត្ថុ ដោយទទួលយកមកអនុវត្តនូវច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយ ដែលដាក់ចេញដោយធនាគារកណ្តាល ដើម្បីសម្រេចបាននូវគោលដៅរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនប្រកបដោយចីរភាព។ ដើម្បីសម្រេចបាននូវគោលដៅនេះ ធនាគារកណ្តាលមានឧបករណ៍គោលនយោបាយរូបិយវត្ថុដ៏មានឥទ្ធិពល ក្នុងការធ្វើអន្តរាគមន៍នៅក្នុងទីផ្សារ ដើម្បីកែប្រែស្ថានភាពសេដ្ឋកិច្ចឱ្យបានប្រសើរឡើង។ ឧបករណ៍គោលនយោបាយរូបិយវត្ថុ ត្រូវប្រើប្រាស់ឱ្យបានសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច ដើម្បីប្រមូលផ្តុំធនធានគ្រប់ប្រភេទដែលសង្គមមាន ដូចជាធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងៗទៀត រួមមានដីធ្លី អាគារ គ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខារ វត្ថុធាតុដើម និងប្រើប្រាស់ឱ្យអស់សក្តានុពល ដើម្បីឈានទៅទទួលបានផលប្រយោជន៍ សេដ្ឋកិច្ច-សង្គម ក្នុងកម្រិតអតិបរមា។

## ២. ឧបករណ៍គោលនយោបាយរូបិយវត្ថុ

ធនាគារកណ្ដាលនៃប្រទេសនីមួយៗ មានឧបករណ៍គោលនយោបាយរូបិយវត្ថុ ដើម្បីធ្វើអន្តរាគមន៍ នៅពេលដែលមានហេតុការណ៍មិនប្រក្រតីកើតឡើង ដូចជា តម្លៃក្រដាសប្រាក់ធ្លាក់ចុះ ឬអត្រាប្ដូរប្រាក់ប្រែប្រួល ការប្រឈមនឹងអត្រាអតិផរណាខ្ពស់ ឬប្រឈមនឹងវិបត្តិសេដ្ឋកិច្ច ជាដើម។ ទោះបីជា គេប្រើឧបករណ៍គោលនយោបាយណាមួយក៏ដោយ វាតែងមានឥទ្ធិពលទៅលើបរិមាណប្រាក់នៅក្នុងចរាចរណ៍ និងអត្រាការប្រាក់ ជាដំបូង។ បន្ទាប់មក វានឹងមានឥទ្ធិពលទៅលើបរិមាណប្រាក់បញ្ញើ ឥណទាន និងការវិនិយោគ ហើយទីបំផុត វានឹងមានឥទ្ធិពលទៅលើគោលដៅនៃគោលនយោបាយសេដ្ឋកិច្ចជារួម។ បើយើងដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ នោះយើងនឹងទទួលបានផលវិជ្ជមាន ប៉ុន្តែ បើគោលនយោបាយមិនសមស្របទៅនឹងស្ថានភាពជាក់ស្ដែងនៃសេដ្ឋកិច្ចទេ នោះនឹងទទួលបានផលអវិជ្ជមានជាមិនខាន។

ឧបករណ៍គោលនយោបាយរូបិយវត្ថុទាំងនោះ រួមមាន ទុនបម្រុងកាតព្វកិច្ច អត្រាអប្បហារ និងប្រតិបត្តិការទីផ្សារបើកចំហ។

### ២.១. ទុនបម្រុងកាតព្វកិច្ច (Reserve requirement)

ធនាគារពាណិជ្ជ តម្រូវឱ្យរក្សាទុកប្រាក់បម្រុងនៅធនាគារកណ្ដាល។ ប្រាក់បម្រុងតម្រូវឱ្យតម្កល់នៅធនាគារកណ្ដាល មានពីរប្រភេទ គឺប្រាក់តម្កល់ធានាលើដើមទុន (Capital guarantee) និងទុនបម្រុងកាតព្វកិច្ច (Reserve requirement)។ ប្រាក់តម្កល់ធានាលើដើមទុន ជាប្រាក់បម្រុងដែលអ្នកវិនិយោគស្នើសុំបើកធនាគារនៅគ្រាដំបូង ត្រូវតម្កល់នៅធនាគារកណ្ដាល ដើម្បីទទួលបានអាជ្ញាប័ណ្ណ។ ប្រាក់តម្កល់ធានាលើដើមទុន ត្រូវគណនាធៀបនឹងដើមទុនអប្បបរិមា។ ចំណែក ទុនបម្រុងកាតព្វកិច្ចវិញ គឺជាប្រាក់បម្រុង ដែលធនាគារពាណិជ្ជត្រូវតម្កល់នៅធនាគារកណ្ដាល ក្រោយពីធ្វើប្រតិបត្តិការទទួលប្រាក់បញ្ញើ ហើយត្រូវគណនាធៀបនឹងបរិមាណប្រាក់បញ្ញើសរុប ឬអាស្រ័យតាមច្បាប់របស់ប្រទេសនីមួយៗ។

ទុនបម្រុងកាតព្វកិច្ច គឺជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ដែលធនាគារកណ្ដាលប្រើក្នុងការធ្វើអន្តរាគមន៍នៅក្នុងទីផ្សារ ដើម្បីឱ្យបរិមាណប្រាក់នៅក្នុងចរាចរណ៍ប្រែប្រួល កើនឡើង ឬថយចុះ តាមការចង់បានរបស់ធនាគារកណ្ដាល។

ឧទាហរណ៍ៈ ធនាគារជាតិនៃកម្ពុជា បានតម្លើងអត្រាទុនបម្រុងកាតព្វកិច្ច ពី៨% ទៅ ១៦% នៅក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុសកល កាលពីឆ្នាំ២០០៨-២០០៩កន្លងទៅ ក្នុងគោលបំណងរឹតបន្តឹងការផ្តល់ឱ្យខ្ចី ដោយព្រួយបារម្ភពីការប្រឈមរបស់ធនាគារពាណិជ្ជ ក្នុងការប្រមូលប្រាក់មកវិញ ក្នុងស្ថានភាពសេដ្ឋកិច្ចដ៏លំបាកនាពេលនោះ។ ប៉ុន្តែ ដោយសង្កេតឃើញថា ធនាគារពាណិជ្ជនៅកម្ពុជា មិនទទួលរងឥទ្ធិពលដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុសកលទេ ធនាគារជាតិនៃកម្ពុជា បានកែប្រែអត្រាទុនបម្រុងកាតព្វកិច្ចឱ្យមកនៅត្រឹម១២%វិញ។ ពីព្រោះ បើធនាគារជាតិនៃកម្ពុជានៅរក្សាអត្រាទុនបម្រុងកាតព្វកិច្ចខ្ពស់ពេក នោះនឹងមានឥទ្ធិពលអវិជ្ជមាន គឺធ្វើឱ្យអត្រាកំណើនសេដ្ឋកិច្ចធ្លាក់ចុះ នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមនឹងការធ្លាក់ចុះស្រាប់ ដោយសារឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសកល។ បច្ចុប្បន្ន អត្រាទុនបម្រុងកាតព្វកិច្ចសម្រាប់ប្រាក់ដុល្លារ ១២,៥% និង ៨% សម្រាប់ប្រាក់រៀល។

ចំណែកនៅក្នុងប្រទេសអភិវឌ្ឍន៍វិញ អត្រាទុនបម្រុងកាតព្វកិច្ច មាននិន្នាការធ្លាក់ចុះ ដូចជា នៅជប៉ុន អត្រា០,៨២% និងនៅសហរដ្ឋអាមេរិក អត្រា៣% ចំពោះធនាគារដែលមានប្រាក់បញ្ញើពី១៦,៩លានដុល្លារ ដល់១២៧,៥លានដុល្លារ និងអត្រា១០% ចំពោះធនាគារដែលមានប្រាក់បញ្ញើលើសពី១២៧,៥លានដុល្លារឡើងទៅ។ ចំណែក ធនាគារដែលមានប្រាក់បញ្ញើតិចជាង១៦,៩លានដុល្លារ មិនតម្រូវឱ្យមានទុនបម្រុងកាតព្វកិច្ចទេ។

ជារួម ធនាគារកណ្តាលនៃប្រទេសនីមួយៗ អាចបង្កើន ឬ បន្ថយទុនបម្រុងកាតព្វកិច្ច អាស្រ័យលើស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសនោះ។ ឧបមាថា បើធនាគារកណ្តាលបង្កើនអត្រាទុនបម្រុងកាតព្វកិច្ច នោះវានឹងធ្វើឱ្យមានឥទ្ធិពលទៅលើកត្តាមួយចំនួន ដូចខាងក្រោមៈ

- ប្រាក់បញ្ញើ និងមេគុណរូបិយវត្ថុ[56] (money multipliers) ធ្លាក់ចុះ ហើយបន្ថយល្បឿនកំណើនសាច់ប្រាក់ ប្រាក់បញ្ញើ និងឥណទាន។

---

[56] មេគុណរូបិយវត្ថុ គឺជាការកើនឡើងនៃការប្រែប្រួលបរិមាណប្រាក់ផ្គត់ផ្គង់ ដែលជាលទ្ធផលនៃការចាក់បញ្ចូលទៅក្នុងប្រព័ន្ធធនាគារនូវទុនបម្រុងបន្ថែម។ ឧទាហរណ៍ៈ ប្រសិនបើ ធនាគារពាណិជ្ជ

- កាត់បន្ថយទុនបម្រុងដែលច្បាប់តម្រូវរបស់ធនាគារពាណិជ្ជ ធ្វើឱ្យធនាគារពាណិជ្ជមិនមានទុនបម្រុងគ្រប់គ្រាន់។ ហេតុនេះ ធនាគារពាណិជ្ជបង្ខំចិត្តត្រូវលក់មូលប័ត្រ កាត់បន្ថយទំហំឥណទាន ឬត្រូវស្វែងរកកម្ចីពីប្រភពហិរញ្ញវត្ថុផ្សេងទៀត។
- ធ្វើឱ្យអត្រាប្រាក់កើនឡើង ជាពិសេស នៅក្នុងទីផ្សាររូបិយវត្ថុ ដោយសារធនាគារពាណិជ្ជប្រជែងគ្នាដើម្បីបានប្រាប់ សម្រាប់បំពេញកង្វះខាតសាច់ប្រាក់ទាំងនោះ។

### ២.២. អត្រាអប្បហារ (Discount rate)

អត្រាអប្បហារ គឺជាអត្រាការប្រាក់ប្រចាំឆ្នាំរបស់ធនាគារកណ្តាល ដែលត្រូវយកពីធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលសម្រេចចិត្តខ្ចីប្រាក់ពីធនាគារកណ្តាល។ ការផ្តល់ឱ្យខ្ចីក្នុងអត្រាអប្បហារ គឺជាឧបករណ៍គោលនយោបាយរូបិយវត្ថុ និងជាផ្នែកមួយក្នុងការបំពេញមុខងារជា "អ្នកផ្តល់ឱ្យខ្ចីចុងក្រោយ" របស់ធនាគារកណ្តាល។ ការផ្តល់ឱ្យខ្ចីក្នុងអត្រាអប្បហារ ចំពោះធនាគារពាណិជ្ជ កើតឡើងក្រោមរូបភាពបីទម្រង់ផ្សេងគ្នា៖

#### ក. ឥណទានដំបូង (Primary credit)

ឥណទានដំបូង គឺការផ្តល់ឱ្យខ្ចីក្នុងអត្រាអប្បហារ ដែលបានបំពេញតួនាទីយ៉ាងសំខាន់នៃគោលនយោបាយរូបិយវត្ថុ។ ធនាគារពាណិជ្ជដែលទទួលបានជោគជ័យត្រូវបានលើកទឹកចិត្ត និងអនុញ្ញាតឱ្យខ្ចីប្រាក់តាមតម្រូវការ ក្នុងរយៈពេលខ្លី តាមរយៈមធ្យោបាយឥណទានដំបូងនេះ។

#### ខ. ឥណទានបន្ទាប់ (Secondary credit)

ឥណទានបន្ទាប់ គឺការផ្តល់ឱ្យខ្ចីចំពោះធនាគារពាណិជ្ជណា ដែលប្រឈមនឹងបញ្ហាហិរញ្ញវត្ថុ និងមានបញ្ហាសន្ទនីយភាពធ្ងន់ធ្ងរ។ អត្រាការប្រាក់សម្រាប់ឥណទាន

---

ទទួលបានប្រាក់បញ្ញើ១លានដុល្លារ នោះបរិមាណប្រាក់ផ្គត់ផ្គង់ចុងក្រោយ ស្មើនឹង៨លានដុល្លារ បើមេគុណរូបិយវត្ថុស្មើនឹង៨។

ប្រភេទនេះ ជាទូទៅ ខ្ពស់ជាង អត្រាអប្បហារ ពីព្រោះ វាជាអត្រាការប្រាក់សម្រាប់ដាក់ពិន័យចំពោះធនាគារពាណិជ្ជ ដែលគ្រប់គ្រងប្រតិបត្តិការមិនបានល្អ។

**គ. ឥណទានតាមរដូវកាល** (Seasonal credit)

ឥណទានតាមរដូវកាល គឺជាការផ្ដល់ឱ្យខ្ចី ដើម្បីបំពេញតម្រូវការរបស់ធានាគារពាណិជ្ជតូចៗ ដែលមានពេលវេលាឈប់សម្រាកតាមរដូវកាល ជាពិសេស នៅតំបន់កសិកម្ម ដែលមានប្រាក់បញ្ញើប្រែប្រួលតាមរដូវកាល។ អត្រាការប្រាក់នៃឥណទានតាមរដូវកាលនេះ ជាអត្រាមធ្យមនៃអត្រាអប្បហារ និងអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់ (វិញ្ញាបនប័ត្រទទួលប្រាក់បញ្ញើ)។ អត្រាការប្រាក់នេះ អាចត្រូវបានកំណត់ខុសៗគ្នា ទៅតាមប្រទេសនីមួយៗ។

ជារួម អត្រាអប្បហារត្រូវបានប្រើប្រាស់ ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់បរិមាណប្រាក់បម្រុងរបស់ធនាគារពាណិជ្ជ ឬធ្វើឱ្យប្រែប្រួលដល់បរិមាណប្រាក់ផ្គត់ផ្គង់នៅក្នុងចរាចរណ៍។ អត្រាអប្បហារ មានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ និងដោះស្រាយអហេតុកភ័យហិរញ្ញវត្ថុ (Financial panics)។ នៅពេលមានវិបត្តិកើតឡើងម្ដងៗ ធនាគារកណ្ដាលតែងបន្ទាបអត្រាអប្បហារ ដើម្បីបង្កើនការផ្ដល់ឱ្យខ្ចីចំពោះធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលកំពុងតែប្រឈមនឹងកង្វះខាតសាច់ប្រាក់ធ្ងន់ធ្ងរ ហើយអាចទប់ទល់បាននូវស្ថានភាពបរាជ័យ ឱ្យវិលត្រឡប់មកស្ថានភាពដែលអាចត្រួតត្រាបានឡើងវិញ។ ម៉្យាងទៀត នៅពេលដែលធនាគារពាណិជ្ជមិនអាចរកប្រភពទុនផ្សេងទៀតដើម្បីបំពេញតម្រូវការបាន នោះធនាគារកណ្ដាលត្រូវប្រើអត្រាអប្បហារ ដើម្បីបង្កើនការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ដែលជួយដល់ធនាគារពាណិជ្ជផង និងជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានកំណើនកាន់តែខ្ពស់ឡើងវិញផង។

ជារួម នៅពេលដែលធនាគារកណ្ដាលបង្កើនអត្រាអប្បហារ នោះនឹងធ្វើឱ្យប្រែប្រួលដល់កត្តាមួយចំនួន ដូចខាងក្រោម៖

- ➢ កាត់បន្ថយបរិមាណឥណទាន ដែលត្រូវខ្ចីពីធនាគារកណ្ដាល ដោយសារការចំណាយការប្រាក់កើនឡើងខ្ពស់។ ការជះឥទ្ធិពលនេះ គឺដោយសារការកើនឡើងនៃថ្លៃមូលធន (cost effect)។

- ធ្វើឱ្យការខ្ចីប្រាក់ពីធនាគារកណ្តាល មិនសូវមានការចាប់អារម្មណ៍ ដោយសារតែការប្រាក់កើនឡើងខ្ពស់ពេក។ ហេតុនេះ ធនាគារពាណិជ្ជត្រូវស្វែងរកប្រភពទុនផ្សេងទៀត ដែលមានការប្រាក់ទាបជាង (substitution effect)។
- បង្ហាញសញ្ញាថា ធនាគារកណ្តាលកំពុងរឹតបន្តឹងលក្ខខណ្ឌ ក្នុងការផ្តល់ឥណទាន ដោយផ្តល់ដំណឹងថា ធនាគារកណ្តាលនឹងបង្កើនអត្រាអប្បហារ (announcement effect) ឬមានបំណងកាត់បន្ថយការផ្តល់ឥណទាន ហើយភាគីពាក់ព័ន្ធ ដូចជា ធនាគារពាណិជ្ជ ឬវិនិយោគិន នឹងឆ្លើយតបវិញ ដោយកាត់បន្ថយផែនការចំណាយ ឬ កាត់បន្ថយការខ្ចីប្រាក់ពីធនាគារកណ្តាល។

ក្នុងការអនុវត្តជាក់ស្តែង នៅពេលប្រឈមនឹងវិបត្តិសេដ្ឋកិច្ច ធនាគារកណ្តាលនៃប្រទេសជាច្រើនបានកាត់បន្ថយអត្រាអប្បហារ ដើម្បីជំរុញនិងលើកទឹកចិត្តធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ឱ្យខ្ចីប្រាក់ពីធនាគារកណ្តាលកាន់តែច្រើន។ មូលហេតុសំខាន់ គឺ នៅពេលមានវិបត្តិកើតឡើង សកម្មភាពសេដ្ឋកិច្ចតែងធ្លាក់ចុះ ធនាគារពាណិជ្ជប្រឈមនឹងបញ្ហាឥណទានសង្ស័យ មិនអាចប្រមូលប្រាក់ត្រឡប់មកវិញបានទាន់ពេលវេលា។ ហេតុផលមួយទៀត ធនាគារកណ្តាលត្រូវបង្កើនការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍ ដើម្បីស្តារសេដ្ឋកិច្ចដែលកំពុងធ្លាក់ចុះ ឱ្យងើបឡើងវិញ។ ហេតុនេះ ធនាគារកណ្តាលត្រូវបន្ទាបអត្រាអប្បហារ ដើម្បីជំរុញការផ្តល់ឱ្យខ្ចីចំពោះធនាគារពាណិជ្ជ។ នៅពេលបរិមាណប្រាក់នៅក្នុងចរាចរណ៍កើនឡើង អត្រាការប្រាក់នៅក្នុងទីផ្សារថយចុះ ការផ្តល់ឥណទានកើនឡើង បង្កើនសកម្មភាពអាជីវកម្ម ការវិនិយោគ និងជំរុញកំណើនសេដ្ឋកិច្ចឡើង។ ឧទាហរណ៍ៈ ក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨-២០០៩កន្លងទៅ មានប្រទេសជាច្រើន ដូចជា សហរដ្ឋអាមេរិក អង់គ្លេស ចិន ជប៉ុន និងប្រទេសផ្សេងទៀតនៅសហភាពអឺរ៉ុប បានបន្ទាបអត្រាអប្បហារ ដើម្បីជំរុញការស្តារសេដ្ឋកិច្ចឡើងវិញ។

### ២.៣. ប្រតិបត្តិការទីផ្សារបើកចំហ (Open market operation-OMO)

ប្រតិបត្តិការទីផ្សារបើកចំហ គឺជាការទិញ ឬ លក់ មូលប័ត្រ ដោយធនាគារកណ្តាល ដើម្បីធ្វើឱ្យមានឥទ្ធិពលដល់បរិមាណប្រាក់ និងបរិមាណធនបម្រុងរបស់

ធនាគារពាណិជ្ជ ដែលតម្រូវដោយច្បាប់ ហើយចុងក្រោយ នឹងមានឥទ្ធិពលទៅលើលក្ខខណ្ឌឥណទាន។ OMO គឺជាឧបករណ៍គោលនយោបាយ ដែលមានភាពបត់បែន និងសមស្រប ដើម្បីកែប្រែស្ថានភាពទីផ្សារហិរញ្ញវត្ថុដែលកំពុងជួបឱ្យប្រសើរឡើងវិញ។

នៅពេលប្រើឧបករណ៍ទីផ្សារបើកចំហ (OMO) ដោយទិញមូលប័ត្រ នោះវានឹងមានឥទ្ធិពលដល់សកម្មភាពពីរជាសំខាន់ៗ៖

- នៅពេលដែលធនាគារកណ្តាលទិញមូលប័ត្រពីទីផ្សារហិរញ្ញវត្ថុ នោះនឹងធ្វើឱ្យកើនបន្ថែមនូវតម្រូវការមូលប័ត្រនៅក្នុងទីផ្សារ ធ្វើឱ្យថ្លៃទីផ្សារមូលប័ត្រកើនឡើង និងអត្រាចំណូលរបស់សញ្ញាប័ណ្ណធ្លាក់ចុះ ហេតុនេះ អត្រាការប្រាក់ទីផ្សារក៏ធ្លាក់ចុះដែរ។
- នៅពេលដែលធនាគារកណ្តាលទិញមូលប័ត្ររដ្ឋាភិបាល នោះនឹងធ្វើឱ្យទុនបម្រុងនៅក្នុងប្រព័ន្ធធនាគារកើនឡើង ពង្រីកលទ្ធភាពក្នុងការផ្តល់ឥណទាន និងបង្កើនការទទួលប្រាក់បញ្ញើ ហេតុនេះ នឹងធ្វើឱ្យមានកំណើនបរិមាណប្រានៅក្នុងចរាចរណ៍ ហើយបរិមាណឥណទាននឹងកើនឡើង។

ការទិញ-លក់មូលប័ត្ររបស់ធនាគារកណ្តាល កើតឡើងក្រោមរូបភាពផ្សេងៗនៃប្រតិបត្តិការជួញដូរ ដោយប្រើ OMO អាចបង្ហាញតាមរយៈគំនូសបំព្រួញ ដូចខាងក្រោម៖

**ក. ប្រតិបត្តិការត្រង់នៅក្នុងទីផ្សារបើកចំហ**

(ការប្រែប្រួលជាអចិន្ត្រៃយ៍កម្រិតទុនបម្រុងរបស់ស្ថាប័នសន្សំ)

- នៅពេលដែលធនាគារកណ្តាលទិញមូលប័ត្រពីទីផ្សារហិរញ្ញវត្ថុ (ពីឈ្មួញឬវិនិយោគិន) នោះធនាគារកណ្តាលត្រូវបញ្ចេញប្រាក់ទូទាត់ឱ្យវិនិយោគិន ធ្វើឱ្យបរិមាណប្រាក់នៅក្នុងចរាចរណ៍កើនឡើង អត្រាការប្រាក់ថយចុះ។
- ផ្ទុយទៅវិញ បើធនាគារកណ្តាលលក់មូលប័ត្រទៅក្នុងទីផ្សារហិរញ្ញវត្ថុវិញ នោះវិនិយោគិនត្រូវទូទាត់ប្រាក់មកឱ្យធនាគារកណ្តាលវិញ ធ្វើឱ្យបរិមាណ

ប្រាក់នៅក្នុងចរាចរណ៍ថយចុះ អត្រាការប្រាក់កើនឡើង (ដូចមានក្នុង គំនូសបំព្រួញ១០.១)។

**គំនូសបំព្រួញ១០.១: ប្រតិបត្តិការត្រង់**







**ខ. ប្រតិបត្តិការដោយទិញយកវិញ** (Repurchase agreements) **នៅក្នុងទីផ្សារបើកចំហ** (ការប្រែប្រួលបណ្ដោះអាសន្នកម្រិតទុនបម្រុងរបស់ស្ថាប័នសន្សំ)

**គំនូសបំព្រួញ១០.២: ប្រតិបត្តិការដោយទិញយកវិញ**






គំនូសបំព្រួញ១០.២ បង្ហាញពីការធ្វើអន្តរាគមន៍របស់ធនាគារកណ្តាល ដោយប្រើប្រាស់ OMO ដើម្បីកែសម្រួលស្ថានភាពទីផ្សារ។ គំនូសបំព្រួញទី១០.២ (រូបទី១) បង្ហាញថា ធនាគារកណ្តាលទិញមូលប័ត្រពីទីផ្សារនៅគ្រាដំបូង ដើម្បីបង្កើនការផ្គត់ផ្គង់ប្រាក់នៅក្នុងចរាចរណ៍។ បន្ទាប់មក ក្នុងរយៈពេលខ្លី ធនាគារ កណ្តាលបានធ្វើអន្តរាគមន៍បញ្ច្រាសវិញ ដោយលក់មូលប័ត្រទៅក្នុងទីផ្សារ ធ្វើឱ្យបរិមាណប្រាក់នៅក្នុងចរាចរណ៍ថយចុះវិញ។ ចំណែកគំនូសបំព្រួញទី១០.២ (រូបទី២) ជាការធ្វើអន្តរាគមន៍ផ្ទុយពីរូបទី១។ មានន័យថា នៅគ្រាដំបូង ធនាគារកណ្តាលលក់មូលប័ត្រទៅក្នុងទីផ្សារ ដើម្បីប្រមូលប្រាក់ពីចរាចរណ៍ចូលមកធនាគារកណ្តាលវិញ។ បន្ទាប់មក ក្នុងរយៈពេលខ្លី ធនាគារកណ្តាលបានធ្វើអន្តរាគមន៍បញ្ច្រាស ដោយទិញមូលប័ត្រពីទីផ្សារមកវិញ ធ្វើឱ្យបរិមាណប្រាក់នៅក្នុងចរាចរណ៍កើនឡើង។

គ. ប្រតិបត្តិការទូទាត់ផុតថ្ងៃកំណត់សង (Run-Off Transaction)

(ថយចុះជាអចិន្ត្រៃយ៍កម្រិតទុនបម្រុងរបស់ស្ថាប័នទទួលប្រាក់បញ្ញើ)

គំនូសបំព្រួញ១០.៣ បង្ហាញថា នៅពេលដែលមូលប័ត្ររតនាគារដល់ថ្ងៃកំណត់សង ធនាគារកណ្តាលបញ្ជូនមូលប័ត្រទាំងនោះទៅឱ្យរតនាគារវិញ ដើម្បីទទួលបានការទូទាត់សងពីរតនាគារ។

**គំនូសបំព្រួញ១០.៣: ប្រតិបត្តិការទូទាត់ផុតថ្ងៃកំណត់សង**



ក្នុងករណីរតនាគារ ឬរដ្ឋាភិបាលត្រូវការខ្ចីទុនបន្ថែម នោះរតនាគារនឹងបោះផ្សាយមូលប័ត្រថ្មី លក់នៅក្នុងទីផ្សារ ដើម្បីប្រមូលទុនបន្ថែម តាមតម្រូវការរបស់រដ្ឋាភិបាល។ មានន័យថា រតនាគារលក់មូលប័ត្រថ្មីនៅក្នុងទីផ្សារ ដើម្បីប្រមូលប្រាក់សងមូលប័ត្រចាស់ ដែលដល់ថ្ងៃកំណត់សង។ បន្ទាប់មក ឈ្មួញ ឬវិនិយោគិន ដែលជាអ្នកទិញមូលប័ត្រថ្មី ត្រូវទូទាត់ប្រាក់ចូលទៅគណនីចរន្តរបស់រដ្ឋាភិបាល ដែលមាននៅធនាគារកណ្តាល។

**ឃ. គោលដៅនៃការប្រើ** OMO

OMO ត្រូវបានប្រើប្រាស់ក្នុងគោលដៅពីរយ៉ាង គឺ៖

- OMO ដើម្បីការពារ (Defensive OMO): គឺជាបច្ចេកទេសកែសម្រួលលក្ខខណ្ឌទីផ្សារ ដោយប្រើ OMO ដើម្បីការពារស្ថានភាពដើមឱ្យនៅដដែល មានន័យថា ថែរក្សាស្ថានភាពអត្រាការប្រាក់នៅក្នុងទីផ្សារ និងបរិមាណឥណទានដែលអាចផ្តល់ឱ្យខ្ចីបាន មិនប្រែប្រួល ពីព្រោះគេយល់ថា ស្ថានភាពអត្រាការប្រាក់ និងទំហំឥណទាន មានលក្ខណៈសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ច។
- OMO ប្រកបថាមភាព (Dynamic OMO): គឺជាការធ្វើអន្តរាគមន៍ដោយប្រើ OMO ដើម្បីកែសម្រួលស្ថានភាពអត្រាការប្រាក់ និងលក្ខខណ្ឌឥណទានបច្ចុប្បន្ន (ដែលគេយល់ថាមិនសមស្រប) ឱ្យប្រែប្រួល (កើនឡើង ឬថយចុះ) ដែលធនាគារកណ្តាលជឿជាក់ថា មានលក្ខណៈសមស្រប ស៊ីសង្វាក់ទៅនឹងគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចផង។

**ង. គោលដៅអត្រាការប្រាក់** (Interest Rate Targeting)

ធនាគារកណ្តាលនៃប្រទេសនីមួយៗ ផ្តល់សារៈសំខាន់ (ផ្តល់ទម្ងន់) ទៅលើគោលដៅនៃអត្រាការប្រាក់ និងឥណទានដែលអាចផ្តល់ឱ្យខ្ចីបាន នៅក្នុងទីផ្សាររូបិយវត្ថុ ដើម្បីធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃស្ថានភាពទីផ្សារ និងដាក់ចេញនូវគោលនយោបាយរូបិយវត្ថុ ដែលជាយុទ្ធសាស្ត្រកែសម្រួលស្ថានភាពអត្រាការប្រាក់ និងបរិមាណប្រាក់ផ្គត់ផ្គង់នៅក្នុងចរាចរណ៍ ដើម្បីសម្រេចគោលដៅកំណើនសេដ្ឋកិច្ច។

ធនាគារកណ្ដាលអាចសម្រេច ដោយប្រើ OMO ដែលធ្វើឱ្យមានឥទ្ធិពលទៅលើទុនបម្រុងមិនមែនកម្ចី និងទុនបម្រុងសរុប ដែលមាននៅក្នុងប្រព័ន្ធធនាគារ[57]។

**ក្រាហ្វិក១០.១: គោលដៅអត្រាការប្រាក់**




ក្រាហ្វិក១០.១ បង្ហាញថា ក្នុងករណីខ្សែកោងតម្រូវការ D និងផ្គត់ផ្គង់ S នោះគេទទួលបានចំណុចសមាតា $E_0$។ ប៉ុន្តែ នៅពេលខ្សែកោង D រំកិលទៅ D' អត្រាការប្រាក់កើនឡើងដល់ r' ហើយចំណុចសមាតារំកិលទៅ E'។ ដើម្បីឱ្យអត្រាការប្រាក់ធ្លាក់ចុះមក r វិញ (រក្សាស្ថិរភាពអត្រាការប្រាក់) នោះខ្សែកោងផ្គត់ផ្គង់ S ត្រូវរំកិលទៅ S' ហើយចំណុចសមាតា ក៏រំកិលទៅ $E_1$ ដែរ។

សរុបសេចក្ដីមក ឧបករណ៍គោនយោបាយរូបិយវត្ថុ មានសារៈសំខាន់ណាស់សម្រាប់ធនាគារកណ្ដាលនៃប្រទេសនីមួយៗ។ នៅពេលមានវិបត្តិកើតឡើងម្ដងៗ គេតែងធ្វើការសិក្សា ស្រាវជ្រាវ និងវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ច ឬទីផ្សារជាក់ស្ដែងមុននឹងធ្វើសេចក្ដីសម្រេចថា ត្រូវប្រើប្រាស់ឧបករណ៍គោលនយោបាយណាមួយដែលមានលក្ខណៈសមស្របជាងគេ ក្នុងការធ្វើអន្តរាគមន៍ ដើម្បីកែប្រែស្ថានភាពសេដ្ឋកិច្ច ឬទីផ្សារ ដែលកំពុងប្រឈម ឱ្យប្រសើរឡើងវិញ ដោយទទួលរងការខាតបង់ ឬ ជះឥទ្ធិពលអវិជ្ជមានដល់កត្តាផ្សេងៗទៀត តិចតួចបំផុត៕

✧✧✧ចប់✧✧✧

[57] Peter S. Rose, *Money and Capital Markets*, 2005.

## ឯកសារយោង៖


ធនាគារជាតិនៃកម្ពុជា *របាយការណ៍ប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១*

ហ្សង់ ម៉ីយែរ *រូបិយវត្ថុ និងអធិបតេយ្យភាព* ភាគ១ ឆ្នាំ២០០៩

Byoung-Jo C. et al., *Financial Sector Blueprint for 2001-2010*, ADB 2001.

Frederic S., *The economics of money, banking, and financial markets*, Tenth Edition, Columbia University, 2013.

Glyn D., *A History of Money: From Ancient Times to the Present Day*, University of Wales Press, 2002.

Hakan Ş., *An Essay on the Nature and Types of Money*, Medipol University, 2017.

Jeff Madura, *Financial Markets and Institutions*, Florida Atlantic University, 11th Edition, 2015.

Muhammad Rizwan, *Introductionand Evolution of Money. Why is it needed?* 2014.

Peter S. Rose, *Bank Managemnt & Financial Services*, Seventh Edition, 2008.

Peter S. Rose, *Commercial Bank Managemnt*, 2003.

Peter S. Rose, *Money and Capital Markets*, 2005.

Robert E. et al, *Money and Banking*, Flat World Knowledge, Inc., 2009.

Roger L. and David V., *Money, Banking, and Financial Markets*, 2001.

Stephen G. and Kermit L., *Money, Banking, and Financial Markets*, 4th Edition, Brandeis International Business School, 2015.

*2019 AIIB Annual Report and Financials*, https://www.aiib.org/en/news-events/ annual-report/2019/_common/pdf/2019-aiib-annual-report-and-financials.pdf

*សម្តេច ហ៊ុន សែន ផ្តល់ «ប្រាក់ស្លឹង» ជារង្វាន់លើកទឹកចិត្តដល់សិស្សនិទ្ទេស A នៅឆ្នាំនេះ*, ២០១៨, https://www.interconrooster.com/archives/2018/11/08/25213

*រូបិយវត្ថុស្ថិតក្នុងចរាចរណ៍* https://www.nbc.org.kh/about the bank/banknotes in circulation. php

*COVID-19 Crisis Recovery Facility*, https://www.aiib.org/en/policies-strategies/ COVID-19-Crisis-Recovery-Facility/index.html

David D., *The IMF and the World Bank, How Do They Differ*? https://www.imf.org/external/pubs/ft/exrp/differ/differ.htm

*Financial system*, https://en.wikipedia.org/wiki/Financial_system.

*Funan Kingdom*, https://www.cointalk.com/threads/funan-kingdom.240800/

*How money is created?* https://shankarmuthu.com/2015/09/19/how-money-is-created/

James Chen, *What Is M3?* https://www.investopedia.com.

James R., *The History of Money: From Its Origins to Our Time*, November 2007. http://www.jamesrobertson.com/book/historyofmoney.pdf

*King Croesus*, https://www.allaboutturkey.com/croesus.html

Madhuri Thakur, *Functions of Financial Markets*, https://www.wallstreetmojo.com/functions-of-financial-markets/

*Margin Requirement*, https://www.firstrade.com/content/enus/education/margin/ marginrequirements/

Monnaie athénienne, https://fr.wikipedia.org/wiki/Monnaie_ath%C3%A9nienne

Paul B., *Commodity Money Definition | 9 Examples | 4 Characteristics*, 2020. https://boycewire.com/commodity-money-definition/

*The History of Money*, https://www.pbs.org/wgbh/nova/article/ history-money/

*The History of Money*, https://www.pbs.org/wgbh/nova/article/history-money/ Wikipedia,

*The Economist explains: Why China is creating a new "World Bank" for Asia*, November 11, 2014, http://www.economist.com/blogs/economist-explains/ 2014/11/ economist-explains-6

*The Role of the IMF: Past, Present, and Future*--Remarks by Michel Camdessus, https://www.imf.org/en/News/Articles/2015/09/28/04/53/sp021398

Tim S. & Friederike N, *The role of bank guarantees in international trade*, 2014, https://voxeu.org/article/role-bank-guarantees-international-trade

The World Bank, *History*,https://www.worldbank.org/en/about/history.

Youtube, *ប្រវត្តិធនាគារដោយចាប់ផ្តើមកសាងឡើងវិញពីចំណុចសូន្យ*, March 24, 2021, https://www.youtube.com/watch?v=qmfcvWjH0Eo

*What Is a Mutual Fund*? https://www.investopedia.com/terms/m/mutualfund.asp

Wikipedia, *Croeseid*, https://en.wikipedia.org/wiki/Croeseid

Wikipedia, *Gold Standard*, https://en.wikipedia.org/wiki/Gold_standard.

Wikipedia, https://km.wikipedia.org/wiki/និក្ខេប

គាំទ្រថវិកាលើការរៀបរៀង និពន្ធ និងកែលម្អដោយ

ក្រសួងអប់រំ យុវជន និងកីឡា

មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

CAMBODIA
RESEARCH CREATIVITY INNOVATION